អង្គធាតុដែលងាយឆាបឆេះឆ្លាយចេញ ដោយសារការដុតកម្តៅនៅជិតទុយោអង្គធាតុរាវដែលមានសម្ពាធ ដែលបណ្តាលឲ្យមានការរលាកធ្ងន់ធ្ងរចំពោះខ្លួនអ្នក ឬអ្នកនៅឈរក្បែរ។ កុំដុតកម្តៅដោយការផ្សារ ឬប្រើប្រាស់ក្បាលភ្លើងផ្សារនៅជិតទុយោអង្គធាតុរាវដែលមានសម្ពាធ ឬនៅក្បែរវត្ថុធាតុដែលងាយឆាបឆេះផ្សេងៗ។ ទុយោអង្គធាតុរាវដែលមានសម្ពាធ អាចផ្ទុះបែកដោយចៃដន្យ នៅពេលដែលកម្តៅភាយចេញពីអណ្តាតភ្លើង។

DX,TORCH-KM-10DEC04

## ជៀសវាងប៉ះជាមួយគ្រឿងដែលមានចលនា



TS256—UN—23AUG88

រក្សាដៃ ជើង និងសម្លៀកបំពាក់ឲ្យនៅឆ្ងាយពីគ្រឿងទាំងឡាយណាដែលដើរដោយថាមពល។ ហាមដាក់ប្រេងរំអិលធ្វើការថែទាំ ឬលៃតម្រូវគ្រឿងចក្រខណៈដែលវាកំពុងតែដំណើរការ។

H01,9000SA,E-KM-15JUN90

## ការសម្អាតធុងគ្រាប់ធញ្ញជាតិនិងសម្អាតកន្លែងដែលស្ទះ



TS256—UN—23AUG88

ចូរចៀសវាងកុំឲ្យរងរបួសធ្ងន់ធ្ងរ ឬស្លាប់បាត់បង់ជីវិតដោយសារការទាក់ជាប់នឹងគ្រឿងម៉ាស៊ីននៅក្នុងប្រដាប់បួងកាត់តាមធុងគ្រាប់ធញ្ញជាតិ។ ដើម្បីឲ្យវាបំពេញមុខងារ ប្រដាប់បួងកាត់មិនអាចគ្របដណ្តប់បានទាំងស្រុងទេ។ ហាមចូលក្នុងធុងគ្រាប់ធញ្ញជាតិនៅពេលម៉ាស៊ីនកំពុងដំណើរការ។ មុនពេលចូលក្នុងធុងដើម្បីសម្អាតគ្រាប់ដែលនៅសេសសល់ ជានិច្ចកាល ត្រូវពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។

ប្រសិនបើស្ទះគ្រាប់ធញ្ញជាតិ ហើយមិនហូរចូលទៅក្នុងប្រដាប់បួងកាត់ទេ ចូរពន្លត់ម៉ាស៊ីន ដោះសោចេញ ហើយប្រើឈើ អំបោស ឬប៉ែលរុកដើម្បីឲ្យគ្រាប់ធញ្ញជាតិហូរឡើងវិញ។

OUO6043,00015E2-KM-24MAY04

## នៅឲ្យឆ្ងាយពីកាឡេកំពុងវិល



TS1644—UN—22AUG95


ការទាក់ចូលជាប់នៅក្នុងកាឡេដែលកំពុងវិល អាចបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ ឬស្លាប់បាន។

រក្សារបាំងការពារឲ្យនៅនឹងកន្លែងនៅគ្រប់ពេលទាំងអស់។ ធ្វើឲ្យប្រាកដថា របាំងការពារ អាចរំលឹកបានដោយសេរី។

ស្លៀកពាក់សម្លៀកបំពាក់បិទជិត។ ពន្លត់ម៉ាស៊ីន និងប្រាកដថា រាល់គ្រឿងបន្លាស់បង្វិល និងការបញ្ជូនថាមពលពីម៉ាស៊ីនទៅកង់ (drivelines) ត្រូវបានបញ្ឈប់មុនពេលធ្វើការកែសម្រួល ធ្វើការតភ្ជាប់ ឬអនុវត្តសេវាគ្រប់ប្រភេទនៅលើម៉ាស៊ីន ឬគ្រឿងម៉ាស៊ីនដែលត្រូវបានបញ្ជាដោយបរិក្ខារនានា។

DX,ROTATING-KM-18AUG09

## ដំឡើងរបាំងនិងប្រដាប់ការពារ



TS677—UN—21SEP89


កង្ហារត្រលប់ ខ្សែពាន និងដ្រាយអាចបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ។

ចាប់ភ្ជាប់ប្រដាប់ការពារ/របាំងទាំងឡាយនៅនឹងកន្លែងគ្រប់ពេលវេលាអំឡុងពេលប្រតិបត្តិការ។

ស្លៀកពាក់សម្លៀកបំពាក់ដែលស័ក្តិសមនឹងខ្លួន។ បញ្ឈប់ម៉ាស៊ីន និងប្រាកដថា កង្ហារ ខ្សែក្រវាត់ រ៉ក និងដងបញ្ជាត្រូវបានបញ្ឈប់មុនពេលធ្វើការកែសម្រួល ការតភ្ជាប់ ឬការសម្អាតដែលនៅក្បែរកង្ហារ និងសមាសធាតុនៃការបញ្ជារបស់ពួកវា។

OUO6075,0000C23-KM-03MAY11

## ចៀសវាងសារធាតុរាវសម្ពាធខ្ពស់



X9811—UN—23AUG88

ត្រួតពិនិត្យទុយោអ៊ីដ្រូលីកជាប្រចាំ – យ៉ាងហោចណាស់មួយឆ្នាំម្តង – ក្រែងលោមានការលេចធ្លាយ ស្នាមក្រពើត ស្នាមដាច់ ស្នាមប្រេះ ស្នាមសឹក ស្នាមជ៉ោង ច្រេះស៊ី ស្នាមរបក និងសញ្ញាផ្សេងៗអំពីការសឹក ឬខូចខាត។

ផ្លាស់ប្តូរថ្មីនូវបន្តុំទុយោដែលដាច់រហែក ឬខូចខាតជាបន្ទាន់ជាមួយគ្រឿងបន្លាស់សម្រាប់ផ្លាស់ប្តូរដែលមានការអនុញ្ញាតដោយ John Deere ។

សារធាតុរាវរងសម្ពាធដែលបាញ់ចេញមកអាចធ្វើឲ្យធ្លុះស្បែក និងបង្ករឲ្យមានរបួសធ្ងន់ធ្ងរ។

ជៀសវាងគ្រោះថ្នាក់ដោយបន្ទរសម្ពាធមុននឹងផ្តាច់ខ្សែទុយោប្រេង ឬខ្សែទុយោផ្សេងៗទៀត។ មួលបន្តឹងរាល់តំណភ្ជាប់ទាំងអស់មុនពេលប្រើសម្ពាធ។

រកមើលកកន្លែងលេចដោយប្រើក្រដាសកាតុងរឹង។ ការពារដៃនិងដងខ្លួនក្រែងលោប៉ះនឹងសារធាតុរាវសម្ពាធខ្ពស់។

ប្រសិនបើមានគ្រោះថ្នាក់កើតឡើង សូមទៅជួបវេជ្ជបណ្ឌិតជាបន្ទាន់។ រាល់ធាតុរាវដែលចាក់ចូលទៅក្នុងស្បែកត្រូវតែរះយកចេញក្នុងរយៈពេលពីរ ឬបីម៉ោង បើពុំដូច្នោះទេ វាអាចបណ្តាលឲ្យកើតដំបៅរលួយ។ វេជ្ជបណ្ឌិតដែលពុំមានការយល់ដឹងអំពីរបួសប្រភេទនេះ គួរស្វែងរកឯកសារយោងពីប្រភពវេជ្ជសាស្ត្រដែលមានចំណេះដឹងច្រើន។ ព័ត៌មាននេះមានជាភាសាអង់គ្លេសពីនាយកដ្ឋានវេជ្ជសាស្ត្ររបស់សាជីវកម្ម Deere & Company នៅ Moline, Illinois, U.S.A, ទូរសព្ទ 1-800-822-8262 ឬ +1 309-748-5636។

DX,FLUID-KM-12OCT11

## កុំបើកប្រព័ន្ធប្រេងឥន្ធនៈមានសម្ពាធខ្ពស់



TS1343—UN—18MAR92

ធាតុរាវមានសម្ពាធខ្ពស់ដែលតែមាននៅក្នុងទុយោប្រេងឥន្ធនៈ អាចបង្កឲ្យមានរបួសធ្ងន់ធ្ងរ។ កុំផ្តាច់ ឬព្យាយាមជួសជុលទុយោប្រេង សិនស័រ ឬសមាសភាគផ្សេងៗដែលស្ថិតនៅ ចន្លោះបូមប្រេងដែលមានសម្ពាធខ្ពស់ និងក្បាលទុយោនៅលើម៉ាស៊ីនដែលមានប្រព័ន្ធប្រេងឥន្ធនៈបំពង់រួមសម្ពាធខ្ពស់ (HPCR) ។

មានតែអ្នកបច្ចេកទេសដែលមានចំណេះដឹងផ្នែកប្រព័ន្ធប្រភេទនេះប៉ុណ្ណោះ ដែលអាចធ្វើការជួសជុលបាន។ (សូមទៅជួបអ្នកចែកចាយ John Deere របស់អ្នក។)

DX,WW,HPCR1-KM-07JAN03

## ផ្តល់សេវាថែទាំប្រព័ន្ធធុងសម្ពាធដោយសុវត្ថិភាព



TS281—UN—15APR13

ការបង្ហូរសារធាតុរាវ ឬឧស្ម័នចេញពីប្រព័ន្ធដែលមានធុងសម្ពាធ ដែលត្រូវបានប្រើប្រាស់នៅក្នុងប្រព័ន្ធម៉ាស៊ីន ត្រជាក់ ប្រព័ន្ធអ៊ីដ្រូលីក និងប្រព័ន្ធហ្វ្រាំងខ្យល់ អាចបណ្តាលឲ្យមានការរងរបួសធ្ងន់ធ្ងរ។ កម្តៅក្តៅហួសហេតុអាចបណ្តាលឲ្យធុងសម្ពាធផ្ទុះ ហើយទុយោដែលមានសម្ពាធអាចដាច់ដោយចៃដន្យ។ កុំផ្សារ ឬប្រើក្បាលផ្សារនៅជិតធុងសម្ពាធ ឬទុយោដែលមានសម្ពាធ។

បន្ធូរសម្ពាធចេញពីប្រព័ន្ធដែលមានសម្ពាធ មុននឹងដោះធុងសម្ពាធចេញ។

បន្ធូរសម្ពាធចេញពីប្រព័ន្ធអ៊ីដ្រូលីក មុននឹងដោះធុងសម្ពាធប្រេងចេញ។ កុំព្យាយាមបន្ធូរសម្ពាធនៃប្រព័ន្ធអ៊ីដ្រូលីកឬសម្ពាធធុងសម្ពាធដោយបន្ធូរគ្រឿងខ្ជៅ។

ធុងសម្ពាធពុំអាចជួសជុលបានទេ។

DX,WW,ACCLA2-KM-22AUG03

## ការពារប្រឆាំងស្រុំពោយដែលមានសម្ពាធខ្ពស់




TS1343—UN—18MAR92

ការបាញ់ស្រុំពោយដោយប្រើក្បាលបាញ់ដែលមានសម្ពាធខ្ពស់អាចជ្រាបចូលស្បែក និងអាចបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ។ ទុកស្រុំពោយកុំឲ្យប៉ះដៃ ឬខ្លួនប្រាណ។

ប្រសិនបើមានគ្រោះថ្នាក់កើតឡើង សូមទៅជួបវេជ្ជបណ្ឌិតជាបន្ទាន់។ រាល់ស្រុំពោយដែលមានសម្ពាធខ្ពស់ណាមួយដែលបានចាក់ចូលទៅក្នុងស្បែក ត្រូវតែរះយកចេញក្នុងរយៈពេលពីរ ឬបីម៉ោង បើពុំដូច្នោះទេ អាចបណ្តាលឲ្យកើតដំបៅរលួយ។ វេជ្ជបណ្ឌិតដែលពុំមានការយល់ដឹងអំពីរបួសប្រភេទនេះ គួរស្វែងរកឯកសារយោងពីប្រភពវេជ្ជសាស្ត្រដែលមានចំណេះដឹងច្រើន។ ព័ត៌មាននេះមានជាភាសាអង់គ្លេសពីផ្នែកវេជ្ជសាស្ត្ររបស់សាជីវកម្ម Deere & Company ដែលមានអាសយដ្ឋាននៅ Moline, Illinois, USA។

DX,SPRAY-KM-16APR92

## អនុវត្តតាមការណែនាំអំពីសំបកកង់



H111235—UN—13MAY14

រក្សាគ្រឿងម៉ាស៊ីនរបស់អ្នកឲ្យស្ថិតនៅក្នុងលំដាប់លំដោយ ដំណើរការត្រឹមត្រូវ។

ប្រើប្រាស់តែទំហំសំបកកង់ដែលបានបញ្ជាក្តិដោយមានការកំណត់កម្រិតត្រឹមត្រូវ និងសប់ខ្សល់វាឲ្យដល់សម្ពាធដែលបានបញ្ជាក់នៅក្នុងសៀវភៅណែនាំនេះ។

ការប្រើប្រាស់សំបកកង់ផ្សេងពីសំបកដែលបានបញ្ជាក្តិអាចកាត់បន្ថយភាពល់នឹង ប៉ះពាល់ដល់ការបញ្ជាចង្កូត បណ្តាលឲ្យមានការខូចមុនពេលកំណត់ ឬបណ្តាលឲ្យមានបញ្ហាដល់ការប្រើប្រាស់បានយូរ ឬសុវត្ថិភាពផ្សេងទៀត។

DX,TIRE,INFO-KM-19MAY14

## ផ្តល់សេវាសំបកកង់ដោយសុវត្ថិភាព



RXA0103438—UN—11JUN09

ការផ្ទុះបែកសំបកកង់ និងផ្នែកខ្ជងកង់ អាចបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ ឬស្លាប់។

កុំព្យាយាមដំឡើងសំបកកង់ លុះត្រាតែអ្នកមានឧបករណ៍ និងបទពិសោធន៍ត្រឹមត្រូវក្នុងការធ្វើការងារនេះ។

ជានិច្ចកាល ត្រូវរក្សាសម្ពាធខ្សល់ក្នុងសំបកកង់ឲ្យបានត្រឹមត្រូវ។ សូមកុំសប់ខ្សល់សំបកកង់លើសពីសម្ពាធខ្សល់ដែលបានណែនាំ។ សូមកុំផ្សារ ឬដុតកម្តៅកង់ និងបង្គុំសំបកកង់។ កម្តៅអាចបណ្តាលឲ្យសម្ពាធខ្សល់កើនឡើងដែលធ្វើឲ្យសំបកកង់ផ្ទុះ។ ការផ្សារអាចធ្វើឲ្យខ្សោយរចនាសម្ព័ន្ធ ឬខូចទ្រង់ទ្រាយរបស់កង់។


នៅពេលសប់ខ្សល់ចូលសំបកកង់ សូមប្រើក្បាលស្នប់កៀប និងទុយោបន្តដែលមានប្រវែងវែងល្មមដែលអាចឲ្យអ្នកឈរនៅម្ខាង ហើយមិនមែននៅពីមុខ ឬពីលើបង្គុំសំបកកង់ទេ។ ប្រើទ្រុងសុវត្ថិភាព ប្រសិនបើមាន។

ត្រួតពិនិត្យមើលកង់ ក្រែងលោមានសម្ពាធខ្សល់ទាប ស្នាមដាច់ ស្នាមប៉ោង តែមខូច ឬបាត់ប៊ូឡុង និងខ្ចៅរឺត។

កង់ និងសំបកកង់គឺធ្ងន់។ នៅពេលកាន់កង់ និងសំបកកង់ប្រើឧបករណ៍លើកដោយសុវត្ថិភាព ឬប្រើឧបករណ៍ជំនួយ ដើម្បីជួយលើក ឬដោះចេញ។

DX,WW,RIMS-KM-28FEB17

## ការឈប់ដំណើរការ៖ ការកែច្នៃឡើងវិញ និងការបោះចោលសារធាតុរាវ និងសមាសភាគផ្សេងៗឲ្យបានត្រឹមត្រូវ



TS1133—UN—15APR13

ត្រូវពិចារណាទៅលើវិធានការការពារសុវត្ថិភាព និងបរិស្ថាន នៅពេលឈប់ដំណើរការគ្រឿងចក្រ និង/ឬ សមាសភាគរបស់វា។ វិធានការទាំងនេះរួមមានដូចតទៅ៖

- ប្រើប្រាស់ឧបករណ៍ និងគ្រឿងបរិក្ខារការពារខ្លួនដូចជា សម្លៀកបំពាក់ស្រោមដៃ របាំងការពារមុខ ឬវ៉ែនតាការពារ នៅអំឡុងពេលដោះចេញ ឬចាប់កាន់វត្ថុ និងវត្ថុធាតុផ្សេងៗ។
- គោរពតាមសេចក្តីណែនាំសម្រាប់សមាសភាគឯកទេស។
- បញ្ចេញថាមពលដែលបានរក្សាទុក ដោយបន្ទាបគ្រឿងរបស់ម៉ាស៊ីនដែលបានលើកឡើងលើបន្ទូរីស័រ ផ្តាច់អាគុយ ឬថាមពលអគ្គិសនីផ្សេងទៀត និងបន្ទូរសម្ពាធនៅក្នុងគ្រឿងអ៊ីដ្រូលីកធុងសំពាធ និងប្រព័ន្ធស្រដៀងគ្នាដទៃទៀត។
- កាត់បន្ថយការប៉ះនឹងសមាសភាគផ្សេងៗ ដែលអាចមានកាកសំណល់ពីថ្នាំកសិកម្មដូចជាជីគីមី និងថ្នាំសម្លាប់សត្វល្អិត។ ធ្វើការជាមួយ និងបោះចោលសមាសភាគទាំងនេះឲ្យបានសមស្រប។
- បង្ហូរចេញឲ្យអស់នូវ ប្រេងពីម៉ាស៊ីន ប្រេងពីធុងប្រេង ទឹកពីកញ្ចែងវ៉ាឌីយ៉ាទ័រប្រេងពីស៊ុឡាំងអ៊ីដ្រូលីក សារជាតុរាវពីធុងស្តុក និងទុយោផ្សេងៗមុននឹងពេលដោះគ្រឿងម៉ាស៊ីនសម្រាប់ប្រើឡើងវិញ។ប្រើសម្ភារផ្ទុកដែលធន់នឹងការលេចធ្លាយនៅពេលបង្ហូរប្រេង។ កុំប្រើសម្ភារផ្ទុកចំណីអាហារឬភេសជ្ជៈ។
- កុំចាក់ប្រេងសំណល់ទៅលើដី ចូលទៅក្នុងលូ ឬចូលទៅក្នុងប្រភពទឹក។
- ប្រតិបត្តិតាមច្បាប់ បទបញ្ជា បទបញ្ជាក្តីថ្នាក់ជាតិ រដ្ឋ និងមូលដ្ឋានទាំងឡាយដែលគ្រប់គ្រងការចាត់ចែង ឬការបោះចោលកាកសំណល់សារធាតុរាវ (ឧទាហរណ៍៖ ប្រេងម៉ាស៊ីន ប្រេងឥន្ធនៈ ទឹកស្នំម៉ាស៊ីនប្រេងហ្វ្រាំង) តម្រង អាគុយ និងសារធាតុ ឬគ្រឿងបន្លាស់ផ្សេងៗ។ ការដុតប្រេងឬសមាសភាគទាំងឡាយដែលងាយឆាបឆេះនៅក្នុងឡដុតសំរាមក្រៅពីឡដុតសំរាមដែលត្រូវបាន

រចនាឡើងជាពិសេសអាចត្រូវបានហាមឃាត់ដោយច្បាប់ ហើយអាចបណ្តាលឲ្យប៉ះនឹងចំហាយផ្សែង និងផេះដែលបង្កគ្រោះថ្នាក់។

- ផ្តល់សេវា និងបោះចោលប្រព័ន្ធម៉ាស៊ីនត្រជាក់ឲ្យបានសមស្រប។ បទបញ្ជាតុិរដ្ឋាភិបាលអាចតម្រូវឲ្យមជ្ឈមណ្ឌលផ្តល់សេវាដែលមានការទទួលស្គាល់ ក្នុងការកែឆ្នៃ និងកែប្រែឧប្រើប្រាស់ឡើងវិញនូវជាតុត្រជាក់នៅក្នុងម៉ាស៊ីនត្រជាក់ដែលអាចធ្វើឲ្យខូចបរិយាកាស ប្រសិនបើឲ្យវាភាយចេញមកក្រៅ។
- វាយតម្លៃជម្រើសក្នុងការប្រើប្រាស់ឡើងវិញសម្រាប់សំបកកង លោហៈធាតុផ្លាស្ទិក កញ្ចក់ ដែរ និងសមាសភាគអេឡិចត្រូនិច ដែលអាចប្រើប្រាស់ឡើងវិញបានដោយផ្នែក ឬទាំងមូល។
- សូមទាក់ទងមជ្ឈមណ្ឌលបរិស្ថាន ឬប្រើប្រាស់ឡើងវិញនៅក្នុងស្រុករបស់អ្នកឬអ្នកចែកចាយ John Deere របស់អ្នកសម្រាប់ព័ត៌មានអំពីវិធីក្នុងការប្រើប្រាស់ឡើងវិញឬបោះចោលសំរាមដែលត្រឹមត្រូវ។

DX,DRAIN-KM-01JUN15

## ផ្តល់សេវាប្រព័ន្ធបន្តយកម្តៅដោយសុវត្ថិភាព



TS281—UN—15APR13

ការផ្ទុះធាតុរាវចេញពីប្រព័ន្ធបញ្ចុះកម្តៅដែលមានសម្ពាធអាចបណ្តាលឲ្យរលាកធ្ងន់ធ្ងរ។

ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។

ហាមបន្ថែមទឹកថ្នាំស្អុំម៉ាស៊ីននៅពេលម៉ាស៊ីនកំពុងក្តៅខ្លាំង។ ចូររង់ចាំទាល់តែវាចុះត្រជាក់សិន។

ហាមបើកគម្របធុងខ្ចោលចេញនៅពេលទឹកថ្នាំស្អុំម៉ាស៊ីន ឬម៉ាស៊ីនកំពុងក្តៅ។ ចូររង់ចាំទាល់តែទឹកថ្នាំស្អុំម៉ាស៊ីនចុះត្រជាក់សិន ទើបដោះគម្របចេញ។

មួលបន្លួគម្របបន្តិចម្តងៗដើម្បីបន្ធូរសម្ពាធសិន មុននឹងដោះចេញទាំងស្រុង។

បន្ថែមទឹកថ្នាំស្អុំម៉ាស៊ីនចូល តែនៅពេលម៉ាស៊ីនមិនដំណើរការប៉ុណ្ណោះ។

OUO6075,0004E98-KM-26JUN20

## សម្អាតកម្ទេចកម្ទីដើមដំណាំដែលកកកុញ




TS227—UN—15APR13

គំនរអំពុកចំបើងនៅក្នុងបន្ទប់ម៉ាស៊ីន នៅលើម៉ាស៊ីន និងនៅជិតគ្រឿងមានចលនាអាចបង្ករជាអគ្គីភ័យ។ ចូរពិនិត្យនិងសម្អាតតំបន់ទាំងនេះឲ្យបានញឹកញាប់។ មុនពេលត្រួតពិនិត្យនិងផ្តល់សេវាថែទាំ ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃនិងដកសោចេញ។

HX,9010SA,B-KM-23AUG97

## ទ្រគ្រឿងចក្រឲ្យបានត្រឹមត្រូវ



TS229—UN—23AUG88

ជានិច្ចកាល សូមបន្ទាបប្រដាប់ប្រដា និងឧបករណ៍បន្ទាប់បន្សំឲ្យដល់ដី មុនពេលអ្នកធ្វើការនៅលើគ្រឿងចក្រ។ ប្រសិនបើការងារនោះតម្រូវឲ្យលើកគ្រឿងចក្រ ឬឧបករណ៍បន្ទាប់បន្សំ សូមលើកទ្រវាឲ្យមានសុវត្ថិភាព។ ប្រសិនបើទុកវាចោលក្នុងទីតាំងលើកផុតពីដី ឧបករណ៍ទ្រដោយប្រើអ៊ីដ្រូលីក អាចស្រុត ឬលេចជ្រាបបាន។

កុំទ្រគ្រឿងចក្រនៅលើប្លុកស៊ីម៉ង់ត៍ ឥដ្ឋប្រហោង ឬជន្លង់ដែលអាចបាក់ស្រុបចុះក្រោមបន្ទុកជាបន្តបន្ទាប់។ កុំធ្វើការនៅក្រោមគ្រឿងចក្រដែលទ្រដោយដែកគ្រឹបតែមួយគត់។ សូមគោរពតាមនីតិវិធីដែលបានណែនាំនៅក្នុងសៀវភៅណែនាំនេះ។

នៅពេលប្រដាប់ប្រដា ឬឧបករណ៍បន្ទាប់បន្សំត្រូវបានប្រើប្រាស់ជាមួយគ្រឿងចក្រ ជានិច្ចកាលសូមគោរពតាមការប្រុងប្រយ័ត្នសុវត្ថិភាពជាមុន ដែលមានរៀបរាប់នៅក្នុងសៀវភៅណែនាំប្រតិបត្តិករប្រដាប់ប្រដា ឬឧបករណ៍បន្ទាប់បន្សំ។

DX,LOWER-KM-24FEB00

## រក្សាទុកឧបករណ៍បំពាក់បន្ថែមដោយសុវត្ថិភាព




TS219—UN—23AUG88

ឧបករណ៍បំពាក់បន្ថែមដែលបានរក្សាទុក ដូចជា កង់ឧបកង់ដែក និងប៉ែលលើកដាក់អាចធ្លាក់ ហើយបណ្តាលឲ្យមានការរងរបួស និងស្លាប់បាន។

រក្សាទុកឧបករណ៍បំពាក់បន្ថែមឲ្យមានសុវត្ថិភាពដើម្បីបង្ការការធ្លាក់។ រក្សាឲ្យកុមារដែលកំពុងរត់លេង និងអ្នកឈរមើលនៅឆ្ងាយពីកន្លែងរក្សាទុក។

DX,STORE-KM-03MAR93

## ថែទាំជួសជុលខ្សែពានអូសដោយសុវត្ថិភាព



TS285—UN—23AUG88

នៅពេលថែទាំជួសជុលខ្សែពានអូស ចូរពិនិត្យមើលចំណុចទាំងនេះ៖

- ចូរចៀសវាងកុំឲ្យរងរបួសធ្ងន់ធ្ងរដោយសារតែដៃប៉ះគ្រឿងម៉ាស៊ីន។ ចូរកុំព្យាយាមសម្អាតពិនិត្យ ឬលៃតម្រូវខ្សែពានខណៈដែលគ្រឿងចក្រកំពុងដំណើរការ។ ជានិច្ចកាល ចូរពន្លត់ម៉ាស៊ីនដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
- ចូរកុំសម្អាតខ្សែពានជាមួយសារធាតុរំលាយសម្អាតដែលឆាបឆេះ។

OUO6075,00026A4-KM-06FEB03

## ធ្វើការជាមួយគ្រឿងអេឡិចត្រូនិច និងក្រចាប់វាដោយសុវត្ថិភាព



TS249—UN—23AUG88

ការធ្លាក់ចុះខណៈពេលកំពុងដំឡើង ឬដោះសមាសភាគអេឡិចត្រូនិចដែលត្រូវបានដាក់ដំឡើងនៅលើឧបករណ៍ អាចបណ្តាលឲ្យមានការរងរបួសធ្ងន់ធ្ងរ។ សូមប្រើជណ្តើរ ឬរន្ធាដើម្បីដាយស្រួលក្នុងការឈានទៅដល់ទីតាំងដាក់ដំឡើងនីមួយៗ។ ប្រើទម្រជើង និងទម្រដៃដែលរឹងមាំ និងមានសុវត្ថិភាព។ កុំដំឡើង ឬដោះចេញនូវសមាសភាគផ្សេងៗនៅ ក្នុងលក្ខខណ្ឌសើម ឬមានទឹកកក។

ប្រសិនបើដំឡើង ឬធ្វើសេវាថែទាំស្ថានីយ៍មូលដ្ឋាន RTK នៅលើប៉ម ឬរចនាសម្ព័ន្ធខ្ពស់ សូមប្រើអ្នកឡើងដែលមានការទទួលស្គាល់។

ប្រសិនបើដំឡើង ឬផ្តល់សេវាថែទាំសរសរបង្គោលអង់តែនចាប់ទីតាំង ដែលត្រូវបានប្រើនៅលើឧបករណ៍បំពាក់បន្ថែម សូមប្រើបច្ចេកទេសលើកដាក់ឲ្យបានត្រឹមត្រូវ និងពាក់ឧបករណ៍ការពារឲ្យបានត្រឹមត្រូវ។ សរសរបង្គោលធំៗមានទម្ងន់ធ្ងន់ ហើយអាចពិបាកក្នុងការចាប់កាន់។ ត្រូវការមនុស្សពីរនាក់នៅពេលទីតាំងដាក់ដំឡើងពុំអាចទៅដល់បានពីដី ឬពីរន្ធាសេវា។

DX,WW,RECEIVER-KM-24AUG10

## ជៀសវាងគ្រោះថ្នាក់ដោយសារមើលមនុស្សខាងក្រោយមិនឃើញ



PC10857XW—UN—15APR13

មុនពេលផ្លាស់ទីគ្រឿងចក្រ ត្រូវប្រាកដថា មនុស្សទាំងអស់មិនស្ថិតនៅផ្លូវរបស់គ្រឿងចក្រ។ មើលឆ្វេងស្តាំ ហើយមើលដោយផ្ទាល់នូវរយៈចម្ងាយដែលអាចមើលឃើញដោយភ្នែកទទេបានល្អបំផុត។ ប្រើមនុស្សសម្រាប់ជួយសុំញ៉ូវរំពេលថយក្រោយ ប្រសិនបើចាំងមើលមិនឃើញ ឬនៅកន្លែងចង្អៀត។


កុំពឹងផ្អែកតែទៅលើម៉ាស៊ីនថត ក្នុងការកំណត់ថាតើមានបគ្គលិក ឬឧបសគ្គនៅពីក្រោយដែរឬយ៉ាងណានោះ។ ប្រព័ន្ធអាចមានកម្រិតដោយសារកត្តាជាច្រើនដូចជា ការអនុវត្តន៍ក្នុងការថែទាំ លក្ខខណ្ឌអាកាសធាតុ និងទំហំនៃការប្រតិបត្តិការ។

DX,AVOID,BACKOVER,ACCIDENTS-KM-30AUG10

## ធ្វើការជាមួយនឹងអាគុយដោយសុវត្ថិភាព



TS204—UN—15APR13



TS203—UN—23AUG88

ឧស្ម័នអាគុយអាចផ្ទុះបាន។ រក្សាឲ្យផ្កាភ្លើង និងអណ្តាភ្លើងស្ថិតនៅឆ្ងាយពីអាគុយ។ ប្រើពិលដើម្បីត្រួតពិនិត្យមើលកម្រិតអេឡិចត្រូលីត។

កុំឆែកកំរិតភ្លើងរបស់អាគុយដោយដាក់លោហៈប៉ះប៉ូលទាំងពីររបស់វា។ ប្រើវ៉ុលម៉ែត្រ ឬអ៊ីដ្រូម៉ែត្រ។

ជានិច្ចកាល ដោះដង្កៀបអាគុយម៉ាស់ (-) ជាមុនសិន ហើយចាប់ដង្កៀបម៉ាស់មកវិញក្រោយគេ។

អាស៊ីតស៊ុលផួរិចនៅក្នុងអេឡិចត្រូលីតរបស់អាគុយ មានជាតិពុល ហើយខ្លាំងល្មមដែលអាចធ្វើឲ្យស្បែករលាក ធ្វើឲ្យសម្លៀកបំពាក់ឆ្លុះឆ្លាយ និងធ្វើឲ្យខ្វាក់បាន ប្រសិនបើខ្ចាត់ចូលទៅក្នុងភ្នែក។

**ជៀសវាងគ្រោះថ្នាក់ដោយ:**

- បំពេញទឹកអាគុយនៅកន្លែងដែលមានខ្យល់ចេញចូលគ្រប់គ្រាន់
- ពាក់ឧបករណ៍ការពារភ្នែក និងស្រោមដៃជ័រ
- ជៀសវាងការប្រើប្រាស់សម្ភាធខ្យល់ដើម្បីសម្អាតអាគុយ
- ជៀសវាងការហឹតចំហាយភាយនៅពេលបន្ថែមអេឡិចត្រូលីត
- ជៀសវាងការហៀរកំពប់ ឬស្រក់អេឡិចត្រូលីត
- ប្រើប្រដាប់ដំឡើងតុងស្បូងអាគុយ ឬវិធីសាកអាគុយអោយបានត្រឹមត្រូវ។

**ប្រសិនបើអាស៊ីតហៀរកំពប់ទៅស្បែក ឬចូលទៅក្នុងភ្នែក:**

1. លាងជម្រះស្បែកជាមួយទឹក។
2. ប្រើម្សៅសូដាសម្រាប់ដាក់ដុតនំ ឬកំបោរដើម្បីជួយបន្សាបជាតិអាស៊ីត។
3. លាងជម្រះភ្នែកជាមួយទឹក រយៈពេល 15—30 នាទី។ ទទួលការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រជាបន្ទាន់។

**ប្រសិនបើបានលេបអាស៊ីតចូល:**

1. កុំជំរុញឲ្យក្អួត។
2. ផឹកទឹក ឬទឹកដោះគោឲ្យបានច្រើន ប៉ុន្តែមិនត្រូវលើសពី 2 L (2 qt.)ទេ។
3. ទទួលការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រជាបន្ទាន់។


**ការព្រមាន:** ក្បាល និងក្រចាប់អាគុយ និងគ្រឿងដែលពាក់ព័ន្ធ មានផ្ទុកជាតិសំណ និងសមាសភាគសំណ ដែលជាសារធាតុគីមីដែលគេដឹងនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាថាបណ្តាលឲ្យកើតជាជំងឺមហារីក និងគ្រោះថ្នាក់ចំពោះសុខភាពបន្តពូជ។ **លាងសម្អាតដៃក្រោយពេលធ្វើការជាមួយនឹងវា។**

DX,WW,BATTERIES-KM-02DEC10


## សម្អាតតម្រងបំពង់ស៊ីមុាំងដោយសុវត្ថិភាព



TS227—UN—15APR13



TS271—UN—23AUG88



TS1693—UN—09DEC09

ក្នុងពេលធ្វើការសម្អាតតម្រងបំពង់ស៊ីមុំង ម៉ាស៊ីនអាចបញ្ចេះនៅការ៉ង់ទីខ្ពស់ និងសីតុណ្ហភាពខ្ពស់នៅក្នុងរយៈពេលវែង។ ផ្សែង និងគ្រឿងតម្រងបំពង់ស៊ីមុំង ឡើងដល់សីតុណ្ហភាពក្តៅខ្លាំងដែលអាចធ្វើឲ្យរលាកមនុស្ស ឬឆេះ ឬរំលាយវត្ថុធាតុធម្មតាបាន។

រក្សាឲ្យគ្រឿងចក្រស្ថិតនៅឆ្ងាយពីមនុស្ស សត្វ ឬសំណង់ទាំងឡាយដែលងាយរងគ្រោះថ្នាក់ ឬការខូចខាតដោយសារផ្សែង ឬគ្រឿងបំពង់ស៊ីមុំងក្តៅ។ ជៀសវាងគ្រោះថ្នាក់អគ្គីភ័យ ឬការផ្ទុះដែលអាចកើតមានឡើងដោយសារសារធាតុ ឬចំហាយដែលងាយឆាបឆេះដែលដាក់ក្បែរបំពង់ស៊ីមុំង។ រក្សាឲ្យមាត់បំពង់ស៊ីមុំងនៅឆ្ងាយពីមនុស្ស និងអ្វីៗដែលអាចរលាយ រលាក ឬផ្ទុះបាន។

អង្កេតមើលគ្រឿងចក្រ និងទីជុំវិញឲ្យបានល្អិតល្អន់ ក្រែងលោមានរងឹកភ្លើងនៃកំទេចកំទីនៅអំឡុងពេល និងក្រោយពេលដែលសម្អាតតម្រងបំពង់ស៊ីមុំង។

ការចាក់បន្ថែមប្រេងខណៈពេលគ្រឿងចក្រកំពុងដំណើរការ អាចបង្កើតបានជាអគ្គីភ័យ ឬ គ្រោះថ្នាក់ដោយសារការផ្ទុះ។ ជានិច្ចកាល ត្រូវពន្លត់ម៉ាស៊ីនសិនមុននឹងចាក់ប្រេងគ្រឿងចក្រ និងសម្អាតប្រេងដែលហៀរកំពប់ចេញឲ្យបានស្អាត។

ជានិច្ចកាល ត្រូវប្រាកដថាបានពន្លត់ម៉ាស៊ីន ខណៈពេលសណ្តោងគ្រឿងចក្រស្ថិតនៅលើឡានដឹក ឬរទេះសណ្តោង។

ការប៉ះពាល់គ្រឿងបំពង់ស៊ីមុំងពេលវានៅក្តៅ អាចបណ្តាលឲ្យមានការរងរបួសធ្ងន់ធ្ងរ។

ជៀសវាងការប៉ះជាមួយសមាសភាគទាំងនេះ រហូតដល់វាត្រជាក់ដល់សីតុណ្ហភាពដែលមានសុវត្ថិភាព។

ប្រសិនបើនីតិវិធីផ្តល់សេវាជួសជុល តម្រូវឲ្យម៉ាស៊ីនដំណើរការ៖

- ភ្ជាប់តែផ្នែកទាំងឡាយណាដែលដើរដោយថាមពល ដែលតម្រូវដោយនីតិវិធីក្នុងការផ្តល់សេវាប៉ុណ្ណោះ
- ត្រូវប្រាកដថា អ្នកដទៃទៀតស្ថិតនៅឆ្ងាយពីកន្លែងសម្រាប់អ្នកបើកបរនិងគ្រឿងចក្រទាំងមូល

រក្សាឲ្យដៃ ជើង និងសម្លៀកបំពាក់នៅឲ្យឆ្ងាយពីផ្នែកទាំងឡាយណាដែលដើរដោយថាមពល។

ជានិច្ចកាល ត្រូវបិទចលនា (នៅនឹង) ដាក់យន្តការចតឬចាប់ហ្វ្រាំង ហើយផ្តាច់ថាមពលទៅនឹងប្រដាប់ប្រដា ឬឧបករណ៍ផ្សេងៗមុននឹងចាកចេញពីស្ថានីយ៍ប្រតិបត្តិការ។

ពន្លត់ម៉ាស៊ីន ហើយដកកូនសោចេញ (ប្រសិនបើមានបំពាក់មកជាមួយ) មុននឹងទុកគ្រឿងចក្រចោលដោយគ្មានមនុស្សនៅ។

OUO6075,0000E81-KM-07FEB12

## ជៀសវាងការប៉ះពាល់បំពង់ស៊ីមុំងក្តៅ



RG17488—UN—21AUG09


ការផ្តល់សេវាដល់គ្រឿងចក្រ ឬឧបករណ៍បន្ទាប់បន្សំនៅពេលម៉ាស៊ីនកំពុងដំណើរការ អាចបណ្តាលឲ្យមានការរងរបួសធ្ងន់ធ្ងរ។ ជៀសវាងការប៉ះពាល់ផ្សែង និងគ្រឿងពីបំពង់ស៊ីមុំង។

គ្រឿងនៃប្រព័ន្ធបំពង់ស៊ីមុំង និងផ្សែង មានកំដៅក្តៅខ្លាំងនៅពេលត្រាក់ទ័រដំណើរការ។ ឧស្ម័ន និងសមាសភាគនៅក្រែងបំពង់ស៊ីមុំង ឈានឡើងដល់សីតុណ្ហភាពក្តៅល្មមដែលអាចធ្វើឲ្យមនុស្សរលាក ឆេះ ឬរំលាយវត្ថុធាតុធម្មតាបាន។

DX,EXHAUST-KM-20AUG09

# សញ្ញាសុវត្ថិភាព (សម្រាប់ទីផ្សារនាំចេញ)

## ផ្លាស់ប្តូរស្លាកសញ្ញាសុវត្ថិភាពជាថ្មី




TS201—UN—15APR13

ផ្លាស់ប្តូរសញ្ញាសុវត្ថិភាពដែលបាត់បង់ ឬខូចខាត។ ប្រើប្រាស់សៀវភៅណែនាំរបស់ប្រតិបត្តិករគ្រឿងម៉ាស៊ីនសម្រាប់ការដាក់ស្លាកសញ្ញាសុវត្ថិភាពឲ្យបានត្រឹមត្រូវ។

អាចមានព័ត៌មានអំពីសុវត្ថិភាពបន្ថែមនៅលើគ្រឿងបន្លាស់ និងសមាសភាគដែលទទួលបានពីអ្នកផ្គត់ផ្គង់ ដែលពុំត្រូវបានផលិតឡើងវិញនៅក្នុងសៀវភៅណែនាំប្រតិបត្តិករនេះ។

DX,SIGNS-KM-18AUG09

## សញ្ញាសុវត្ថិភាពជារូបគំនូរ





TS231—KM—18MAY17

នៅតាមទីកន្លែងសំខាន់ៗមួយចំនួននៅលើគ្រឿងចក្រនេះ សញ្ញាសុវត្ថិភាពត្រូវបានបិទដើម្បីផ្តល់ដំណឹងពីគ្រោះថ្នាក់ដែលអាចកើតឡើង។ គ្រោះថ្នាក់ត្រូវកំណត់ដោយរូបគំនូរក្នុងសញ្ញាត្រីកោណព្រមានគ្រោះថ្នាក់។ រូបគំនូរដែលនៅជិតនោះផ្តល់ព័ត៌មានពីរបៀបចៀសវាងគ្រោះថ្នាក់ផ្ទាល់ខ្លួន។ សញ្ញាសុវត្ថិភាពទាំងនេះ ការបិទនៅលើគ្រឿងចក្រនិងអត្ថបទពន្យល់ខ្លីត្រូវបង្ហាញនៅខាងក្រោម។

OUO6075,0001163-KM-19JUN12

## សៀវភៅណែនាំប្រើប្រាស់




YC21255—UN—21DEC22

សៀវភៅណែនាំប្រតិបត្តិកររនេះ មានព័ត៌មានសំខាន់ៗទាំងអស់ដែលចាំបាច់សម្រាប់ដំណើរការគ្រឿងចក្រដោយសុវត្ថិភាព។ ប្រតិបត្តិតាមវិធានសុវត្ថិភាពទាំងអស់ដោយប្រុងប្រយ័ត្ន ដើម្បីចៀសវាងគ្រោះថ្នាក់។

cp00834,1668991983756-KM-20NOV22

## ការជួសជុលនិងថែទាំ

*កំណត់ចំណាំ៖ រូបសញ្ញាសុវត្ថិភាពនៅលើទូបញ្ជាខាងស្តាំដៃខាងក្នុងកាប៊ីន។*




YC21256—UN—21DEC22

មុនពេលធ្វើការជួសជុល និងថែទាំ ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។ ដើម្បីជ្រាបពីកិច្ចការថែទាំទាំងអស់ ចូរអានសៀវភៅណែនាំសម្រាប់ប្រតិបត្តិករ។

cp00834,1668992413311-KM-20NOV22

## ខ្សែក្រវាត់សុវត្ថិភាព




YC21254—UN—21DEC22

ពាក់ខ្សែក្រវាត់សុវត្ថិភាពនៅពេលប្រតិបត្តិការគ្រឿងចក្រ។

cp00834,1668992073399-KM-20NOV22

## ហ្វ្រាំងដៃ

*កំណត់ចំណាំ៖ រូបសញ្ញាសុវត្ថិភាពនៅលើទូបញ្ជាខាងស្តាំដៃ ខាងក្នុងកាប៊ីន។*




YC21257—UN—21DEC22

ខ្ទាស់ហ្វ្រាំងជើងទាំងពីរមុនពេលបើកបរលើផ្លូវថ្នល់។ ដាក់ហ្វ្រាំងដៃមុនពេលចាកចេញពីគ្រឿងចក្រ។

cp00834,1668993153296-KM-20NOV22

## ថៀសវាងខ្សែអគ្គិសនីដែលស្ថិតនៅទាប




YC21258—UN—21DEC22

ប្រយ័ត្នក្រែងលោរងរបួសធ្ងន់ធ្ងរ ឬស្លាប់ដោយសារការឆក់ចរន្តអគ្គិសនី។ ប្រយ័ត្នប៉ះខ្សែបណ្តាញអគ្គិសនី។ រក្សាប្រដាប់បូមដំឡើងនៅក្នុងទីតាំងដឹកជញ្ជូន។

cp00834,1668993405121-KM-20NOV22

## ជណ្តើរឡើងទៅកាន់កាប៊ីន/ផ្លែតហ្វម




YC21259—UN—21DEC22

ប្រយ័ត្នក្រែងលោធ្លាក់រងរបួសធ្ងន់ធ្ងរ។ ហាមឲ្យអ្នកជិះស្ថិតនៅលើជណ្តើរ ឬតំបន់ផ្លែតហ្វមខណៈដែលគ្រឿងចក្រកំពុងដំណើរការ។

cp00834,1668993620720-KM-20NOV22

## ចូរប្រយ័ត្នក្រែងលោប៉ះទង្គិចជាមួយយានយន្តដទៃ




YC21260—UN—21DEC22

ប្រយ័ត្នក្រែងលោប៉ះទង្គិចជាមួយយានយន្តដទៃ និងរបួសធ្ងន់ធ្ងរ ឬស្លាប់បាត់បង់ជីវិត។ ជានិច្ចកាល ចូរបត់ជណ្តើរឡើងទៅទីតាំងដឹកជញ្ជូនមុននឹងបើកបរគ្រឿងចក្រនៅតាមផ្លូវថ្នល់។


cp00834,1668993764625-KM-20NOV22

## ប្រដាប់ការពារសុវត្ថិភាពមាត់ច្រកបួងចូល




YC21261—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ចំហៀងខាងឆ្វេងដៃនៃមាត់ច្រកបួងចូល)



YC21262—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ចំហៀងខាងឆ្វេងដៃនៃមាត់ច្រកបួងចូលខាងក្តួងរបាំងការពារ)




YC21263—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ចំហៀងខាងស្តាំដៃមាត់ច្រកបួងចូល)

ប្រយ័ត្នរងរបួសដោយសារការប៉ះទង្គិច។ ដាក់ឧបករណ៍ក្បាលកាត់នៅលើដី ឬទំនប់សុវត្ថិភាព ដែលស្ថិតនៅលើស៊ីឡាំងទម្រេតមាត់ច្រកបួងចូលមុនពេលចូលក្រោមក្បាលឧបករណ៍កាត់។

cp00834,1668994428825-KM-20NOV22

## ដែកការពារមាត់ច្រកបួងចូល




YC21264—UN—21DEC22

ចូរប្រយ័ត្នក្រែងលោរងរបួសធ្ងន់ធ្ងរ ឬស្លាប់ដោយសារទាក់ជាប់នឹងគ្រឿងម៉ាស៊ីន។ ហាមលើករបាំងការពារឡើងនៅពេលម៉ាស៊ីនកំពុងដំណើរការ។ ពន្លត់ម៉ាស៊ីន រួចដកកូនសោចេញ។

cp00834,1668994598619-KM-20NOV22

## ទ្វារពិនិត្យមាត់ច្រកបួងចូល




YC21265—UN—21DEC22

ប្រយ័ត្នក្រែងលោរងរបួសធ្ងន់ធ្ងរដោយសារប៉ះគ្រឿងដែលមានចលនា។ ហាមបើកទ្វារពិនិត្យមើល ចាំទាល់តែចលនាមាត់ច្រកបួងចូលឈប់ដំណើរការសិន។

cp00834,1668994718539-KM-20NOV22

## ទ្វារពិនិត្យមើលស៊ីឡាំងបោកបែន




YC21266—UN—21DEC22

ប្រយ័ត្នក្រែងលោរងរបួសធ្ងន់ធ្ងរដោយសារប៉ះគ្រឿងដែលមានចលនា។ ហាមបើកទ្វារពិនិត្យមើល ចាំទាល់តែចលនាស៊ីឡាំងបោកបែនឈប់ដំណើរការសិន។


cp00834,1668994851180-KM-20NOV22

## ប្រដាប់ការពារ




YC21267—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ចំហៀងខាងឆ្វេងដៃគ្រឿងចក្រ)




YC21270—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ចំហៀងខាងឆ្វេងដៃគ្រឿងចក្រ)



YC21268—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ចំហៀងខាងស្តាំដៃគ្រឿងចក្រ)




YC21269—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ចំហៀងខាងស្តាំដៃគ្រឿងចក្រ)

ចូរប្រយ័ត្នក្រែងលោរងរបួសធ្ងន់ធ្ងរ ឬស្លាប់ដោយសារទាក់ជាប់នឹងគ្រឿងម៉ាស៊ីន។ ហាមលើករបាំងការពារឡើងនៅពេលម៉ាស៊ីនកំពុងដំណើរការ។ ពន្លត់ម៉ាស៊ីន រួចដកកូនសោចេញ។

cp00834,1668996397535-KM-20NOV22

## ប្រដាប់យោងគ្រាប់ធញ្ញជាតិ




YC21271—UN—21DEC22

ចូរប្រយ័ត្នក្រែងលោរងរបួសធ្ងន់ធ្ងរ ឬស្លាប់ដោយសារទាក់ជាប់នឹងគ្រឿងម៉ាស៊ីន។ ហាមបើកគម្របនៅពេលម៉ាស៊ីនកំពុងដំណើរការ។ ពន្លត់ម៉ាស៊ីន រួចដកកូនសោចេញ។

cp00834,1668996832741-KM-20NOV22

## ទ្វារសម្អាតប្រដាប់បួងទម្លាក់




YC21272—UN—21DEC22

ចូរប្រយ័ត្នក្រែងលោរងរបួសធ្ងន់ធ្ងរ ឬស្លាប់ដោយសារទាក់ជាប់នឹងគ្រឿងម៉ាស៊ីន។ ពន្លត់ម៉ាស៊ីន រួចដកកូនសោចេញ មុននឹងបើកទ្វារសម្អាត។

cp00834,1668996955880-KM-20NOV22

## ទ្វារតម្រងសំណាញ់វិល និងកង្ហារធុងទឹកម៉ាស៊ីន




YC21279—UN—21DEC22

ប្រយ័ត្នក្រែងលោរងរបួសដោយសារតែកង្ហារវិលនិងសមាសភាពគ្រឿងតម្រងសំណាញ់។ ពន្លត់ម៉ាស៊ីន ហើយដកសោចេញ មុននឹងបើកទ្វារតម្រងសំណាញ់វិល។

cp00834,1668998678315-KM-20NOV22

## ប្រព័ន្ធបញ្ចុះកម្តៅ




YC21278—UN—21DEC22

ប្រព័ន្ធបញ្ចុះកម្តៅប្រើសម្ពាធ។ ដើម្បីការពារកុំឲ្យរបួសដោយសាររលាក ដោយសារតែការបញ្ចេញចំហាយមិនបានគ្រប់គ្រង ហើយទឹកថ្នាំសំណើច រង់ចាំរហូតដល់ប្រព័ន្ធត្រជាក់។ បន្ធូរគម្របយឺតៗ ទុកឲ្យសម្ពាធចេញអស់មុននឹងដោះគម្រប។


cp00834,1668998486034-KM-20NOV22

## ប្រេងអ៊ីដ្រូលិកដែលរងសម្ពាធ




YC21282—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ចំហៀងខាងឆ្វេងដៃនៃមាត់ច្រកបូងចូល)




YC21283—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ចំហៀងខាងស្តាំដៃគ្រឿងចក្រ)



YC21284—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ចំហៀងខាងឆ្វេងដៃគ្រឿងចក្រ)



YC21285—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ធុងស្តុកអ៊ីដ្រូស្តាទិក)


ប្រយ័ត្នរងរបួសធ្ងន់ធ្ងរដោយសារប៉ះនឹងប្រេងអ៊ីដ្រូលិកដែលរងសម្ពាធ។

មុនពេលដោះសមាសភាគ្រឿងអ៊ីដ្រូលិកចេញ៖

1. បន្ធូរសម្ពាធអ៊ីដ្រូលិកប្រព័ន្ធ។ សូមយោងតាមសៀវភៅណែនាំ និងសៀវភៅជួសជុលសម្រាប់ព័ត៌មានអំពីប្រព័ន្ធ។
2. ពន្លត់ម៉ាស៊ីន រួចដកកូនសោចេញ។


cp00834,1669001320789-KM-20NOV22

## កម្ទេចកម្ទីខ្ចាត់ចេញពីប្រដាប់ចិញ្ច្រាំ



YC21273—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ចំហៀងខាងឆ្វេងដៃកាំបិតចិញ្ច្រាំ)




YC21274—UN—21DEC22

រូបសញ្ញាសុវត្ថិភាព (ចំហៀងខាងស្តាំដៃកាំបិតចិញ្ច្រាំ)

ចៀសវាងកុំឲ្យមានរបួសពីការធ្លាក់វត្ថុផ្សេងៗ។ នៅឲ្យឆ្ងាយពេលម៉ាស៊ីនកំពុងដំណើរការ។

cp00834,1668997444362-KM-20NOV22




YC21287—UN—21DEC22

ជណ្តើរចូលទៅផ្នែកខាងមុខ

ប្រយ័ត្នក្រែងលោធ្លាក់រងរបួសធ្ងន់ធ្ងរ។ កុំដិះលើជណ្តើរឬផ្នែកហ្វូមម៉ាស៊ីនពេលម៉ាស៊ីនកំពុងផ្លាស់ទី។

cp00834,1668997683492-KM-20NOV22

## ផ្នែកាំបិតចិញ្ច្រាំ




YC21275—UN—21DEC22

ចូរប្រយ័ត្នក្រែងលោរងរបួសធ្ងន់ធ្ងរដោយសារប៉ះនឹងកាំបិតចិញ្ច្រាំ។ ប្រដាប់ចិញ្ច្រាំវិលក្តាងទីតាំងជួរពាំនូក។ សូមនៅឲ្យឆ្ងាយ។

cp00834,1668997487137-KM-20NOV22


## ជណ្តើរចូលនិងផ្នែតហ្វូមសេវ៉ា



YC21276—UN—21DEC22

ជណ្តើរចូលទៅផ្នែកខាងក្រោយ

## ជៀសវាងអគ្គីភ័យ




YC21277—UN—21DEC22

ចៀសវាងការឆាបឆេះគ្រឿងបរិក្ខារ។ គំនរអំពុកដើមដំណាំ ស្លឹក និងសម្ភារដំណាំដទៃទៀតនៅជុងប្រេងឥន្ធនៈអាចបង្ករជាអគ្គិភ័យ។ ពិនិត្យមើល និងសម្អាតតំបន់នេះឲ្យបានញឹកញាប់។

cp00834,1668998256727-KM-20NOV22

## អង្គបណ្តុំ




YC21280—UN—21DEC22

ដើម្បីបង្ការគ្រោះថ្នាក់រងរបួសនិងខូចខាតដែលអាចកើតឡើងចំពោះអង្គបណ្តុំឬប្រព័ន្ធអ៊ីដ្រូលិក ចូររក្សាសម្ពាធឧស្ម័ននីដ្រូសែនតាមការណែនាំ។ សាកតែជាមួយនីដ្រូសែនស្ងួតប៉ុណ្ណោះ។

cp00834,1668998953206-KM-20NOV22

## ធុងគ្រាប់ធញ្ញជាតិ




YC21286—UN—21DEC22

ចូរប្រយ័ត្នក្រែងលោរងរបួសធ្ងន់ធ្ងរ ឬស្លាប់ដោយសារទាក់ជាប់នឹងគ្រឿងម៉ាស៊ីន។ កុំបញ្ចូលធុងគ្រាប់ធញ្ញជាតិនៅពេលម៉ាស៊ីនកំពុងដំណើរការ។

cp00834,1669002893664-KM-20NOV22

## សីតុណ្ហភាពស៊ីម៉ាំង



YC21281—UN—21DEC22

គ្រឿងប្រព័ន្ធផ្សែងបំពង់ស៊ីម៉ាំងអាចក្តៅ។ ដើម្បីចៀសវាងការរលាកធ្ងន់ធ្ងរ ហាមចូលទៅជិតគ្រឿងប្រព័ន្ធបំពង់ស៊ីម៉ាំង។

cp00834,1668999270256-KM-20NOV22

## ឧបករណ៍បញ្ជា និងឧបករណ៍




YC1536—UN—25NOV13

មុនពេលដំណើរការគ្រឿងចក្រច្រូតកាត់ថ្មី ត្រូវស្វែងយល់ឱ្យស្គាល់ទីតាំង និងមុខងារប្រដាប់បញ្ជា និងឧបករណ៍នីមួយៗ។

CP00834,0008DE5-KM-27MAY21


## ទិដ្ឋភាពរួមនៃប្រដាប់បញ្ជា និងឧបករណ៍ (ការអូសដោយមេកានិក)




YC20971—UN—07DEC22

ប្រដាប់បញ្ជាគ្រឿងបញ្ជាខាងស្តាំដៃ

**A—ចង្កឹះល្បឿនលើឌី**
**B—ដៃគ្រប់គ្រងលើក/បន្ទាបក្បាលឧបករណ៍កាត់**
**C—ដៃគ្រប់គ្រងលើក/បន្ទាបកង់រ៉ក**
**D—កុងតាក់សោ**
**E—កុងតាក់ល្បឿនកង់រ៉ក**
**F—កុងតាក់ភ្លើងការងារ**
**G—កុងតាក់ភ្លើងព្រមានគ្រោះថ្នាក់**
**H—កុងតាក់ភ្លើង**
**I—កុងតាក់ភ្លើងកាំពន្លឺខ្ពស់**
**J—កុងតាក់ភ្លើងទម្លាក់ និងភ្លើងវិល**
**K—កុងតាក់ហ្គែរ**
**M—ព្រីម៉ាមពលជំនួយ (សម្រាប់ទីផ្សារនាំចេញប៉ុណ្ណោះ)**
**N—ចង្កឹះលែតម្រូវល្បឿនបោកបែន**
**O—ដៃលែតម្រូវចន្លោះប្រអប់កញ្ចែង**
**P—ចង្កឹះហ្វ្រាំងដៃ**
**Q—ព្រី Service Advisor**
**R—កុងតាក់ភ្លើងសញ្ញាបត់**
**S—កុងតាក់ស៊ុតថ្នេ**
**T—ចង្កឹះលេខ**





YC17965—UN—14JUL21

ប្រដាប់បញ្ជាគ្រឿងបញ្ជាខាងឆ្វេងដៃនិងខាងមុខ

**U—អេក្រង់បង្ហាលកាច់ជ្រុង**
**V—ឈ្នាន់ហ្វ្រាំងជើង (ប្រើ 2)**
**W—ដៃភ្ជាប់ក្បាលឧបករណ៍កាត់**
**X—ដៃគ្រប់គ្រងការអូសកង់ក្រោយ (ជាជម្រើស)**
**Y—ដៃភ្ជាប់ប្រព័ន្ធបោកបែន**
**Z—ដៃភ្ជាប់ប្រដាប់ប្តូរទម្លាក់**
**AA—ឈ្នាន់លែតម្រូវដៃចង្កូត**
**BB—ឈ្នាន់អង្រឹយ៉ា**

cp00834,1668583678051-KM-17NOV22

## ទិដ្ឋភាពរួមនៃប្រដាប់បញ្ជា និងឧបករណ៍ (ការអូសដោយអ៊ីដ្រូស្តាទិក)




YC20972—UN—07DEC22

ប្រដាប់បញ្ជាគ្រឿងបញ្ជាខាងស្តាំដៃ

**A—កុងតាក់ភ្លើងសញ្ញាបត់**
**B—កុងតាក់សោ**
**C—កុងតាក់ល្បឿនកង់រ៉ក**
**D—កុងតាក់ភ្លើងការងារ**
**E—កុងតាក់ភ្លើងព្រមានគ្រោះថ្នាក់**
**F—កុងតាក់ភ្លើង**
**G—ដៃបញ្ជាពហុមុខងារ**
**H—កុងតាក់លើផ្ទៃវិទ្យុ**

J—ព្រីថាមពលជំនួយ (សម្រាប់ទីផ្សារនាំចេញប៉ុណ្ណោះ)
K—ដៃលៃតម្រូវចន្លោះប្រអប់ញ្ជែង
L—កុងតាក់ល្បឿនបោកបែន
M—កុងតាក់ហ្គែរ
N—កុងតាក់ភ្លើងទម្លាក់ និងភ្លើងវិល
O—កុងតាក់ភ្លើងកាំពន្លឺខ្ពស់
P—ចង្កឹះលេខ
Q—ព្រី Service Advisor
R—ចង្កឹះហ្វ្រាំងដៃ
S—កុងតាក់ស៊ីផ្លេ




YC17962—UN—14JUL21

ប្រដាប់បញ្ជាគ្រឿងបញ្ជាខាងឆ្វេងដៃនិងខាងមុខ

T—អេក្រង់បង្ហោលកាច់ជ្រុង
U—ឈ្នាន់ហ្វ្រាំងជើង (ប្រើ 2)
V—ដៃភ្ជាប់ក្បាលឧបករណ៍កាត់
W—ដៃគ្រប់គ្រងការអូសកង់ក្រោយ (ជាជម្រើស)
X—ដៃភ្ជាប់ប្រព័ន្ធបោកបែន
Y—ដៃភ្ជាប់ប្រដាប់បួងទម្លាក់
Z—ឈ្នាន់លៃតម្រូវដៃចង្កូត

## ដៃបញ្ជាពហុមុខងារ





YC17963—UN—14JUL21

A—ប៊ូតុងលើកឡើងក្បាលឧបករណ៍កាត់
B—ប៊ូតុងលើកកង់រកឡើង
C—ប៊ូតុងបន្ទាបកង់រក
D—ប៊ូតុងយោលប្រដាប់បួងទម្លាក់ចេញក្រៅ
E—ប៊ូតុងយោលប្រដាប់បួងទម្លាក់ចូលក្នុង
F—ប៊ូតុងបន្ទាបក្បាលឧបករណ៍កាត់


cp00834,1668583788869-KM-17NOV22

## ទិដ្ឋភាពរួមផ្នែកខាងក្នុងស្ថានីយប្រតិបត្តិករ




YC17966—UN—14JUL21

A—កុងតាក់ផ្ទិតទឹក
B—កុងតាក់ម៉ូដ HVAC
C—ក្បាលមួលគ្រប់គ្រងល់ហ្វារខ្យល់
D—ក្បាលមួលលៃតម្រូវសីតុណ្ហភាព AC
E—វិទ្យុ (ជម្រើស)





YC17967—UN—14JUL21

F—ភ្លើងពន្លឺតិចៗ

CP00834,0008F93-KM-28SEP21

## អេក្រង់បង្ហោលកាច់ជ្រុង

### អេក្រង់បង្ហោលកាច់ជ្រុងនៅលើអ៊ីនធឺហ្វេសត្រួតពិនិត្យ




YC14238—UN—24DEC19

**A - ភ្លើងសញ្ញាឈប់ (ក្រហម)៖** ភ្លឺឡើង នៅពេលម៉ាស៊ីនត្រូវការឈប់ភ្លាម ដោយសារបញ្ហាធ្ងន់ធ្ងរអ្វីមួយ។ កូដបញ្ហារោគវិនិច្ឆ័យពាក់ព័ន្ធគ្នានឹងជុសឡើងរហូតទាល់តែបញ្ហាត្រូវបានដោះស្រាយរួច។

**B - ភ្លើងសញ្ញាជូនដំណឹងពីសេវាថែទាំ (ពណ៌លឿង)៖** ភ្លឺឡើងនៅពេលមានបញ្ហាជាមួយម៉ាស៊ីន។ ទាមទារបញ្ឈប់គ្រឿងចក្រឲ្យបានលឿនបំផុតតាមដែលអាចធ្វើបាន។ កូដបញ្ហារោគវិនិច្ឆ័យពាក់ព័ន្ធគ្នានឹងជុសឡើង។

**C - ភ្លើងសញ្ញាព័ត៌មាន (ពណ៌ខៀវ)៖** ភ្លឺឡើងដើម្បីជូនដំណឹងដល់អ្នកបើកបរពីលក្ខខណ្ឌអ្វីមួយ។ កូដបញ្ហារោគវិនិច្ឆ័យពាក់ព័ន្ធគ្នានឹងជុសឡើង។ នៅពេលចុចទទួលស្គាល់ការព្រមាន សារអេក្រង់រលត់ទៅវិញ ហើយភ្លើងសញ្ញាបិទ។

**D - ភ្លើងសញ្ញាបត់ស្តាំ៖** ភ្លឺឡើងនៅពេលបត់ស្តាំ។ ដំណើរការដោយកុងតាក់ភ្លើងសញ្ញាបត់។

**E - ភ្លើងសញ្ញាហ្វ្រាំងដៃ៖** បើកឡើងពេលជាប់ហ្វ្រាំងដៃ។

**F - ប្រដាប់វាស់ថាមពលម៉ាស៊ីន៖** បង្ហាញភាគរយថាមពលដែលម៉ាស៊ីនកំពុងប្រើប្រាស់ស្ថិតក្នុងពេលកំណត់៖

- តំបន់បៃតង៖ 35—100%
- តំបន់ពណ៌លឿង៖ 101—107%
- តំបន់ក្រហម៖ 108—114%

**សំខាន់៖ ប្រសិនបើភ្លើងសញ្ញាម៉ែត្រថាមពលរំកិលចូលទៅក្នុងតំបន់ក្រហម នោះថាមពលម៉ាស៊ីនត្រូវបង្អាក់ជាអតិបរមា ហើយគ្រឿងចក្រអាចគាំង។ ចូរបន្ថយបន្ទុកនៅលើគ្រឿងចក្ររហូតទាល់តែភ្លើងសញ្ញារំកិលថយទៅក្នុងតំបន់ពណ៌បៃតង ឬលឿង។**

**G - ភ្លើងសញ្ញាល្បឿនលើដី** បង្ហាញល្បឿនលើដីរបស់គ្រឿងចក្រពេលបច្ចុប្បន្ន។

**H - ប្រដាប់វាស់ល្បឿនរង្វិល៖** បង្ហាញល្បឿនម៉ាស៊ីនបច្ចុប្បន្ន។

**I - ភ្លើងសញ្ញាល្បឿនបោកបែន៖** បង្ហាញល្បឿនបោកបែនបច្ចុប្បន្ន។

**J - ភ្លើងសញ្ញាល្បឿនកង្ហារសម្អាត៖** បង្ហាញល្បឿនកង្ហាសម្អាតបច្ចុប្បន្ន។

**K - ភ្លើងសញ្ញាកម្រិតប្រេងឥន្ធនៈ៖** បង្ហាញពីបរិមាណប្រេងដែលនៅសល់នៅក្នុងធុង។ នៅពេលកម្រិតប្រេងឈានដល់ 10% ភ្លើងសញ្ញាប្រេងឥន្ធនៈលោតភ្លឺបភ្លែត សញ្ញាជូនដំណឹងបន្លឺឡើង ហើយសារនឹងជុសឡើង។

**L - ម៉ោងការងារ៖** បង្ហាញម៉ោងធ្វើការរបស់យានយន្ត។

**M - កម្លាំងវ៉ុលត៍អាគុយ៖** បង្ហាញកម្លាំងវ៉ុលត៍របស់យានយន្ត។

**N - ភ្លើងសញ្ញាគាំងរបាំងការពារខាងក្រោយ៖** ភ្លឺឡើងដើម្បីជូនដំណឹងដល់ប្រតិបត្តិការថារបាំងការពារខាងក្រោយគាំង។

**O - ភ្លើងសញ្ញាធុងគ្រាប់ធញ្ញជាតិពេញ៖** ភ្លឺឡើងនៅពេលធុងគ្រាប់ធញ្ញជាតិពេញ។

**P - ភ្លើងសញ្ញាសីតុណ្ហភាពទឹកផ្សំសុំម៉ាស៊ីន៖** បង្ហាញសីតុណ្ហភាពទឹកសុំម៉ាស៊ីនបច្ចុប្បន្ន។ តំបន់បៃតងបង្ហាញអំពីសីតុណ្ហភាពប្រតិបត្តិការធម្មតា។

**Q - ភ្លើងសញ្ញាសម្ពាធគ្រប់គ្រងប្រេងអ៊ីដ្រូលិក៖** ភ្លឺឡើងដើម្បីជូនដំណឹងអ្នកបើកថាសម្ពាធគ្រប់គ្រងប្រេងអ៊ីដ្រូលិកមានកម្រិតខ្ពស់។

**R - ភ្លើងសញ្ញាសីតុណ្ហភាពប្រេងអ៊ីដ្រូស្ទាទិក៖** ភ្លឺឡើងដើម្បីជូនដំណឹងអ្នកបើកថាសីតុណ្ហភាពគ្រប់គ្រងប្រេងអ៊ីដ្រូស្ទាទិកមានកម្រិតខ្ពស់។


**S—ភ្លើងសញ្ញាបត់ឆ្វេង៖** ភ្លឺឡើងពេលគ្រោងនឹងបន្តទៅខាងឆ្វេង។ ដំណើរការដោយកុងតាក់ភ្លើងសញ្ញាបត់។

**T - ភ្លើងសញ្ញាកម្រិតប្រេងហ្គ្រាំង៖** ភ្លឺឡើងដើម្បីជូនដំណឹងអ្នកបើកថាកម្រិតប្រេងហ្គ្រាំងទាប។

**U - ភ្លើងសញ្ញាសម្គាធប្រេងម៉ាស៊ីន៖** បង្ហាញសម្គាធប្រេងម៉ាស៊ីនបច្ចុប្បន្ន។ តំបន់បៃតងបង្ហាញអំពីសម្គាធប្រតិបត្តិការធម្មតា។

**V - ភ្លើងសញ្ញាកាំពន្លឺខ្ពស់៖** ភ្លឺឡើងនៅពេលបើកភ្លើងកាំពន្លឺខ្ពស់។


**ទំព័រដើមបន្ទាប់ពីបញ្ជោះ**




YC18022—UN—14JUL21

**A—ប្រដាប់វាស់ថាមពលម៉ាស៊ីន**
**B—ភ្លើងសញ្ញាល្បឿនលើន៏**
**C—ប្រដាប់វាស់ល្បឿនរង្វិល**
**D—ភ្លើងសញ្ញាល្បឿនបោកបែន**
**E—ភ្លើងសញ្ញាល្បឿនកង្ហារសម្អាត**
**F—ភ្លើងសញ្ញាកម្រិតប្រេងឥន្ធនៈ**
**G—ម៉ោងការងារ**
**H—កម្លាំងវ៉ុលត៍អាគុយ**
**I—ភ្លើងសញ្ញាបង្ហាញសីតុណ្ហភាពទឹកថ្នាំស្អុំម៉ាស៊ីន**
**J—ភ្លើងសញ្ញាសម្គាធប្រេងម៉ាស៊ីន**

**ប៊ូតុង**




YC14241—UN—20DEC19

**A—ប៊ូតុង**
**B—ប៊ូតុង**
**C—ប៊ូតុង**


មានប៊ូតុងចំនួនបី (A, B, និង C) នៅផ្នែកខាងក្រោមអេក្រង់បង្ហោលកាច់ជ្រុង។

ចុចប៊ូតុងទាំងនោះដើម្បីបើកដំណើរការមុខងារស្របគ្នា។

cp00834,1668584223761-KM-16NOV22

## ការរាវរកផ្លូវម៉ឺនុយលើអេក្រង់បង្ហោលកាច់ជ្រុង

### ការរាវរកផ្លូវម៉ឺនុយចម្បង




YC17401—UN—27APR21

ទំព័រដើមរបស់អេក្រង់បង្ហោលកាច់ជ្រុង

1. កាច់កុងតាក់ទៅទីតាំងដំណើរការ។ ជាវ៉ាម៉ែត្រនិងភ្លើងសញ្ញាទាំងអស់បើក។

   ទំព័រដើមរបស់អេក្រង់បង្ហោលកាច់ជ្រុងប្តូរទៅទំព័រទី 2 ពីទំព័រទី 1 ។

*កំណត់ចំណាំ៖ ប៊ូតុងទាំងបី (A, B, និង C) ដែលបង្ហាញជាស្នាដៃសិល្ប: គឺជាប៊ូតុងទាំងបីនៅផ្នែកខាងក្រោមអេក្រង់បង្ហោលកាច់ជ្រុង។*




YC20405—UN—01AUG22


តំបន់អេក្រង់បង្ហាញការកំណត់ និងទិន្នន័យការងារ

**A—ប៊ូតុងរមូរ**
**B—ប៊ូតុងថយក្រោយ**
**C—ប៊ូតុង Enter**

2. ចុចប៊ូតុងនៅខាងស្តាំ នៅជាតរបស់អេក្រង់បង្ហោលកាច់ជ្រុង ដើម្បីទៅកាន់ទំព័រទី2 ពីទំព័រទី 1 ។
3. ចុចប៊ូតុងអូស (A) ដើម្បីជ្រើសរើសម៉ឺនុយរងតាមចង់បាន។
4. ចុចប៊ូតុង Enter (C) ដើម្បីទៅកាន់ម៉ឺនុយរង។ ចុចប៊ូតុងថយក្រោយ (B)ដើម្បីត្រឡប់ទៅកាន់ម៉ឺនុយមេវិញ។

### ការចូលទៅកាន់ម៉ឺនុយរងទិន្នន័យការងារ

*កំណត់ចំណាំ៖ ប៊ូតុងទាំងបី (A, B, និង C) ដែលបង្ហាញជាស្នាដៃសិល្ប: គឺជាប៊ូតុងទាំងបីនៅផ្នែកខាងក្រោមអេក្រង់បង្ហោលកាច់ជ្រុង។*




YC20404—UN—01AUG22

ទំព័រម៉ឺនុយរងទិន្នន័យការងារ *1, 2, 3*


**A—ប៊ូតុងរមូរឡើងលើ**
**B—ប៊ូតុងរមូរចុះក្រោម**
**C—ប៊ូតុង Enter**

ចុចប៊ូតុងរមូរចុះក្រោម (B) និងប៊ូតុងរមូរឡើងលើ (A) ដើម្បីជ្រើសរើសម៉ឺនុយរងនៃទិន្នន័យការងារដែលចង់បាន និងពិនិត្យមើលទិន្នន័យការងារដែលត្រូវគ្នា។

ចុចប៊ូតុង "enter" (C) ដើម្បីត្រឡប់ទៅកាន់ម៉ឺនុយមេវិញ។

### ការចូលទៅកាន់ម៉ឺនុយរងកំណត់ប្រព័ន្ធ

*កំណត់ចំណាំ៖ ប៊ូតុងទាំងបី (A, B, និង C) ដែលបង្ហាញជាស្នាដៃសិល្ប: គឺជាប៊ូតុងទាំងបីនៅផ្នែកខាងក្រោមអេក្រង់បង្ហោលកាច់ជ្រុង។*




YC14244—UN—02JAN20

ម៉ឺនុយរងកំណត់ប្រព័ន្ធ

**A—ជ្រើសរើសភាសា**
**B—ពន្លឺ**
**C—ឯកតារង្វាស់**
**D—ម៉ូដែល និង ការកំណត់រចនាសម្ព័ន្ធ**
**E—ប៊ូតុង Enter**
**F—ប៊ូតុងការលៃតម្រូវ**
**G—ប៊ូតុងរមូរ**


ចុចប៊ូតុងអូស (G) ដើម្បីជ្រើសរើសម៉ឺនុយរងនៃការកំណត់ប្រព័ន្ធដែលខ្លួនចង់បាន។

- **ជ្រើសរើសភាសា (A)៖** ចុចប៊ូតុងលៃតម្រូវ(F)ដើម្បីជ្រើសរើសភាសា (អង់គ្លេស ឬចិន)។
- **ពន្លឺ (B)៖** ចុចប៊ូតុងលៃតម្រូវដើម្បីលៃតម្រូវពន្លឺ។
- **ឯកតារង្វាស់ (C)៖** ចុចប៊ូតុងលៃតម្រូវដើម្បីផ្លាស់ប្តូរឯកតារង្វាស់(រង្វាស់ខ្នាតម៉ែត្រ ឬខ្នាតឯកតារាស់)
- **ម៉ូដែល និងការកំណត់រចនាសម្ព័ន្ធ (D)៖** ម៉ឺនុយរងនេះមិនអាចកំណត់បានឡើយ។

ចុចប៊ូតុង "enter" (E) ដើម្បីត្រឡប់ទៅកាន់ម៉ឺនុយមេវិញ។

### ការចូលទៅកាន់ម៉ឺនុយរងនៃការខូចបច្ចុប្បន្ន

*កំណត់ចំណាំ៖ ប៊ូតុងទាំងបី (E, F, និង G) ដែលបង្ហាញជាស្នាដៃសិល្បៈ គឺជាប៊ូតុងទាំងបីនៅផ្នែកខាងក្រោមអេក្រង់បង្ហោលកាច់ជ្រុង។*




YC17355—UN—20APR21


**A—SPN (លេខជំរាំម៉ែត្រគួរឱ្យសង្ស័យ)**
**B—ការខូចបច្ចុប្បន្ន**
**C—FMI (ភ្លើងសញ្ញាបញ្ជាក់ម៉ូដកំហុស)**
**D—តំបន់ព័ត៌មាន DTC**
**E—ប៊ូតុង Enter**
**F—ប៊ូតុងបន្ទាប់**
**G—ប៊ូតុងរមូរ**

ចុចប៊ូតុងអូស (G) ដើម្បីជ្រើសរើស DTC ដែលខ្លួនចង់បាន និង ពិនិត្យមើលព័ត៌មាន DTC ។ ចុចប៊ូតុងបន្ទាប់ (F) ដើម្បីមើល DTC ក្នុងទំព័របន្ទាប់។

ចុចប៊ូតុង Enter (E) ដើម្បីត្រឡប់ទៅកាន់ទំព័រមុនវិញ។

### ការចូលទៅកាន់ម៉ឺនុយរងនៃកំហុសពីមុន

*កំណត់ចំណាំ៖ ប៊ូតុងទាំងបី (E, F, និង G) ដែលបង្ហាញជាស្នាដៃសិល្បៈ គឺជាប៊ូតុងទាំងបីនៅផ្នែកខាងក្រោមអេក្រង់បង្ហោលកាច់ជ្រុង។*




YC17356—UN—20APR21

**A—SPN (លេខជាវ៉ារ៉ាម៉ែត្រគួរឱ្យសង្ស័យ)**
**B—ការខូចបច្ចុប្បន្ន**
**C—FMI (ភ្លើងសញ្ញាបញ្ជាក់ម៉ូដកំហុស)**
**D—តំបន់ព័ត៌មាន DTC**
**E—ប៊ូតុង Enter**
**F—ប៊ូតុងបន្ទាប់**
**G—ប៊ូតុងរមូរ**

ចុចប៊ូតុងអូស (G) ដើម្បីជ្រើសរើស DTC ដែលខ្លួនចង់បាន និង ពិនិត្យមើលព័ត៌មាន DTC ។ ចុចប៊ូតុងបន្ទាប់ (F) ដើម្បីមើល DTC ក្នុងទំព័របន្ទាប់។

ចុចប៊ូតុង Enter (E) ដើម្បីត្រឡប់ទៅកាន់ទំព័រមុនវិញ។


## កូដបញ្ហារោគវិនិច្ឆ័យ

| លេខ DTC | ព័ត៌មាន DTC | លេខ DTC | ព័ត៌មាន DTC |
|---|---|---|---|
| 91.03 | អាណាឡូកទីតាំងកុងតាក់ហ្គែរ OOR ខ្ពស់ | 637.07 | ភាពមិនដូចគ្នានៃសិនស័រកំណត់ពេល / សិនស័រទីតាំងម៉ាស៊ីន |
| 91.04 | អាណាឡូកទីតាំងកុងតាក់ហ្គែរ OOR L | 637.08 | អង្គញ្ញាណពេលបានបាត់សញ្ញា |
| 94.03 | កម្លាំងរ៉ុលត៍សម្ពាធប្រេងឥន្ធនៈ OOR ខ្ពស់ | 637.10 | រកឃើញកំហុសលំនាំអង្គញ្ញាណកំណត់ពេល |
| 94.04 | កម្លាំងរ៉ុលត៍សម្ពាធប្រេងឥន្ធនៈ OOR ទាប | 651.00 | ប៊ិចប្រេងត្រូវបានកំណត់ដោយរយៈពេលសន្ទុះអតិបរមានៅលើស៊ីឡាំងលេខ 1 |
| 94.18 | សម្ពាធប្រេងទាប - កម្រិតខ្លាំងល្មម | 651.01 | ប៊ិចប្រេងត្រូវបានកំណត់ដោយរយៈពេលសន្ទុះអប្បបរមានៅលើស៊ីឡាំងលេខ 1 |
| 107 | សម្ពាធខ្យល់ទាបនៅរន្ធឧបករណ៍បីតខ្យល់ចូល | 651.02 | លេខគ្រឿងបន្លាស់ប៊ិចប្រេងលេខ 1 មិនត្រឹមត្រូវ |
| 627.18 | កម្លាំងរ៉ុលត៍អាគុយនៅខាងក្រោមកម្រិតជម្ពូតា - កម្រិតខ្លាំងល្មម | 651.05 | ចរន្តទៅប៊ិចប្រេងក្នុងស៊ីឡាំងលេខ 1 តិចជាងការរំពឹងទុក |
| 729.03 | គ្រឿងកម្តៅខ្យល់រីឡេ (បញ្ជូន) ទិន្នផលខ្ពស់នៅពេលរីឡេ (ការបញ្ជូន) មិនសកម្ម។ | 651.06 | SPV[0] មានខ្លី |
| 729.05 | គ្រឿងកម្តៅខ្យល់ រីឡេ (បញ្ជូន) ទិន្នផលទាបនៅពេល រីឡេ (ការបញ្ជូន) មិនសកម្ម។ | 651.13 | កំហុសខ្សែកូដ QR លេខ 1 |
| 1075.05 | ចរន្តទាបជាងការរំពឹងទុក | 652.00 | ប៊ិចប្រេងត្រូវបានកំណត់ដោយរយៈពេលសន្ទុះអតិបរមានៅលើស៊ីឡាំងលេខ 2 |
| 97.03 | ទឹកនៅក្នុងកម្លាំងរ៉ុលត៍ប្រេងឥន្ធនៈ OOR ខ្ពស់ | 652.01 | ប៊ិចប្រេងត្រូវបានកំណត់ដោយរយៈពេលសន្ទុះអប្បបរមានៅលើស៊ីឡាំងលេខ 2 |
| 97.04 | ទឹកនៅក្នុងកម្លាំងរ៉ុលត៍ប្រេងឥន្ធនៈ OOR ទាប | 652.02 | លេខគ្រឿងបន្លាស់ប៊ិចប្រេងលេខ 2 មិនត្រឹមត្រូវ |
| 97.16 | មានទឹកក្នុងឥន្ធនៈត្រូវបានរកឃើញ | 652.05 | ចរន្តទៅប៊ិចប្រេងក្នុងស៊ីឡាំងលេខ 1 តិចជាងការរំពឹងទុក |
| 100.01 | សម្ពាធប្រេងទាប - កម្រិតខ្លាំងបំផុត | 652.06 | SPV[1] មានខ្លី |
| 100.04 | កម្លាំងរ៉ុលត៍សម្ពាធប្រេង OOR ទាប | 652.13 | កំហុសខ្សែកូដ QR លេខ 2 |
| 100.18 | សម្ពាធប្រេងទាប - កម្រិតខ្លាំងល្មម | 653.00 | ប៊ិចប្រេងត្រូវបានកំណត់ដោយរយៈពេលសន្ទុះអតិបរមានៅលើស៊ីឡាំងលេខ 3 |
| 100.31 | សម្ពាធប្រេងត្រូវបានរកឃើញនៅក្នុងល្បឿនសូន្យនៃម៉ាស៊ីន | 653.01 | ប៊ិចប្រេងត្រូវបានកំណត់ដោយរយៈពេលសន្ទុះអប្បបរមានៅលើស៊ីឡាំងលេខ 3 |
| 105.00 | សីតុណ្ហភាពបំពង់ខ្យល់ខ្ពស់ - កម្រិតខ្លាំងបំផុត | 653.02 | លេខគ្រឿងបន្លាស់ប៊ិចប្រេងលេខ 3 មិនត្រឹមត្រូវ |
| 105.03 | កម្លាំងរ៉ុលត៍សីតុណ្ហភាពបំពង់ខ្យល់ OOR ខ្ពស់ | 653.05 | ចរន្តទៅប៊ិចប្រេងក្នុងស៊ីឡាំងលេខ 3 តិចជាងការរំពឹងទុក |

| លេខ DTC | ព័ត៌មាន DTC | លេខ DTC | ព័ត៌មាន DTC |
|---|---|---|---|
| 105.04 | កម្លាំងវ៉ុលត៍សីតុណ្ហភាពបំពង់ខ្យល់ OOR ទាប | 653.06 | SPV[2] មានខ្លី |
| 105.15 | សីតុណ្ហភាពបំពង់ខ្យល់ខ្ពស់ - កម្រិតខ្លាំងទាប | 653.13 | កំហុសខ្សែកូដ QR លេខ 3 |
| 105.16 | សីតុណ្ហភាពបំពង់ខ្យល់ខ្ពស់ - កម្រិតខ្លាំងល្មម | 654.00 | ប៊ិចប្រេងត្រូវបានកំណត់ដោយរយៈពេលសន្ទុះអតិបរមានៅលើស៊ីឡាំងលេខ 4 |
| 108.02 | កម្រិតសម្គាជមិនត្រឹមត្រូវ | 654.01 | ប៊ិចប្រេងត្រូវបានកំណត់ដោយរយៈពេលសន្ទុះអប្បបរមានៅលើស៊ីឡាំងលេខ 4 |
| 110.00 | សីតុណ្ហភាពទឹកថ្នាំស្កុំម៉ាស៊ីនខ្ពស់ - កម្រិតខ្លាំងបំផុត | 654.02 | លេខគ្រឿងបន្លាស់ប៊ិចប្រេងលេខ 4 មិនត្រឹមត្រូវ |
| 110.03 | កម្លាំងវ៉ុលត៍សីតុណ្ហភាពទឹកស្កុំម៉ាស៊ីន OOR ខ្ពស់ | 654.05 | ចរន្តទៅប៊ិចប្រេងក្នុងស៊ីឡាំងលេខ 4 តិចជាងការរំពឹងទុក |
| 110.04 | កម្លាំងវ៉ុលត៍សីតុណ្ហភាពទឹកស្កុំម៉ាស៊ីន OOR ទាប | 654.06 | SPV[3] មានខ្លី |
| 110.15 | សីតុណ្ហភាពទឹកថ្នាំស្កុំម៉ាស៊ីនខ្ពស់ - កម្រិតខ្លាំងទាប | 654.13 | កំហុសខ្សែកូដ QR លេខ 4 |
| 110.16 | សីតុណ្ហភាពទឹកថ្នាំស្កុំម៉ាស៊ីនខ្ពស់ - កម្រិតខ្លាំងល្មម | 655.00 | ប៊ិចប្រេងត្រូវបានកំណត់ដោយរយៈពេលសន្ទុះអតិបរមានៅលើស៊ីឡាំងលេខ 5 |
| 157.03 | កម្លាំងវ៉ុលត៍សម្គាធដង OOR ខ្ពស់ | 655.01 | ប៊ិចប្រេងត្រូវបានកំណត់ដោយរយៈពេលសន្ទុះអប្បបរមានៅលើស៊ីឡាំងលេខ 5 |
| 157.04 | កម្លាំងវ៉ុលត៍សម្គាធដង OOR ទាប | 655.02 | លេខគ្រឿងបន្លាស់ប៊ិចប្រេងលេខ 5 មិនត្រឹមត្រូវ |
| 157.17 | សម្គាធដងមិនត្រូវបានបង្កើតឡើងក្នុងអំឡុងពេលរៃបញ្ចោះ (10Mpa ជាមួយ 8 វិនាទី) | 655.05 | ចរន្តទៅប៊ិចប្រេងក្នុងស៊ីឡាំងលេខ 5 តិចជាងការរំពឹងទុក |
| 158.17 | ECU មិនអាចបន្ថយថាមពលបានទេ | 655.06 | SPV[4] មានខ្លី |
| 174.00 | សីតុណ្ហភាពប្រេងឥន្ធនៈខ្ពស់ - កម្រិតខ្លាំងបំផុត | 655.13 | កំហុសខ្សែកូដ QR លេខ 5 |
| 174.03 | កម្លាំងវ៉ុលត៍សីតុណ្ហភាពប្រេងឥន្ធនៈ OOR ខ្ពស់ | 656.00 | ប៊ិចប្រេងត្រូវបានកំណត់ដោយរយៈពេលសន្ទុះអតិបរមានៅលើស៊ីឡាំងលេខ 6 |
| 174.04 | កម្លាំងវ៉ុលត៍សីតុណ្ហភាពប្រេងឥន្ធនៈ OOR ទាប | 656.01 | ប៊ិចប្រេងត្រូវបានកំណត់ដោយរយៈពេលសន្ទុះអប្បបរមានៅលើស៊ីឡាំងលេខ 6 |
| 174.16 | សីតុណ្ហភាពទឹកប្រេងឥន្ធនៈខ្ពស់ - កម្រិតខ្លាំងល្មម | 656.02 | លេខគ្រឿងបន្លាស់ប៊ិចប្រេងលេខ 6 មិនត្រឹមត្រូវ |
| 189.00 | មានលក្ខខណ្ឌមួយដែលកំពុងបណ្តាលឱ្យម៉ាស៊ីនអន់ខ្សោយ។ | 656.05 | ចរន្តទៅប៊ិចប្រេងក្នុងស៊ីឡាំងលេខ 6 តិចជាងការរំពឹងទុក |
| 611.03 | ឱ្យមិនគ្របទៅអាគុយនៅលើបណ្តាញប៊ិចប្រេង | 656.06 | SPV[5] មានខ្លី |
| 611.04 | ឱ្យមិនគ្រប់ទៅខ្សែដីនៅលើបណ្តាញប៊ិចប្រេង | 656.13 | កំហុសខ្សែកូដ QR លេខ 6 |
| 627.01 | ប៊ិចប្រេងទាញចរន្តទាបពេក ឬទប់ចរន្តមិនត្រឹមត្រូវ | 1347.03 | ស្ទាប់បូមត្រឡប់ការឆ្លងភ្លើងខ្លីទៅកម្លាំងវ៉ុលត៍បូក។ |
| 629.12 | ឧបករណ៍វៃឆ្លាត ឬគ្រឿងបន្លាស់មិនល្អ | 1347.05 | សៀគ្វីដើម្បីបូមសូលេណូអ៊ីតលេខ 1 ត្រូវបានបើក បានឆ្លងភ្លើងទៅខ្សែដី ឬលើសបន្តក។ |
| 636.02 | សំឡេងរំខាននៃចរន្តអង្គញ្ញាណទីតាំងរបស់ម៉ាស៊ីនត្រូវបានរកឃើញ | 1347.07 | ការគ្រប់គ្រងសម្គាធដងមិនអាចផ្លូវផ្គងនឹងសម្គាធដងដែលត្រូវការទេ។ វាអាចនឹងខ្ពស់ពេក ឬទាបពេក |
| 636.05 | ចរន្តអង្គញ្ញាណទីតាំងនៃម៉ាស៊ីន ស្ថិតក្រោមកម្រិតធម្មតា ឬសៀគ្វីបើក | 1569.31 | មានលក្ខខណ្ឌមួយដែលកំពុងបណ្តាលឱ្យម៉ាស៊ីនអន់ខ្សោយ។ |
| 636.06 | ចរន្តអង្គញ្ញាណទីតាំងនៃម៉ាស៊ីន ស្ថិតនៅលើកម្រិតធម្មតា ឬសៀគ្វីដី | 3509.03 | កម្លាំងវ៉ូលត៍ផ្គត់ផ្គង់អង្គញ្ញាណ OOR ខ្ពស់ |
| 636.08 | អង្គញ្ញាណទីតាំងរបស់ម៉ាស៊ីនត្រូវបានបាត់សញ្ញា | 3509.04 | កម្លាំងវ៉ូលត៍ផ្គត់ផ្គង់អង្គញ្ញាណ OOR ទាប |
| 636.10 | កំហុសលំនាំនៃអង្គញ្ញាណទីតាំងរបស់ម៉ាស៊ីនត្រូវបានរកឃើញ | 3510.03 | កម្លាំងវ៉ូលត៍ផ្គត់ផ្គង់អង្គញ្ញាណ OOR ខ្ពស់ |
| 637.02 | សំឡេងរំខាននៃអង្គញ្ញាណកំណត់ពេលត្រូវបានរកឃើញ | 3510.04 | កម្លាំងវ៉ូលត៍ផ្គត់ផ្គង់អង្គញ្ញាណ OOR ទាប |
| 637.05 | ចរន្តអង្គញ្ញាណកំណត់ពេល ស្ថិតក្រោមកម្រិតធម្មតា ឬសៀគ្វីបើក | 3511.03 | កម្លាំងវ៉ូលត៍ផ្គត់ផ្គង់អង្គញ្ញាណ OOR ខ្ពស់ |
| 637.06 | ចរន្តអង្គញ្ញាណកំណត់ពេល ស្ថិតនៅលើកម្រិតធម្មតា ឬសៀគ្វីដី | 3511.04 | កម្លាំងវ៉ូលត៍ផ្គត់ផ្គង់អង្គញ្ញាណ OOR ទាប |

cp00834,1668584463907-KM-16NOV22

## ការបង្ហាញការព្រមានអំពីកំហុសនៃអេក្រង់បង្ហាលកាច់ជ្រុង





YC17401—UN—27APR21

ទំព័រដើមរបស់អេក្រង់បង្ហាលកាច់ជ្រុង

1. កាច់កុងតាក់ទៅទីតាំងដំណើរការ។ ជាំរ៉ាម៉ែត្រនិងភ្លើងសញ្ញាទាំងអស់បើក។

   ទំព័រដើមរបស់អេក្រង់បង្ហាលកាច់ជ្រុងប្តូរទៅទំព័រទី 2 ពីទំព័រទី 1 ។




YC17405—UN—27APR21

2. ប្រសិនបើមានលេខកូដកំហុសសកម្ម ទំព័រដើមរបស់អេក្រង់បង្ហាលកាច់ជ្រុងប្តូរទៅទំព័រទី2 ពីទំព័រទី 1 ព័ណ៌មាន DTCs និង DTCs នឹងបង្ហាញគ្រប់ពេល។

   នៅពេលកំហុសត្រូវបានដោះស្រាយ និងចុចប៊ូតុងនៅខាងស្តាំ នៅត្រង់ផ្នែកខាងក្រោមអេក្រង់បង្ហាលកាច់ជ្រុង នោះការព្រមានអំពីកំហុសនឹងរលត់ទៅវិញ។

*កំណត់ចំណាំ៖ លុបជម្រះការព្រមានកំហុសនីមួយៗ។*

cp00834,1668585160989-KM-16NOV22

# ពិនិត្យមើលមុនពេលបញ្ជូះ

## តារាងពិនិត្យមើលមុនពេលបញ្ជូះ

រាល់ថ្ងៃមុននឹងបញ្ជូះម៉ាស៊ីន ចូរពិនិត្យមើលធាតុទាំងអស់នៅក្នុងតារាងនេះ។

| |
|---|
| ពិនិត្យមើល និងចាក់ប្រេងម៉ាស៊ីនចូល |
| ពិនិត្យមើល និងចាក់ទឹកថ្នាំស្អុំម៉ាស៊ីនចូល |
| ពិនិត្យមើល និងចាក់ប្រេងអ៊ីដ្រូលីកចូល |
| ពិនិត្យមើល និងចាក់ប្រេងអ៊ីដ្រូស្តាទិកចូល (ការអូសដោយអ៊ីដ្រូស្តាទិក) |
| ពិនិត្យមើល និងចាក់ប្រេងឥន្ធនៈចូល |
| បង្ហូរទឹកចេញពីតម្រងឥន្ធនៈទឹមួយ |
| ពិនិត្យមើល និងសម្អាតតម្រងសំណាញ់រ៉ាឌីអាទ័រត្រជាក់ |


cp00834,1668587107376-KM-16NOV22

## ពិនិត្យមើល និងចាក់ប្រេងម៉ាស៊ីនចូល


**សំខាន់៖ ការរក្សាកម្រិតប្រេងម៉ាស៊ីនឱ្យបានត្រឹមត្រូវគឺចាំបាច់សម្រាប់អាយុកាលថែទាំរបស់ម៉ាស៊ីន។ ពិនិត្យកម្រិតប្រេងម៉ាស៊ីននៅពេលដែលគ្រឿងចក្រចតនៅលើដីរាបស្មើ។**

**សំខាន់៖ ហាមចាក់ប្រេងម៉ាស៊ីនចូល មុននឹងកម្រិតប្រេងធ្លាក់ក្រោមសញ្ញា "ADD" នៅលើម៉ាក្ទេរ៍។**

**សំខាន់៖ ហាមចាក់ប្រេងចូលលើផ្នែកខាងលើតំបន់គំនូសខ្វែង (B) នៅលើម៉ាក្ទេរ៍ប្រេង។ ហាមដំណើរការម៉ាស៊ីននៅពេលកម្រិតប្រេងម៉ាស៊ីនស្ថិតនៅក្រោមគំនូសសញ្ញា "ADD" នៅលើម៉ាក្ទេរ៍។**




YC20973—UN—07DEC22




YC20975—UN—21DEC22


ម៉ាក្ទេរ៍ប្រេងម៉ាស៊ីន

**A—ម៉ាក្ទេរ៍**
**B—តំបន់គូសខ្វែង**

ពិនិត្យកម្រិតប្រេងម៉ាស៊ីនដោយប្រើម៉ាក្ទេរ៍ប្រេងរាល់ថ្ងៃ (A) ។ ហាមដំណើរការម៉ាស៊ីននៅពេលកម្រិតប្រេងម៉ាស៊ីនស្ថិតនៅក្រោមគំនូសសញ្ញា "ADD" នៅលើម៉ាក្ទេរ៍។

*កំណត់ចំណាំ៖ ផ្ទៀងផ្ទាត់ថាម៉ាក្ទេរ៍ប្រេងត្រូវបានមួល និងរុញចូលសម្បុកទាំងស្រុងមុនពេលដោះចេញ ដើម្បីពិនិត្យមើលកម្រិតប្រេងម៉ាស៊ីន។*

ដោះម៉ាក្ទេរ៍ប្រេងចេញ ហើយពិនិត្យមើលកម្រិតប្រេង។ កម្រិតប្រេងម៉ាស៊ីនគួរតែស្ថិតនៅក្នុងតំបន់គំនូសខ្វែង (B) នៅលើម៉ាក្ទេរ៍។




YC20974—UN—07DEC22

ចាក់ប្រេងម៉ាស៊ីនចូល

**C—គម្របចាក់ប្រេង**

ប្រសិនបើកម្រិតប្រេងម៉ាស៊ីនស្ថិតក្រោមសញ្ញា “ADD” នៅលើម៉ាក្ទេរ៍ ចូរដោះគម្របចាក់ប្រេង (C) ចេញដើម្បីថែមប្រេងចូលតាមចាំបាច់។

ម៉ាស៊ីនថ្មីត្រូវបានចាក់ប្រេង John Deere Break-In ពីរោងចក្រ។ នៅអំឡុងពេលប្រើប្រាស់ដំបូង សូមបន្ថែមប្រេងម៉ាស៊ីនម៉ាក John Deere Break-In តាមតម្រូវការដើម្បីរក្សាកម្រិតប្រេងតាមលក្ខណៈបច្ចេកទេស។ សម្រាប់ការណែនាំ ចូរអានផ្នែកប្រេងម៉ាស៊ីនម៉ាស៊ូតដែលទើបប្រើថ្មី — គ្មានការភាយឧស្ម័ន ថ្នាក់ទី 1 ថ្នាក់ទី 2 ថ្នាក់ទី 3 ដំណាក់កាលទី I ដំណាក់កាលទី II និងដំណាក់កាលទី III នៅក្នុងផ្នែកប្រេងឥន្ធនៈ ទឹកស្អុំ និងប្រេងរំអិល។


បន្ទាប់ពីរយៈពេលរ៉ូដាស់, យកល្អគួរប្រើប្រេងម៉ាស៊ីន John Deere Plus-50™ II ។ សម្រាប់ការណែនាំ ចូរអានអំពីប្រេងម៉ាស៊ីនម៉ាស៊ូត — ចំណាត់ថ្នាក់ 3 និងដំណាក់កាល IIIA នៅផ្នែកប្រេងឥន្ធនៈ ប្រេងរំអិល និងទឹកថ្នាំស្អុំម៉ាស៊ីន។

cp00834,1668585815853-KM-16NOV22

## ពិនិត្យមើល និងចាក់ទឹកថ្នាំស្អុំម៉ាស៊ីនចូល

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។ ប្រយ័ត្នរលាកទឹកក្តៅ នៅពេលបើកគម្របធុងខ្ចោល។ ហាមបើកគម្របពេលម៉ាស៊ីនកំពុងក្តៅ។ បើកគម្របយឺតៗ ដើម្បីបន្ធូរសម្ពាធ។**

**សំខាន់៖ គម្របពិសេសត្រូវប្រើនៅលើធុងខ្ចោល។ ប្រសិនបើគម្របខូច ឬបាត់ត្រូវតែប្តូរដាក់គម្របថ្មី។**




YC20976—UN—07DEC22

**A—គម្របធុងខ្ពោល**
**B—សញ្ញា MAX (អតិ.)**
**C—សញ្ញា MIN (អប្ប.)**
**D—ធុងខ្ពោល**


ទុកឲ្យម៉ាស៊ីនចុះត្រជាក់។ កម្រិតទឹកថ្នាំស្អំម៉ាស៊ីនគួរតែស្ថិតនៅចន្លោះសញ្ញា MIN (C) និងសញ្ញា MAX (B) នៅលើធុងខ្ពោល។

ប្រសិនបើទឹកថ្នាំស្អំម៉ាស៊ីនស្ថិតនៅក្រោម MIN សញ្ញា ចូរដោះគម្របធុងខ្ពោល (A) ចេញដើម្បីបែមទឹកថ្នាំស្អំម៉ាស៊ីនតាមចាំបាច់។

សម្រាប់ការណែនាំ ចូរអានអំពីទឹកថ្នាំស្អំម៉ាស៊ីនម៉ាស៊ូត (ម៉ាស៊ីនដែលមានស៊ីឡាំងប្រភេទសើម) នៅក្នុងផ្នែកទឹកថ្នាំស្អំម៉ាស៊ីន និងប្រេងរំអិល។

cp00834,1668586765298-KM-16NOV22

## ពិនិត្យមើល និងចាក់ប្រេងអ៊ីដ្រូលីកចូល




YC3221—UN—24DEC13

ពិនិត្យមើល និងចាក់ប្រេងអ៊ីដ្រូលីកចូល




YC20977—UN—21DEC22

**A—គម្របចាក់ប្រេង**
**B—ម៉ាក្រេរ៍**
**C—គំនូសសញ្ញាអតិបរមា**
**D—គំនូសសញ្ញាអប្បបរមា**


បន្ទាបក្បាលឧបករណ៍កាត់ទៅដី ហើយបង្ហូរមស៊ីឡាំងអ៊ីដ្រូលីកទាំងអស់។ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។

1. ដោះគម្របចាក់ប្រេង (A) ចេញ។
2. ដោះនិងសម្អាតម៉ាក្រេរ៍ (B)។
3. ស៊កម៉ាក្រេរ៍ចូល ហើយពិនិត្យមើលកម្រិតប្រេងអ៊ីដ្រូលីក។ កម្រិតប្រេងគួរតែស្ថិតនៅចន្លោះសញ្ញាអប្បបរមា(D) និងសញ្ញាអតិបរមា (C) នៅលើម៉ាក្រេរ៍។
4. បន្ថែមប្រេងតាមការចាំបាច់ ប៉ុន្តែកុំឲ្យលើស។

សម្រាប់ការណែនាំ ចូរអានអំពីប្រេងអ៊ីដ្រូលីក/អ៊ីដ្រូស្តាទិកនៅក្នុងផ្នែកប្រេងឥន្ធនៈ ទឹកថ្នាំស្អំម៉ាស៊ីន និងប្រេងរំអិល។

cp00834,1668587072094-KM-16NOV22

## ពិនិត្យមើល និងចាក់ប្រេងអ៊ីដ្រូស្តាទិកចូល (ការអូសដោយអ៊ីដ្រូស្តាទិក)




YC20978—UN—21DEC22




YC20982—UN—21DEC22

ចាក់ប្រេងអ៊ីដ្រូស្តាទិកចូល

**A—ធុងស្តុកអ៊ីដ្រូស្តាទិក**
**B—កញ្ចក់មើលឃើញ**
**C—គម្របចាក់ប្រេង**

ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។


កម្រិតប្រេងត្រូវតែស្ថិតនៅផ្នែកខាងលើនៃកែវមើលឃើញ

(B)។ ដោះគម្របចាក់ប្រេង (C) ដើម្បីថែមប្រេងអ៊ីដ្រូស្តាទិកចូលតាមចាំបាច់ ប៉ុន្តែកុំចាក់ឲ្យហៀរ។

សម្រាប់ការណែនាំ ចូរអានអំពីប្រេងអ៊ីដ្រូលីក/អ៊ីដ្រូស្តាទិក នៅក្នុងផ្នែកប្រេងឥន្ធនៈ ទឹកថ្នាំស្អំម៉ាស៊ីន និងប្រេងរំអិល។


cp00834,1668587492268-KM-16NOV22

## ពិនិត្យមើល និងចាក់ប្រេងឥន្ធនៈចូល





YC20979—UN—21DEC22

ពិនិត្យកម្រិតប្រេងឥន្ធនៈ




YC20984—UN—21DEC22




YC20985—UN—21DEC22

**A—ប្រដាប់វាស់កម្រិតប្រេងឥន្ធនៈ**
**B—គម្របចាក់ប្រេង**
**C—រ៉ូប៊ីណេបង្ហូរ**

ពិនិត្យមើលកម្រិតប្រេងឥន្ធនៈនៅត្រឹមប្រដាប់វាស់កម្រិតប្រេងឥន្ធនៈ (A) នៅលើអេក្រង់បង្ហោលកាច់ជ្រុង។

ដោះគម្របចាក់ប្រេង (B) ចេញដើម្បីចាក់ប្រេងចូលធុងតាមចាំបាច់។ សម្រាប់ការណែនាំ ចូរអានអំពីប្រេងម៉ាស៊ូតនៅក្នុងផ្នែកប្រេងឥន្ធនៈ ទឹកថ្នាំស្អំម៉ាស៊ីន និងប្រេងរំអិល។


ប្រសិនបើម៉ាស៊ីនមិនដំណើរការក្នុងរយៈពេលយូរ ចូរបើកវ៉ាល់បង្ហូរ (C) ដើម្បីបង្ហូរទឹកចេញពីធុងប្រេង ហើយចាក់ប្រេងចូលធុង។

**សំខាន់៖ ប្រេងឥន្ធនៈគឺងាយឆេះខ្លាំង ហើយអាចបណ្តាលឱ្យរងរបួសធ្ងន់ធ្ងរ ឬស្លាប់បាន។ ចូរកុំចាក់ប្រេងចូលគ្រឿងចក្រខណៈពេលកំពុងជក់បារី ឬពេលស្ថិតនៅជិតអណ្តាតភ្លើង ឬផ្កាភ្លើង។ ជានិច្ចកាល ត្រូវពន្លត់ម៉ាស៊ីនមុននឹងចាក់ប្រេងគ្រឿងចក្រ។ ចាក់ប្រេងចូលធុងប្រេងឥន្ធនៈនៅទីវាលជានិច្ច។ ត្រូវប្រាកដថាមួលគម្របចាក់ប្រេងធុងប្រេង និងតម្រងសំណាញ់ខាងក្រោយវិញ បន្ទាប់ពីចាក់បំពេញ។ ត្រូវជូតសម្អាតប្រេងដែលហៀរកំពប់ជានិច្ច។ កុំចាក់ឲ្យពេញហៀរ។**

cp00834,1668588868326-KM-16NOV22

## បង្ហូរទឹកចេញពីតម្រងឥន្ធនៈទីមួយ

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**




YC20980—UN—21DEC22

**A—តម្រងប្រេងឥន្ធនៈទីមួយ**
**B—ចានចម្រោះទឹក**
**C—វ៉ាល់បង្ហូរ**

អង្គញ្ជាណចាប់សញ្ញាទឹកនៅក្នុងឥន្ធនៈស្ថិតនៅក្នុងចានចម្រោះទឹក (B)។ នៅពេលតម្រងប្រេងឥន្ធនៈទីមួយ (A) មានទឹកនៅក្នុងប្រព័ន្ធប្រេងឥន្ធនៈ លេខកូដវិនិច្ឆ័យត្រូវបានបង្កើតឡើង។ ប្រសិនបើកូដបញ្ហារោគវិនិច្ឆ័យដុសឡើង ចូរបន្ធូរវ៉ាល់បង្ហូរ (C) ដើម្បីបង្ហូរទឹកចេញ។


រាល់ថ្ងៃមុននឹងបញ្ជោះម៉ាស៊ីន ចូរពិនិត្យមើលចានចម្រោះទឹក និងបង្ហូរទឹកចេញតាមចាំបាច់។

cp00834,1668589283494-KM-16NOV22


## ពិនិត្យមើល និងសម្អាតតម្រងសំណាញ់វិលនៅរដូវត្រជាក់

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**

**សំខាន់៖ នៅរដូវត្រជាក់មុននឹងបញ្ជោះម៉ាស៊ីន ចូរពិនិត្យ និងសម្អាតទឹកក ឬសំណើមកកនៅលើតម្រងសំណាញ់វិល។**




YC20983—UN—21DEC22




YC20981—UN—21DEC22

**A—តម្រងសំណាញ់វិល**
**B—ខ្សែពានអូស**


សម្អាតតម្រងសំណាញ់វិល (A) នៅផ្នែកខាងលើគ្រឿងចក្រ។

បើករបាំងការពារខាងស្តាំដើម្បីសម្អាតតម្រងសំណាញ់វិល។

ចូរប្រាកដថាខ្សែពានអូស (B) មិនរឹងកំព្រឹសមុននឹងបញ្ជោះម៉ាស៊ីននៅសីតុណ្ហភាពក្រោម 0°C។

cp00834,1668589293711-KM-16NOV22

## បើកដំណើរការកុងតាក់សោ




YC17947—UN—12JUL21

**A—ទីតាំងគ្រឿងបន្ទាប់បន្សំ**
**B—ទីតាំងឈប់**
**C—ទីតាំងប្រតិបត្តិការ**
**D—ទីតាំងបញ្ឆេះ**

**ទីតាំងគ្រឿងបន្ទាប់បន្សំ (A)៖** រុញចូល និងកាច់សោទៅទីតាំង "ACCESSORY" ដើម្បីបើកដំណើរការមុខងារអគ្គិសនី។

**ទីតាំងឈប់ (B)៖** កាច់សោទៅទីតាំងឈប់ដើម្បីពន្លត់ម៉ាស៊ីន និងបិទមុខងារអគ្គិសនី។

**ទីតាំងប្រតិបត្តិការ (C)៖** កាច់សោទៅទីតាំងប្រតិបត្តិការ (RUN)។ ពិនិត្យមើលប្រដាប់វាស់ និងពន្លឺភ្លើងសញ្ញាមុននឹងបញ្ឆេះម៉ាស៊ីន។


**ទីតាំងបញ្ឆេះ (D)៖** កាច់សោទៅទីតាំងបញ្ឆេះ (បញ្ឆេះ) ដើម្បីបញ្ឆេះម៉ាស៊ីន។ សោនឹងត្រឡប់ទៅកាន់ទីតាំង RUN វិញនៅពេលលែងវា។

CP00834,0008F85-KM-12JUL21

## បញ្ឆេះម៉ាស៊ីន

**⚠ ប្រយ័ត្ន៖ មុននឹងបញ្ឆេះម៉ាស៊ីននៅក្នុងកន្លែងចង្អៀត ចូរដំឡើងគ្រឿងបរិក្ខារបញ្ចេញឧស្ម័យឲ្យបានត្រឹមត្រូវ។ ជានិច្ចកាល ចូរអនុវត្តការទុកដាក់ និងការតទុយោគន្ធៈដែលអនុញ្ញាតដើម្បីសុវត្ថិភាព។**

**មុននឹងបញ្ឆេះម៉ាស៊ីន ចូរប្រាកដថាមិនមានអ្នកណានៅជិតគ្រឿងចក្រឡើយ។ បន្លឺស៊ីរ៉ែនដើម្បីជូនដំណឹងដល់អ្នកដទៃ។**




YC20986—UN—21DEC22

ឧបករណ៍បញ្ជា និងឧបករណ៍ (ការអូសដោយអ៊ីដ្រូស្តាទិក)




YC17959—UN—14JUL21

**A—ចង្កឹះលេខ**
**B—ដៃបញ្ជាពហុមុខងារ**
**C—កុងតាក់ហ្គែរ**
**D—ទីតាំងប្រតិបត្តិការ**
**E—ទីតាំងបញ្ឆេះ**

1. សម្រាប់គ្រឿងចក្រអូសដោយអ៊ីដ្រូស្តាទិក ចូរដាក់ដៃបញ្ជាពហុមុខងារ(B) នៅក្នុងទីតាំងនឹង។
2. ពិនិត្យមើលចង្កឹះលេខ (A) ក្រែងលោមិនស្ថិតនៅក្នុងទីតាំងនឹង។
3. ពិនិត្យមើលក្រែងលោដៃភ្ជាប់ប្រព័ន្ធបោកបែន ដៃភ្ជាប់ក្បាលឧបករណ៍កាត់និងដៃភ្ជាប់ប្រដាប់បួងទម្លាក់ផ្តាច់ចេញ។
4. កាច់សោបញ្ឆេះទៅទីតាំង RUN (D), ពិនិត្យមើល និងលុបជម្រះ DTC នៅលើអេក្រង់បង្ហោលកាច់ជ្រុង។

*កំណត់ចំណាំ៖ កូដបង្ហាញឡើងរហូតទាល់តែបញ្ហាត្រូវបានដោះស្រាយរួច។ ប្រសិនបើមិនអាចដោះស្រាយបញ្ហាបានទេ ចូរពិគ្រោះជាមួយអ្នកចែកចាយក្រុមហ៊ុន John Deere របស់លោកអ្នក។*

**⚠ ប្រយ័ត្ន៖ ដើម្បីកុំឲ្យមានគ្រោះថ្នាក់រងរបួស ឬការស្លាប់បាត់បង់ជីវិតដោយចៃដន្យ ចូរបញ្ឆេះម៉ាស៊ីនតែពីកៅអីប្រតិបត្តិករប៉ុណ្ណោះ។ ហាមបញ្ឆេះម៉ាស៊ីនដោយការចងភ្ជាប់អគ្គិសនីកាត់តាមក្បាលតំណដេម៉ារ។ ម៉ាស៊ីនឆេះនៅពេលចូលលេខ ប្រសិនបើឆ្លងកាត់ (bypass)។**

**ស់ខាន់៖ ដើម្បីកុំឲ្យខូចដេម៉ារ ចូរកុំប្រតិបត្តិការដេម៉ារលើសពី 30 វិនាទី ក្នុងមួយលើក។ ប្រសិនបើម៉ាស៊ីនមិនឆេះទេនោះ រង់ចាំយ៉ាងហោចណាស់ពីរនាទី មុននឹងបញ្ឆេះម្តងទៀត។ ប្រសិនបើម៉ាស៊ីនមិនឆេះបន្ទាប់ពីព្យាយាមបញ្ឆេះចំនួនបួនដង ចូរអានអំពីដំណោះស្រាយបញ្ហាម៉ាស៊ីននៅក្នុងផ្នែកដំណោះស្រាយបញ្ហា។**

*កំណត់ចំណាំ៖ នៅពេលកាច់សោបញ្ឆេះទៅទីតាំងបញ្ឆេះនោះនឹងមានការពន្យារយៈពេលពីរបីនាទី។ ប្រការនេះអនុញ្ញាតឲ្យប្រអប់បញ្ជាឡើងថាមពលវីឡេបិទ ហើយសូលេណូអ៊ីតដេម៉ារផ្តល់ថាមពល។*

5. កំណត់កុងតាក់ហ្គែរ (C) នៅត្រង់ទីតាំង “អណ្តើក” បន្លឺស៊ីរ៉ែ និងកាច់សោបញ្ឆេះទៅទីតាំងបញ្ឆេះ(E) ដើម្បីបញ្ឆេះម៉ាស៊ីន។
6. ការ៉ង់ទីម៉ាស៊ីនរយៈពេលពី 1 ដល់ 2 នាទីដើម្បីកម្តៅម៉ាស៊ីនជាមុន។


**សំខាន់៖ ហាមដំណើរការម៉ាស៊ីនក្នុងការរង់ទីទាបលើសពី 5 នាទី។**

cp00834,1668646376592-KM-16NOV22

## បញ្ជោះពេលអាកាសធាតុត្រជាក់

**⚠ ប្រយ័ត្ន៖ មុននឹងបញ្ជោះម៉ាស៊ីន ចូរប្រាកដថាមិនមានអ្នកណានៅជិតគ្រឿងចក្រឡើយ។ បន្លឺសុីផ្លេដើម្បីជូនដំណឹងដល់អ្នកដទៃ។**

**អេទែរងាយនឹងឆាបឆេះបំផុត។ កុំប្រើអេទែរនៅពេលណាដែលបញ្ជោះម៉ាស៊ីនដែលមានបំពាក់ឧបករណ៍កម្តៅខ្យល់ចូល។**




YC17947—UN—12JUL21


**A—ទីតាំងគ្រឿងបន្ទាប់បន្សំ**
**B—ទីតាំងឈប់**
**C—ទីតាំងប្រតិបត្តិការ**
**D—ទីតាំងបញ្ជោះ**

ជំនួយបញ្ជោះគឺចាំបាច់នៅពេលសីតុណ្ហភាពក្រោម 0°C (32°F) ។

ត្រូវការប្រើជំនួយបញ្ជោះនៅក្នុងអាកាសធាតុត្រជាក់ផ្សេងទៀតនៅសីតុណ្ហភាព -25°C (-13°F) ឬរយៈកម្ពស់លើ 1500 ម (5000 ហ្វីត)។ អានអំពីការប្រើប្រាស់អាគុយកូវ ឬប្រដាប់សាកដើម្បីបញ្ជោះម៉ាស៊ីននៅក្នុងផ្នែកនេះ។

1. កាច់កុងតាក់សោបញ្ជោះទៅទីតាំង RUN (C) ដើម្បីកម្តៅម៉ាស៊ីនជាមុន។វានឹងចំណាយពេលពី 15 ដល់ 20 វិនាទី ដើម្បីបញ្ចប់ការកម្តៅជាមុន។

*កំណត់ចំណាំ៖ ហាមបញ្ជោះម៉ាស៊ីនមុននឹងការកម្តៅជាមុនត្រូវបានបញ្ចប់។*




YC17948—UN—12JUL21
កុងតាក់ហ្គ្លែរ (មានបង្ហាញការអូសដោយអ៊ីដ្រូស្តាទិក)

**E—កុងតាក់ហ្គ្លែរ**

2. កំណត់កុងតាក់ហ្គ្លែរ (E) នៅត្រង់ទីតាំង “អណ្តើក” បន្លឺសុីផ្លេនិងកាច់សោបញ្ជោះទៅទីតាំងបញ្ជោះ (D) ដើម្បីបញ្ជោះម៉ាស៊ីន។
3. ការង់ទីម៉ាស៊ីនរយៈពេលពី 2 ដល់ 4 នាទីដើម្បីកម្តៅម៉ាស៊ីនជាមុន។

**សំខាន់៖ ហាមដំណើរការម៉ាស៊ីនក្នុងការរង់ទីទាបលើសពី 5 នាទី។**


cp00834,1668646437316-KM-16NOV22

## អានអំពីការប្រើប្រាស់អាគុយកូវ ឬប្រដាប់សាកដើម្បីបញ្ជោះម៉ាស៊ីន។

**⚠ ប្រយ័ត្ន៖ ឧស្ម័នដែលបញ្ចេញពីអាគុយអាចផ្ទុះបាន។ រក្សាឲ្យផ្កាភ្លើង និងអណ្តាតភ្លើងស្ថិតនៅឆ្ងាយពីអាគុយ។ មុនពេលត ឬផ្តាច់ឧបករណ៍សាកអាគុយចេញ ចូរបិទវាសិន។ ដំបូងផ្តាច់ចេញ ហើយតភ្ជាប់ពេលចុងក្រោយនៅចំណុចដែលឆ្ងាយពីអាគុយ។ ជានិច្ចកាល ចូរភ្ជាប់ខ្សែអវិជ្ជមានចុងក្រោយ និងផ្តាច់ខ្សែនេះចេញមុនគេ។**



TS204—UN—15APR13




RG4678—UN—14DEC88

**A—អាគុយគ្រឿងចក្រកម្លាំង 12 V**
**B—អាគុយកូវកម្លាំង 12 V**
**C—ខ្សែកូវបញ្ជោះ**
**D—ខ្សែកាបដេម៉ារ**

ត្រូវការប្រើជំនួយបញ្ជោះនៅសីតុណ្ហភាព -25°C (-13°F) ឬ រយៈកម្ពស់លើ 1500 ម (5000 ហ្វីត)។

អាគុយកូវ ឬប្រដាប់សាកកម្លាំង 12 V អាចតភ្ជាប់ស្របគ្នាជាមួយអាគុយនៅលើគ្រឿងដើម្បីជួយបញ្ជោះក្នុងអាកាសធាតុត្រជាក់។ ជានិច្ចកាល ចូរប្រើខ្សែកូវបញ្ជោះដែលធន់។

**⚠ ប្រយ័ត្ន៖ ក្បាល និងក្រចាប់អាគុយ និងគ្រឿងដែលពាក់ព័ន្ធ មានផ្ទុកជាតិសំណ និងសមាសភាគសំណដែលគេដឹងនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាថាបណ្តាលឲ្យកើតជាជំងឺមហារីក និងគ្រោះថ្នាក់ចំពោះសុខភាពបន្តពូជ។ លាងសម្អាតដៃក្រោយពេលធ្វើការជាមួយនឹងវា។**

**សំខាន់៖ បិទកុងតាក់ផ្តាច់អាគុយមុននឹងភ្ជាប់ខ្សែកាបកូវបញ្ជោះ។ ចូរកុំកូវបញ្ជោះជាមួយអាគុយដែលមានកម្លាំងលើសពី 12 វ៉ូលត៍។**

**ត្រូវចំណាំប៉ូលអាគុយឲ្យបានច្បាស់មុននឹងធ្វើការតភ្ជាប់។ ការតបញ្ច្រាសធ្វើឲ្យខូចប្រព័ន្ធអគ្គិសនី។ ជានិច្ចកាល ចូរភ្ជាប់ខ្សែវិជ្ជមានទៅកាន់វិជ្ជមាន និងអវិជ្ជមានទៅកាន់ម៉ាស។ ប្រើអាគុយកូវកម្លាំង 12 វ៉ូលត៍សម្រាប់ប្រព័ន្ធអគ្គិសនី 12 វ៉ូលត៍។**

1. ដោះគម្របការពារចេញ។

*កំណត់ចំណាំ៖ ដើម្បីបង្ការនូវផ្កាភ្លើង ចូរកុំទុកឲ្យចុងខ្សែកូវទទេប៉ះម៉ាស៊ីន។*

2. តភ្ជាប់ខ្សែកូវទីមួយទៅកាន់ខ្សែវិជ្ជមាននៃអាគុយកូវ និងចុងម្ខាងទៀតទៅកាន់ខ្សែវិជ្ជមាននៃអាគុយគ្រឿងចក្រ។
3. តភ្ជាប់ខ្សែកូវទីពីទៅកាន់ខ្សែអវិជ្ជមាននៃអាគុយកូវ និងចុងម្ខាងទៀតទៅកាន់ខ្សែអវិជ្ជមាននៃអាគុយគ្រឿងចក្រឬទៅកាន់តំណម៉ាស។
4. បញ្ជោះម៉ាស៊ីន។ ផ្តាច់ខ្សែកូវបញ្ជោះភ្លាមបន្ទាប់ពីម៉ាស៊ីនឆេះ។ជានិច្ចកាល ចូរផ្តាច់ខ្សែអវិជ្ជមានចេញមុនគេ។

CP00834,0008DDA-KM-29AUG21

## ចៀសវាងការងារទីម៉ាស៊ីនយូរពេក


ចៀសវាងការងារទីម៉ាស៊ីនយូរពេក។ ការនៅបន្តការងារទីម៉ាស៊ីនទៀតអាចធ្វើឲ្យសីតុណ្ហភាពទឹកថ្នាំស្អំម៉ាស៊ីនធ្លាក់ចុះក្រោមកម្រិតធម្មតារបស់វា។ ផ្ទុយទៅវិញ ការធ្វើដូច្នេះបណ្តាលឲ្យប្រេងរាវប្រអប់រំ ដោយសារតែការដុតប្រេងតន្ទនៈមិនពេញលេញ និងបណ្តាលឲ្យមានកំណកស្អិតនៅលើស៊ូប៉ាប់ ពីស្តុង និងក្រវាត់ពីស្តុង។ វាក៏បង្កឲ្យមាននូវកំណខាប់ក្នុងម៉ាស៊ីនយ៉ាងឆាប់រហ័ស និងតន្ទនៈឆេះមិនអស់នៅក្នុងប្រព័ន្ធបំពង់ផ្សែង។

នៅពេលម៉ាស៊ីនឡើងកម្តៅទៅដល់សីតុណ្ហភាពប្រតិបត្តិការធម្មតា ម៉ាស៊ីនគួរតែការងារទីនៅល្បឿនការងារទីទាប។ ប្រសិនបើម៉ាស៊ីននឹងការងារទីលើសពីប្រាំនាទី ចូរពន្លត់ហើយបញ្ជោះឡើងវិញនៅពេលក្រោយ។

ដើម្បីកាត់បន្ថយកំណម្រេងភ្លើងខណៈពេលដំណើរការនៅល្បឿនការងារទីទាប ECU បង្កើនល្បឿនប្រតិបត្តិការទៅដល់ល្បឿនកម្រិតអត្រានៅពេលណាដែលការដោតមុខ DOC អាចធ្វើទៅបាន។ ល្បឿនប្រតិបត្តិការម៉ាស៊ីនកើនឡើងបង្កើនសីតុណ្ហភាពបញ្ចេញ និងលទ្ធភាពឆេះម្រេងភ្លើងពីមុខ DOC ។

CP00834,0008DDB-KM-26MAY21

## ពន្លត់ម៉ាស៊ីន




YC20987—UN—21DEC22

ឧបករណ៍បញ្ជា និងឧបករណ៍ (ការអូសដោយអ៊ីដ្រូស្តាទិក)

**A—ចង្កឹះលេខ**
**B—ដៃបញ្ជាពហុមុខងារ**
**C—កុងតាក់ហ្គែរ**
**D—ចង្កឹះហ្វ្រាំងដៃ**

1. សម្រាប់គ្រឿងចក្រអូសដោយអ៊ីដ្រូស្តាទិក ចូររំកិលដៃបញ្ជាពហុមុខងារ(B) ទៅក្នុងទីតាំងនឹង។
2. សម្រាប់គ្រឿងចក្រអូសដោយមេកានិក ចូរពិនិត្យមើលចង្កឹះលេខ (A) ក្រែងលោមិនស្ថិតនៅក្នុងទីតាំងនឹង។
3. ដាក់កុងតាក់ហ្គែរ (C) ក្នុងទីតាំង "អណ្តើក"។
4. បន្ទាបក្បាលកាត់ទៅដី។
5. ពិនិត្យមើលក្រែងលោដៃភ្ជាប់ប្រព័ន្ធបោកបែន ដៃភ្ជាប់ក្បាលឧបករណ៍កាត់និងដៃភ្ជាប់ប្រដាប់បួងទម្លាក់ផ្តាច់ចេញ។
6. ទាញចង្កឹះហ្វ្រាំងដៃ (D) ឡើងលើដើម្បីភ្ជាប់ហ្វ្រាំងដៃ។
7. ការងារទីម៉ាស៊ីនពីរបីនាទីដើម្បីឲ្យតួប៊ីនចុះត្រជាក់។
8. ពន្លត់ម៉ាស៊ីន។

cp00834,1668646812486-KM-16NOV22

# សេវាអំឡុងពេលរ៉ូដាស់

## ម៉ាស៊ីនពេលរ៉ូដាស់

ការថែទាំបន្ថែមក្នុងអំឡុងពេលប្រតិបត្តិការ 100 ម៉ោងដំបូងនឹងផ្តល់នូវលទ្ធផលល្អ និងដំណើរការបានយូរអង្វែងរបស់ម៉ាស៊ីន។

1. ម៉ាស៊ីននេះត្រូវបានចាក់ប្រេងម៉ាស៊ីន John Deere Break-In មកពីរោងចក្រ។ប្រតិបត្តិការម៉ាស៊ីនដោយផ្នែកធ្ងន់ជាមួយនឹងការកាំរ៉ងទីម៉ាស៊ីនតិចតួចបំផុតក្នុងអំឡុងពេលរ៉ូដាស់ម៉ាស៊ីន។
2. ប្រសិនបើម៉ាស៊ីនមានពេលវេលាប្រតិបត្តិការគួរឱ្យកត់សម្គាល់នៅល្បឿនការ៉ងទីល្បឿនថេរ និង/ឬការប្រើប្រាស់បន្តកស្រាល ឬចាំបាច់ត្រូវការប្រេងថ្មែមក្នុងរយៈពេល100 ម៉ោងដំបូង រយៈពេលរ៉ូដាស់យូរជាងនេះអាចមានភាពចាំបាច់។ ក្នុងស្ថានភាពទាំងនេះយកល្អគួរតែរ៉ូដាស់ម៉ាស៊ីន 100 ម៉ោងបន្ថែមទៀត ដោយប្តូរប្រេងម៉ាស៊ីនថ្មីរបស់John Deere Break-In និងតម្រងប្រេងថ្មីរបស់ John Deere ។
3. ពិនិត្យមើលកម្រិតប្រេងឲ្យបានញឹកញាប់ជាងនេះក្នុងអំឡុងពេលរ៉ូដាស់ម៉ាស៊ីន។ប្រសិនបើត្រូវតែបន្ថែមប្រេងក្នុងកំឡុងពេលនេះ សូមប្រើប្រាស់ប្រេងម៉ាស៊ីនJohn Deere Break-In។ (សូមអានផ្នែកប្រេងម៉ាស៊ីនម៉ាស៊ូតដែលទើបប្រើថ្មី— គ្មានការភាយឧស្ម័ន ថ្នាក់ទី 1 ថ្នាក់ទី 2 ថ្នាក់ទី 3 ដំណាក់កាលទី ।ដំណាក់កាលទី ॥ និងដំណាក់កាលទី ॥। នៅក្នុងផ្នែកប្រេងឥន្ធនៈ ទឹកស៊ុំនិងប្រេងរំអិល។)

**សំខាន់៖ កុំបន្ថែមប្រេងសម្រួលរហូតដល់កម្រិតប្រេងស្ថិតក្រោមសញ្ញា "ADD" នៅលើម៉ាក្រ៊ែរប្រេង។ ប្រេងម៉ាស៊ីន John Deere Break-In គួរត្រូវបានប្រើប្រាស់ដើម្បីសម្រួលដល់ប្រេងមួយចំនួនបានប្រើប្រាស់ក្នុងអំឡុងពេលនេះ។**

**ហាមប្រើប្រាស់ប្រេងម៉ាស៊ីន Plus-50™ នៅអំឡុងពេលរ៉ូដាស់របស់ម៉ាស៊ីនថ្មី ឬម៉ាស៊ីនដែលរើសជួសជុលធំដុំ។ ប្រេងទាំងនេះនឹងមិនធ្វើឲ្យម៉ាស៊ីនថ្មី ឬបានជួសជុលសឹកក្នុងកំឡុងពេលរ៉ូដាស់នេះទេ។**

**ហាមចាក់ប្រេងចូលលើសញ្ញាខ្ទែងនៅលើម៉ាក្រ៊ែរ។**

4. អំឡុងពេល 20 ម៉ោងដំបូង ហាមការ៉ងទីម៉ាស៊ីនរយៈពេលយូរ។ ប្រសិនបើម៉ាស៊ីនការ៉ងទីលើសពី5 នាទី ចូរពន្លត់ម៉ាស៊ីនភ្លាម។
5. អំឡុងពេលប្រតិបត្តិការម៉ាស៊ីនថ្មី ឬម៉ាស៊ីនជួសជុលរួចលើកដំបូង ដោយប្រើប្រេងម៉ាស៊ីនJohn Deere Break-In ចូរប្តូរប្រេងនិងតម្រងក្នុងចន្លោះពេលជាអប្បបរមាចំនួន100 ម៉ោងរហូតដល់អតិបរមាចំនួន 375 ម៉ោងសម្រាប់ប្រេងម៉ាស៊ីន John DeerePlus-50™។ (សូមអានអំពីប្រេងម៉ាស៊ីនម៉ាស៊ូត — ចំណាត់ថ្នាក់ 3 និងដំណាក់កាលIIIA នៅផ្នែកប្រេងឥន្ធនៈ ប្រេងរំអិល និងទឹកថ្នាំស៊ុំម៉ាស៊ីន។)
6. មើលភ្លើងសញ្ញាសីតុណ្ហភាពទឹកថ្នាំស៊ុំម៉ាស៊ីននៅលើអេក្រង់បង្ហោលកាច់ជ្រុងឲ្យបានដិតដល់នៅអំឡុងពេលប្រតិបត្តិការម៉ាស៊ីន។ប្រសិនបើប្រដាប់វាស់រំកិលចូលតំបន់ពណ៌ក្រហម ចូរកាត់បន្ថយបន្ទុកនៅលើម៉ាស៊ីននិងកំណត់បញ្ហាមុននឹងបន្តប្រតិបត្តិការ។
7. ពិនិត្យមើលកម្រិតទឹកថ្នាំស៊ុំឲ្យបានទៀងទាត់ ហើយមើលសញ្ញាលេចធ្លាយ។ចាក់ទឹកថ្នាំស៊ុំម៉ាស៊ីនចូលក្នុងធុងខ្ពោលទៅដល់បន្ទាត់ Max Cold។

cp00834,1668646964359-KM-16NOV22

## គ្រឿងចក្ររ៉ូដាស

1. បន្ទាប់ពីម៉ាស៊ីនដំណើរការបាន 15 នាទី ចូរភ្ជាប់/ផ្តាច់ប្រព័ន្ធបោកបែន។ប្រសិនមើលឃើញសំឡេងខុសប្រក្រតី ចូរផ្តាច់ប្រព័ន្ធបោកបែនជាបន្ទាន់ ហើយពន្លត់ម៉ាស៊ីន។ពិនិត្យកូដបញ្ហារោគវិនិច្ឆ័យនិងជួសជុល។
2. បន្ទាប់ពីគ្រឿងចក្រដំណើរការបានពី 15 ទៅ 30 នាទី ចូរផ្តាច់ប្រព័ន្ធបោកបែនហើយពន្លត់ម៉ាស៊ីន។ពិនិត្យមើលបាដាងទាំងអស់ក្រែងលោក្តៅខ្លាំង។
3. បន្ទាប់ពីម៉ាស៊ីនដំណើរការបានពីរបីម៉ោង ចូរពិនិត្យមើល និងរឹតបន្តឹងខ្សែពានិងច្រវាក់ទាំងអស់។

CP00834,0008FEB-KM-29AUG21

## ការថែទាំរយៈពេលរ៉ូដាស់

ក្នុងអំឡុងពេលរ៉ូដាស់, ចូរធ្វើការថែទាំនៅប៉ុន្មានម៉ោងដំបូង, ការថែទាំ 25 ម៉ោងដំបូង និងការថែទាំ 100 ម៉ោងដំបូង។ (អានតារាងថែទាំ—រយៈពេលរ៉ូដាស់នៅក្នុងផ្នែកនេះ។)

នៅអំឡុងពេលរ៉ូដាស់ ចូរធ្វើការថែទាំរាល់ 10 ម៉ោង (រាល់ថ្ងៃ) ផងដែរ ការថែទាំរាល់ 50 ម៉ោង និងរាល់ 100 ម៉ោង។

- អានតារាងដាក់ប្រេងរំអិល និងការថែទាំ—រាល់ 10 ម៉ោង (រាល់ថ្ងៃ) នៅក្នុងផ្នែកដាក់ប្រេងរំអិលនិងថែទាំ—រាល់ 10 ម៉ោង (រាល់ថ្ងៃ)
- អានតារាងដាក់ប្រេងរំអិល និងការថែទាំ—រាល់ 50 ម៉ោង នៅក្នុងផ្នែកដាក់ប្រេងរំអិលនិងថែទាំ—រាល់ 50 ម៉ោង
- អានតារាងដាក់ប្រេងរំអិល និងការថែទាំ—រាល់ 100 ម៉ោងនៅក្នុងផ្នែកដាក់ប្រេងរំអិលនិងថែទាំ—រាល់ 100 ម៉ោង

CP00834,0008FE8-KM-05AUG21

## តារាងថែទាំ—រយៈពេលរ៉ូដាស់

*កំណត់ចំណាំ៖ នៅអំឡុងពេលរ៉ូដាស់ ចូរធ្វើការថែទាំរាល់ 10 ម៉ោង (រាល់ថ្ងៃ) ផងដែរ ការថែទាំរាល់ 50 ម៉ោង និងរាល់ 100 ម៉ោង។*

| ធាតុ | ពីរបីម៉ោងដំបូង | 25 ម៉ោងដំបូង | 100 ម៉ោងដំបូង |
|---|---|---|---|
| ពិនិត្យមើល និងរឹតបន្តឹងប៊ូឡុងកង់និងក្បាលឡោស៊ី | • | • | |
| ពិនិត្យមើល និងរឹតបន្តឹងប៊ូឡុងភ្លៅមុខ និងក្បាលឡោស៊ី | | • | |
| ប្តូរប្រេងម៉ាស៊ីននិងតម្រងប្រេង | | | • |
| ប្តូរតម្រងប្រេងអ៊ីដ្រូលីក | | | • |

| ធាតុ | ពីរបីម៉ោងដំបូង | 25 ម៉ោងដំបូង | 100 ម៉ោងដំបូង |
|---|---|---|---|
| ប្តូរស់ណាញ់តម្រងអ៊ីដ្រូស្តាទិក (ការអូសដោយអ៊ីដ្រូស្តាទិក) | | | • |
| ប្តូរប្រេងប្រអប់លេខប្រអប់ស្តី | | | • |
| ប្តូរប្រេងដុំអូសទាញខាងចុង | | | • |
| ប្តូរប្រេងរអិលស្តីកាត់បន្ថយល្បឿនស៊ីឡាំងបោកបែន (ជម្រើស) | | | • |
| ប្តូរប្រេងហ្គ្រែង | | | • |
| ប្តូរប្រេងប្រអប់ស្តីរ៉ូទ័រគ្រឿងបំបែក | | | • |
| ប្តូរប្រេងភ្លៅអូសកង់ក្រោយ (ជម្រើស) | | | • |
| ប្តូរប្រេងគ្រឿងបញ្ជូនខាងចុងអូសកង់ក្រោយ (ជម្រើស) | | | • |
| ប្តូរប្រេងប្រអប់ស្តីអូសកង់ក្រោយ (ជម្រើស) | | | • |


cp00834,1668647266968-KM-16NOV22

## ពិនិត្យមើល និងរឹតបន្តឹងប៊ូឡុងកង់និងក្បាលឡោស៊ុ

| ចន្លោះពេលផ្តល់សេវា | ពីរបីម៉ោងដំបូង |
|---|---|
| | 25 ម៉ោងដំបូង |
| | រាល់ 200 ម៉ោង (រាល់រដូវ)* |

*បន្ទាប់ពីរយៈពេល 25 ម៉ោងដំបូង ចូរពិនិត្យមើល និងរឹតបន្តឹងប៊ូឡុងកង់និងក្បាលឡោស៊ីរាល់ 200 ម៉ោង ឬរាល់រដូវ ទោះបីជាមួយណាដល់មុនក៏ដោយ។

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្គ្រែងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**




YC17586—UN—28MAY21

កង់មុខ





YC17587—UN—28MAY21

កង់ក្រោយ




YC18358—UN—02SEP21

កង់ក្រោយ *(ដុំអូសកង់ក្រោយ ជម្រើស)*




YC12755—UN—06AUG18
លំដាប់កម្លាំងបង្វិល

**A—ក្បាលឡោស៊ី (ប្រើ 8)**
**B—ប៊ូឡុង (ប្រើ 8)**

ពិនិត្យ និងរឹតបន្តឹងក្បាលឡោស៊ីកង់មុខ (A) និងប៊ូឡុងកង់ក្រោយ (B) ដោយអនុវត្តលំដាប់តំណឹងទៅតាមលក្ខណៈបច្ចេកទេស។

**លក្ខណៈបច្ចេកទេស**

| | |
|---|---|
| ឡោស៊ីកង់មុខ—កម្លាំងបង្វិល | 420 ញូតុនម៉ែត្រ (310 ផោនហ្វីត) |
| ប៊ូឡុងកង់ក្រោយ—កម្លាំងបង្វិល | 180 ញូតុនម៉ែត្រ (133 ផោនហ្វីត) |


cp00834,1661848485905-KM-30AUG22

## ពិនិត្យមើល និងរឹតបន្តឹងប៊ូឡុងភ្លៅមុខ និងក្បាលឡោស៊ុ

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 25 ម៉ោងដំបូង |
| | រាល់ 200 ម៉ោង (រាល់រដូវ)* |

*បន្ទាប់ពីរយៈពេល 25 ម៉ោងដំបូង ចូរពិនិត្យមើល និងរឹតបន្តឹងប៊ូឡុងភ្លៅមុខ និងក្បាលឡោស៊ីរាល់ 200 ម៉ោង ឬរាល់រដូវ ទោះបីជាមួយណាដល់មុនក៏ដោយ។

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**




YC8202—UN—12MAR15
**A—ក្បាលឡោស៊ី (ប្រើ 2)**
**B—ក្បាលឡោស៊ុ (ប្រើ 4)**
**C—ប៊ូឡុង (ប្រើ 8)**

ពិនិត្យ និងរឹតបន្តឹងប៊ូឡុងភ្ជាប់ភ្លៅមុខនិងក្បាលឡោស៊ីទៅតាមលក្ខណៈបច្ចេកទេស។

**លក្ខណៈបច្ចេកទេស**

| | |
|---|---|
| ក្បាលឡោស៊ីភ្លៅមុខ (A)—កម្លាំងបង្វិល | 240 ញូតុនម៉ែត្រ |
| ក្បាលឡោស៊ីភ្លៅមុខ (B)—កម្លាំងបង្វិល | 435 ញូតុនម៉ែត្រ |
| ប៊ូឡុងប៉ុងមុខ (C)—កម្លាំងបង្វិល | 435 ញូតុនម៉ែត្រ |

cp00834,1661848574698-KM-30AUG22

## ប្តូរប្រេងម៉ាស៊ីននិងតម្រងប្រេង

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 375 ម៉ោង* |

*ប្រសិនបើប្រេងម៉ាស៊ីននិងតម្រងប្រេងដែលណែនាំឲ្យប្រើមិនមែនជារបស់ John Deere ត្រូវបានប្រើប្រាស់ បន្ទាប់ពីរយៈពេលរ៉ូដាស ចូរបង្រួមចន្លោះពេលផ្តល់សេវាទៅដល់ 250 ម៉ោង។


*កំណត់ចំណាំ៖ ជានិច្চកាល ចូរប្តូរតម្រងប្រេងម៉ាស៊ីននៅពេលប្តូរប្រេងម៉ាស៊ីន។*

បន្ទាប់ពីរ៉ូដាស់រួច ចូរប្តូរប្រេងម៉ាស៊ីននិងតម្រងប្រេង។ John Deere Plus-50™ គឺជាប្រេងម៉ាស៊ីនដែលគួរប្រើ។ ចូរអានអំពីចន្លោះពេលសេវាថែទាំប្រេងម៉ាស៊ីន និងតម្រងនៅក្នុងផ្នែកប្រេងឥន្ធនៈ ប្រេងរអិល និងទឹកថ្នាំស្អុំម៉ាស៊ីន។

*កំណត់ចំណាំ៖ ប្រសិនបើប្តូរប្រេងម៉ាស៊ីននៅអំឡុងពេលរ៉ូដាស ចូរប្រើប្រេងម៉ាស៊ីន John Deere John Deere Break-In ។ សម្រាប់ការណែនាំ ចូរអានផ្នែកប្រេងម៉ាស៊ីនម៉ាស៊ូតដែលទើបប្រើថ្មី — គ្មានការភាយឧស្ម័ន ថ្នាក់ទី 1 ថ្នាក់ទី 2 ថ្នាក់ទី 3 ដំណាក់កាលទី I ដំណាក់កាលទី II និងដំណាក់កាលទី III នៅក្នុងផ្នែកប្រេងឥន្ធនៈ ទឹកស្អុំ និងប្រេងរអិល។*

1. ដំណើរការម៉ាស៊ីនប្រហែល 5 នាទីដើម្បីកម្តៅប្រេងម៉ាស៊ីន។


2. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។




YC8631—UN—28FEB16

**A—រ៉ូប៊ីណែបង្ហូរ**


3. បើករ៉ូប៊ីណែបង្ហូរ (A) នៅផ្នែកខាងក្រោមម៉ាស៊ីន។




YC20988—UN—21DEC22


**B—ឆ្នុកបង្ហូរប្រេងម៉ាស៊ីន**
**C—បំពង់បង្ហូរប្រេង**

4. បន្ទរបំពង់បង្ហូរប្រេងម៉ាស៊ីន (B) ដើម្បីបង្ហូរប្រេងម៉ាស៊ីនចូលទៅក្នុងធុងសមស្របដោយប្រើបំពង់បង្ហូរប្រេង(C)។





YC20989—UN—21DEC22

ប្តូរតម្រងប្រេងម៉ាស៊ីន




YC20990—UN—21DEC22

ហ្វីតតម្រងប្រេង




YC20991—UN—21DEC22

តម្រង និងការបំបាក់ក្បាលឧបករណ៍កាត់

**D—ស្បែតម្រង**
**E—ហ៊ីតខាងក្រៅ**
**F—ហ៊ីតខាងក្នុង**
**G—ហ៊ីតការពារធូលី**
**H—ផ្ទៃបិទហ៊ីតនៅក្បាលឧបករណ៍កាត់**
**I—ផ្ទៃបិទហ៊ីតនៅក្បាលឧបករណ៍កាត់**

5. បន្ធូរ និងដោះស្បែតម្រងចេញ (D) ដោយប្រើម៉ាឡេតដោះតម្រង។ បោះស្បែតម្រងប្រេងចោល


6. លាបប្រេងម៉ាស៊ីនស្អាតលើស្បែតម្រងថ្មីនៅត្រង់ហ៊ីតខាងក្នុង (F)និងហ៊ីតខាងក្រៅ (E) និងលើធ្មេញខ្ចៅតម្រង។

7. ជូតផ្ទៃហ៊ីតទាំងពីររបស់ក្បាលឧបករណ៍កាត់ (H និង I) ដោយប្រើក្រណាត់ស្អាត។ចូរប្រាកដថាគន្លាក់ក្នុងហ៊ីតការពារធូលី (G) ត្រូវបានដំឡើងយ៉ាងត្រឹមត្រូវនៅតាមចន្លោះនៅក្នុងសម្បក។ ប្តូរហ៊ីតធូលីចេញប្រសិនបើវាខូច


**សំខាន់៖ ពេលដំឡើងសំណាញ់តម្រង ត្រូវរឹតដោយដៃប៉ុណ្ណោះ។ អាចប្រើម៉ាឡេតម្រងសម្រាប់ការដោះប៉ុណ្ណោះ។ ចូរប្រាកដថាគន្លាក់ក្នុងហ៊ីតការពារធូលី (G) ត្រូវបានដំឡើងយ៉ាងត្រឹមត្រូវ នៅតាមចន្លោះនៅក្នុងសម្បក។**

8. ដំឡើង ហើយរឹតបន្តឹងស្បែតម្រងដោយដៃ រហូតដល់អឺបណែននឹងហ៊ីតការពារធូលី(G)។ ហាមរឹតន្តែម 3/4 ជុំទៅ 1-1/4 ជុំបន្ទាប់ពីប៉ះរង ដូចធ្វើជាមួយនឹងតម្រងស្តង់ដារនោះ។

9. បិទរ៉ូប៊ីណេបង្ហូរ (A) នៅផ្នែកខាងក្រោមម៉ាស៊ីន។
10. រឹតបន្តឹងឆ្នុកបង្ហូរប្រេងម៉ាស៊ីន (B)។




YC20992—UN—21DEC22




YC20993—UN—21DEC22

ម៉ាក្ការ៍ប្រេងម៉ាស៊ីន

**J—គម្របចាក់ប្រេង**
**K—ម៉ាក្ការ៍**

11. ដោះគម្របចាក់ប្រេង (J) ចេញហើយចាក់ប្រេងម៉ាស៊ីនដែលបានបញ្ជាក់ចូលក្នុងប្រអប់រំវៃម៉ាស៊ីន។

*កំណត់ចំណាំ៖ ពិនិត្យមើលចំណុះប្រេងម៉ាស៊ីននៅក្នុងផ្នែកលក្ខណៈបច្ចេកទេស។*


12. ដោះម៉ាក្ការ៍ប្រេងចេញ (K) ហើយពិនិត្យមើលកម្រិតប្រេង។ កម្រិតប្រេងម៉ាស៊ីនគួរតែស្ថិតនៅក្នុងតំបន់គំនូសខ្វែងនៅលើម៉ាក្ការ៍។
13. បញ្ឆោះម៉ាស៊ីន ហើយដំណើរការ ដើម្បីពិនិត្យរកមើលការលេចធ្លាយដែលអាចកើតមាន។
14. ពន្លត់ម៉ាស៊ីន ហើយ 10 នាទីបន្ទាប់មក សូមពិនិត្យមើលកម្រិតប្រេងម៉ាស៊ីន។

cp00834,1668647470682-KM-16NOV22

## ប្តូរតម្រងប្រេងអ៊ីដ្រូលីក

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC20994—UN—21DEC22

**A—ស្បែកម្រងប្រេងអ៊ីដ្រូលីក**


ដោះស្បែកម្រងប្រេងអ៊ីដ្រូលីក (A) ចេញ ហើយប្តូរដាក់ស្បែកម្រងថ្មី។

cp00834,1668649506342-KM-16NOV22

## ប្តូរសំណាញ់តម្រងអ៊ីដ្រូស្តាទិក (ការអូសដោយអ៊ីដ្រូស្តាទិក)


| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC20995—UN—21DEC22

ធុងស្តុកអ៊ីដ្រូស្តាទិក




YC20996—UN—21DEC22

**A—ធុងស្តុកអ៊ីដ្រូស្តាទិក**
**B—គម្រប**
**C—ប៊ូឡុង (ប្រើ 6)**
**D—វ៉ង់ហ្គីត**
**E—សំណាញ់តម្រង**

1. ដោះប៊ូឡុង (C) និងគម្រប (B) ចេញដើម្បីប្តូរសំណាញ់តម្រង (E)។

**សំខាន់៖ រក្សាប្រេងអ៊ីដ្រូស្តាទិកឲ្យស្អាត។**


2. លាបការបិទវ៉ង់ដែលមិនមានជាតិស៊ីលីកូនលើគម្រប និងប៊ូឡុង។
3. ដាក់គម្រប និងរឹតបន្តឹងប៊ូឡុង។

cp00834,1668649758942-KM-18NOV22

## ប្តូរប្រេងប្រអប់លេខប្រអប់ស្តី

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 500 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**




YC20997—UN—21DEC22

**A—ឆ្នុកចាក់ប្រេង**
**B—ឆ្នុកបង្ហូរ**


1. ដាក់ធុងត្រងសមស្របខាងក្រោមប្រអប់លេខប្រអប់ស្តីហ្គែរ។
2. ដោះឆ្នុកចាក់បំពេញ (A) និងឆ្នុកបង្ហូរ (B) ចេញដើម្បីបង្ហូរប្រេង។
3. ដំឡើង និងរឹតបន្តឹងឆ្នុកបង្ហូរប្រេង។
4. ចាក់ប្រេងជាក់លាក់ចូលក្នុងប្រអប់លេខប្រអប់ស្តី។
   - **ប្រេងស្តី៖** ប្រេងស្តី GL-5 80W/90
   - **ចំណុះប្រអប់ស្តី៖** 6.6 ល
5. ដំឡើង និងរឹតបន្តឹងឆ្នុកចាក់បំពេញរហូតដល់ប្រេងហូរចេញពីរន្ធចាក់បំពេញ។

cp00834,1668655504668-KM-16NOV22

## ប្តូរប្រេងដុំអូសទាញខាងចុង

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 500 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**




YC20998—UN—21DEC22
បានបង្ហាញដុំអូសខាងចុងចំហៀងខាងស្តាំ

**A—ឆ្នុកកម្រិតប្រេង**
**B—ឆ្នុកបង្ហូរ**
**C—ឆ្នុកបង្ហូរ**

**D—ឆ្នុកចាក់ប្រេង**

1. ដាក់ធុងត្រងសមស្របនៅក្រោមដុំអូសខាងចុង។
2. ដោះឆ្នុកចាក់បំពេញ (D) ឆ្នុកកម្រិតប្រេង (A) និងឆ្នុកបង្ហូរ (B)ចេញដើម្បីបង្ហូរប្រេង។
3. ដំឡើង និងរឹតបន្តឹងឆ្នុកបង្ហូរប្រេង។
4. ចាក់បំពេញប្រេងជាក់លាក់ចូលដុំអូសខាងចុង។
   - **ប្រេងស្ពឺ៖** ប្រេងស្ពឺ GL-5 80W/90
   - **ចំណុះដុំអូសខាងចុង៖** 3.1 ល
5. ដំឡើង និងរឹតបន្តឹងឆ្នុកកម្រិតប្រេងរហូតដល់ប្រេងហៀរចេញពីរន្ធ។
6. ដំឡើង និងរឹតបន្តឹងឆ្នុកចាក់ប្រេង។


cp00834,1668655537671-KM-16NOV22

## ប្តូរប្រេងរំអិលស្ពឺកាត់បន្ថយល្បឿនស៊ីឡាំងបោកបែន (ជម្រើស)

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 500 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**

**សំខាន់៖ មុននឹងចាក់បំពេញស្ពឺបន្ថយល្បឿនស៊ីឡាំងបើកបែន ឬពិនិត្យមើលកម្រិតប្រេង ចូរបិទប៉ូលីល្បឿនប្រែប្រួល។**




YC20999—UN—21DEC22

**A—ហ៊ីយ**
**B—ឆ្នុកចាក់ប្រេង**
**C—ឆ្នុកបង្ហូរ**

1. ដាក់ធុងត្រងសមស្របខាងក្រោមស្ពឺបន្ថយល្បឿនស៊ីឡាំង។
2. ដោះហ៊ីយ (A), ឆ្នុកចាក់បំពេញ (B), និងឆ្នុកបង្ហូរ (C) ដើម្បីបង្ហូរប្រេងរំអិលចេញ។
3. ដំឡើង និងរឹតបន្តឹងឆ្នុកបង្ហូរប្រេង។
4. ចាក់ប្រេងរំអិលជាក់លាក់ចូលក្នុងស្ពឺបន្ថយល្បឿនស៊ីឡាំងបោកបែន។
   - **ប្រេងរំអិល៖** ប្រេងរំអិល MOBILITH SHC007
   - **ចំណុះប្រេងរំអិល៖** 0.8 គ.ក
5. ដំឡើង និងរឹតបន្តឹងឆ្នុកចាក់បំពេញរហូតដល់ប្រេងហៀរចេញពីរន្ធ។
6. ដំឡើង ហើយរឹតបន្តឹងហ៊ីយ។


**សំខាន់៖ ពិនិត្យកម្រិតប្រេងម្តងទៀតបន្ទាប់ពីដំណើរការបាន 15 នាទី។ ចាក់ប្រេងចូលតាមចាំបាច់។**

cp00834,1668655573735-KM-16NOV22


## ប្តូរប្រេងហ្វ្រាំង

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 500 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**




YC21000—UN—21DEC22




YC21101—UN—21DEC22

**A—គម្រប**
**B—ក្បាលឡោស៊ីមានឡក់ (ប្រើ 2)**
**C—ស៊ីឡាំងដនួយហ្វ្រាំង (ប្រើ 2)**

1. ដាក់ធុងត្រងសមស្របខាងក្រោមប្រអប់លេខប្រអប់ស្ពឺហ្គែរ។


2. ដោះគម្រប (A)។
3. បន្ធូរក្បាលឡោស៊ីមានឡក់ (B) ដើម្បីដោះទុយោប្រេងអ៊ីដ្រូលីកចេញពីស៊ុមឡាងដំនួយហ្វ្រាំង(C)។
4. ជាន់ឈ្នាន់ហ្វ្រាំងដើម្បីបង្ហូរប្រេងហ្វ្រាំង។
5. តទុយោប្រេងអ៊ីដ្រូលីក ហើយរឹតបន្តឹងក្បាលឡោស៊ីមានឡក់។
6. ចាក់ប្រេងដែលបានបញ្ជាក់ចូលក្នុងធុងស្តុកប្រេងហ្វ្រាំង។
   - **ប្រេង៖** 10# ប្រេងអ៊ីដ្រូលីកយន្តហោះ
   - **ចំណុះប្រព័ន្ធហ្វ្រាំង៖** 3 ល
   - **ចំណុះកំប៉ុងប្រេងហ្វ្រាំង៖** 0.75 ល
7. ដាក់គម្របចូល ហើយរឹតបន្តឹងរហូតទាល់តែធុងស្តុកប្រេងហ្វ្រាំងពេញ។
8. សាប់បន្ធូរប្រព័ន្ធហ្វ្រាំង។ (អានអំពីសាប់បន្ធូរប្រព័ន្ធហ្វ្រាំងនៅក្នុងផ្នែកថែទាំប្រព័ន្ធអូសទាញ។)

cp00834,1668655605003-KM-16NOV22

## ប្តូរប្រេងប្រអប់ស្តីរ៉ូទ័រគ្រឿងបំបែក


| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 500 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**




YC21102—UN—21DEC22

ប្រអប់ស្តីលែតម្រូវបាន




YC21103—UN—21DEC22

ប្រអប់ស្តីមិនអាចលែតម្រូវបាន

**A—ឆ្នុកចាក់ប្រេង**
**B—ឆ្នុកបង្ហូរ**


1. ដាក់ធុងត្រងសមស្របខាងក្រោមប្រអប់ស្តីហ្គែរ។
2. ដោះឆ្នុកចាក់បំពេញ (A) និងឆ្នុកបង្ហូរ (B) ចេញដើម្បីបង្ហូរប្រេង។
3. ដំឡើង និងរឹតបន្តឹងឆ្នុកបង្ហូរប្រេង (B)។
4. ចាក់ប្រេងជាក់លាក់ចូលក្នុងប្រអប់ស្តី។
   - **ប្រេង៖** John Deere Hy-Gard™
   - **ចំណុះប្រអប់ស្តីលែតម្រូវបាន៖** 2.5 ល
   - **ចំណុះប្រអប់ស្តីមិនអាចលែតម្រូវបាន៖** 1.6ល
5. ដំឡើង និងរឹតបន្តឹងឆ្នុកចាក់បំពេញរហូតដល់ប្រេងហៀរចេញពីរន្ធ។

cp00834,1668658597852-KM-16NOV22

## ប្តូរប្រេងភ្លៅអូសកង់ក្រោយ (ជម្រើស)

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 1600 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**




YC21104—UN—21DEC22

**A—ឆ្នុកចាក់ប្រេង**
**B—ឆ្នុកបង្ហូរ**

1. ដាក់ធុងត្រងសមស្របនៅក្រោមភ្លៅអូសកង់ក្រោយ។
2. ដោះឆ្នុកចាក់បំពេញ (A) និងឆ្នុកបង្ហូរ (B) ចេញដើម្បីបង្ហូរប្រេង។
3. ដំឡើង និងរឹតបន្តឹងឆ្នុកបង្ហូរប្រេង។
4. ចាក់ប្រេងដែលបានបញ្ជាក់ចូលក្នុងភ្លៅអូសកង់ក្រោយ។
   - **ប្រេងស្ពឺ៖** ប្រេងស្ពឺ GL-5 80W/90
   - **ចំណុះប្រេង៖** 18 ល
5. ដំឡើង និងរឹតបន្តឹងឆ្នុកចាក់បំពេញរហូតដល់ប្រេងហៀរចេញពីរន្ធ។

cp00834,1668658861006-KM-16NOV22

## ប្តូរប្រេងគ្រឿងបញ្ជូនខាងចុងអូសកង់ក្រោយ (ជម្រើស)

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 800 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**




YC16665—UN—13JAN21

ដោតនៅត្រង់ទីតាំងទាប់បំផុត




YC17612—UN—01JUN21

ដោតនៅត្រង់ទីតាំងផ្តេក

**A—ឆ្នុក**


1. បង្វិលកង់ក្រោយដើម្បីឲ្យឆ្នុក (A) ស្ថិតនៅត្រង់ទីតាំងទាបបំផុត។
2. ដាក់ធុងសមស្របដើម្បីត្រងប្រេង។
3. ដោះឆ្នុកចេញដើម្បីបង្ហូរប្រេង។
4. បង្វិលកង់ក្រោយដើម្បីឲ្យឆ្នុកស្ថិតនៅត្រង់ទីតាំងផ្តេក។
5. ចាក់បំពេញប្រេងជាក់លាក់ចូលដុំអូសខាងចុង។
   - **ប្រេងស្ពឺ៖** ប្រេងស្ពឺ GL-5 80W/90
   - **ចំណុះប្រេង៖** 1.5 ល
6. ដំឡើង និងរឹតបន្តឹងឆ្នុករហូតដល់ប្រេងហៀរចេញពីរន្ធ។

CP00834,0008E77-KM-10JUN21

## ប្តូរប្រេងប្រអប់ស្ពឺអូសកង់ក្រោយ (ជម្រើស)


| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 400 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**





YC21105—UN—21DEC22

ផ្នែកខាងលើប្រអប់ស្ពឺ




YC11508—UN—08MAR17

ចំហៀងប្រអប់ស្ពឺ




YC11509—UN—08MAR17

ផ្នែកខាងក្រោមប្រអប់ស្តី

**A—ប្រអប់ស្តី**
**B—ឆ្នុកចាក់ប្រេង**
**C—ឆ្នុកកម្រិតប្រេង**
**D—ហ៊ីយ**
**E—ឆ្នុកបង្ហូរ**

1. ដាក់ធុងត្រងសមស្របខាងក្រោមប្រអប់ស្តីហ្គែរ។
2. ដោះឆ្នុកចាក់បំពេញ (B) ឆ្នុកកម្រិតប្រេង (C) និងឆ្នុកបង្ហូរ (E)ចេញដើម្បីបង្ហូរប្រេង។
3. ដំឡើង និងរឹតបន្តឹងឆ្នុកបង្ហូរប្រេង។
4. ចាក់ប្រេងជាក់លាក់ចូលក្នុងប្រអប់ស្តី។
   - **ប្រេងស្តី៖** ប្រេងស្តី GL-5 80W/90
   - **ចំណុះប្រេង៖** 3.2 គ.ក
5. ដំឡើង និងរឹតបន្តឹងឆ្នុកកម្រិតប្រេងរហូតដល់ប្រេងហៀរចេញពីរន្ធ។
6. ដំឡើង និងរឹតបន្តឹងឆ្នុកចាក់ប្រេង។

cp00834,1668658901044-KM-16NOV22

# ប្រតិបត្តិការភ្លើងបំភ្លឺនិងអគ្គិសនី

## ប្រតិបត្តិតាមការប្រុងប្រយ័ត្នអគ្គិសនី

**ប្រយ័ត្ន: កុំឲ្យមានផ្កាភ្លើង និងអណ្តាតភ្លើងនៅជិតអាគុយ ពីព្រោះឧស្ម័នដែលបញ្ចេញដោយអេឡិចត្រូតអាចផ្ទុះបាន។ ដើម្បីចៀសវាងផ្កាភ្លើង ត្រូវតភ្ជាប់ខ្សែកាបអវិជ្ជមាន (ម៉ាស់) ចុងក្រោយ ហើយផ្តាច់វាដាមុនសិន។ ដើម្បីចៀសវាងការឆក់ និងនេះ កាច់បិទកុងតាក់ផ្តាច់អាគុយ មុននឹងជួសជុលផ្នែកណាមួយនៃប្រព័ន្ធអគ្គិសនី ឬនៅពេលដោះអាគុយចេញ។**

CP00834,0008ED3-KM-24JUN21

## ពិនិត្យស្ថានភាពអាគុយ

**សំខាន់: ហាមដាក់អេឡិចត្រូលីតទៅក្នុងអាគុយដែលមិនត្រូវការការថែទាំ។ អាគុយមិនត្រូវទម្រេត។**




YC19414—UN—09JAN22

ស្លាកអាគុយ

អាគុយនេះមិនចាំបាច់ថែទាំឡើយ។ ពិនិត្យពណ៌ភ្លើងសញ្ញាស្ថានភាពអាគុយនៅលើអាគុយឱ្យបានញឹកញាប់។ សាកឡើងវិញ ឬប្តូរអាគុយចេញតាមចាំបាច់។


| ពណ៌ភ្លើងសញ្ញា | ស្ថានភាពអាគុយ |
|---|---|
| បៃតង | ល្អ |
| ខ្មៅ | ប្តូរអាគុយ |
| ស | ប្តូរអាគុយ |

CP00834,0008DEB-KM-10JAN22

## ការប្រើប្រាស់កុងតាក់ផ្តាច់អាគុយ

**សំខាន់: កុងតាក់ផ្តាច់អាគុយមិនគ្រប់គ្រងថាមពលទៅប្រអប់បញ្ជាម៉ាស៊ីន (ECU)។ ប្រសិនបើមិនប្រើប្រាស់ម៉ាស៊ីនរយៈពេលយូរ ផ្តាច់ខ្សែម៉ាសអាគុយចេញ។**

**សំខាន់: ដើម្បីចៀសវាងការជាត់បងទិន្នន័យពី ECU រងចាំយ៉ាងតិច 30 វិនាទីមុនផ្តាច់កុងតាក់ផ្តាច់អាគុយបន្ទាប់ពីពន្លត់ម៉ាស៊ីន។**




YC21106—UN—21DEC22

កុងតាក់ផ្តាច់អាគុយ (ទីតាំងបើក)


**A—កុងតាក់ផ្តាច់អាគុយ**

រាល់ថ្ងៃ ចូរកាច់កុងតាក់ផ្តាច់អាគុយ (A) ទៅទីតាំងបិទបន្ទាប់ពីច្រូតកាត់រួច។

មុនពេលជួសជុលសមាសធាតុអគ្គិសនី បិទកុងតាក់ផ្តាច់ចរន្តអាគុយ។

cp00834,1668658994143-KM-16NOV22


## ការកំណត់អត្តសញ្ញាណបន្ទះហ្វ៊ុយហ្ស៊ីបកាប៊ីន




YC21107—UN—21DEC22

ហ្វ៊ុយហ្ស៊ីប និងរីឡេនៅក្នុងកាប៊ីន

**A—រីឡេភ្លើងការបារខាងក្នុងផ្នែកខាងមុខ និងកណ្តាល**
**B—រីឡេស៊ីផ្លេ**
**C—រីឡេបើកភ្លើង**
**D—ហ្វ៊ុយហ្ស៊ីបបម្រុង**
**E—រីឡេថាមពល**
**F—រីឡេម៉ាស៊ីនប្រេងឥន្ធនៈ**
**G—រីឡេភ្លើងមុខកាំពន្លឺខ្ពស់**
**H—រីឡេភ្លើងមុខកាំពន្លឺទាប**
**I—រីឡេភ្លើងការងារខាងក្រៅផ្នែកខាងមុខ**




YC21108—UN—21DEC22

ហ្វ៊ុយហ្ស៊ីប


| ធាតុ | ហ្វ៊ុយហ្ស៊ីប | ធាតុ | ហ្វ៊ុយហ្ស៊ីប | ធាតុ | ហ្វ៊ុយហ្ស៊ីប | ធាតុ | ហ្វ៊ុយហ្ស៊ីប |
|---|---|---|---|---|---|---|---|
| 1 | ហ្វ៊ុយហ្ស៊ីបភ្លើងការងារខាងក្នុងផ្នែកខាងមុខ និងកណ្តាល 25A | 2 | ហ្វ៊ុយហ្ស៊ីបបម្រុង 10A | 3 | ហ្វ៊ុយហ្ស៊ីបបម្រុង 25A | 4 | ភ្លើងការងារខាងក្រៅផ្នែកខាងមុខ 15A |
| 5 | ហ្វ៊ុយហ្ស៊ីបស៊ីផ្លេ 10A | 6 | ហ្វ៊ុយហ្ស៊ីបកុងតាក់ភ្លើងការងារខាងមុខ 10A | 7 | ហ្វ៊ុយហ្ស៊ីបភ្លើងវិល 15A | 8 | ហ្វ៊ុយហ្ស៊ីបភ្លើងមុខកាំពន្លឺទាប 15A |
| 9 | ហ្វ៊ុយហ្ស៊ីបភ្លើងសញ្ញាបត់ 10A | 10 | ហ្វ៊ុយហ្ស៊ីបដៃបញ្ជាពហុមុខងារ 10A | 11 | ហ្វ៊ុយហ្ស៊ីបភ្លើងមុខកាំពន្លឺខ្ពស់ 15A | 12 | ហ្វ៊ុយហ្ស៊ីបបម្រុង 10A |
| 13 | ហ្វ៊ុយហ្ស៊ីបបម្រុង 15A | 14 | ហ្វ៊ុយហ្ស៊ីបបម្រុង 10A | 15 | ហ្វ៊ុយហ្ស៊ីបបម្រុង 25A | 16 | ហ្វ៊ុយហ្ស៊ីបបម្រុង 15A |
| 17 | ហ្វ៊ុយហ្ស៊ីបអេក្រង់បង្ហោលកាច់ជ្រុង 10A | 18 | ហ្វ៊ុយហ្ស៊ីបភ្លើងពន្លឺតិចៗ និង A/C 15A | 19 | ហ្វ៊ុយហ្ស៊ីបភ្លើងថយក្រោយនិងស៊ីផ្លេ 15A | 20 | ហ្វ៊ុយហ្ស៊ីបសំឡេងរោទ៍ថយក្រោយ 10A |
| 21 | ហ្វ៊ុយហ្ស៊ីបម៉ូទ័រលៃតម្រូវល្បឿនកង់រ៉ក 10A | 22 | ហ្វ៊ុយហ្ស៊ីបប្រអប់បញ្ជាដៃបញ្ជាពហុមុខងារ 5A | | | | |

cp00834,1668659495547-KM-21NOV22

## ហ្វ៊ុយហ្ស៊ីបនិងរីឡេនៅក្នុងប្រអប់អគ្គិសនី

**សំខាន់៖ ប្រសិនបើហ្វ៊ុយហ្ស៊ីបនិងរីឡេនៅក្នុងប្រអប់អគ្គិសនីត្រូវការប្តូរ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់លោកអ្នក។**

**ត្រូវប្រាកដថាកុងតាក់ផ្តាច់អាគុយគឺបិទមុនពេលប្តូរហ្វ៊ុយហ្ស៊ីប។**





YC11126—UN—04DEC17

**A—ហ្វុយហ្ស៊ីបផ្គត់ផ្គង់ថាមពលចម្បង (100 A)**
**B—ហ្វុយហ្ស៊ីបគ្រឿងកម្តៅបញ្ចោះពេលត្រជាក់ (100A)**
**C—រីឡេអង្គបញ្ចោះ**
**D—រីឡេគ្រឿងកម្តៅបញ្ចោះពេលត្រជាក់**
**E—ហ្វុយហ្ស៊ីប (ហ្វុយហ្ស៊ីប ECU 20 A និងហ្វុយហ្ស៊ីបកុងតាក់សោ 15 A)**


ប្រអប់អគ្គិសនីស្ថិតនៅចំហៀងខាងឆ្វេងដៃម៉ាស៊ីន។

cp00834,1668660276868-KM-16NOV22


## ទីតាំងភ្លើងបំភ្លឺ




YC21109—UN—21DEC22




YC21110—UN—21DEC22




YC21111—UN—21DEC22


ទិដ្ឋភាពខាងក្រោយ

**A—ភ្លើងការងារ (ប្រើ 2)**
**B—ភ្លើងការងារ (ប្រើ 4)**
**C—ភ្លើងវិល (សម្រាប់ទីផ្សារនាំចេញប៉ុណ្ណោះ)**
**D—ភ្លើងលើកដាក់**
**E—ភ្លើងព្រមានគ្រោះថ្នាក់ខាងមុខ/ភ្លើងសញ្ញាបត់ខាងមុខ (ប្រើ 2)**
**F—ភ្លើងសញ្ញាខាងមុខ (ប្រើ 2)**
**G—ភ្លើងមុខ (ភ្លើងកាំពន្លឺខ្ពស់/ទាប, ប្រើ 2)**
**H—ភ្លើងធុងគ្រាប់ធញ្ញជាតិ**
**I—ភ្លើងសញ្ញាបត់ក្រោយ (ប្រើ 2)**
**I—ភ្លើងសម្គាល់ខាងក្រោយ (ប្រើ 2)**
**J—ភ្លើងហ្វ្រាំង (ប្រើ 2)**


cp00834,1668662516505-KM-16NOV22

## ប្រើភ្លើងការងារ

**⚠ ប្រយ័ត្ន៖ ដើម្បីកុំឲ្យអ្នកប្រើប្រាស់យានយន្តយល់ច្រឡំ ហាមបើកភ្លើងការងារនៅពេលបើកបរលើផ្លូវសាធារណៈ។**




YC18231—UN—05AUG21




YC21112—UN—21DEC22

**A—កុងតាក់ភ្លើងការងារ**
**B—ភ្លើងការងារ (ប្រើ 2)**
**C—ភ្លើងការងារ (ប្រើ 4)**

កុងតាក់ភ្លើងការងារ (A) គ្រប់គ្រងភ្លើងការងារ (B និង C)។

កុងតាក់ភ្លើងការងារគឺជាកុងតាក់មានបីទីតាំង៖

- ទីតាំងខាងលើ៖ ភ្លើងការងារទាំងអស់បិទ។
- ទីតាំងខាងក្រោម៖ ភ្លើងការងារ (B) បើក។
- ទីតាំងទាបជាងគេ៖ ភ្លើងការងារ (B និង C) បើក។

cp00834,1668663033916-KM-16NOV22

## ប្រើភ្លើងមុខ និងភ្លើងអង្គសម្គាល់

**⚠ ប្រយ័ត្ន៖ ការបុកជាមួយយានយន្តផ្សេងដោយចៃដន្យ អាចបង្ករឲ្យអ្នក ឬអ្នកផ្សេងមានរបួសធ្ងន់ធ្ងរ ឬដល់ស្លាប់។ តែងតែអនុលោមតាមបទបញ្ជាចរាចរណ៍ជានិច្ច នៅពេលបើកបរគ្រឿងចក្រលើផ្លូវ។**

**ភ្លើងមុខពន្លឺតិចៗទៅកាន់ភ្លើងកាំពន្លឺទាបសម្រាប់យានយន្តមកពីខាងមុខ។**




YC18233—UN—05AUG21

**A—កុងតាក់ភ្លើង**
**B—កុងតាក់ភ្លើងកាំពន្លឺខ្ពស់**

កុងតាក់ភ្លើង (A) គ្រប់គ្រងភ្លើងអង្គសម្គាល់ និងភ្លើងកាំពន្លឺទាប។

ភ្លើងកាំពន្លឺខ្ពស់ត្រូវបានគ្រប់គ្រងដោយកុងតាក់ភ្លើងកាំពន្លឺខ្ពស់ (B) រួមគ្នាជាមួយកុងតាក់ភ្លើង។

កុងតាក់ភ្លើងគឺជាកុងតាក់មានបីទីតាំង៖

- ទីតាំងខាងលើ៖ ភ្លើងមុខ និងភ្លើងអង្គសម្គាល់បិទ។
- ទីតាំងខាងក្រោម៖ ភ្លើងអង្គសម្គាល់បើក។
- ទីតាំងទាបជាងគេ៖ ភ្លើងអង្គសម្គាល់និងភ្លើងកាំពន្លឺទាបបើក។

កុងតាក់ភ្លើងកាំពន្លឺទាបគឺជាកុងតាក់មានពីរទីតាំង៖

- ទីតាំងខាងលើ៖ ភ្លើងកាំពន្លឺខ្ពស់បិទ។

*កំណត់ចំណាំ៖ មុននឹងប្រើកុងតាក់ភ្លើងកាំពន្លឺខ្ពស់ កុងតាក់ភ្លើងគួរតែនៅក្នុងទីតាំងខាងក្រោមជាងនេះ។*


- ទីតាំងខាងក្រោម៖ ភ្លើងកាំពន្លឺខ្ពស់បើក។

*កំណត់ចំណាំ៖ នៅពេលភ្លើងកាំពន្លឺខ្ពស់បើក ភ្លើងសញ្ញាកាំពន្លឺខ្ពស់ស្ថិតនៅក្នុងអេក្រង់បង្ហាលកាច់ជ្រុងបើក។*

cp00834,1665381246293-KM-10OCT22

## ប្រើប្រាស់ភ្លើងសញ្ញាបត់

*កំណត់ចំណាំ៖ ភ្លើងសញ្ញាបត់ដំណើរការនៅពេលណាដែកុងតាក់សោបើក។*




YC18019—UN—14JUL21

**A—កុងតាក់ភ្លើងសញ្ញាបត់**

កុងតាក់ភ្លើងសញ្ញាបត់ (A) បញ្ជាភ្លើងសញ្ញាបត់។

កុងតាក់ភ្លើងគឺជាកុងតាក់មានបីទីតាំង៖


- ទីតាំងខាងលើ៖ ភ្លើងសញ្ញាបត់ស្តាំបើក។
- ទីតាំងនឹង៖ ភ្លើងសញ្ញាបត់ស្តាំបិទ។
- ទីតាំងទាបជាងគេ៖ ភ្លើងសញ្ញាបត់ឆ្វេងបើក។

*កំណត់ចំណាំ៖ ភ្លើងសញ្ញាបត់មិនរលត់ដោយខ្លួនឯងទេដូច្នេះត្រូវតែកាច់កុងតាក់ទៅទីតាំងនឹងដោយដៃ។*

*ពន្លឺភ្លើងសញ្ញា (ឆ្វេងឬស្តាំ) នៅលើអេក្រង់បង្ហាលកាច់ជ្រុងភ្លឺឡើង និងបង្ហាញការបត់។*

CP00834,0008FAD-KM-20OCT21

## ប្រើភ្លើងពន្លឺតិចៗ




YC18018—UN—14JUL21

**A—ភ្លើងពន្លឺតិចៗ**
**B—កុងតាក់ភ្លើង**

ភ្លើងពន្លឺតិចៗ (A) ផ្តល់ការបំភ្លឺពីលើក្បាលសម្រាប់ការប្រើប្រាស់នៅពេលយប់ ឬនៅក្នុងលក្ខខណ្ឌពន្លឺទាប។


កុងតាក់ភ្លើង (B) គ្រប់គ្រងភ្លើងពន្លឺតិចៗ។

កុងតាក់ភ្លើងគឺជាកុងតាក់មានពីរទីតាំង៖

- **បើក**
- **បិទ**

CP00834,0008FAC-KM-29AUG21

## ប្រតិបត្តិការប្រព័ន្ធគ្រឿងកម្តៅ/ខ្យល់ចេញចូល/ម៉ាស៊ីនត្រជាក់ (HVAC)




YC18017—UN—14JUL21

**A—កុងតាក់ម៉ូដ HVAC**
**B—ក្បាលមួលគ្រប់គ្រងល់ហូរខ្យល់**
**C—ភ្លើងសញ្ញា**
**D—ភ្លើងសញ្ញា**
**E—ភ្លើងសញ្ញា**
**F—ក្បាលមួលលៃតម្រូវសីតុណ្ហភាព AC**

**កុងតាក់ម៉ូដ HVAC (A)៖** បើកដំណើរការប្រព័ន្ធម៉ាស៊ីនត្រជាក់ និងប្រព័ន្ធកម្តៅ។

- ទីតាំងខាងលើ៖ ប្រព័ន្ធកម្តៅត្រូវបានបើកដំណើរការ ហើយភ្លើងសញ្ញា(C និង D) បើក។
- ទីតាំងនឹង៖ ប្រព័ន្ធ HVAC បិទ ហើយភ្លើងសញ្ញាបិទ។
- ទីតាំងទាបជាងគេ៖ ប្រព័ន្ធត្រជាក់ត្រូវបានបើកដំណើរការ ហើយភ្លើងសញ្ញា(C និង E) បើក។

**ក្បាលមួលគ្រប់គ្រងល់ហូរខ្យល់ (B)៖** លៃតម្រូវល្បឿនកង្ហារ និងបរិមាណខ្យល់ដែលចេញក្រៅស្លាបព្រឹល។

- ទីតាំងបិទ - ថាមពលទាំងអស់ទៅកាន់ប្រព័ន្ធគឺបិទ។
- ទីតាំងបើក - ល្បឿនកង្ហារកើនឡើងដោយការមួលក្បាលមួយស្របទ្រនិចនាឡិកាទៅកាន់ទីតាំងមួយក្នុងចំណោមទីតាំងទាំងបី៖ល្បឿនទាប, មធ្យម, និងខ្ពស់


**ក្បាលមួលលៃតម្រូវសីតុណ្ហភាព AC (F)៖** លៃតម្រូវសីតុណ្ហភាពកាប៊ីន។

- មួលក្បាលមួលស្របទ្រនិចនាឡិកាដើម្បីបង្កើនសីតុណ្ហភាព។
- មួលក្បាលមួលច្រាសទ្រនិចនាឡិកាដើម្បីបន្ថយសីតុណ្ហភាព។

CP00834,0008FAF-KM-28SEP21

## ការប្រើប្រាស់ផ្លិតទឹក

*កំណត់ចំណាំ៖ កុងតាក់សៅត្រូវតែបើក ឬបើកដំណើរការគ្រឿងចក្រដើម្បីឲ្យផ្លិតទឹកដំណើរការ។*




YC18016—UN—14JUL21

**A—កុងតាក់ផ្លិតទឹក**

កុងតាក់ផ្លិតទឹក (A) ប្រើដើម្បីគ្រប់គ្រងផ្លិតទឹក។

- ទាញកុងតាក់ផ្លិតទឹកចេញក្រៅទៅកាន់ទីតាំងទីមួយ នោះផ្លិតទឹកនឹងប្រតិបត្តិការបន្តបន្ទាប់នៅល្បឿនទាប។
- ទាញកុងតាក់ផ្លិតទឹកចេញក្រៅទៅកាន់ទីតាំងទីពីរ នោះផ្លិតទឹកនឹងប្រតិបត្តិការបន្តបន្ទាប់នៅល្បឿនខ្ពស់។
- រុញកុងតាក់ផ្លិតទឹកទៅផ្នែកខាងក្រោម នោះផ្លិតទឹកនឹងបិទ។


CP00834,0008FAE-KM-15JUL21

# ប្រតិបត្តិការប្រព័ន្ធអូសទាញ

## ម៉ូដផ្លូវថ្នល់/វាលស្រែ (ការអូសដោយអ៊ីដ្រូស្តាទិក)




YC17949—UN—12JUL21




YC21113—UN—21DEC22

**A—កុងតាក់លើផ្លូវទីវាល**
**B—ភ្លើងសញ្ញា**

គេប្រើកុងតាក់ផ្លូវថ្នល់/វាលស្រែ (A) នៅពេលបើកបរម៉ាស៊ីនច្រូតតាមផ្លូវថ្នល់។

ចុចផ្នែកខាងក្រោមកុងតាក់ផ្លូវថ្នល់/វាលស្រែ ពន្លឺភ្លើងសញ្ញានៅលើកុងតាក់ និងពន្លឺភ្លើង (B) នៅលើអេក្រង់បង្ហោលកាច់ជ្រុងនឹងភ្លឺឡើង ម៉ូដផ្លូវថ្នល់នឹងបើកដំណើរការ។

ម៉ូដផ្លូវថ្នល់បង្ហាញមុខងារដូចតទៅនេះ៖

- ក្បាលឧបករណ៍កាត់ លើកឡើង/បន្ទាប
- ការលើក/បន្ទាបកង់រ៉ក
- យោលប្រដាប់បួងលើកដាក់

នៅពេលប្រតិបត្តិការក្នុងការដ្ឋាន ចូរចុចផ្នែកខាងលើកុងតាក់ផ្លូវថ្នល់/ការដ្ឋាន ហើយភ្លើងសញ្ញានឹងរលត់។ គេអាចប្រើមុខងារខាងលើ។


*កំណត់ចំណាំ៖ នៅពេលភ្លើងសញ្ញាបើក គ្រឿងចក្រស្ថិតនៅក្នុងម៉ូដផ្លូវថ្នល់។*

*នៅពេលភ្លើងសញ្ញាបិទ គ្រឿងចក្រស្ថិតនៅក្នុងម៉ូដវាលស្រែ។*


cp00834,1668663913898-KM-16NOV22

## បើកបរគ្រឿងចក្រ (ការអូសដោយមេកានិក)

**⚠ ប្រយ័ត្ន៖ មុននឹងបញ្ឆោះម៉ាស៊ីន ចូរប្រាកដថាមិនមានអ្នកណានៅជិតគ្រឿងចក្រឡើយ។ បន្ទឺស៊ីផ្លេដើម្បីជូនដំណឹងដល់អ្នកដទៃ។**




YC17953—UN—13JUL21




YC21114—UN—21DEC22

**A—ដៃភ្ជាប់ក្បាលឧបករណ៍កាត់**
**B—ដៃភ្ជាប់ប្រព័ន្ធបោកបែន**
**C—ដៃភ្ជាប់ប្រដាប់បួងទម្លាក់**
**D—ចង្កឹះល្បឿនលើដី**
**E—ចង្កឹះលេខ**
**F—ចង្កឹះហ្វ្រាំងដៃ**
**G—ប៊ូតុង**

1. ពិនិត្យមើលក្រែងលោដៃភ្ជាប់ក្បាលឧបករណ៍កាត់ (A), ដៃភ្ជាប់ប្រព័ន្ធបោកបែន(B), និងដៃភ្ជាប់ប្រដាប់បួងទម្លាក់ (C) ត្រូវបានផ្តាច់ចេញ។
2. បន្ទឺស៊ីផ្លេ ហើយបញ្ឆោះម៉ាស៊ីន។
3. លើកក្បាលឧបករណ៍កាត់ទៅទីតាំងការងារ ឬដឹកជញ្ជូន។
4. **ផ្តាច់ហ្វ្រាំងដៃ៖** ទាញដៃបញ្ជាហ្វ្រាំងដៃ(F) ឡើងលើបន្តិច, ចុចប៊ូតុង (G), រុញដៃបញ្ជាហ្វ្រាំងដៃចុះក្រោមឲ្យអស់ហើយលែងប៊ូតុង។
5. សង្កត់ឈ្នាន់អំប្រាយ៉ា ហើយរំកិលដៃបញ្ជាស្តីលេខ (E) ទៅក្នុងទីតាំងដែលចង់បាន។

*កំណត់ចំណាំ៖ នៅក្នុងកាល:ទេស:មួយចំនួន ស្តីមិនប្តូរនៅពេលព្យាយាមលើកដំបូងឡើយ ដូច្នេះព្យាយាមឲ្យបានច្រើនដងរហូតទាល់តែស្តីប្តូរ។*

- ប្តូរចង្កឹះលេខទៅកាន់ស្តីលេខបួនសម្រាប់ការដឹកជញ្ជូននៅលើផ្លូវថ្នល់។
- ប្តូរចង្កឹះលេខទៅកាន់ស្តីលេខដែលចង់បានសម្រាប់ប្រតិបត្តិការក្នុងវាលស្រែ។


6. រុញចង្កឹះល្បឿនលើដី (D) ទៅមុខដើម្បីបង្កើនល្បឿនបើកបរ។

   រុញចង្កឹះល្បឿនលើដីមកក្រោយដើម្បីបន្ថយល្បឿនបើកបរ។


cp00834,1668664022594-KM-16NOV22

## បើកបរគ្រឿងចក្រ (ការអូសដោយអ៊ីដ្រូស្តាទិក)

**⚠ ប្រយ័ត្ន៖ មុននឹងបញ្ឆោះម៉ាស៊ីន ចូរប្រាកដថាមិនមានអ្នកណានៅជិតគ្រឿងចក្រឡើយ។ បន្លឺស៊ីផ្លេដើម្បីជូនដំណឹងដល់អ្នកដទៃ។**




YC17951—UN—13JUL21




YC21115—UN—21DEC22

**A—ដៃភ្ជាប់ក្បាលឧបករណ៍កាត់**
**B—ដៃភ្ជាប់ប្រព័ន្ធបោកបែន**
**C—ដៃភ្ជាប់ប្រដាប់បួងទម្លាក់**
**D—ចង្កឹះលេខ**
**E—ដៃបញ្ជាពហុមុខងារ**
**F—ចង្កឹះហ្វ្រាំងដៃ**
**G—ប៉ូតុង**

1. ដាក់ចង្កឹះពហុមុខងារ (E) នៅក្នុងទីតាំងនឹង។
2. ពិនិត្យមើលក្រែងលោដៃភ្ជាប់ក្បាលឧបករណ៍កាត់ (A), ដៃភ្ជាប់ប្រព័ន្ធបោកបែន(B), និងដៃភ្ជាប់ប្រដាប់បួងទម្លាក់ (C) ត្រូវបានផ្តាច់ចេញ។
3. បន្លឺស៊ីផ្លេ ហើយបញ្ឆោះម៉ាស៊ីន។
4. រំកិលចង្កឹះលេខ (D) ទៅកាន់ទីតាំងដែលចង់បាន។

*កំណត់ចំណាំ៖ នៅក្នុងកាល:ទេស:មួយចំនួន ស្តីមិនប្តូរនៅពេលព្យាយាមលើកដំបូងឡើយ ដូច្នេះព្យាយាមឲ្យបានច្រើនដងរហូតទាល់តែស្តីប្តូរ។*


- ប្តូរចង្កឹះលេខទៅកាន់ស្តីលេខបួនសម្រាប់ការដឹកជញ្ជូននៅលើផ្លូវថ្នល់។
- ប្តូរចង្កឹះលេខទៅកាន់ស្តីលេខដែលចង់បានសម្រាប់ប្រតិបត្តិការក្នុងវាលស្រែ។

5. លើកក្បាលឧបករណ៍កាត់ទៅទីតាំងការងារ ឬដឹកជញ្ជូន។
6. **ផ្តាច់ហ្វ្រាំងដៃ៖** ទាញដៃបញ្ជាហ្វ្រាំងដៃ(F) ឡើងលើបន្តិច, ចុចប៉ូតុង (G), រុញដៃបញ្ជាហ្វ្រាំងដៃចុះក្រោមឲ្យអស់ហើយលែងប៉ូតុង។
7. **ការបើកបរទៅមុខ៖** រុញដៃបញ្ជាពហុមុខងារទៅមុខដើម្បីបើកបរគ្រឿងចក្រទៅមុខ។រុញដៃបញ្ជាពហុមុខងារទៅមុខថែមទៀតដើម្បីបង្កើនល្បឿនបើកបរ។


   **ការបើកបរថយក្រោយ៖** រុញដៃបញ្ជាពហុមុខងារមកក្រោយដើម្បីបើកបរគ្រឿងចក្រថយក្រោយ។ រុញដៃបញ្ជាពហុមុខងារថយក្រោយថែមទៀតដើម្បីបង្កើនល្បឿនបើកបរ។

cp00834,1668664118251-KM-16NOV22

## បញ្ឈប់គ្រឿងចក្រ (ការអូសដោយមេកានិក)




YC17953—UN—13JUL21




YC21116—UN—21DEC22

**A—ដៃភ្ជាប់ក្បាលឧបករណ៍កាត់**
**B—ដៃភ្ជាប់ប្រព័ន្ធបោកបែន**
**C—ដៃភ្ជាប់ប្រដាប់បួងទម្លាក់**
**D—ចង្កឹះល្បឿនលើដី**
**E—ចង្កឹះលេខ**
**F—កុងតាក់ហ្គែរ**
**G—ចង្កឹះហ្គ្រាំងដៃ**


1. រុញចង្កឹះល្បឿនលើដី (D) មកក្រោយឲ្យអស់ទៅកាន់ទីតាំងល្បឿនទាប។
2. ជាន់ឈ្នាន់ហ្គ្រាំងជើងដើម្បីបញ្ឈប់គ្រឿងចក្រ។
3. សង្កត់ឈ្នាន់អំប្រាយ៉ា ហើយរំកិលដៃបញ្ហាស្តីលេខ (E) ទៅក្នុងទីតាំងនឹងហើយបន្ធូរឈ្នាន់ហ្គ្រាំងជើង។

*កំណត់ចំណាំ៖ នៅក្នុងកាល:ទេស:មួយចំនួន ស្តីមិនប្តូរនៅពេលព្យាយាមលើកដំបូងឡើយ ដូច្នេះព្យាយាមឲ្យបានច្រើនដងរហូតទាល់តែស្តីប្តូរ។*


4. ដាក់កុងតាក់ហ្គែរ (F) ក្នុងទីតាំង "អណ្តើក"។
5. បន្ទាបក្បាលកាត់ទៅដី។
6. ផ្តាច់ដៃភ្ជាប់ក្បាលឧបករណ៍កាត់ (A), ដៃភ្ជាប់ប្រព័ន្ធបោកបែន (B),និងដៃភ្ជាប់ប្រដាប់បួងទម្លាក់ (C)។
7. ទាញចង្កឹះហ្គ្រាំងដៃ (G) ឡើងលើដើម្បីភ្ជាប់ហ្គ្រាំងដៃ។
8. ការ៉ងទីម៉ាស៊ុនពីរបីនាទីដើម្បីឲ្យតួបីនចុះត្រជាក់។
9. ពន្លត់ម៉ាស៊ីន។

cp00834,1668664210284-KM-16NOV22

## បញ្ឈប់គ្រឿងចក្រ (ការអូសដោយអ៊ីដ្រូស្តាទិក)




YC17951—UN—13JUL21




YC21117—UN—21DEC22

**A—ដៃភ្ជាប់ក្បាលឧបករណ៍កាត់**
**B—ដៃភ្ជាប់ប្រព័ន្ធបោកបែន**
**C—ដៃភ្ជាប់ប្រដាប់បួងទម្លាក់**
**D—ចង្កឹះលេខ**
**E—ដៃបញ្ហាពហុមុខងារ**
**F—កុងតាក់ហ្គែរ**
**G—ចង្កឹះហ្គ្រាំងដៃ**

1. ជាន់ឈ្នាន់ហ្គ្រាំងជើងដើម្បីបញ្ឈប់គ្រឿងចក្រ។
2. រំកិលដៃបញ្ហាពហុមុខងារ (E) ទៅក្នុងទីតាំងនឹង ហើយបន្ធូរឈ្នាន់ហ្គ្រាំងជើង។
3. ដាក់កុងតាក់ហ្គែរ (F) ក្នុងទីតាំង "អណ្តើក"។
4. បន្ទាបក្បាលកាត់ទៅដី។
5. ផ្តាច់ដៃភ្ជាប់ក្បាលឧបករណ៍កាត់ (A), ដៃភ្ជាប់ប្រព័ន្ធបោកបែន (B),និងដៃភ្ជាប់ប្រដាប់បួងទម្លាក់ (C)។
6. ទាញចង្កឹះហ្គ្រាំងដៃ (G) ឡើងលើដើម្បីភ្ជាប់ហ្គ្រាំងដៃ។
7. ការ៉ងទីម៉ាស៊ុនពីរបីនាទីដើម្បីឲ្យតួបីនចុះត្រជាក់។
8. ពន្លត់ម៉ាស៊ីន។

cp00834,1668664291054-KM-16NOV22

## ប្រតិបត្តិការឈ្នាន់អំប្រាយ៉ា (ដុំអូសមេកានិច)

**ស់ខាន់៖ ដើម្បីកុំឲ្យខូចខាតដល់ប្រអប់ស្តី ចូរកុំជាន់ឈ្នាន់អំប្រាយ៉ានៅពេលកំពុងបើកបរគ្រឿងចក្រ។**

**ដើម្បីចៀសវាងសំណឹកឥតប្រយោជន៍ ហាមប្រតិបត្តិការដោយប្រដាប់គងជើងនៅលើឈ្នាន់អំប្រាយ៉ា។**




YC18072—UN—23JUL21


**A—ឈ្នាន់អំប្រាយ៉ា**

សង្កត់ឈ្នាន់អំប្រាយ៉ា (A) ឲ្យអស់ បន្ទាប់មកប្តូរចង្កឹះលេខទៅកាន់ទីតាំងដែលចង់បាន។

CP00834,0008FF1-KM-23JUL21

## ប្រតិបត្តិការឈ្នាន់ហ្វ្រាំងជើង

**សំខាន់៖ ដើម្បីបង្ការស់ណឹកដោយមិនចាំបាច់ ហាមប្រតិបត្តិការដោយប្រដាប់គងជើងនៅលើឈ្នាន់ហ្វ្រាំង។**




YC8055—UN—21JAN15


**A—គន្លឹះឈ្នាន់ហ្វ្រាំង**
**B—ឈ្នាន់ហ្វ្រាំងជើង (ប្រើ 2)**

- សម្រាប់ការងារនៅវាលស្រែ ចូរដោះសោឈ្នាន់ហ្វ្រាំងជើង (B)។ ជាន់ឈ្នាន់ហ្វ្រាំងខាងស្តាំថ្នមៗដើម្បីជួយសម្រួលដល់ការបត់ស្តាំនៅត្រែងផ្លូវកែងខ្លាំងនិងជាន់ឈ្នាន់ហ្វ្រាំងខាងឆ្វេងសម្រាប់ការបត់ឆ្វេង។
- មុននឹងប្រតិបត្តិការគ្រឿងចក្រនៅលើផ្លូវថ្នល់ ឬដឹកជញ្ជូន ចូរប្រើសោឈ្នាន់ហ្វ្រាំង(A) ដើម្បីទប់ឈ្នាន់ហ្វ្រាំងជើងរួមគ្នា។

CP00834,0008F88-KM-13JUL21

## បម្រុងប្រយ័ត្នចំពោះការកាច់ចង្កូត

*កំណត់ចំណាំ៖ កង់ក្រោយរបស់គ្រឿងចក្រគឺជាកង់កាច់ចង្កូត ចូរប្រាកដថាមានចន្លោះគ្រប់គ្រាន់សម្រាប់កាច់ចង្កូត។*



YC2755—UN—29OCT12

នៅពេលគ្រឿងចក្រឈប់ នឹងមានការលំបាកក្នុងការកាច់ចង្កូត។

បួងចង្កូតទៅឆ្វេងក្នុងមុំតូចជាងនេះ។ បួងចង្កូតទៅខាងស្តាំក្នុងមុំធំជាងនេះ។

CP00834,0008DCB-KM-24MAY21

## ប្រតិបត្តិការដែបញ្ជាដុំអូសកង់ខាងក្រោយ (ជម្រើស)

**សំខាន់៖ កុំភ្ជាប់ ឬផ្តាច់ដុំអូសកង់ក្រោយខណៈពេលកំពុងបើកបរគ្រឿងចក្រ។**

**ផ្តាច់ការអូសកង់ក្រោយមុនពេលចូលដល់កម្រិតចោទខ្លាំង។**




YC17957—UN—14JUL21

**A—ដៃគ្រប់គ្រងក្តៅអូសកង់ខាងក្រោយ**


មុននឹងភ្ជាប់ការអូសកង់ក្រោយ ចូរបញ្ឈប់គ្រឿងចក្រ និងដាក់ដែបញ្ឈប់ហុមុខងារ (បើមាន) និងចង្កឹះលេខនៅក្នុងទីតាំងនឹង។

- **ភ្ជាប់ការអូសកង់ក្រោយ៖** រុញដែបញ្ជាអូសកង់ក្រោយ (A) ចុះក្រោម។
- **ផ្តាច់ការអូសកង់ក្រោយ៖** ទាញដែបញ្ជាការអូសកង់ក្រោយ(A) ឡើងលើ។

cp00834,1660809813275-KM-18AUG22

# ប្រតិបត្តិការក្បាលឧបករណ៍កាត់ និងមាត់ច្រកបួងចូល

## ព័ត៌មានទូទៅ




YC17731—UN—21JUN21

គ្រឿងចក្រនេះអាចមានបំពាក់ផ្លែតហ្វូមកាត់ 212R/F, 215R/F, និង 218 R/F សម្រាប់ការច្រូតកាត់ស្រូវសាឡី ស្រូវសណ្តែកសៀង និង។ល។

*កំណត់ចំណាំ៖ ផ្លែតហ្វូមកាត់ 212R/F គឺសម្រាប់តែទីផ្សារប្រទេសចិនប៉ុណ្ណោះ។*



YC17732—UN—21JUN21

គ្រឿងចក្រនេះអាចមានបំពាក់ក្បាលកាត់ពោត 206C (ចន្លោះជួរ 650 ម.ម) សម្រាប់ប្រមូលផលពោតសម្រាប់ទីផ្សារប្រទេសចិន។


គ្រឿងចក្រនេះអាចមានបំពាក់ក្បាលកាត់ពោត 204C, 205C, 206C (ចន្លោះជួរ 762 ម.ម) សម្រាប់ប្រមូលផលពោតសម្រាប់ទីផ្សារនាំចេញ។

cp00834,1669092574913-KM-21NOV22


## មាត់ច្រកបួងចូល និងតំណក្បាលឧបករណ៍កាត់

### តំណច្រវាក់


*កំណត់ចំណាំ៖ កុំលៃតម្រូវខ្ជៅនៅលើសម្បកជាដាង (B) នៅផ្នែកខាងក្រោយមាត់ច្រកបួងចូល។*




YC19561—UN—26JAN22



YC7312—UN—10JUN14





YC19586—UN—26JAN22

**A—សម្បកជាដាង**
**B—សម្បកជាដាង**
**C—រចាំងសុវត្ថិភាព**

រុញដងបង្វិលទាំងពីរមកគ្នា។ បន្ទះកង់ច្រវាក់ចំនួនពីរគួរតែស្របគ្នាទាំងផ្តេក និងបញ្ឈរ។ ដើម្បីដាក់កង់ច្រវាក់ទាំងពីរនេះនៅក្នុងទីតាំងត្រឹមត្រូវ ចូរលៃតម្រូវខ្ជៅនៅលើសម្បកជាដាង (A)។

ដាក់ច្រវាក់នៅជុំវិញកង់ច្រវាក់រួមគ្នានៅពេលចុងផ្នែនៃកង់ទាំងពីស្ថិតនៅកៀកគ្នា ឬចន្លោះរវាងផ្នែខាងចុងនៃកង់ច្រវាក់ទាំងពីរស្មើគ្នា។ រឹតច្រវាក់ឲ្យជាប់ ហើយគ្របរចាំងសុវត្ថិភាព (C)។

អនុវត្តទម្រង់ការដដែលនេះនៅជ្រុងម្ខាងទៀត។




YC19560—UN—26JAN22

ការលៃតម្រូវ

**D—ប៊ូឡុង**


**E—ប៊ូឡុង**

*កំណត់ចំណាំ៖ ការលៃតម្រូវអាចធ្វើឡើងនៅពេលលៃតម្រឹមកង់ច្រវាក់នៃមាត់ច្រកបួងចូល និងក្បាលឧបករណ៍កាត់ដូចគ្នាទៅ (លំណែនាំតទៅនេះបង្ហាញឧទាហរណ៍សម្រាប់ខាងឆ្វេងដៃ ហើយចំហៀងខាងស្តាំដៃលៃតម្រូវដូចគ្នា)៖*

នៅពេលកង់ច្រវាក់ទាំងពីរត្រូវគ្នាហើយ ចូរកុំរុញកង់ច្រវាក់ទាំងពីររួមគ្នា។

នៅពេលឃើញថាភ្លៅនៃដងទាំងពីមិនអាចលៃតម្រូវបានចូរបន្ធូរប៊ូឡុង (D និង E) នៃបន្ទះទម្រនៅផ្នែកខាងក្រោយក្បាលឧបករណ៍កាត់ ដើម្បីឲ្យកង់ច្រវាក់ទាំងពីរនៅចំចំណុចកណ្តាល ចាក់ខ្នាស់ច្រវាក់ បន្ទាប់មករឹតបន្តឹងប៊ូឡុង (D និង E)។

**តំណអ៊ីដ្រូលីកនិងអគ្គិសនី**




YC19771—UN—08MAR22

**A—តំណអគ្គិសនី**
**B—គូប្លើរអ៊ីដ្រូលីក**


- ភ្ជាប់តំណអគ្គិសនីទៅនឹងសមាសភាគគ្រឿងអគ្គិសនីនៅលើក្បាលឧបករណ៍កាត់។
- ភ្ជាប់គូប្លើរអ៊ីដ្រូលីកទៅនឹងគូប្លើរអគ្គិសនីនៅលើក្បាលឧបករណ៍កាត់។

CP00834,00020D1-KM-09MAR22

## ប្រតិបត្តិការភ្ជាប់/ផ្តាច់ក្បាលឧបករណ៍កាត់

**⚠ ប្រយ័ត្ន៖ មុននឹងភ្ជាប់ក្បាលឧបករណ៍កាត់ ចូរប្រាកដថាមិនមានមនុស្សនៅជុំវិញគ្រឿងចក្រឡើយ។**

**ដើម្បីកុំឲ្យខូចខាតដល់គ្រឿងចក្រ មុននឹងភ្ជាប់ក្បាលឧបករណ៍កាត់ ចូរភ្ជាប់ប្រព័ន្ធជោកបែន។**




YC12268—UN—11DEC17

ដៃភ្ជាប់ក្បាលឧបករណ៍កាត់ (ការអូសដោយមេកានិក)

**A—ដៃភ្ជាប់ក្បាលឧបករណ៍កាត់**
**B—ប៊ូតុង**

ដៃភ្ជាប់ក្បាលឧបករណ៍កាត់ (A) ប្រើដើម្បីភ្ជាប់ ឬផ្តាច់ការអូសក្បាលឧបករណ៍កាត់។

ដៃភ្ជាប់ក្បាលឧបករណ៍កាត់ស្ថិតនៅចំហៀងខាងឆ្វេងដៃកៅអី។

- រុញដៃភ្ជាប់ក្បាលឧបករណ៍កាត់ឡើងលើដើម្បីភ្ជាប់ក្បាលឧបករណ៍កាត់។
- ចុចប៊ូតុង (B) ហើយរុញដៃភ្ជាប់ក្បាលឧបករណ៍កាត់ចុះក្រោមដើម្បីផ្តាច់ក្បាលឧបករណ៍កាត់។

*កំណត់ចំណាំ៖ បន្ទាប់ពីចុចប៊ូតុងនេះ ដៃភ្ជាប់ក្បាលឧបករណ៍កាត់អាចធ្លាក់ចុះក្រោមដោយស្វ័យប្រវត្តិ។*

CP00834,0008F79-KM-04AUG21

## ប្រតិបត្តិការលើក/បន្ទាបក្បាលឧបករណ៍កាត់ (ការអូសដោយមេកានិច)




YC17937—UN—11JUL21

**A—ដៃគ្រប់គ្រងលើក/បន្ទាបក្បាលឧបករណ៍កាត់**

ដៃបញ្ជាលើក/បន្ទាបក្បាលឧបករណ៍កាត់ (A) អនុញ្ញាតឲ្យប្រតិបត្តិការលើក ឬបន្ទាបក្បាលឧបករណ៍កាត់។

- ទាញដៃបញ្ជាមកក្រោយដើម្បីលើកក្បាលឧបករណ៍កាត់។
- រុញដៃបញ្ជាទៅមុខដើម្បីបន្ទាបក្បាលឧបករណ៍កាត់។

CP00834,0008F72-KM-12JUL21

## ប្រតិបត្តិការលើក/បន្ទាបក្បាលឧបករណ៍កាត់ (ការអូសដោយអ៊ីដ្រូស្តាទិក)




YC17936—UN—11JUL21

**A—ប៊ូតុងលើកឡើងក្បាលឧបករណ៍កាត់**
**B—ដៃបញ្ជាពហុមុខងារ**
**C—កុងតាក់លើផ្លូវទិវាល**
**D—ប៊ូតុងបន្ទាបក្បាលឧបករណ៍កាត់**

ប៊ូតុងលើក/បន្ទាបក្បាលឧបករណ៍កាត់អនុញ្ញាតឲ្យប្រតិបត្តិការលើក ឬបន្ទាបក្បាលឧបករណ៍កាត់។

*កំណត់ចំណាំ៖ មុននឹងលើក/បន្ទាបក្បាលឧបករណ៍កាត់ ចូរប្រាកដថាកុងតាក់លើផ្លូវថ្នល់/វាលស្រែ (C) ស្ថិតនៅក្នុងម៉ូដវាលស្រែ (ពន្លឺភ្លើងសញ្ញានៅលើកុងតាក់មិនបើកឡើយ)។*

- ចុចទប់ប៊ូតុងលើកក្បាលឧបករណ៍កាត់ (A) ដើម្បីលើកក្បាលឧបករណ៍កាត់។
- ចុចទប់ប៊ូតុងបន្ទាបក្បាលឧបករណ៍កាត់ (D) ដើម្បីបន្ទាបក្បាលឧបករណ៍កាត់

CP00834,0009463-KM-20OCT21

## ប្រតិបត្តិការលើក/បន្ទាបកង់រ៉ក (ការអូសដោយមេកានិច)

*កំណត់ចំណាំ៖ ប្រតិបត្តិការលើក/បន្ទាប់កង់រ៉កត្រូវបានផ្តើឡើងសម្រាប់តែគ្រឿងចក្រដែលមានផ្លែតហ្វមកាត់ប៉ុណ្ណោះ។*




YC17938—UN—11JUL21

**A—ដៃគ្រប់គ្រងលើក/បន្ទាបកង់រ៉ក**

ដៃបញ្ជាលើក/បន្ទាបកង់រ៉ក (A) អនុញ្ញាតឲ្យប្រតិបត្តិការលើក ឬបន្ទាបកង់រ៉ក។

- ទាញដៃបញ្ជាមកក្រោយដើម្បីលើកកង់រ៉ក។
- រុញដៃបញ្ជាទៅមុខដើម្បីបន្ទាបកង់រ៉ក។

CP00834,0008F74-KM-12JUL21

## ប្រតិបត្តិការលើក/បន្ទាបកង់រ៉ក (ការអូសដោយអ៊ីដ្រូស្តាទិក)

*កំណត់ចំណាំ៖ ប្រតិបត្តិការលើក/បន្ទាប់កង់រ៉កត្រូវបានផ្តើឡើងសម្រាប់តែគ្រឿងចក្រដែលមានផ្លែតហ្វមកាត់ប៉ុណ្ណោះ។*




YC17939—UN—13SEP21

**A—ប៊ូតុងលើកកង់រ៉កឡើង**
**B—ដៃបញ្ជាពហុមុខងារ**
**C—កុងតាក់លើផ្លូវទិវាល**
**D—ប៊ូតុងបន្ទាបកង់រ៉ក**

ប៊ូតុងលើក/បន្ទាបកង់រ៉កអនុញ្ញាតឲ្យប្រតិបត្តិការលើក ឬបន្ទាបកង់រ៉ក។

*កំណត់ចំណាំ៖ មុននឹងលើក/បន្ទាបកង់រ៉ក ចូរប្រាកដថាកុងតាក់លើផ្លូវថ្នល់/វាលស្រែ (C) ស្ថិតនៅក្នុងម៉ូដវាលស្រែ (ពន្លឺភ្លើងសញ្ញានៅលើកុងតាក់មិនបើកឡើយ)។*

- ចុចទប់ប៊ូតុងលើកកង់រ៉ក (A) ដើម្បីលើកកង់រ៉ក។
- ចុចទប់ប៊ូតុងបន្ទាបកង់រ៉ក (D) ដើម្បីបន្ទាបកង់រ៉ក។

CP00834,0009464-KM-20OCT21

## លៃតម្រូវល្បឿនកង់រ៉ក

*កំណត់ចំណាំ៖ ភ្ជាប់ក្បាលឧបករណ៍កាត់មុននឹងលៃតម្រូវល្បឿនកង់រ៉ក។*




YC16898—UN—02MAR21

**A—កុងតាក់ល្បឿនកង់រ៉ក**


កុងតាក់ល្បឿនកង់រ៉ក (A) អនុញ្ញាតឲ្យប្រតិបត្តិករលៃតម្រូវល្បឿនកង់រ៉ក។

- ចុចទប់ផ្នែកខាងលើនៃកុងតាក់ល្បឿនកង់រ៉កដើម្បីបង្កើនល្បឿនកង់រ៉ក។
- ចុចទប់ផ្នែកខាងក្រោមនៃកុងតាក់ល្បឿនកង់រ៉កដើម្បីបន្ថយល្បឿនកង់រ៉ក។

*កំណត់ចំណាំ៖ បន្ទាប់ពីប្រើប្រាស់កុងតាក់ល្បឿនកង់រ៉ក ចូរបន្ធូរកុងតាក់ ហើយកុងតាក់នឹងត្រឡប់ទៅកាន់ទីតាំងនឹងវិញ។*

CP00834,0008F76-KM-12JUL21

## លៃតម្រូវកម្ពស់ស្ពរអវណ្តែតនៃមាត់ច្រកបួងចូល




YC21297—UN—21DEC22

ផ្នែកខាងស្តាំនៃមាត់ច្រកបួងចូលដែលបានបង្ហាញ

**A—ក្បាលឡោស៊ី (ប្រើ 2)**
**B—រីស័រ (ប្រើ 2)**


លៃតម្រូវប្រវែងរីស័រ (B) ដោយមួលក្បាលឡោស៊ី (A) នៅចំហៀងសងខាងនៃមាត់ច្រកបួងចូល។

- **សម្រាប់ដំណាំភាគច្រើនលើកលែងតែពោត និងគ្រាប់រ៉ែបស៊ុតក្នុងបរិមាណដ៏ច្រើន៖** រីស័រមានប្រវែង 140 ម.ម។
- **សម្រាប់ពោត៖** រីស័រមានប្រវែងពី 107ដល់ 113 ម.ម។

cp00834,1669014979019-KM-21NOV22

# ប្រតិបត្តិការប្រព័ន្ធបោកបែន និងបំបែក

## ប្រតិបត្តិការភ្ជាប់/ផ្តាច់ប្រព័ន្ធបោកបែន




YC8773—UN—10JUN15

ដៃភ្ជាប់ប្រព័ន្ធបោកបែន (ការអូសដោយមេកានិក)

**A—ដៃភ្ជាប់ប្រព័ន្ធបោកបែន**

ដៃភ្ជាប់ប្រព័ន្ធបោកបែន (A) ប្រើដើម្បីភ្ជាប់ ឬផ្តាច់ការអូសប្រព័ន្ធបោកបែន។

ដៃភ្ជាប់ប្រព័ន្ធបោកបែនស្ថិតនៅចំហៀងខាងឆ្វេងដៃកៅអី។


*កំណត់ចំណាំ៖ មុននឹងភ្ជាប់ប្រព័ន្ធបោកបែន ចូរដំណើរការម៉ាស៊ីននៅល្បឿនការ៉ង់ទីទាប។*

*មុននឹងផ្តាច់ប្រព័ន្ធបោកបែន ចូរបន្តយល្បឿនម៉ាស៊ីនទៅកាន់ល្បឿនការ៉ង់ទីទាប។*

- ទាញដៃភ្ជាប់ប្រព័ន្ធបោកបែនឡើងលើដើម្បីភ្ជាប់ការអូសប្រព័ន្ធបោកបែន។
- រុញដៃភ្ជាប់ប្រព័ន្ធបោកបែនចុះក្រោយដើម្បីផ្តាច់ការអូសប្រព័ន្ធបោកបែន។

CP00834,0008F7D-KM-29AUG21

## អត្ថសញ្ញាណស៊ីឡាំងបោកបែន និងប្រអប់កញ្ជ្រោង




YC21118—UN—21DEC22

ស៊ីឡាំងបោកបែនរបារូស និងប្រអប់កញ្ជ្រោងលួសតូច/ធំ

ស៊ីឡាំងបោកបែនរបារូស ប្រើសម្រាប់ស្រូវសាឡី និងដំណាំគ្រាប់ល្អិតផ្សេងទៀតដែលច្រូតកាត់រួមគ្នាដោយប្រើប្រអប់កញ្ជ្រោងសរសៃលួសតូច។

ស៊ីឡាំងបោកបែនរបារូស ប្រើសម្រាប់ពោត សណ្តែកសៀង និងដំណាំគ្រាប់ធំផ្សេងទៀតដែលច្រូតកាត់រួមគ្នាដោយប្រើប្រអប់កញ្ជ្រោងសរសៃលួសធំ។



YC21119—UN—21DEC22

ស៊ីឡាំងបោកបែនធ្មេញវែង និងប្រអប់កញ្ជ្រោងធ្មេញវែង

ស៊ីឡាំងបោកបែនធ្មេញវែងប្រើសម្រាប់ការច្រូតកាត់ស្រូវរួមគ្នាជាមួយប្រអប់កញ្ជ្រោងធ្មេញវែង។

cp00834,1668665378651-KM-17NOV22

## គោលការណ៍លៃតម្រូវចន្លោះប្រអប់កញ្ជ្រោង និងល្បឿនបោកបែន

| ល្បឿនបោកបែន | ចន្លោះប្រអប់កញ្ជ្រោង | ឥទ្ធិពលប្រមូលផល |
|---|---|---|
| ខ្ពស់ | ចង្អៀត | សកម្មភាពបោកបែនល្អ |
| ខ្ពស់ពេក | ចង្អៀតពេក | បោកបែនជ្រុល |
| ទាប | ទូលាយ | សកម្មភាពបោកបែនមិនល្អ |
| ទាបពេក | ទូលាយពេក | ការបោកបែនមិនសូវល្អ |

- **ដើមដំណាំសើម៖** បង្កើនល្បឿនបោកបែន និងបន្តយចន្លោះប្រអប់កញ្ជ្រោង។
- **ដើមដំណាំស្ងួត៖** បន្តយល្បឿនបោកបែន និងបង្កើនចន្លោះប្រអប់កញ្ជ្រោង។
- **បោកបែនជ្រុល៖** បន្តយល្បឿនបោកបែនត្រឹម5%។ ប្រសិនបើការធ្វើដូច្នេះមិនដោះស្រាយបញ្ហាបានទេ ចូរបន្តយល្បឿនបោកបែនត្រឹម10%។ ប្រសិនបើការធ្វើដូច្នេះនៅតែមិនអាចដោះស្រាយបញ្ហាបានទៀត ចូរបង្កើនចន្លោះប្រអប់កញ្ជ្រោងបន្តិច។ប្រសិនបើមិនអាចកែតម្រូវការបោកបែនជ្រុលបានតាមវិធានការនេះទេ ចូរបន្តយល្បឿនលើដី។
- **ការបោកបែនមិនសូវល្អ៖** បង្កើនល្បឿនបោកបែនត្រឹម5%។ ប្រសិនបើការធ្វើដូច្នេះមិនអាចដោះស្រាយបញ្ហាបានទៀត ចូរបន្តយចន្លោះប្រអប់កញ្ជ្រោងបន្តិច។ប្រសិនបើសកម្មភាពបោកបែននៅតែមិនដំណើរការស្រួលទៀត ចូរបង្កើនល្បឿនលើដី។

CP00834,0008DBE-KM-08MAR22

## លៃតម្រូវចន្លោះប្រអប់កញ្ជ្រោង

*កំណត់ចំណាំ៖ ដំណើរការម៉ាស៊ីនមុននឹងលៃតម្រូវចន្លោះប្រអប់កញ្ជ្រោង។*

*កំណត់ចំណាំ៖ ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែក 120 ដើម្បីជ្រាបពីចន្លោះប្រអប់កញ្ជ្រោងតាមការណែនាំ។*




YC16797—UN—28FEB21

ដៃលៃតម្រូវចន្លោះប្រអប់កញ្ជ្រោង (ការអូសដោយមេកានិក)

**A—ដៃលៃតម្រូវចន្លោះប្រអប់កញ្ជ្រោង**
**B—ប៊ូតុង**

ដៃលៃតម្រូវចន្លោះប្រអប់កញ្ជ្រោង (A) ប្រើដើម្បីលៃតម្រូវចន្លោះប្រអប់កញ្ជ្រោង។

ចង្កឹះលៃតម្រូវចន្លោះប្រអប់កញ្ជ្រោងគឺនៅខាងស្តាំដៃកៅអី។

- ចុចប៊ូតុង (B) ហើយទាញដៃបញ្ជាឡើងលើដើម្បីបន្ថយចន្លោះប្រអប់កញ្ជ្រោង។
- ចុចប៊ូតុង (B) ហើយរុញដៃបញ្ជាចុះក្រោមដើម្បីបង្កើនចន្លោះប្រអប់កញ្ជ្រោង។


*កំណត់ចំណាំ៖ ការប្តូរទំហំចន្លោះប្រអប់កញ្ជ្រោងពី 2 ដល់ 3 ម.ម ដែលប្រើធ្មេញមួយ។*

CP00834,0008F7F-KM-12JUL21

## លៃតម្រូវល្បឿនបោកបែន (ការអូសដោយមេកានិច)

*កំណត់ចំណាំ៖ ភ្ជាប់ប្រព័ន្ធបោកបែនមុននឹងលៃតម្រូវល្បឿនបោកបែន។*

*កំណត់ចំណាំ៖ ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែក 120 ដើម្បីជ្រាបពីល្បឿនបោកបែនតាមការណែនាំ។*





YC14209—UN—20DEC19

**A—ចង្កឹះលៃតម្រូវល្បឿនបោកបែន**

ដៃលៃតម្រូវល្បឿនបោកបែន (A) អនុញ្ញាតឲ្យប្រតិបត្តិការលៃតម្រូវល្បឿនបោកបែន។

ចង្កឹះលៃតម្រូវល្បឿនបោកបែនស្ថិតនៅខាងស្តាំដៃកៅអី។

- ទាញលៃតម្រូវល្បឿនបោកបែនឡើងលើដើម្បីបង្កើនល្បឿនបោកបែន។
- រុញលៃតម្រូវល្បឿនបោកបែនចុះក្រោមដើម្បីបន្ថយល្បឿនបោកបែន។




YC21120—UN—21DEC22

**B—តម្លៃល្បឿនបោកបែន**

តម្លៃល្បឿនបោកបែន (B) បង្ហាញនៅអេក្រង់បង្គោលកាច់ជ្រុង។

cp00834,1668666772966-KM-17NOV22

## លៃតម្រូវល្បឿនបោកបែន (ការអូសដោយអ៊ីដ្រូស្តាទិក)

*កំណត់ចំណាំ៖ ភ្ជាប់ប្រព័ន្ធបោកបែនមុននឹងលៃតម្រូវល្បឿនបោកបែន។*

*កំណត់ចំណាំ៖ ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែក 120 ដើម្បីជ្រាបពីល្បឿនបោកបែនតាមការណែនាំ។*





YC17942—UN—12JUL21

**A—កុងតាក់ល្បឿនបោកបែន**

កុតតាក់ល្បឿនបោកបែន (A) អនុញ្ញាតឲ្យប្រតិបត្តិការលៃតម្រូវល្បឿនបោកបែន។

- ចុចទប់ផ្នែកខាងលើនៃកុងតាក់ល្បឿនបោកបែនដើម្បីបង្កើនល្បឿនបោកបែន។
- ចុចទប់ផ្នែកខាងក្រោមកុងតាក់ល្បឿនបោកបែនដើម្បីបន្ថយល្បឿនបោកបែន។

*កំណត់ចំណាំ៖ បន្ទាប់ពីប្រើប្រាស់កុងតាក់ល្បឿនបោកបែន ចូរបន្ធូរកុងតាក់ ហើយកុងតាក់នឹងត្រឡប់ទៅកាន់ទីតាំងនឹងវិញ។*





YC21120—UN—21DEC22

**B—តម្លៃល្បឿនបោកបែន**

តម្លៃល្បឿនបោកបែន (B) បង្ហាញនៅអេក្រង់បង្ហោលកាច់ជ្រុង។

cp00834,1668666780974-KM-17NOV22

## ប្រតិបត្តិការស្តីបន្ថយល្បឿនស៊ីឡាំងបោកបែន (ជាជម្រើស)




YC21121—UN—21DEC22


**A—ប្រតិបត្តិការស្តីបន្ថយល្បឿនស៊ីឡាំងបោកបែន**
**B—ប៊ូឡុង (ប្រើ 2)**
**C—ក្បាលឡោស៊ីមានឡក់ (ប្រើ 2)**
**D—អង្គប្តូរប្រឡោ**

1. បន្ធូរក្បាលឡោស៊ីមានឡក់ (C) និងប៊ូឡុង (B), បន្ទាប់មកលៃតម្រូវល្បឿនបោកបែន៖
   - រុញអង្គប្តូរប្រឡោ (D) ចូលក្នុងទៅកាន់ល្បឿនធម្មតាចន្លោះពី 350ដល់ 1100 ជុំ/នាទី។
   - រុញអង្គប្តូរប្រឡោចេញក្រៅដើម្បីបន្ថយល្បឿនពី 130 ដល់ 390 ជុំ/នាទី។
2. រឹតបន្តឹងប៊ូឡុង និងក្បាលឡោស៊ីមានឡក់បន្ទាប់ពីលៃតម្រូវរួច។


cp00834,1668667091765-KM-17NOV22

## លៃតម្រូវល្បឿនគ្រឿងបំបែក (ដែលប្រើប្រអប់ស្តីមិនអាចលៃតម្រូវបាន)

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21302—UN—21DEC22




YC9548—UN—30NOV15

**A—ប៉ូលីអូស**
**B—ប៉ូលីអូស**

ប៉ូលីអូស (A) ត្រូវបានដំឡើងនៅរោងចក្រ ហើយល្បឿនគ្រឿងបំបែកគឺ 700 ជុំ/នាទី។


ល្បឿនគ្រឿងបំបែកផ្សេងៗ (800 ជុំ/នាទី និង 500 ជុំ/នាទី) អាចមានដោយប្តូរទៅប្រើប៉ូលីអូស (B)។

cp00834,1669170138757-KM-22NOV22


## លៃតម្រូវល្បឿនគ្រឿងបំបែក (ដែលប្រើប្រអប់ស្តីដែលអាចលៃតម្រូវបាន)

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

**សំខាន់៖ មុនពេលប្តូរចង្កឹះលេខ ចូរដាក់ចង្កឹះលេខពីរនៅក្នុងទីតាំងនីង។**




YC21122—UN—21DEC22




YC17447—UN—12MAY21

**A—ចង្កឹះប្តូរលេខ**
**B—សោ ( ប្រើ 2)**
**C—ចង្កឹះប្តូរលេខ**
**D—ទីតាំង (មិនជាប់លេខ)**
**E—ទីតាំងទី (500 ជុំ/នាទី)**
**F—ទីតាំងទី (800 ជុំ/នាទី)**
**G—ទីតាំងទី (700 ជុំ/នាទី)**

ប្តូរចង្កឹះលេខ (A និង C) ទៅទីតាំងផ្សេងៗដើម្បីទទួលបានល្បឿនគ្រឿងបំបែកផ្សេង។

លើកសោ (B), ប្តូរចង្កឹះលេខ ហើយបន្ទាប់មកបន្ទូរសោ។

- ទីតាំង (D)៖ មិនជាប់លេខ
- ទីតាំង (E)៖ 500 ជុំ/នាទី
- ទីតាំង (F)៖ 800 ជុំ/នាទី
- ទីតាំង (G)៖ 700 ជុំ/នាទី


cp00834,1668667537188-KM-17NOV22

# ប្រតិបត្តិការប្រព័ន្ធសម្អាត

## លៃតម្រូវល្បឿនកង្ហារសម្អាត


**សំខាន់៖ ល្បឿនកង្ហារសម្អាតអាចលៃតម្រូវបានតែនៅពេលកង្ហារសម្អាតកំពុងដំណើរការ ឬគ្រឿងមួយចំនួននឹងត្រូវខូចខាត។**

*កំណត់ចំណាំ៖ ជាធម្មតាល្បឿនកង្ហារសម្អាតទាបអាចបណ្តាលឲ្យបាត់បង់គ្រាប់ធញ្ញជាតិច្រើនជាងល្បឿនកង្ហារសម្អាតខ្ពស់។*




YC2414—UN—25JUL14

លៃតម្រូវល្បឿនកង្ហារសម្អាត




YC21123—UN—21DEC22

**A—ដៃលៃតម្រូវ**
**B—តម្លៃល្បឿនកង្ហារសម្អាត**

មួលដៃលៃតម្រូវ (A) ស្របទ្រនិចនាឡិកាដើម្បីបង្កើនល្បឿន។

មួលដៃលៃតម្រូវ (A) ច្រាសទ្រនិចនាឡិកាដើម្បីបន្ថយល្បឿន។

តម្លៃល្បឿនកង្ហារ (B) បង្ហាញនៅអេក្រង់បង្ហោលកាច់ជ្រុង។

ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែកតម្រុយប្រមូលផល (Harvesting Hints) ដើម្បីជ្រាបពីល្បឿនកង្ហារសម្អាតដើមដំណាំផ្សេងៗតាមការណែនាំ។

*កំណត់ចំណាំ៖ ពិនិត្យមើលលទ្ធផលលៃតម្រូវចុងក្រោយមុននឹងលៃតម្រូវ។*


*មុននឹងលៃតម្រូវល្បឿនកង្ហារសម្អាត ចូរលៃតម្រូវប្រឡោះធ្មេញ និងតម្រងទៅតាមតម្លៃអតិបរមានៃគ្រាប់ធញ្ញជាតិផ្សេងៗតាមការណែនាំ។ បង្កើនល្បឿនកង្ហារសម្អាតបន្តិចម្តងៗពីល្បឿនអប្បបរមាដែលបានណែនាំរហូតដល់មិនមានគ្រាប់ធញ្ញជាតិត្រូវផ្លុំចេញពីគ្រឿងចក្រ ឬផ្លុំចូលទៅក្នុងបន្ទះហូតគ្រាប់។*

*នៅពេលល្បឿនកង្ហារសម្អាតឡើងដល់តម្លៃអតិបរមា ចូរលៃតម្រូវប្រឡោះធ្មេញបន្តិចតាមចាំបាច់ បន្ទាប់មកលៃល្បឿនកង្ហារសម្អាត។*

cp00834,1668668576037-KM-17NOV22

## លៃតម្រូវអង្គបង្វែរខ្យល់

*កំណត់ចំណាំ៖ ដៃលៃតម្រូវ (A) ស្ថិតនៅទីតាំងកណ្តាលតាំងពីរោងចក្រមក។*




YC8174—UN—25MAR15

**A—ដៃលៃតម្រូវ**


ដាក់ដៃលៃតម្រូវនៅក្នុងទីតាំងខាងលើសម្រាប់ដំណាំគ្រាប់ល្អិត។

ដាក់ដៃលៃតម្រូវនៅក្នុងទីតាំងខាងក្រោមសម្រាប់ដំណាំគ្រាប់ធំ។

cp00834,1668668776790-KM-17NOV22

## លៃតម្រូវប្រឡោះធ្មេញ

### ការលៃតម្រូវ




YC17148—UN—01APR21

**A—ធ្មេញ**

**B—ដៃលៃតម្រូវ**

មួលដៃលៃតម្រូវ (B) ទៅខាងឆ្វេងដើម្បីបង្កើនប្រឡោះ។


មួលដៃលៃតម្រូវ (B) ទៅខាងស្តាំដើម្បីបន្ថយប្រឡោះ។

ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែកតម្រុយប្រមូលផល (Harvesting Hints) ដើម្បីជ្រាបពីប្រឡោះធ្មេញសម្រាប់គ្រាប់ធញ្ញជាតិផ្សេងៗតាមការណែនាំ។

*កំណត់ចំណាំ៖ ពិនិត្យមើលលទ្ធផលលៃតម្រូវចុងក្រោយមុននឹងលៃតម្រូវ។*

*លៃតម្រូវប្រឡោះធ្មេញឲ្យបានតូចតាមដែលអាចធ្វើទៅបាន នឹងប្រាកដថាគ្រាប់ធញ្ញជាតិធ្លាក់តាមមុននឹងឆ្លងកាត់បណ្តោយធ្មេញ។*

**រង្វាស់**



YC1661—UN—27NOV12


**X—ប្រឡោះធ្មេញ**

វាស់ប្រឡោះធ្មេញរវាងស្លាបព្រិលដែកចំនួនពីរ។

cp00834,1659687195991-KM-05AUG22

## លៃតម្រូវប្រឡោះកន្ត្រែង

### ការលៃតម្រូវ




YC17149—UN—01APR21

**A—កន្ត្រែង**
**B—ដៃលៃតម្រូវ**

មួលដៃលៃតម្រូវ (B) ទៅខាងឆ្វេងដើម្បីបង្កើនប្រឡោះ។


មួលដៃលៃតម្រូវ (B) ទៅខាងស្តាំដើម្បីបន្ថយប្រឡោះ។

ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែកតម្រុយប្រមូលផល (Harvesting Hints) ដើម្បីជ្រាបពីប្រឡោះកន្ត្រែងសម្រាប់គ្រាប់ធញ្ញជាតិផ្សេងៗតាមការណែនាំ។

*កំណត់ចំណាំ៖ ពិនិត្យមើលលទ្ធផលលៃតម្រូវចុងក្រោយមុននឹងលៃតម្រូវ។*

*លៃតម្រូវប្រឡោះកន្ត្រែងឲ្យបានជិតតាមដែលអាចធ្វើទៅបាន នឹងប្រាកដថាអំពុកនិងដើមដំណាំមិនធ្លាក់តាមហ្នឹងឡើយ។*

**រង្វាស់**



YC1661—UN—27NOV12


**X—ប្រឡោះកន្ត្រែង**

វាស់ប្រឡោះកន្ត្រែងរវាងស្លាបព្រិលដែកចំនួនពីរ។

cp00834,1659687221945-KM-05AUG22

## លៃតម្រូវប្រឡោះពន្លាធ្មេញកញ្ជ្រែង

### ការលៃតម្រូវ




YC17147—UN—01APR21

**A—ផ្នែកពន្លាធ្មេញកញ្ជ្រែង**
**B—ដៃលៃតម្រូវ**

មួលដៃលៃតម្រូវ (B) ទៅខាងឆ្វេងដើម្បីបង្កើនប្រឡោះ។


មួលដៃលៃតម្រូវ (B) ទៅខាងស្តាំដើម្បីបន្ថយប្រឡោះ។

ប្រឡោះពន្លាធ្មេញកញ្ជ្រែងទូលាយជាងប្រឡោះធ្មេញបន្តិច។

ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែកតម្រុយប្រមូលផល (Harvesting Hints) ដើម្បីជ្រាបពីប្រឡោះធ្មេញសម្រាប់គ្រាប់ធញ្ញជាតិផ្សេងៗតាមការណែនាំ។

*កំណត់ចំណាំ៖ លើកប្រដាប់ពង្រីធ្មេញបន្ទិចដើម្បីឲ្យស់ដីស្រូវស្រួលធ្លាក់កាត់តាម។*

**រង្វាស់**





YC1661—UN—27NOV12

**X—ប្រឡោះពន្លាធ្មេញកញ្ជ្រែង**


វាស់ប្រឡោះពន្លាធ្មេញកញ្ជ្រែងរវាងស្លាបព្រិលដែកចំនួនពីរ។

cp00834,1659687241866-KM-05AUG22

## ការលៃតម្រូវទីតាំងសន្ទះទ្វារក្រោយ




YC17150—UN—01APR21




YC21124—UN—21DEC22

**A—កន្លាស់ខ្ចាស់ (ប្រើ 2)**
**B—ទីតាំងលៃតម្រូវ (ប្រើ 4)**
**C—ផ្នែកពន្លាធ្មេញកញ្ជ្រែង**
**D—ផ្ទាំងទ្វារក្រោយ**
**E—ក្បាលឡោស៊ីមានឡក់ (ប្រើ 2)**

បន្ថយចន្លោះរវាងផ្នែកពន្លាធ្មេញកញ្ជ្រែង (C) និង ផ្ទាំងទ្វារក្រោយ (D) ដើម្បីបង្ការការបាត់បង់ច្រើនដោយសារខ្យល់។

1. បន្ធូរឡោស៊ីចាក់សោ (E)។
2. ទាញកន្លះខ្ចាស់ (A) ហើយរំកិលផ្ទាំងទ្វារក្រោយទៅទីតាំងតម្រូវ។
3. ស៊កកន្លាស់ខ្ចាស់ក្នុងរន្ធ។

*កំណត់ចំណាំ៖ ផ្ទាំងទ្វារក្រោយ មានបួនទីតាំង។*

4. រឹតបន្តឹងឡោស៊ីមានឡក់បន្ទាប់ពីលៃតម្រូវរួច។

*កំណត់ចំណាំ៖ រំកិល ផ្ទាំងទ្វារក្រោយ ឡើងលើឲ្យឆ្ងាយតាមដែលអាចធ្វើទៅបាន។ ប្រសិនបើចន្លោះនៅតែធំទៀត ចូររំកិលផ្នែកពន្លាធ្មេញកញ្ជ្រែង ចុះក្រោម។*

cp00834,1668669307283-KM-17NOV22


# ប្រតិបត្តិការប្រដាប់យោង និងប្រព័ន្ធបួងទម្លាក់

## ប្រតិបត្តិការផ្តាច់/ភ្ជាប់ប្រដាប់បួងទម្លាក់

**សំខាន់៖ មុននឹងភ្ជាប់ប្រដាប់បួងទម្លាក់ ចូរប្រាកដថាប្រដាប់បួងទម្លាក់ស្ថិតនៅត្រង់ទីតាំងបួងទម្លាក់។**

**ផ្តាច់ប្រដាប់បួងទម្លាក់ចេញតែនៅពេលទម្លាក់គ្រាប់ធញ្ញជាតិអស់ទាំងស្រុង។ ចាក់គ្រាប់ចេញពីធុងគ្រាប់ធញ្ញជាតិឲ្យអស់ក្នុងប្រតិបត្តិការតែមួយដង (តែមួយលើក)។**

*កំណត់ចំណាំ៖ គ្រាប់អាចត្រូវបានទម្លាក់តែមួយលើក (ខណៈដែលគ្រឿងចក្រកំពុងមានចលនា)។*




YC12270—UN—11DEC17

ដៃភ្ជាប់ប្រដាប់បួងទម្លាក់ (ការអូសដោយមេកានិក)

**A—ដៃភ្ជាប់ប្រដាប់បួងទម្លាក់**
**B—ប៊ូតុង**

ដៃភ្ជាប់ប្រដាប់បួងទម្លាក់ (A) ប្រើដើម្បីភ្ជាប់ ឬផ្តាច់ប្រព័ន្ធបួងទម្លាក់។

ដៃភ្ជាប់ប្រដាប់បួងទម្លាក់ស្ថិតនៅខាងឆ្វេងកៅអី។

- ទាញដៃឡើងលើដើម្បីភ្ជាប់ប្រព័ន្ធបួងទម្លាក់។
- ចុចប៊ូតុង (B) ហើយរុញដៃចុះក្រោមដើម្បីផ្តាច់ប្រព័ន្ធបួងទម្លាក់។

*កំណត់ចំណាំ៖ បន្ទាប់ពីចុចប៊ូតុងនេះ ដៃភ្ជាប់ប្រដាប់បួងទម្លាក់អាចធ្លាក់ចុះក្រោមដោយស្វ័យប្រវត្តិ។*

*កំណត់ចំណាំ៖ ដើម្បីភ្ជាប់ប្រដាប់បួងទម្លាក់ ចូរទាញដៃភ្ជាប់ប្រដាប់បួងទម្លាក់យឺតៗ។ ទាញដៃភ្ជាប់ប្រដាប់បួងទម្លាក់ឲ្យលឿន នៅពេលប្រដាប់បួងទម្លាក់កំពុងរំលៃ។*

CP00834,0008F7A-KM-29AUG21

## ប្រតិបត្តិការយោលប្រដាប់បួងទម្លាក់ (ការអូសដោយមេកានិក)

*កំណត់ចំណាំ៖ នៅពេលមិនប្រើប្រាស់ប្រដាប់បួងទម្លាក់ យកល្អគួរបត់ប្រដាប់បួងទម្លាក់ត្រឡប់ទៅទីតាំងដឹកជញ្ជូនវិញ។*




YC1410—UN—06MAR14

**A—ដៃយោលប្រដាប់បួងទម្លាក់**


ដៃយោលប្រដាប់បួងទម្លាក់ (A) ប្រើដើម្បីយោលប្រដាប់បួងទម្លាក់ចូលក្នុង ឬចេញក្រៅ។

- ទាញដៃយោលប្រដាប់បួងទម្លាក់ឡើងលើដើម្បីយោលប្រដាប់បួងទម្លាក់ចេញក្រៅ។
- រុញដៃយោលប្រដាប់បួងទម្លាក់ចុះក្រោមដើម្បីយោលប្រដាប់បួងទម្លាក់ចូលក្នុង។

CP00834,0008F7B-KM-12JUL21

## ប្រតិបត្តិការយោលប្រដាប់បួងទម្លាក់ (ការអូសដោយអ៊ីដ្រូស្តាទិក)

*កំណត់ចំណាំ៖ នៅពេលមិនប្រើប្រាស់ប្រដាប់បួងទម្លាក់ យកល្អគួរបត់ប្រដាប់បួងទម្លាក់ត្រឡប់ទៅទីតាំងដឹកជញ្ជូនវិញ។*




YC17940—UN—12JUL21

**A—ប៊ូតុងយោលប្រដាប់បួងទម្លាក់ចេញក្រៅ**
**B—ប៊ូតុងយោលប្រដាប់បួងទម្លាក់ចូលក្នុង**
**C—កុងតាក់លើផ្លូវទីវាល**
**D—ដៃបញ្ជាពហុមុខងារ**

ដៃយោលប្រដាប់បួងទម្លាក់ចេញ/ចូលប្រើដើម្បីយោលប្រដាប់បួងទម្លាក់ចូលក្នុង ឬចេញក្រៅ។


*កំណត់ចំណាំ៖ មុននឹងយោលប្រដាប់បួងទម្លាក់ចេញឬចូល ចូរប្រាកដថាកុងតាក់លើផ្លូវថ្នល់/វាលស្រែ (C) ស្ថិតនៅក្នុងម៉ូដវាលស្រែ (ពន្លឺភ្លើងសញ្ញានៅលើកុងតាក់មិនបើកឡើយ)។*

- ចុចទប់ប៊ូតុងយោលប្រដាប់បួងទម្លាក់ចេញក្រៅ (A) ប្រើដើម្បីយោលប្រដាប់បួងទម្លាក់ចេញក្រៅ។
- ចុចទប់ប៊ូតុងយោលប្រដាប់បួងទម្លាក់ចូលក្នុង (B) ប្រើដើម្បីយោលប្រដាប់បួងទម្លាក់ចូលក្នុង។

CP00834,0008F7C-KM-20OCT21

## លៃតម្រូវប្រឡោះបួងទម្លាក់នៅក្នុងធុងគ្រាប់ធញ្ញជាតិ

**សំខាន់៖ ប្រសិនបើលើកបន្ទះទាំងនេះខ្ពស់ពេក ប៊ូឡុងសងខាងដុំអូសប្រដាប់បួងអាចជាក់ម្តងហើយម្តងទៀត ឬអាចធ្វើឲ្យខូចប្រដាប់បួង ឬធុងគ្រាប់ធញ្ញជាតិ។**




YC21125—UN—21DEC22

**A—ក្បាលឡោស៊ី (ប្រើ 12)**
**B—បន្ទះ (ប្រើ 6)**

បន្ធូរក្បាលឡោស៊ី (A) និងរំកិលបន្ទះ (B) ឡើងលើដើម្បីបង្កើនប្រឡោះបួងទម្លាក់។ រឹតបន្តឹងក្បាលឡោស៊ីក្រោយពីលៃតម្រូវរួច។

បន្ធូរក្បាលឡោស៊ី (A) និងរំកិលបន្ទះ (B) ចុះក្រោមដើម្បីបន្ថយប្រឡោះបួងទម្លាក់។ រឹតបន្តឹងក្បាលឡោស៊ីក្រោយពីលៃតម្រូវរួច។


*កំណត់ចំណាំ៖ បង្កើនប្រឡោះបួងទម្លាក់សម្រាប់ដំណាំសួត។*
*បន្ថយប្រឡោះបួងទម្លាក់សម្រាប់ដំណាំសើម។*

cp00834,1668670051368-KM-17NOV22

# ការចាត់ចែងកាកសំណល់

## លៃតម្រូវប្រដែងដើមដំណាំចិញ្ច្រាំ

**សំខាន់៖ កំណត់កំបិតវិលនៅទៅតាំងប្រដែងកាត់អប្បបរមា (A) នៅពេលប្រមូលផលសណ្តែក ដែបស៊ីដ ឬដំណាំដែលស្តួក។**





YC17142—UN—31MAR21


**A—ទីតាំងប្រដែងកាត់អប្បបរមា**
**B—ទីតាំងប្រដែងកាត់អតិបរមា**
**C—ប៊ូឡុង (ប្រើ 2)**
**D—ប្រដាប់ក្តាប់**

បន្ទូរប៊ូឡុង (C) នៅចំហៀងសងខាងរបស់គ្រឿងចក្រ។ លៃតម្រូវប្រដាប់ក្តាប់ (D) ទៅកាន់ទីតាំងដែលចង់បាន បន្ទាប់មកវិតបន្តឹងប៊ូឡុងនោះវិញ។

CP00834,0008BD7-KM-08MAR22




YC21127—UN—21DEC22
អង្គបង្វែរនៅក្នុងទីតាំងប្រតិបត្តិការ





YC21128—UN—21DEC22
អង្គបង្វែរស្ថិតក្នុងទីតាំងដឹកជញ្ជូន

## ប្តូរទីតាំងអង្គបង្វែរ

**⚠ ប្រយ័ត្ន៖ ចាក់ខ្ទាស់អង្គបង្វែរនៅក្នុងទីតាំងដឹកជញ្ជូនមុននឹងដឹកជញ្ជូន។ ហាមភ្ជាប់កាំបិតចិញ្ច្រាំដើមដំណាំនៅអំឡុងពេលដឹកជញ្ជូន។**

**ហាមឈរពីក្រោយម៉ាស៊ីននៅពេលកាំបិតចិញ្ច្រាំដើមដំណាំកំពុងដំណើរការ។**




YC8296—UN—09FEB15

**A—ប៊ូឡុង (ប្រើ 2)**
**B—បន្ទះចាក់ខ្ទាស់ (ប្រើ 2)**
**C—គន្លឹះ (ប្រើ 2)**
**D—តម្កក់ (ប្រើ 2)**

### ប្តូរអង្គបង្វែរទៅកាន់ទីតាំងប្រតិបត្តិការ

*កំណត់ចំណាំ៖ ប្រតិបត្តិការនៅចំហៀងសងខាងគ្រឿងចក្រនៅក្នុងពេលដំណាលគ្នា។*

1. បន្ធូរប៊ូឡុង (A) និងបង្វិលបន្ទះចាក់ខ្ទាស់ (B) ចេញពីដង។

**⚠ ប្រយ័ត្ន៖ អង្គបង្វែរមានទម្ងន់ប្រហែល 37 គ.ក។ វាចាំបាច់ត្រូវការមនុស្សពីរនាក់ដើម្បីចាត់ចែងវា។**

2. លើកអង្គបង្វែរចេញពីតម្កក់ ហើយដាក់វាចុះក្រោម។
3. ចាក់គន្លឹះ (C)។
4. បង្វិលបន្ទះចាក់ខ្ទាស់លើដង ហើយវិតបន្តឹងប៊ូឡុង។

### ប្តូរអង្គបង្វែរទៅទីតាំងដឹកជញ្ជូន

*កំណត់ចំណាំ៖ ប្រតិបត្តិការនៅចំហៀងសងខាងគ្រឿងចក្រនៅក្នុងពេលដំណាលគ្នា។*


1. បន្ធូរគន្លឹះ (C)។
2. បន្ធូរប៊ូឡុង (A) និងបង្វិលបន្ទះចាក់ខ្ទាស់ (B) ចេញពីដង។

**⚠ ប្រយ័ត្ន៖ អង្គបង្ហៀរមានទម្ងន់ប្រហែល 37 គ.ក។ វាចាំបាច់ត្រូវការមនុស្សពីរនាក់ដើម្បីចាត់ចែងវា។**

3. លើកអង្គបង្ហៀរឡើង ហើយដាក់វាលើតម្គក់។
4. បង្វិលបន្ទះចាក់ខ្ទាស់លើដង ហើយរឹតបន្តឹងប៊ូឡុង។

cp00834,1668672131613-KM-17NOV22

## លៃតម្រូវស្លាបនៅលើអង្គបង្ហៀរ




YC21126—UN—21DEC22

**A—ប៊ូឡុង (ប្រើ 12)**
**B—ស្លាប (ប្រើ 6)**

បន្ធូរប៊ូឡុង (A)។ លៃតម្រូវទីតាំងស្លាប (B) ដើម្បីប្តូរមុំ និងកម្រិតពង្រាយ។

ទទឹងពង្រាយគួរតែត្រូវគ្នាជាមួយទទឹងក្បាលឧបករណ៍កាត់។

cp00834,1668670535929-KM-17NOV22

# ការប្រើប្រាស់ស្តាយនីយប្រតិបត្តិករ

## ប្រើប្រាស់ខ្សែក្រវាត់សុវត្ថិភាព

**⚠ ប្រយ័ត្ន៖ ត្រួតពិនិត្យខ្សែក្រវាត់សុវត្ថិភាព ហើយភ្ជាប់គ្រឿងខ្ចៅនៅលើគ្រឿងចក្ររបស់អ្នកយ៉ាងហោចណាស់មួយឆ្នាំម្តង។ ប្រសិនបើប្រព័ន្ធខ្សែក្រវាត់សុវត្ថិភាពរួមមានគ្រឿងដំឡើងភ្ជាប់ជាមួយក្តាស់គន្លឹះ ខ្សែក្រវាត់ ឬប្រដាប់ពន្លឹបចូល បង្ហាញឲ្យឃើញនូវសញ្ញាខូចខាតដូចជាដាច់ រសាត់ ឬសឹក ដេចរិលខុសប្រក្រតី ស្លេកពណ៌ មានស្នាមរលាត់ ប្រព័ន្ធខ្សែក្រវាត់សុវត្ថិភាពទាំងមូលគួរតែផ្លាស់ប្តូរជាបន្ទាន់។ ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នក ផ្លាស់ប្តូរប្រព័ន្ធខ្សែក្រវាត់តែជាមួយនឹងគ្រឿងបន្លាស់ដែលមានការអនុញ្ញាតសម្រាប់គ្រឿងចក្ររបស់អ្នក ចូរពិគ្រោះជាមួយភ្នាក់ងារចែកចាយក្រុមហ៊ុន John Deere របស់អ្នកប៉ុណ្ណោះ។**





YC17130—UN—29MAR21

**A—ខ្សែក្រវាត់សុវត្ថិភាព**

ខ្សែក្រវាត់សុវត្ថិភាព (A) គឺជាបរិក្ខារស្តង់ដារនៅលើកៅអីប្រតិបត្តិករ។ ខ្សែក្រវាត់សុវត្ថិភាពប្រភេទរឹតភ្លៅមានប្រដាប់បន្ធូរហ៊ាសប៊ូតុងចុច និងប្រដាប់ទាញត្រឡប់ស្វ័យប្រវត្តិដើម្បីឲ្យស្រួលចេញចូល។

CP00834,0008BC3-KM-30MAR21

## លៃតម្រូវកៅអីប្រតិបត្តិករ




YC17131—UN—30MAR21

**A—គន្លឹះលៃតម្រូវកម្ពស់/ទម្ងន់**
**B—ដៃលៃតម្រូវបង្អែកខ្នង**
**C—គន្លឹះលៃតម្រូវកៅអី**
**D—ដៃលៃតម្រូវមុំ**
**E—ដៃលៃតម្រូវមុខ/ក្រោយ**

**ការលៃតម្រូវជាសុកភាព៖** កាច់ដៃលៃតម្រូវទម្ងន់/កម្ពស់ (A) ដើម្បីលៃតម្រូវជាសុកភាពកៅអី។

**ការលៃតម្រូវបង្អែកខ្នង៖** កាច់ដៃលៃតម្រូវបង្អែកខ្នង (B) ដើម្បីលៃតម្រូវមុំបង្អែកខ្នង។

**ការលៃតម្រូវកម្ពស់៖** ចុចដៃលៃតម្រូវកម្ពស់ (C) ដើម្បីលៃតម្រូវពូកកៅអីទៅកាន់ទីតាំងតាមចង់បាន។

**ការលៃតម្រូវមុំ៖** ចុចដៃលៃតម្រូវមុំ (D) ដើម្បីលៃតម្រូវពូកកៅអីទៅកាន់ទីតាំងតាមចង់បាន។

**ការលៃតម្រូវមុខ/ក្រោយ៖** ទាញដៃលៃតម្រូវមុខ/ក្រោយ (E) ឡើងលើ ដើម្បីហូតកៅអីទៅកាន់ទីតាំងតាមចង់បាន។

CP00834,0008F68-KM-09JUL21

## លៃតម្រូវទម្រែតដៃចង្កូត




YC17132—UN—30MAR21

ដៃចង្កូត (ដែលប្រើការអូសដោយអ៊ីដ្រូស្តាទិក)

**A—ដៃចង្កូត**
**B—ឈ្នាន់**


**លៃតម្រូវដៃចង្កូត៖** សង្កត់ឈ្នាន់ (B) ទៅមុខ លៃតម្រូវដៃចង្កូត (A) ទៅកាន់ទីតាំងតាមចង់បាន។

**ចាក់ខ្ទាស់ដៃចង្កូត៖** សង្កត់ឈ្នាន់មកក្រោយដើម្បីចាក់ខ្ទាស់ដៃចង្កូត។

CP00834,0008BC5-KM-30MAR21

## បង្ហួចខាងស្តាំកាប៊ីន (ច្រកចេញក្នុងគ្រាអាសន្ន)

**⚠ ប្រយ័ត្ន៖ ប្រសិនបើមានអាសន្នកើតឡើង ហើយទ្វារច្រកចេញបើកមិនរួច ចូរប្រើបង្ហួចខាងស្តាំដើម្បីចាកចេញពីកាប៊ីន។**





YC17134—UN—30MAR21

**A—បង្ហួចខាងស្តាំ**
**B—ដង**

ទប់ដង (B) ហើយបង្វិលវាស្របទ្រនិចនាឡិកាដើម្បីបើកបង្ហួចខាងស្តាំ (A)។ កាច់ដងបញ្ច្រាសទ្រនិចនាឡិកាដើម្បីបិទបង្ហួចខាងស្តាំ។

CP00834,0008BC6-KM-30MAR21

## ប្រអប់ឧបករណ៍




YC17133—UN—30MAR21


**A—ប្រអប់ឧបករណ៍**
**B—គន្លឹះ**

ប្រអប់ដាក់ឧបករណ៍ (A) ស្ថិតនៅក្រោមកៅអី។

រំកិលគន្លឹះ (B) ឡើងលើដើម្បីបើកប្រអប់ដាក់ឧបករណ៍។

CP00834,0008BC7-KM-30MAR21

## បើកទ្វារ




YC17135—UN—30MAR21

**A—ដង**
**B—សោ**

ប្រសិនបើទ្វារកាប៊ីនមិនបានចាក់ខ្ទាស់ទេ សូមចុចគន្លឹះ (B) ដើម្បីបើកទ្វារកាប៊ីន។ ប្រសិនបើទ្វារកាប៊ីនចាក់ខ្ទាស់ ចូរប្រើសោដើម្បីបើកវា។

ចុចដង (A) ដើម្បីបើកទ្វារកាប៊ីនពីខាងក្នុងកាប៊ីន។

CP00834,0008BC8-KM-30MAR21

## ភ្ជាប់ជណ្តើរនៅទីតាំងដឹកជញ្ជូន

**⚠ ប្រយ័ត្ន៖ មុននឹងបើកបរតាមផ្លូវ ចូរបត់ជណ្តើរ និងទុកដាក់វាឲ្យមានសុវត្ថិភាពនៅក្នុងទីតាំងដឹកជញ្ជូន។**

**ចៀសវាងធ្វើឱ្យអ្នកដទៃរងរបួសនៅពេលលាជណ្តើរ។**



YC21129—UN—21DEC22
cp00834,1669015435856-KM-21NOV22

## ពន្លាជណ្តើរ




YC21303—UN—21DEC22

**A—បន្ទះតភ្ជាប់**

ប្រសិនបើប្រើសម្បកកង់ទូលាយ ចូរដោះប៊ូឡុង ទាញបន្ទះភ្ជាប់ (A) ចេញក្រៅ ដើម្បីរឹតបន្តឹងប៊ូឡុង។

cp00834,1669170530230-KM-22NOV22

# ការទុកដាក់ និងការដឹកជញ្ជូន

## រៀបចំគ្រឿងចក្រសម្រាប់ទុកដាក់

### គ្រឿងចក្រ

- សម្អាតផ្នែកខាងក្រៅនិងខាងក្នុងគ្រឿងចក្រឲ្យបានស្អាតល្អ។
- ដោះ ឬបន្ធូរខ្សែពានអូសទាំងអស់។
- ដាក់ប្រេងរំអិលគ្រឿងចក្រ។ ដាក់ប្រេងរំអិលធ្មេញខ្ចៅលៃតម្រូវទាំងពីរ។ដាក់ប្រេងច្រវាក់ទាំងអស់។
- សម្អាតប្រដាប់បួង ប្រដាប់យោង និងស្បែកជើងសម្អាត។ ទុកទ្វារប្រដាប់យោងឲ្យនៅចំហ។
- ចាក់ប្រេងឥន្ធនៈចូលធុងដើម្បីការពារកំណក។
- បង្ហូរទឹកចេញពីតម្រងចម្រោះទឹក
- លាបថ្នាំត្រង់កន្លែងចាំបាច់ឡើងវិញ។

*កំណត់ចំណាំ៖ បិទកុងតាក់ផ្តាច់អាគុយ ប្រសិនបើលោកអ្នកត្រូវរក្សាគ្រឿងចក្រទុកលើសពី 25 ថ្ងៃ។ ប្រសិនបើរក្សាទុកលើសពី 90 ថ្ងៃ ចូរដោះខ្សែអាគុយអវិជ្ជមានចេញដើម្បីកាត់បន្ថយបន្ទុកអាគុយជាអតិបរមា។*

- សាកអាគុយឲ្យពេញ។ ទំនាញជាក់លាក់ស្មើនឹង 1.260 វ៉ុល។ ដើម្បីកាត់បន្ថយបន្ទុកចំពោះអាគុយជាអតិបរមា ចូរដោះខ្សែអវិជ្ជមានចេញពីអាគុយ។

*កំណត់ចំណាំ៖ ប្រសិនបើត្រូវរក្សាទុកគ្រឿងចក្រក្នុងរយៈពេលយូរ ចូរដោះនិងលាងសម្អាតអាគុយ។ ដាក់អាគុយក្នុងទឹកនៅកន្លែងសួតត្រជាក់ ហើយទុកឲ្យវាចូលភ្លើងពេញ។*

### ម៉ាស៊ីន

- លាងសម្អាតម៉ាស៊ីនសារធាតុរំលាយដែលមានសុវត្ថិភាព។
- សម្អាតធុងទឹកម៉ាស៊ីនដោយប្រើខ្សល់ ទឹក ឬប្រដាប់បូមធូលី។
- សម្អាតអង្គកំណ និងឧបករណ៍បញ្ចេះកម្តៅប្រេងប្រសិនបើមាន។ លាងសម្អាតឧបករណ៍បញ្ចេះកម្តៅខ្សល់
- រាល់ 60 ទៅ 90 ថ្ងៃ ចូរបញ្ចេះម៉ាស៊ីន និងបើកម៉ាស៊ីនត្រជាក់ចោលប្រសិនបើមាន។ ដំណើរការម៉ាស៊ីនការងារទទាបរយៈពេលច្រើននាទី។ ដើម្បីដំណើរការម៉ាស៊ីនត្រជាក់ឲ្យបានត្រឹមត្រូវសីតុណ្ហភាពខាងក្រៅគួរតែលើសពី 5 °C (40 °F)។

**⚠ ប្រយ័ត្ន៖ ហាមប្រើសាំង។**

- សម្អាតផ្នែកខាងក្នុងសំបុកតម្រងខ្សល់ ហើយដាក់ស្បៃតម្រងខ្សល់ថ្មីចូល។
- បង្ហូរប្រេងម៉ាស៊ីនចេញខណៈដែលម៉ាស៊ីនក្តៅ។ ប្តូរតម្រងនិងចាក់ប្រេងត្រឹមត្រូវចូល។បើកដំណើរការម៉ាស៊ីនដើម្បីឲ្យប្រេងជាចសាចសព្វ។
- បង្ហូរ លាងសម្អាត និងចាក់បំពេញប្រព័ន្ធបញ្ចេះកម្តៅជាមួយល្បាយសារធាតុប្រឆាំងកំណកនិងទឹក50/50។

CP00834,0008BB7-KM-29MAR21

## យកគ្រឿងចក្រចេញពីកន្លែងទុកដាក់

- ដំឡើង និងរឹតបន្តឹងខ្សែពានអូសទាំងអស់។ រឹតបន្តឹងច្រវាក់អូសទាំងអស់។
- បិទទ្វារប្រដាប់យោង។
- ពិនិត្យមើលខ្សល់កង់ និងអានសៀវភៅណែនាំប្រើប្រាស់ឡើងវិញ។
- ត្រួតពិនិត្យបំពង់ពន្លត់អគ្គីភ័យដោយអនុវត្តតាមការណែនាំថែទាំនៅលើស្លាកបិទលើបំពង់ពន្លត់អគ្គីភ័យ។សាកឡើងវិញ ឬប្តូរថ្មីតាមចាំបាច់។
- ភ្ជាប់និង/ឬសាកអាគុយឡើងវិញ។
- ពិនិត្យកម្រិតប្រេងម៉ាស៊ីននិងទឹកថ្នាំសំម៉ាស៊ីន។ ពិនិត្យរកមើលកន្លែងលេចធ្លាយហើយបន្ថែមប្រេងម៉ាស៊ីន និងទឹកថ្នាំសំម៉ាស៊ីនចូល ប្រសិនបើចាំបាច់។

CP00834,0008BBB-KM-29MAR21

## បើកបរគ្រឿងចក្រលើផ្លូវ

ដើម្បីបើកបរគ្រឿងចក្រលើផ្លូវ អនុវត្តតាមដូចតទៅ៖

- សម្អាតធុងគ្រាប់ធញ្ញជាតិ ហើយដោះក្បាលឧបករណ៍កាត់ចេញ។
- យោលប្រដាប់បួងទម្លាក់។
- បត់ជណ្តើរឡើង។
- ចាក់សោឈ្នាន់ហ្វ្រាំងជើងរួមគ្នា។
- បើកភ្លើងព្រមានគ្រោះថ្នាក់តាមចាំបាច់។

cp00834,1668677436009-KM-17NOV22

## ដឹកជញ្ជូនគ្រឿងចក្រនៅលើរ៉ឺម៉កសណ្តោង

ដើម្បីដឹកជញ្ជូនគ្រឿងចក្រ អនុវត្តតាមដូចតទៅ៖

1. ដោះក្បាលកាត់ចេញ។
2. បើកបរគ្រឿងចក្រទៅលើរ៉ឺម៉កសណ្តោង។ ដាក់ចង្កឹះលេខ និងដែបញ្ជាអូសដោយអ៊ីដ្រូស្តាទិក(បើមាន)នៅក្តងទិតាងនឹង។
3. បន្ទាបមាត់ច្រកបួងចូលលើរ៉ឺម៉កសណ្តោង។ យោលប្រដាប់បួងទម្លាក់។
4. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
5. បត់ជណ្តើរឡើង។
6. ចងភ្ជាប់គ្រឿងចក្រទៅនឹងរ៉ឺម៉កសណ្តោងដោយប្រើច្រវាក់។

cp00834,1668677457544-KM-17NOV22

## សណ្តោងគ្រឿងចក្រ

**⚠ ប្រយ័ត្ន៖ កុំសណ្តោងគ្រឿងចក្រជាមួយខ្សែភ្លើង។ ប្រសិនបើខ្សែដាច់ សកម្មភាពជោះបង់អាចបង្ករឲ្យមានរបួសដល់រាងកាយ។**

**សំខាន់៖ កុំសណ្តោងគ្រឿងចក្រ លើកលែងតែក្នុងស្ថានភាពមានអាសន្នសម្រាប់ចម្ងាយជិតនៅល្បឿន 20 គ.ម/ម៉ោង អតិបរមា។**

ដើម្បីសណ្តោងគ្រឿងចក្រ អនុវត្តតាមដូចតទៅ៖

- សម្អាតធុងគ្រាប់ធញ្ញជាតិ ហើយដោះក្បាលឧបករណ៍កាត់ចេញ។
- យោលប្រដាប់បួងទម្លាក់។
- បត់ជណ្តើរឡើង។
- ផ្តាច់ហ្វ្រាំងដៃ។

**⚠ ប្រយ័ត្ន៖ កុំដោះឧបករណ៍ភ្ជាប់ចេញ។ នៅពេលឧបករណ៍ភ្ជាប់ត្រូវបានដោះចេញ ហ្វ្រាំងត្រូវបានបិទ។**

- ដាក់ចង្កឹះលេខ និងដៃបញ្ជាអូសដោយអ៊ីដ្រូស្តាទិក (បើមាន) នៅក្នុងទីតាំងនឺង។
- សណ្តោងគ្រឿងចក្រក្តួងទិសដៅទៅមុខ ដោយភ្ជាប់ច្រវាក់ជុំវិញស្តៅមេ។សូមប្រាកដថា ច្រវាក់មិនធ្វើឲ្យខ្សែរារីណាមួយខូចទេ។ មានប្រតិបត្តិករអង្គុយក្នុងកៅអីដើម្បីកាច់ចង្កូត និងជាន់ហ្វ្រាំងគ្រឿងចក្រ។
- បើកភ្លើងព្រមានគ្រោះថ្នាក់។
- ធ្វើដំណើរនៅល្បឿនដែលសមហេតុផល និងមានសុវត្ថិភាព មិនលើសពី 20 គ.ម/ម៉ោង។

**⚠ ប្រយ័ត្ន៖ បង្ការការប៉ះទង្គិចរវាងអ្នកប្រើប្រាស់ផ្លូវដទៃទៀត ត្រាក់ទ័រដែលផ្លាស់ទីយឺតៗដោយមានភ្ជាប់ឧបករណ៍បន្ថែម ឬឧបករណ៍សណ្តោងផ្សេងៗ និងគ្រឿងចក្រមានម៉ាស៊ីននៅលើផ្លូវសាធារណៈ។ ពិនិត្យមើលចរាចរណ៍ឲ្យបានញឹកញាប់ពីផ្នែកខាងក្រោយ ជាពិសេសនៅពេលបត់ និងប្រើដៃជាសញ្ញា ឬភ្លើងសញ្ញាពេលបត់។**

**ប្រើភ្លើងមុខ ភ្លើងព្រមានគ្រោះថ្នាក់ និងភ្លើងសញ្ញាបត់នៅពេលថ្ងៃ និងយប់។**

cp00834,1668677466675-KM-17NOV22

# ប្រេងឥន្ធនៈ ទឹកថ្នាំសំរ៉ាស៊ីន និងប្រេងរំអិល

## ការប្រើប្រាស់ និងរក្សាទុកប្រេងម៉ាស៊ូត

**⚠ ប្រយ័ត្ន៖ កាត់បន្ថយហានិភ័យអគ្គិភ័យ។ គ្រប់គ្រង និងចាត់ចែងប្រេងឥន្ធនៈដោយប្រុងប្រយ័ត្ន។ កុំចាក់បំពេញធុងប្រេងនៅពេលម៉ាស៊ីនកំពុងដំណើរការ។ កុំជក់បារីនៅពេលអ្នកចាក់បំពេញធុងប្រេង ឬផ្តល់សេវាជួសជុលប្រព័ន្ធប្រេង។**

ចាក់បំពេញធុងប្រេងនៅពេលចប់បើកបរក្នុងថ្ងៃនីមួយៗ ដើម្បីបង្ការកុំឲ្យមានញើស ឬកកជាដំណក់ទឹកនៅអំឡុងពេលអាកាសធាតុត្រជាក់។

រក្សាអាងរក្សាទុកទាំងអស់ឲ្យនៅពេញតាមភាពជាក់ស្តែង ដើម្បីកាត់បន្ថយការឡើងកំហាប់ជាអប្បបរមា។

ជានាថា គម្រប និងរបាំងធុងប្រេងទាំងអស់ត្រូវបានដំឡើងត្រឹមត្រូវដើម្បីបង្ការកុំឲ្យសំណើមចូល។ ត្រួតពិនិត្យចំណុះទឹកនៃប្រេងឥន្ធនៈឲ្យបានទៀងទាត់។

នៅពេលដែលប្រើប្រាស់ជីវម៉ាស៊ូត គម្រងប្រេងឥន្ធនៈអាចត្រូវការការផ្លាស់ប្តីកាន់តែញឹកញាប់ដោយសារការដោតប៊ូស៊ីមុនពេលកំណត់។


ត្រួតពិនិត្យកម្រិតប្រេងម៉ាស៊ីនប្រចាំថ្ងៃ មុនពេលបញ្ឆោះម៉ាស៊ីន។ កម្រិតប្រេងដែលឡើង អាចបង្ហាញនូវកម្រិតខីលុយស្បូងឥន្ធនៈនៃប្រេងម៉ាស៊ីន។

**សំខាន់៖ ធុងប្រេងត្រូវមានហ៊ីយដើម្បីឲ្យខ្យល់ចេញចូលតាមគម្របចាក់ប្រេង។ ប្រសិនបើត្រូវការគម្របតម្រងថ្មីមួយ ជានិច្ចកាល ចូរប្តូរដាក់គម្រដើមដែលមានរន្ធហ៊ីយ។**

នៅពេលត្រូវរក្សាទុកប្រេងក្នុងរយៈពេលយូរ ឬមានប្រេងឥន្ធនៈឡើងយឺតចូរបន្ថែមខន់ឌីហ្សិនណាប្រេងដើម្បីស្តេរភាពប្រេងឥន្ធនៈ។ ការបង្ហូរទឹកចេញឲ្យអស់ និងធ្វើប្រព្រឹត្តិកម្មធុងស្តុកប្រេងរាល់ប៉ែខម្តងជាមួយជូសថែទាំនៃប៊ូយ៉ូស៊ីតនិងការពារមិនឲ្យកើនឡើងនូវមីក្រុប។ សូមទាក់ទងអ្នកផ្គត់ផ្គង់ប្រេងឥន្ធនៈ ឬភ្នាក់ងារចែកចាយ John Deere របស់អ្នកដើម្បីសុំការណែនាំ។

DX,FUEL4-KM-13JAN18

## គោរពតាមច្បាប់និងបទប្បញ្ញត្តិការពារបរិស្ថាន



YC1389—UN—07DEC12

មានការយល់ដឹងអំពីប្រព័ន្ធអេកូឡូស៊ីនិងបរិស្ថាន។

កំណត់វិធីសាស្ត្របោះចោលយ៉ាងត្រឹមត្រូវមុនពេលបង្ហូរចេញសំណល់រាវអ្វីមួយ។

តែងតែអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិការពារបរិស្ថានជានិច្ច ពេលទុកដាក់ប្រេង ឥន្ធនៈ ទឹកថ្នាំសំរ៉ាស៊ីន ប្រេងរ្រាំង សារធាតុគម្រង និងអាគុយ។

CP00718,0004295-KM-19DEC17

## ប្រេងម៉ាស៊ូត

ប្រឹក្សាជាមួយភ្នាក់ងារចែកចាយប្រេងឥន្ធនៈក្នុងស្រុករបស់អ្នក សម្រាប់លក្ខណៈសម្បត្តិនៃប្រេងម៉ាស៊ូតដែលអាចរកបាននៅក្នុងតំបន់របស់អ្នក។

គួរប្រើប្រេងម៉ាស៊ូតដែលបានបញ្ជាក់ចំពោះ GB 19147។

**លក្ខណៈប្រេងឥន្ធនៈដែលត្រូវការ**

គ្រប់ករណីទាំងអស់ ប្រេងឥន្ធនៈត្រូវមានគុណភាពដូចតទៅ៖

**ចំនួនសេតានអប្បបរមា 40 ។** ចំនួនសេតានដែលធំជាង 47 រឺតែល្អថែមទៀត ជាពិសេសសម្រាប់សីតុណ្ហភាពក្រោម –20 °C (–4 °F) ឬកម្ពស់លើសពី 1675 ម (5500 ហ្វីត)។

**ចំណុចពពក** គួរតែនៅក្រោមសីតុណ្ហភាពជុំវិញទាបបំផុតដែលរំពឹងទុកឬ **ចំណុចស្ទះតម្រងត្រជាក់** (CFPP) គួរតែមានអតិបរមា 10 អង្សាសេ (18 ° F) ខាងក្រោមចំណុចពពកឥន្ធនៈ។

**ភាពរំអិលនៃប្រេងឥន្ធនៈ:** គួរឆ្លងផុតអង្កត់ផ្ចិតសម្លាកអតិបរមា .52 មម តាមការវាស់វែងដោយ ASTM D6079 ឬ ISO 12156-1។ យកល្អគួរប្រើអង្កត់ផ្ចិតសម្លាកអតិបរមា .45 មម។

**គុណភាព និងចំណុះ:** ស្តង់ដារបស់ប្រេងម៉ាស៊ូត ត្រូវតែអនុលោមតាមបទបញ្ញត្តិបំភាយឧស្ម័នជាធរមានសម្រាប់តំបន់ដែលម៉ាស៊ីនដំណើរការ។ កុំប្រើប្រេងម៉ាស៊ូតដែលមានចំណុះស្តង់ដារធំជាង 10 000 មក្រ/គក្រ (10 000 ភាគក្នុងមួយលាន)។

**សម្ភារៈ** ដូចជាទង់ដែង សំណ ស័ង្កសី សំណប៉ាហាំង ស្តាន់ និងសំរីទ្ធីគួរតែចៀសវាងប្រើជាគ្រឿងបរិក្ខារសម្រាប់ចាត់ចែង ចែកចាយនិងទុកដាក់ប្រេងឥន្ធនៈ ពីព្រោះលោហធាតុទាំងនេះ អាចបង្កើតប្រតិកម្មអុកស៊ីដកម្មប្រេងឥន្ធនៈដែលអាចបណ្តាលឲ្យកកប្រព័ន្ធប្រេងឥន្ធនៈនិងស្ទះតម្រងប្រេង។

**ប្រេងឥន្ធៈ E-Diesel**

កុំប្រើប្រេងម៉ាស៊ូត E-Diesel (ល្បាយប្រេងម៉ាស៊ូត និងអេតាណុល)។ ការប្រើប្រាស់ប្រេងម៉ាស៊ូត E-Diesel នៅក្នុងគ្រឿងចក្រ John Deere ណាមួយ អាចធ្វើឲ្យខូចការធានារ៉ាប់រងចំពោះគ្រឿងចក្រ។

**⚠ ប្រយ័ត្ន៖ ប្រយ័ត្នក្រែងលោរងរបួសធ្ងន់ធ្ងរ ឬស្លាប់ដោយសារការផ្ទុះនិងអគ្គីភ័យដែលបណ្តាលមកពីការប្រើប្រេង E-Diesel។**

**ចំណុះស្តង់ដារសម្រាប់ម៉ាស៊ីនម៉ាស៊ូតនៃគ្រឿងចក្រចល័តមិនប្រើលើផ្លូវថ្នល់ (ប្រទេសចិន IV)**

- ប្រើប្រាស់តែ ប្រេងម៉ាស៊ូតមានស្តាន់ដារទាបខ្លាំង (ULSD) ដែលមានចំណុះស្តាន់ដារអតិបរិមា15 មក្រ/គក្រ (15 ppm) ប៉ុណ្ណោះ។

**សំខាន់៖ កុំលាយប្រេងម៉ាស៊ីនម៉ាស៊ូតដែលប្រើប្រាស់រួច ឬប្រេងរំអិលប្រភេទផ្សេងទៀតជាមួយនឹងប្រេងម៉ាស៊ីនម៉ាស៊ូត។**

**ការប្រើប្រាស់ប្រេងបន្ថែមមិនបានត្រឹមត្រូវ អាចបង្កការខូចខាតដល់ឧបករណ៍ចាក់បញ្ចូលប្រេងឥន្ធនៈរបស់ម៉ាស៊ីនម៉ាស៊ូត។**

cp00834,1661909695490-KM-30AUG22

## ប្រេងម៉ាស៊ីនម៉ាស៊ូតដែលទើបប្រើថ្មី — គ្មានការភាយឧស្ម័ន ថ្នាក់ទី 1 ថ្នាក់ទី 2 ថ្នាក់ទី 3 ដំណាក់កាលទី I ដំណាក់កាលទី II និងដំណាក់កាលទី III

ម៉ាស៊ូតថ្មីត្រូវបានចាក់បំពេញនៅរោងចក្រជាមួយផ្នែកពាណិជ្ជកម្ម John DeereBreak-In™ ឬក៏ប្រេងម៉ាស៊ូនផ្នែកពាណិជ្ជកម្ម John DeereBreak-In Plus™ នៅអំឡុងពេលប្រើប្រាស់ដំបូង សូមបន្ថែមប្រេងម៉ាស៊ីនម៉ាក John Deere Break-In™ ឬ Break-In Plus™ តាមតម្រូវការដើម្បីរក្សាកម្រិតប្រេងតាមលក្ខណៈបច្ចេកទេស។

ប្រតិបត្តិការម៉ាស៊ីនក្រោមលក្ខខណ្ឌផ្សេងៗ ជាពិសេសបន្ទុកធ្ងន់ ជាមួយនឹងការការ៉ងទីម៉ាស៊ីនតិចតួចបំផុត ដើម្បីជួយឲ្យចូលសមាសភាគម៉ាស៊ីនបានត្រឹមត្រូវ។

ប្រសិនបើប្រើប្រេងម៉ាស៊ីនម៉ាក John Deere Break-In™ នៅអំឡុងពេលប្រតិបត្តិការដំបូងនៃម៉ាស៊ីនថ្មី ឬម៉ាស៊ីនដែលផ្តុំឡើងវិញ សូមប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីនក្នុងរយៈពេលអតិបរិមា 100 ម៉ោង។

ប្រសិនបើប្រើប្រេងម៉ាស៊ីនម៉ាក John Deere Break-In Plus™ សូមប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីននៅចន្លោះពេលអប្បបរមា 100 ម៉ោង និងអតិបរមាស្មើនឹងចន្លោះពេលដែលមានបញ្ជាក់លម្អិតសម្រាប់ប្រេងម៉ាក John Deere Plus-50™ II ឬ Plus-50™ ។

ក្រោយពេលរើជួសជុលម៉ាស៊ីន សូមចាក់ប្រេងម៉ាស៊ីនម៉ាក John Deere Break-In™ ឬ Break-In Plus™ ។

ប្រសិនបើពុំអាចរកបានប្រេងម៉ាស៊ីនម៉ាក John Deere Break-In™ ឬ Break-In Plus™ ទេនោះ សូមប្រើប្រេងម៉ាស៊ីនម៉ាស៊ូតដែលមានកម្រិតស្អិតអន្ទិល SAE 10W-30 ដែលត្រូវតាមតម្រូវការណាមួយខាងក្រោម ហើយប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីនក្រោយពេលប្រតិបត្តិការអតិបរិមា 100 ម៉ោង៖

- សេវា API ចំណាត់ថ្នាក់ CE
- សេវា API ចំណាត់ថ្នាក់ CD
- សេវា API ចំណាត់ថ្នាក់ CC
- សេវា ACEA ចំណាត់ថ្នាក់ E2
- ប្រេង ACEA លំដាប់ E1

**សំខាន់៖ កុំប្រើប្រេងម៉ាស៊ីន Plus-50™ II, Plus-50™ ឬប្រេងម៉ាស៊ីនទាំងឡាយណាដែលត្រូវនឹងតម្រូវការណាមួយខាងក្រោម សម្រាប់ការប្រើប្រាស់ដំបូងនៃម៉ាស៊ីនថ្មី ឬម៉ាស៊ីនដែលទើបនឹងផ្តុំនឹងឡើងវិញ៖**

| | |
|---|---|
| **API CK-4** | **ACEA E9** |
| **API CJ-4** | **ACEA E7** |
| **API CI-4 PLUS** | **ACEA E6** |
| **API CI-4** | **ACEA E5** |
| **API CH-4** | **ACEA E4** |
| **API CG-4** | **ACEA E3** |
| **API CF-4** | |
| **API CF-2** | |
| **API CF** | |

**ប្រេងម៉ាស៊ីនទាំងនេះ មិនអនុញ្ញាតឲ្យម៉ាស៊ីនប្រើប្រាស់ដំបូងបានត្រឹមត្រូវទេ។**


*Break-In គឺជានិក្ខិត្តសញ្ញារបស់ Deere & Company។*
*Break-In Plus គឺជានិក្ខិត្តសញ្ញារបស់ Deere & Company*
*PLUS-50 គឺជានិក្ខិត្តសញ្ញារបស់ Deere & Company។*

ប្រេងម៉ាស៊ីនម៉ាក John Deere Break-In Plus™ អាចប្រើប្រាស់សម្រាប់ប្រេងម៉ាស៊ីនម៉ាស៊ូតទាំងអស់របស់ John Deere នៅគ្រប់កម្រិតនៃការបញ្ជាក់អំពីការបំភាយឧស្ម័នទាំងអស់។

ក្រោយពេលចប់រយៈពេលប្រើប្រាស់ដំបូង សូមប្រើប្រេងម៉ាក John Deere Plus-50™ II, John Deere Plus-50™ ឬប្រេងម៉ាស៊ីនម៉ាស៊ូតផ្សេងទៀតតាមការណែនាំនៅក្នុងសៀវភៅណែនាំនេះ។

DX,ENOIL4-KM-02NOV16

## ប្រេងម៉ាស៊ីនម៉ាស៊ូត - ថ្នាក់ទី 3 និងដំណាក់កាល IIIA




TS1743—UN—25APR19
កម្រិតស្អិតខាប់នៃប្រេងរំអិលសម្រាប់លំដាប់សីតុណ្ហភាពខ្យល់

ការមិនអនុវត្តតាមស្តង់ដារប្រេងនិងចន្លោះពេលបង្ហូរអាចបណ្តាលឱ្យខូចម៉ាស៊ីនធ្ងន់ធ្ងរដែលអាចធ្វើឱ្យជាប់បង់ការធានា។ ការធានា ដែលរួមមានការធានារ៉ាប់រងលើការបំភាយឧស្ម័នគឺមិនមែនជាលក្ខខណ្ឌចំពោះការប្រើពពួកប្រេងម៉ាស៊ីន គ្រឿងបន្លាស់ ឬសេវាកម្ម របស់ក្រុមហ៊ុន John Deere ឡើយ។

ប្រើកម្រិតភាពស្អិតខាប់ដោយផ្អែកលើលំដាប់សីតុណ្ហភាពខ្យល់ដែលបានរំពឹងទុកនៅអំឡុងចន្លោះពេលនៃការផ្លាស់ប្តូរប្រេងម៉ាស៊ីនម្តងៗ។

**ប្រេងម៉ាស៊ីន John Deere Plus-50™ II គេនិយមប្រើជាងគេ។**

ប្រេងម៉ាស៊ីន John Deere Plus-50™ ក៏ត្រូវបានណែនាំផងដែរ។

John Deere Torq-Gard™ ក៏ត្រូវបានអនុញ្ញាតឲ្យប្រើផងដែរ។

ប្រេងដទៃទៀតអាចប្រើបាន ប្រសិនបើឆ្លើយតាមបទដ្ឋានមួយឬច្រើនដូចខាងក្រោម៖

- CK-4 ប្រភេទសេវា API
- សេវា API ប្រភេទ CJ-4
- សេវា API ប្រភេទ CI-4 PLUS
- សេវា API ប្រភេទ CI-4
- ប្រេង ACEA លំដាប់ E9
- ប្រេង ACEA លំដាប់ E7
- ប្រេង ACEA លំដាប់ E6
- ប្រេង ACEA លំដាប់ E5
- ប្រេង ACEA លំដាប់ E4

**យកល្អគួរប្រើប្រេងម៉ាស៊ីនម៉ាស៊ូតដែលមានពហុកម្រិតភាពអន្ទិល។**

គុណភាព និងចំណុះស្ពាន់ធ័ររបស់ប្រេងម៉ាស៊ូត ត្រូវតែអនុលោមតាមបទបញ្ជាត្តិបំភាយឧស្ម័នជាធរមានសម្រាប់តំបន់ដែលត្រូវម៉ាស៊ីនដំណើរការ។

កុំប្រើប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រធំជាង 10 000 មក្រ/គក្រ (10 000 ភាគក្នុងមួយលាន)។

DX,ENOIL11-KM-23APR19

## ចន្លោះពេលផ្តល់សេវាថែទាំប្រេងម៉ាស៊ីននិងតម្រង

ចន្លោះម៉ោងថែទាំប្រេង និងតម្រងដែលត្រូវបានណែនាំ គឺផ្អែកលើការរួមបញ្ចូលគ្នារវាងចំណុះនៃធុងប្រេង ប្រភេទប្រេងម៉ាស៊ីន និងតម្រងដែលត្រូវបានប្រើប្រាស់ និងចំណុះស្ពាន់ធ័រនៃប្រេងម៉ាស៊ូត។ ចន្លោះម៉ោងថែទាំជាក់ស្តែងក៏ពឹងផ្អែកលើប្រតិបត្តិការ និងទម្លាប់អនុវត្តតំហែទាំផងដែរ។

ប្រើប្រាស់ការវិភាគអំពីប្រេងដើម្បីវាយតម្លៃអំពីស្ថានភាពប្រេង និងដើម្បីជួយដល់ការជ្រើសរើសចន្លោះម៉ោងថែទាំប្រេង និងតម្រងដែលត្រឹមត្រូវ។ ទាក់ទងឈ្មួញ John Deere របស់អ្នកសម្រាប់ព័ត៌មានបន្ថែមអំពីការវិភាគប្រេងម៉ាស៊ីន។

ផ្លាស់ប្តូរប្រេង និងតម្រងប្រេងយ៉ាងតិចម្តងរៀងរាល់ 12 ខែ ទោះបីជាម៉ោងប្រតិបត្តិការតិចជាងចន្លោះម៉ោងថែទាំដែលបានណែនាំក៏ដោយ។

**ចំណុះស្ពាន់ធ័រប្រេងម៉ាស៊ូត** ប៉ះពាល់ដល់ចន្លោះម៉ោងថែទាំប្រេងម៉ាស៊ីន និងតម្រង។

- គួរប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រតិចជាង 1000 មក្រ/គក្រ(1000 ភាគក្នុងមួយលាន) ។
- មុនពេលប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រច្រើនជាង 5000មក្រ/គក្រ (5000 ភាគក្នុងមួយលាន) កាត់បន្ថយចន្លោះពេលផ្លាស់ប្តូរប្រេងម៉ាស៊ីននិងតម្រងប្រេងម៉ាស៊ីន។
- កុំប្រើប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រធំជាង 10 000 មក្រ/គក្រ(10 000 ភាគក្នុងមួយលាន)។

**សំខាន់៖ ដើម្បីជៀសវាងការខូចខាតដល់ម៉ាស៊ីន៖**

- **កាត់បន្ថយចន្លោះម៉ោងថែទាំប្រេង និងតម្រងត្រឹម 50% នៅពេលប្រើប្រាស់ការរួមបញ្ចូលគ្នានៃជីវម៉ាស៊ូតលើសពីB20។ ការវិភាគប្រេងនឹងអនុញ្ញាតឱ្យមានចន្លោះសេវាកម្មយូរជាងនេះ។**
- **ប្រើប្រាស់តែប្រភេទប្រេងដែលបានអនុម័តប៉ុណ្ណោះ។**

**ប្រភេទប្រេងដែលបានអនុម័តរ:**

- “ពពួកប្រេង Plus-50” រួមមាន John Deere Plus-50™ II និង John DeerePlus-50™
- “ពពួកប្រេងផ្សេងទៀត” រួមមាន John Deere Torq-Gard™, API CK-4, API CJ-4,API CI-4 PLUS, API CI-4, ACEA E9, ACEA E7, ACEA E6, ACEA E5, និង ACEAE4។

| PowerTech™<br>ចន្លោះពេលប្តូរតម្រងនិងប្រេងម៉ាស៊ីន | |
|---|---|
| **ចំណុះជាតិស្ពាន់ធ័ររបស់ប្រេងឥន្ធនៈ:** | ទាប់ជាង 1000 ម.ក/គ.ក (1000 ppm) |
| ប្រេង Plus-50 | 375 ម៉ោង |
| ពពួកប្រេងដទៃទៀត | 250 ម៉ោង |
| **ចំណុះជាតិស្ពាន់ធ័រក្នុងប្រេងឥន្ធនៈ:** | 1000-2000 ម.ក/គ.ក (1000-2000 ppm) |
| ប្រេង Plus-50 | 300 ម៉ោង |
| ពពួកប្រេងដទៃទៀត | 200 ម៉ោង |
| **ចំណុះជាតិស្ពាន់ធ័រក្នុងប្រេងឥន្ធនៈ:** | 2000-5000 ម.ក/គ.ក (2000-5000 ppm) |
| ប្រេង Plus-50 | 275 ម៉ោង |
| ពពួកប្រេងដទៃទៀត | 150 ម៉ោង |
| **ចំណុះជាតិស្ពាន់ធ័រក្នុងប្រេងឥន្ធនៈ:** | 5000-10000 ម.ក/គ.ក (5000-10000 ppm) |
| ប្រេង Plus-50 | 187 ម៉ោង |
| ពពួកប្រេងដទៃទៀត | 125 ម៉ោង |

*Plus-50 គឺជាពាណិជ្ជសញ្ញារបស់ Deere & Company*
*Torq-Gard គឺជានិក្ខីត្តសញ្ញារបស់ Deere & Company*

| PowerTech™<br>ចន្លោះពេលប្តូរតម្រងនិងប្រេងម៉ាស៊ីន |
|---|
| ការវិភាគអំពីប្រេងពន្យារចន្លោះម៉ោងថែទាំរបស់ “ប្រេងផ្សេងទៀត” រហូតដល់ចំនួនអតិបរមាដែលមិនលើសពីចន្លោះម៉ោងថែទាំសម្រាប់ប្រេង Plus-50 ឡើយ។ |

**សំខាន់៖ កុំពន្យាចន្លោះពេលផ្តល់សេវាថែទាំប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីនដល់រយៈពេល 375 ម៉ោងរហូតទាល់តែលក្ខខណ្ឌទាំងអស់ខាងក្រោមត្រូវបានឆ្លើយតប៖**

- **ការប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានបរិមាណស្ពាន់ធ័រតិចជាង 1000 មីលីក្រាម/គីឡូក្រាម(1000 ppm) ។**
- **ការប្រើប្រាស់ប្រេង John Deere Plus-50™ II និង John Deere Plus-50™។**
- **ការប្រើប្រាស់តម្រងប្រេងដែលអនុញ្ញាតដោយ John Deere ។**

CO00263,0001D9F-KM-21MAY20

## ចន្លោះម៉ោងថែទាំប្រេងម៉ាស៊ូតសម្រាប់ការប្រើប្រាស់នៅរយៈកម្ពស់ខ្ពស់សម្រាប់ជាព័ត៌មានបន្ថែម

ដើម្បីជៀសវាងភាពចុះអន់ថយនៃប្រេងខ្លាំងពេក និងការខូចខាតជាសក្តានុពលចំពោះម៉ាស៊ីន ចូរកាត់បន្ថយចន្លោះម៉ោងថែទាំប្រេង និងតម្រងប្រេងមកត្រឹម 50% នៃតម្លៃដើមដែលត្រូវបានណែនាំ នៅពេលធ្វើប្រតិបត្តិការម៉ាស៊ីនដែលមានរយៈកម្ពស់លើស **1675 m (5500 ft)**។

ការវិភាគអំពីប្រេងអាចអនុញ្ញាតឲ្យមានចន្លោះម៉ោងថែទាំយូរជាងនេះ។

ប្រើប្រាស់តែប្រភេទប្រេងដែលបានអនុម័តប៉ុណ្ណោះ។

| ឧទាហរណ៍នៃម៉ោងដើម | ម៉ោងនៃរយៈកម្ពស់ខ្ពស់ដែលពាក់ព័ន្ធគ្នា |
|---|---|
| 125 | 60 |
| 150 | 75 |
| 175 | 85 |
| 200 | 100 |
| 250 | 125 |
| 275 | 135 |
| 300 | 150 |
| 350 | 175 |
| 375 | 185 |
| 400 | 200 |
| 500 | 250 |

DX,ENOIL,SERV,HIALT-KM-11NOV14

## តម្រងប្រេងឥន្ធនៈ

សារសំខាន់របស់ការត្រងប្រេងឥន្ធនៈមិនអាចត្រូវបានបញ្ជាក់ខ្លាំងពេកដោយប្រព័ន្ធប្រេងឥន្ធនៈទំនើបបានឡើយ។ ការរួមបញ្ចូលគ្នារវាងបទប្បញ្ញត្តិស្តីពីការបញ្ចេញផ្សែងដែលមានការរឹតត្បិតកាន់តែខ្លាំងឡើង និងម៉ាស៊ីនដែលមានប្រសិទ្ធភាពកាន់តែខ្លាំងត្រូវការប្រព័ន្ធប្រេងឥន្ធនៈដើម្បីប្រតិបត្តិការក្នុងសម្ពាធកាន់តែខ្ពស់។ គេអាចទទួលបានសម្ពាធកាន់តែខ្ពស់តែនៅពេលដែលប្រើប្រាស់សមាសធាតុនៃការបញ្ចូលប្រេងឥន្ធនៈដែលមានគម្លាតជិតខ្លាំង។ គម្លាតនៃការផលិតជិតៗគ្នាទាំងនេះបានកាត់បន្ថយចំនួនកម្ទេចកម្ទី និងទឹកបានក្នុងបរិមាណច្រើន។

តម្រងប្រេងឥន្ធនៈម៉ាក John Deere ត្រូវបានរចនា និងផលិតឡើងសម្រាប់ម៉ាស៊ីន John Deere ជាពិសេស។

ដើម្បីការពារម៉ាស៊ីនពីកម្ទេចកម្ទី និងទឹក តែងតែផ្លាស់ប្តូរតម្រងប្រេងម៉ាស៊ីនដូចដែលបានបញ្ជាក់នៅក្នុងសៀវភៅណែនាំនេះ។

DX,FILT2-KM-14APR11

## តម្រងប្រេង

ការត្រងប្រេងឥន្ធនៈមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការធ្វើប្រតិបត្តិការត្រឹមត្រូវ និងប្រេងរំអិល។ តម្រងប្រេងម៉ាក John Deere ត្រូវបានរចនា និងផលិតឡើងសម្រាប់ការប្រើប្រាស់របស់ John Deere ជាពិសេស។

តម្រងប្រេង John Deere គោរពតាមលក្ខណៈពិសេសផ្នែកវិស្វកម្មសម្រាប់គុណភាពនៃព័ត៌មានអំពីតម្រង ការកំណត់អត្ថប្រយោជន៍ភាពរបស់តម្រង កម្លាំងរបស់ចំណងរវាងព័ត៌មានអំពីតម្រង និងកាបូននៅខាងចុងសមាសធាតុរយៈពេលមិនដំណើរការរបស់ធុងហ្គាស (ប្រសិនបើមាន) និងចំណុះសម្ពាធរបស់ហ្វឺតតម្រង។ តម្រងប្រេងដែលមិនមែនម៉ាក John Deere អាចមិនបំពេញតាមលក្ខណៈពិសេសសំខាន់ៗរបស់ John Deere ទាំងនេះ។

តែងតែផ្លាស់ប្តូរតម្រងប្រេងជាទៀងទាត់ដូចត្រូវបានបញ្ជាក់នៅក្នុងសៀវភៅណែនាំនេះ។

DX,FILT1-KM-11APR11

## ទឹកស្អុំម៉ាស៊ីនម៉ាស៊ូត (ម៉ាស៊ីនដែលមានស៊ីឡាំងប្រភេទសើម)

ការមិនអនុវត្តតាមស្តង់ដារទឹកថ្នាំស្អុំម៉ាស៊ីននិងចន្លោះពេលបង្ហូរអាចបណ្តាលឱ្យខូចម៉ាស៊ីនធ្ងន់ធ្ងរដែលអាចធ្វើឱ្យជាប់បង់ការធានា។ ការធានា ដែលរួមមានការធានារ៉ាប់រងលើការបំភាយឧស្ម័នគឺមិនមែនជាលក្ខខណ្ឌចំពោះការប្រើពពួកទឹកថ្នាំស្អុំម៉ាស៊ីន គ្រឿងបន្លាស់ ឬសេវាកម្ម របស់ក្រុមហ៊ុន John Deere ឡើយ។

### ទឹកស្អុំម៉ាស៊ីនដែលគេនិយមប្រើ

គេនិយមប្រើទឹកស្អុំម៉ាស៊ីនដែលលាយជាមុនខាងក្រោមនេះ៖

- ទឹកស្អុំម៉ាស៊ីន **John Deere COOL-GARD™II**
- ទឹកស្អុំម៉ាស៊ីន **John Deere COOL-GARD II PG**

ទឹកស្អុំម៉ាស៊ីនដែលលាយជាមុន COOL_GARD II មានកំ

*COOL-GARD គឺជាពាណិជ្ជសញ្ញារបស់ Deere & Company*

ហាប់ផ្សេងៗជាមួយនឹងកម្រិតនៃការការពារការកកផ្សេងៗគ្នា ដូចដែលបានបង្ហាញក្នុងតារាងខាងក្រោម

| COOL-GARD II Pre-Mix | កម្រិតនៃការការពារការកក |
|---|---|
| COOL-GARD II 20/80 | -9°C (16°F) |
| COOL-GARD II 30/70 | -16°C (3°F) |
| COOL-GARD II 50/50 | -37°C (-34°F) |
| COOL-GARD II 55/45 | -45°C (-49°F) |
| COOL-GARD II PG 60/40 | -49°C (-56°F) |
| COOL-GARD II 60/40 | -52°C (-62°F) |

មិនមានទាំងអស់ទេនូវផលិតផលទឹកស្អុំម៉ាស៊ីនដែលលាយជាមុន COOL-GARD II ក្នុងប្រទេសនានា។

ប្រើទឹកស្អុំម៉ាស៊ីន COOL-GARD II PG នៅពេលដែលគេត្រូវការរូបមន្តសារធាតុធ្វើឲ្យត្រជាក់ដែលមិនពុល។

**ទឹកស្អុំត្រជាក់ផ្សេងៗតាមការណែនាំ**

ទឹកស្អុំម៉ាស៊ីនខាងក្រោមក៏ត្រូវបានណែនាំឲ្យប្រើប្រាស់ផងដែរ៖

- ទឹកស្អុំម៉ាស៊ីន COOL-Gard II របស់ John Deere លាយជាល្បាយដែលមានកំហាប់40-60% ជាមួយបរិមាណទឹក

**សំខាន់៖ នៅពេលលាយកំហាប់ទឹកស្អុំម៉ាស៊ីនជាមួយទឹក កុំលាយកំហាប់ទឹកស្អុំម៉ាស៊ីនអោយតិចជាង 40% ឬលើសពី 60%។ ការលាយកំហាប់ទឹកស្អុំម៉ាស៊ីនតិចជាង 40% មិនអាចផ្តល់ឲ្យសារធាតុបន្ថែមជួយការពារពីច្រេះបានទេ។ ការលាយកំហាប់ទឹកស្អុំម៉ាស៊ីនលើសជាង 60% អាចបណ្តាលធ្វើឲ្យទឹកស្អុំម៉ាស៊ីនកក និងមានបញ្ហាដល់ប្រព័ន្ធបញ្ចាះកំដៅ។**

**ទឹកស្អុំម៉ាស៊ីនត្រជាក់ផ្សេងៗ**

ទឹកស្អុំម៉ាស៊ីនផ្សេងទៀតប្រភេទអេទីឡែនគ្លីកូល និងប្រភេទប្រូពីឡែនគ្លីកូល អាចត្រូវបានប្រើប្រាស់ ប្រសិនបើវាបំពេញនូវលក្ខណៈបច្ចេកទេសដូចខាងក្រោម:

- ទឹកស្អុំម៉ាស៊ីនដែលលាយជាមុន ដែលបំពេញនូវលក្ខខណ្ឌចាំបាច់របស់ ASTMD6210
- ត្រូវបានផ្សំរួបមន្តជាមួយនឹងកញ្ចប់សារធាតុបន្ថែមដែលគ្មានសារធាតុនីត្រីត
- កំហាប់ទឹកស្អុំម៉ាស៊ីនដែលបំពេញនូវលក្ខខណ្ឌចាំបាច់របស់ ASTM6210នៅក្នុងល្បាយដែលមានកំហាប់ 40-60% ជាមួយទឹក

ប្រសិនបើទឹកស្អុំម៉ាស៊ីនមិនបំពេញលក្ខណៈបច្ចេកទេសមួយនៃលក្ខណៈបច្ចេកទេសទាំងឡាយ សូមប្រើកំហាប់ទឹកស្អុំម៉ាស៊ីន ឬទឹកស្អុំម៉ាស៊ីនដែលលាយជាមុន ដែលមានលក្ខណៈរូប និងលក្ខណៈគីមី អប្បរមាដូចខាងក្រោម៖

- ផ្តល់ការការពារស្នាមខូងនៅលើទ្រនាប់ស៊ីឡាំងយោងទៅតាមវិធីធ្វើតេស្តតស្នាមខូងឬការសិក្សាដ៏ឆាប់រហ័សរបស់ John Deere ដែលដំណើរការនៅសមត្ថភាពផ្តេកស្មើឬលើស 60%
- ត្រូវបានផ្សំរួបមន្តជាមួយនឹងកញ្ចប់សារធាតុបន្ថែមដែលគ្មានសារធាតុនីត្រីត
- ត្រូវបានផ្សំរួបមន្តជាមួយនឹងកញ្ចប់សារធាតុបន្ថែមដែលគ្មានសារធាតុនីត្រីត
- ការពារលោហៈប្រព័ន្ធបន្តយកម្តៅ (ដែកស្ងួត សំលោហៈអាលុយមីញ៉ូម និងសំលោហៈស្ពាន់លាយស័ង្កសីដូចជាទង់ដែង) ពីការកាត់ស៊ី

**គុណភាពទឹក**

គុណភាពទឹកមានសារៈសំខាន់ចំពោះការអនុវត្តការងាររបស់ប្រព័ន្ធបន្តយកម្តៅ។ គួរប្រើប្រាស់ទឹកចម្រាញ់បំបាត់អ៊ីយ៉ុង ឬបំបាត់ជាតិខណិជ សម្រាប់លាយជាមួយកំហាប់ទឹកថ្នាំស្អុំម៉ាស៊ីនបាសអេទីឡែនគ្លីកុល និងប្រូពីឡែនគ្លីកុល។

**ចន្លោះពេលបង្ហូរទឹកស្អុំម៉ាស៊ីន**

បង្ហូរ និងលាងប្រព័ន្ធបញ្ចាះកំដៅ និងចាក់បំពេញទឹកស្អុំម៉ាស៊ីនថ្មីចូល នៅក្នុងចន្លោះដែលបានកំណត់ ដែលប្រែប្រួលជាមួយនឹងទឹកស្អុំម៉ាស៊ីនដែលបានប្រើ។

នៅពេលដែលគេប្រើប្រាស់ទឹកស្អុំម៉ាស៊ីន COOL-GARD II ឬ COOL-GARD II PG ចន្លោះនៃពេលនៃការបង្ហូរចេញគឺមានរយៈពេល 6ឆ្នាំ ឬ6000ម៉ោងនៃដំណើរការ។

នៅពេលដែលគេប្រើប្រាស់ទឹកស្អុំម៉ាស៊ីនផ្សេងទៀតក្រៅពី COOL-GARD II ឬ COOL-GARD II PG ចន្លោះនៃពេលនៃការបង្ហូរចេញគឺមានរយៈពេល 2ឆ្នាំ ឬ2000ម៉ោងនៃដំណើរការ។[1]

**សំខាន់៖ កុំប្រើសារធាតុបន្ថែមសម្រាប់ភ្ជិតប្រព័ន្ធបន្តយកម្តៅ ឬសារធាតុប្រឆាំងនឹងការកក ដែលផ្តុកសារធាតុបន្ថែមភ្ជិត។**

**កុំលាយទឹកស្អុំសអេទីឡែនគ្លីកុល និងប្រូពីឡែនគ្លីកុល។**

**កុំប្រើធាតុជាក់ដែលផ្តុកសារធាតុនីត្រីត។**

DX,COOL3-KM-25AUG20


## ប្រេងហ្គ្រាំង

ចាក់ប្រេងអ៊ីដ្រូលិកយន្តហោះ 10# ចូលក្នុងធុងស្តុកប្រេងហ្គ្រាំង។

CP00834,0008B2D-KM-11MAR21

*[1] ការវិភាគទឹកថ្នាំស្អុំម៉ាស៊ីនអាចពន្យារយៈពេលសេវាថែទាំ "ទឹកថ្នាំស្អុំម៉ាស៊ីន" ផ្សេងទៀតរហូតដល់កម្រិតអតិបរមាមិនលើសពីបរិមាណនៃទឹកថ្នាំស្អុំម៉ាស៊ីន Cool-Gard II ឡើយ។ ការវិភាគទឹកថ្នាំស្អុំម៉ាស៊ីនមានន័យថាការយកគំរូទឹកថ្នាំស្អុំម៉ាស៊ីនជាបន្តបន្ទាប់ក្នុងរយៈពេល 1000 ម៉ោងលើសពីចន្លោះសេវាកម្មធម្មតារហូតដល់ទីន្នន័យបង្ហាញថាបញ្ចាប់នៃជីវិតទឹកថ្នាំស្អុំម៉ាស៊ីនដែលមានប្រយោជន៍ឬឈានដល់កម្រិតអតិបរិមានៃសេវាថែទាំទឹកថ្នាំស្អុំម៉ាស៊ីន Cool Gardard។*

## ប្រេងអ៊ីដ្រូលីក/អ៊ីដ្រូស្តាទិក




ZX1030848—UN—15SEP02

ប្រើកម្រិតភាពស្អិតខាប់ដោយផ្អែកលើលំដាប់សីតុណ្ហភាពខ្យល់ដែលបានរំពឹងទុកនៅអំឡុងចន្លោះពេលនៃការផ្លាស់ប្តូរប្រេងម៉ាស៊ីនម្តងៗ។

គួរប្រើប្រេងម៉ាស៊ីនខាងក្រោមនេះ៖

- John Deere Hy-Gard™
- ភាពអនុលោមទាប Hy-Gard™John Deere

ប្រេងផ្សេងៗទៀតអាចប្រើប្រាស់បាន ប្រសិនបើវាឆ្លើយតបនឹងចំណុចណាមួយខាងក្រោម៖

- John Deere Standard JDM J20C
- John Deere Standard JDM J20D

CP00834,0008B30-KM-26MAY21

## ប្រេងប្រអប់ស្តីរ៉ូទ័រគ្រឿងបំបែក

ចាក់ប្រេង John Deere Hy-Gard™ ចូលក្នុងប្រអប់ស្តីរ៉ូទ័រគ្រឿងបំបែក។

CP00834,0008B2F-KM-11MAR21


## ប្រេងស្តីកាត់បន្ថយល្បឿនស៊ីឡាំងបោកបែន

ចាក់ប្រេង MOBILITH SHC 007 Grease ចូលក្នុងស្តីបន្ថយល្បឿនស៊ីឡាំងបោកបែន។

cp00834,1666593452957-KM-24OCT22

*Hy-Gard គឺជាពាណិជ្ជសញ្ញារបស់ Deere & Company*

## ប្រេងហ្គ្រែរ




TS1653—UN—14MAR96

កម្រិតរំអិលនៃប្រេងម៉ាស៊ីនសម្រាប់លំដាប់សីតុណ្ហភាពខ្យល់

ប្រើកម្រិតរំអិលលំដាប់សីតុណ្ហភាពខ្យល់ដែលបានរំពឹងទុកនៅអំឡុងចន្លោះពេលនៃការផ្លាស់ប្តូរប្រេងម៉ាស៊ីនម្តងៗ។

គួរប្រើប្រេងម៉ាស៊ីនខាងក្រោមនេះ៖

- ប្រេងម៉ាស៊ីនហ្គ្រែរ John Deere GL-5
- John Deere EXTREME-GARD™

ប្រេងផ្សេងៗទៀតអាចប្រើប្រាស់បាន ប្រសិនបើវាត្រូវនឹងតម្រូវការណាមួយខាងក្រោម៖

- ប្រភេទសេវាកម្ម API នៃ CF-5

DX,GEOIL-KM-14APR11

## ប្រេងប្រអប់ស្តី

ប្រេងស្តី GI-5 80W/90 ប្រើនៅក្នុងទីតាំងដូចតទៅ៖

- ប្រអប់លេខប្រអប់ស្តី
- ដុំអូសទាញខាងចុង
- ភ្លៅអូសកង់ក្រោយ (ជម្រើស)
- គ្រឿងបញ្ជូនខាងចុងអូសកង់ក្រោយ (ជម្រើស)
- ប្រអប់ស្តីអូសកង់ខាងក្រោយ (ជម្រើស)

cp00834,1663051698078-KM-13SEP22

*EXTREME-GARD គឺជានិក្ខិត្តសញ្ញារបស់ Deere & Company*

## ប្រេងពហុបំណង

គួរតែប្រើខ្លាញ់គោដូចតទៅនេះ៖

- ប្រេងរំអិលម៉ូលីដិនីមស៊ុលហ្វីដលីចូម

*កំណត់ចំណាំ៖ សម្រាប់គ្រឿងចក្រច្រូតកាត់ដែលអូសដោយមេកានិក ចូរដាក់ប្រេង Mobil XHP222 លើគ្រឿងខាងក្រោម Posi-Torq™។*

cp00834,1660029171638-KM-09AUG22

## ការរក្សាទុកប្រេងរំអិល

ឧបករណ៍របស់អ្នកអាចប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពខ្ពស់តែនៅពេលណាដែលប្រើប្រាស់ប្រេងរំអិលស្អាតប៉ុណ្ណោះ។

ប្រើសម្ភារផ្ទុកដែលស្អាតក្នុងការរក្សាទុកប្រេងរំអិលទាំងអស់។

រក្សាទុកប្រេងរំអិល និងសម្ភារផ្ទុកនៅកន្លែងដែលត្រូវបានការពារពីធូលី សំណើម និងភាពកខ្វក់ផ្សេងៗ។ រក្សាទុកសម្ភារៈផ្ទុកដោយដាក់ផ្ដៀងដើម្បីជៀសវាងការកកើតឡើងនៃទឹក និងធូលី។

ធ្វើឲ្យប្រាកដថា សម្ភារផ្ទុកទាំងអស់ត្រូវមានគំនូសម្គាល់ចំណុះរបស់វាត្រឹមត្រូវ។

សូមបោះចោលសម្ភារផ្ទុកទាំងអស់ និងប្រេងរំអិលសំណល់ដែលអាចមានផ្ទុកនៅក្នុងនោះឲ្យបានត្រឹមត្រូវ។

DX,LUBST-KM-11APR11

# ជំនួយក្នុងការច្រូតកាត់

## កំណត់ស្ថានភាពដំណាំ

តាមគោលការណ៍គឺត្រូវប្រមូលផលឲ្យបានលឿនតាមដែលអាចធ្វើទៅបាននៅពេលចំណុះសំណើមបានធ្លាក់ចុះដល់កម្រិតដែលអាចទទួលយកបាន។

ការឆាប់ប្រមូលផលបណ្តាលឲ្យបាត់បង់ទិន្នផល និងធ្លាក់ចុះនូវគុណភាព។ គ្រាប់ដែលមិនទាន់ទុំផ្តល់ទិន្នផលតិចជាង និងទម្ងន់ស្រាលជាង។ គ្រាប់ក៏ពិបាកក្នុងការបោកបែនជាងផងដែរដែលបណ្តាលខូចខាតដល់ការបោកបែន និងបោកបែនមិនបានពេញលេញ។

ការយឺតយ៉ាវក្នុងការប្រមូលផលបណ្តាលឲ្យបាត់បង់ដោយសារការរាយប៉ាយគ្រាប់ដំណាំ ដើមដំណាំរីង ដេកដួល និងថយចុះនូវទម្ងន់។ ការបាត់បង់ដោយសារការរាយប៉ាយកើតឡើងដោយសារគ្រាប់ងាយរលេះពេក។

CP00834,0008B43-KM-12MAR21

## កំណត់ការបាត់បង់គ្រាប់ធញ្ញជាតិ

ការបាត់បង់គ្រាប់បណ្តាលមកពីការលៃតម្រូវគ្រឿងចក្រច្រូតកាត់មិនត្រឹមត្រូវ។ ទោះបីជាលៃតម្រូវគ្រឿងចក្រឲ្យកាត់បោកបែន បំបែក និងសម្អាតគ្រាប់ធញ្ញជាតិដែលអាចទទួលយកបានក៏ដោយ ប្រតិបត្តិករគួរពិនិត្យមើលគ្រឿងចក្រច្រូតកាត់ម្តងម្កាលដើម្បីប្រាកដថាវានៅតែប្រតិបត្តិការត្រឹមត្រូវ។

### ប្រភពនៃបាត់បង់គ្រាប់ធញ្ញជាតិ

ការបាត់បង់ខ្លះបណ្តាលមកពីប្រតិបត្តិការមិនត្រឹមត្រូវ និងខ្លះទៀតបណ្តាលមកពីការលៃតម្រូវមិនបានត្រឹមត្រូវ។

ទាំងនេះជាប្រភពនៃការបាត់បង់ដែលប្រតិបត្តិករត្រូវតែកំណត់៖

- **ការបាត់បង់មុនពេលច្រូតកាត់**—ការបាត់បង់មុនពេលច្រូតកាត់គឺជាការបាត់បង់ដែលបានកើតឡើងនៅក្នុងស្រែមុននឹងច្រូតកាត់។ដូចជាបើងដោយសារខ្យល់ ដើមរីង ដំណាំធ្លាក់ ឬស្ថានភាពអាកាសធាតុ។
- **ការបាត់បង់ដោយក្បាលឧបករណ៍កាត់**—ការបាត់បង់ទាំងនេះកើតឡើងនៅពេលប្រតិបត្តិការក្បាលឧបករណ៍កាត់មិនត្រឹមត្រូវឬនៅពេលដំណាំងាយនឹងរាយប៉ាយ។
- **ការបាត់បង់ដោយការបោកបែន**—ការបាត់បង់ដោយការបោកបែនបណ្តាលមកពី៖
  - គ្រាប់ធញ្ញជាតិដែលមិនបានបោកបែនបានរលេះធ្លាក់នៅផ្នែកខាងក្រោយគ្រឿងបំបែក
  - គ្រាប់ប្រេះស្រាំដោយសារបោកបែនខ្លាំងពេក។
  - គ្រាប់ប្រេះស្រាំដោយសារសំឌីច្រើនពេក
- **ការបាត់បង់ដោយសារគ្រឿងបំបែក**—ការបាត់បង់ដោយសារគ្រឿងបំបែកគឺបណ្តាលមកពីការច្រកដើមដំណាំចូលច្រើនពេកពីលើវានៅឡើនស៊ីឡាំងទាបនិងដោយចន្លោះប្រអប់កញ្ជ្រែងទូលាយនៅពេលគ្រឿងចក្រច្រូតកាត់កំពុងប្រតិបត្តិការនៅឡើនលើដីលើនពេក។
- **ការបាត់បង់ដោយសារស្បែកជើងសម្អាត**—ការបាត់បង់នេះអាចបណ្តាលមកពី៖
  - ចេញខ្យល់តាមកង្ហារសម្អាតខ្លាំងពេក។
  - ដើមដំណាំនៅលើធ្មេញកញ្ជ្រែងច្រើនពេក។
  - លៃតម្រូវធ្មេញ និងកន្ត្រងមិនបានត្រឹមត្រូវ
- **ការបាត់បង់ដោយការលេចធ្លាយ**—ការបាត់បង់ដោយការលេចធ្លាយអាចកើតឡើងស្ទើគ្រប់កន្លែងនៅលើគ្រឿងចក្រច្រូតកាត់។ការលេចធ្លាយទាំងអស់ត្រូវតែជួសជុលឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

CP00834,0008B44-KM-12MAR21

## កំណត់សកម្មភាពក្នុងការបោកបែន

**សំខាន់៖ លៃតម្រូវឡើនបោកបែន និងចន្លោះប្រអប់កញ្ជ្រែងរួមគ្នាដើម្បីបោកបែនបានល្អ។**

*កំណត់ចំណាំ៖ នៅពេលច្រូតកាត់ដំណាំដែលមានគ្រាប់ស្អិតជាធម្មតាត្រូវរក្សាឡើនបោកបែនខ្ពស់ និងចន្លោះប្រអប់កញ្ជ្រែងចង្អៀត។*

*នៅពេលច្រូតកាត់ដំណាំដែលមានគ្រាប់ធំ ជាធម្មតាត្រូវរក្សាឡើនបោកបែនទាប និងចន្លោះប្រអប់កញ្ជ្រែងទូលាយ។*

- ឡើនបោកបែន និងចន្លោះប្រអប់កញ្ជ្រែងចង្អៀតជាមួយសកម្មភាពបោកបែនល្អ។ឡើនបោកបែនខ្ពស់ពេក និងចន្លោះប្រអប់កញ្ជ្រែងចង្អៀតពេកជាមួយគ្រាប់ធញ្ញជាតិប្រេះស្រាំច្រើន។
- ឡើនបោកបែនខ្ពស់ និងចន្លោះប្រអប់កញ្ជ្រែងទូលាយជាមួយសកម្មភាពបោកបែនមិនសូវល្អ។ឡើនបោកបែនទាបពេក និងចន្លោះប្រអប់កញ្ជ្រែងទូលាយពេកជាមួយគ្រាប់ធញ្ញជាតិមិនបានបោកបែន។
- **ដំណាំសើម** បង្កើនឡើនបោកបែន និងបន្ថយចន្លោះប្រអប់កញ្ជ្រែង។
- **ដើមដំណាំស្ងួតៈ** បន្ថយឡើនបោកបែន និងបង្កើនចន្លោះប្រអប់កញ្ជ្រែង។

CP00834,0008B45-KM-07MAR22

## កែតម្រូវបញ្ហាបោកបែន

- **ការបោកបែនខ្លាំងជ្រុល**—ព្យាយាមកាត់បន្ថយឡើនបោកបែនត្រឹម5 ភាគរយក្នុងមួយលើក។ ពិនិត្យមើលលទ្ធផលមុននឹងធ្វើការកែប្រែបន្ថែម។ ព្យាយាមបង្កើនចន្លោះបោកបែនបន្តិចប្រសិនបើកាត់បន្ថយឡើនបោកបែន 10 ភាគរយមិនមានប្រយោជន៍ទេនោះ។ ប្រសិនបើការធ្វើដូច្នេះដោះស្រាយបញ្ហាបានចូរបង្កើនចន្លោះប្រអប់កញ្ជ្រែងបន្តិច។ ប្រសិនបើមិនអាចកែតម្រូវការបោកបែនជ្រុលបានតាមវិធានការនេះទេចូរព្យាយាមបន្ថយឡើនលើដី។
- **ការមិនបោកបែន**—ព្យាយាមបង្កើនឡើនបោកបែនចំនួន5 ភាគរយ។ ប្រសិនបើការធ្វើដូច្នេះមិនអាចដោះស្រាយបញ្ហាបានទៀត ចូរបន្ថយចន្លោះប្រអប់កញ្ជ្រែងបន្តិច។ពិនិត្យមើលលទ្ធផលនៃការផ្លាស់ប្តូរទាំងនេះឲ្យបានញឹកញាប់។ ប្រសិនបើការព្យាយាមលៃតម្រូវកម្មភាពបោកបែនទាំងនេះនៅតែមិនមានការប្រែប្រួលទៀតចូរបង្កើនឡើនលើដី។

CP00834,0008B46-KM-07MAR22

## ការកំណត់ដើមដំណាំតាមការណែនាំ

*កំណត់ចំណាំ៖ ទិន្នន័យគឺជាតម្លៃដែលបានណែនាំ។ តម្លៃនេះ ទាមទារការកំណត់ផ្សេងគ្នាបន្តិចដោយផ្អែកលើដំណាំ និងស្ថានភាពវាលស្រែ។*

| ដើមដំណាំ | ល្បឿនស៊ីឡាំងបោកបែន (ជុំ/នាទី)។ | ចន្លោះប្រអប់កញ្ចែង (ម.ម) | ប្រឡោះធ្មេញ (ម.ម) | ប្រឡោះកន្ត្រែង (ម.ម) | ល្បឿនកង្ហារសម្អាត (ជុំ/នាទី) |
|---|---|---|---|---|---|
| ស្រូវសាឡី | 850—1100 | ចន្លោះចូល 7—8 (ការប្រមូលផលដំណាក់កាលដំបូង)<br>ចន្លោះចេញ 4—5 (ការប្រមូលផលដំណាក់កាលដំបូង)<br>ចន្លោះចូល 9—12 (ការប្រមូលផលដំណាក់កាលពាក់កណ្តាលចុងក្រោយ)<br>ចន្លោះចេញ 7—10 (ការប្រមូលផលដំណាក់កាលពាក់កណ្តាលចុងក្រោយ) | 12—17 | 3—7 | 700—1100 |
| ស្រូវ | 500—950 | ចន្លោះចូល 14<br>ចន្លោះចេញ 10 | 14—18 | 5—10 | 700—1100 |
| ពោត | 358—550 | ចន្លោះចូល៖ 30<br>ចន្លោះចេញ៖ 19 | 12—17 | 10—15 | ≥800 |

cp00834,1668731645357-KM-17NOV22

# ការបង្ការអគ្គិភ័យ

## ការបង្ការអគ្គីភ័យតាមការណែនាំ

លោកអ្នកត្រូវតែធ្វើការត្រួតពិនិត្យគ្រឿងចក្រនេះតាមកាលកំណត់ពេញមួយរដូវកាលប្រមូលផល។ គំនរសម្ភារដើមដំណាំ និងកម្ទេចកម្ទីដទៃទៀតត្រូវតែយកចេញ ដើម្បីឲ្យគ្រឿងចក្របំពេញមុខងារបានត្រឹមត្រូវ និងកាត់បន្ថយគ្រោះអគ្គីភ័យ។

ការសម្អាតគ្រឿងចក្របានហ្មត់ចត់និងទៀងទាត់គួបផ្សំនិងទម្រង់ការថែទាំតាមទម្លាប់ដទៃទៀតដែលបានរៀបរាប់នៅក្នុងសៀវភៅណែនាំប្រើប្រាស់នេះ ជួយកាត់បន្ថយគ្រោះអគ្គីភ័យ ឱកាសខូចខាតដែលនាំឲ្យចំណាយប្រាក់កាសច្រើន ហើយជួយបង្កើនប្រសិទ្ធពលរបស់គ្រឿងចក្រ។

ត្រូវគោរពតាមនីតិវិធីសុវត្ថិភាពទាំងអស់ ដែលបានបិទនៅលើគ្រឿងចក្រ និងរៀបរាប់ក្នុងសៀវភៅណែនាំ។ មុនពេលធ្វើការត្រួតពិនិត្យ ឬសម្អាតគ្រឿងចក្រ ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ និងដោះសោចេញ។

គ្រឿងចក្ររបស់លោកអ្នកមានបំពាក់បំពង់ពន្លត់អគ្គីភ័យប្រើម្សៅទូទៅ។ លោកអ្នកត្រូវតែត្រួតពិនិត្យបំពង់ពន្លត់អគ្គីភ័យរាល់ថ្ងៃនៅពេលចូលក្នុង ឬចាកចេញពីកាប៊ីន និងនៅពេលធ្វើការងារជុំវិញគ្រឿងចក្រដើម្បីធានាថាបំពង់ពន្លត់ទាំងអស់អាចប្រើការបាន។ ត្រូវតែប្តូរបំពង់ពន្លត់អគ្គីភ័យចេញ ឬផ្តល់សេវាថែទាំប្រកបដោយជំនាញវិជ្ជាជីវៈនៅរាល់ពេលប្រើរួច។

ដើម្បីជ្រាបនូវព័ត៌មានបន្ថែម ចូរអានផ្នែកលាងសម្អាតគ្រឿងចក្រ។

CP00834,0008B35-KM-11MAR21

## ប្រតិបត្តិការបំពង់ពន្លត់អគ្គីភ័យ




YC4693—UN—03JUL13

គ្រឿងចក្រមានបំពាក់បំពង់ពន្លត់អគ្គីភ័យប្រើម្សៅទូទៅ។ ត្រូវតែត្រួតពិនិត្យបំពង់ពន្លត់អគ្គីភ័យរាល់ថ្ងៃនៅពេលចូលក្នុង ឬចាកចេញពីកាប៊ីន និងនៅពេលធ្វើការងារជុំវិញគ្រឿងចក្រដើម្បីធានាថាបំពង់ពន្លត់ទាំងអស់អាចប្រើការបាន។ ត្រូវតែប្តូរបំពង់ពន្លត់អគ្គីភ័យចេញ ឬផ្តល់សេវាថែទាំប្រកបដោយជំនាញវិជ្ជាជីវៈនៅរាល់ពេលប្រើរួច។

### ការណែនាំអំពីបំពង់ពន្លត់អគ្គីភ័យ

**សំខាន់៖ អានស្លាកសញ្ញានៅលើបំពង់ពន្លត់អគ្គីភ័យ និងស្វែងយល់ពីលំណែនាំនិងបំរាមក្នុងការប្រើប្រាស់វា។**

បំពង់ពន្លត់អគ្គីភ័យប្រើម្សៅទូទៅអាចប្រើប្រាស់បានសម្រាប់អគ្គិភ័យឆាបឆេះប្រេងរំអិល ប្រេង អគ្គិសនី និងគីមី។

### ការប្រើប្រាស់បំពង់ពន្លត់អគ្គីភ័យ៖

ដ្យាក្រាមបង្ហាញពីវិធីដែលបានណែនាំក្នុងការពន្លត់អគ្គីភ័យ។ ជានិច្ចកាល ចូរបាញ់តម្រង់ទៅតួភ្លើង។

ចំណុចដូចតទៅនេះគឺជាជំហានមូលដ្ឋានក្នុងការប្រើប្រាស់បំពង់ពន្លត់អគ្គីភ័យ៖

1. ដោះបំពង់ពន្លត់អគ្គីភ័យចេញពីកែងទម្រ ហើយយកទៅតំបន់មានភ្លើងឆេះ។
2. ចូលទៅកាន់តំបន់អគ្គីភ័យដោយស្ថិតនៅពីលើខ្យល់។
3. ទាញកន្លាស់សុវត្ថិភាពចេញពីផ្នែកខាងលើបំពង់ពន្លត់អគ្គីភ័យចេញ។
4. កាន់ដងបំពង់ពន្លត់អគ្គីភ័យបញ្ឈរ ហើយតម្រង់ទុយោឲ្យចំ **គួ** នៃអណ្តាតភ្លើង។
5. ច្របាច់ដងដើម្បីបាញ់បំពង់ពន្លត់អគ្គីភ័យ។
6. រំកិលក្បាលបាញ់ទៅមុខនិងទៅក្រោយ ដោយស្រោចពពុះម្សៅលើអណ្តាតភ្លើង។

### បញ្ជីផ្ទៀងផ្ទាត់ត្រួតពិនិត្យ៖

ត្រួតពិនិត្យបំពង់ពន្លត់អគ្គិភ័យយ៉ាងតិចម្តងក្នុងមួយខែដើម្បីធានាដូចតទៅ៖

1. តើបំពង់ពន្លត់អគ្គីភ័យដាក់នៅត្រង់ទីតាំងកំណត់នៅលើជណ្តើរកាប៊ីនដែរឬទេ?
2. តើមានអ្វីទើសទែងក្នុងការលូកយក ឬជាំងមើលមិនឃើញទេ?
3. តើលំណែនាំប្រើប្រាស់នៅលើស្លាកឈ្មោះអាចអានដាច់និងបែរចេញក្រៅទេ?
4. តើហ្វឹតសុវត្ថិភាពមានបែកបាក់ ឬបាត់បង់ទេ?
5. តើបំពង់ពន្លត់អគ្គីភ័យពេញឬទេ? (កំណត់ដឹងដោយការថ្លឹង ឬ"ថ្លឹងមើល")
6. តើមានការខូចខាតរូបរាង ការសឹករេចរឹល ការលេចធ្លាយ ឬក្បាលបាញ់ស្ទះទេ?

នៅពេលពិនិត្យបំពង់ពន្លត់អគ្គីភ័យឃើញមានបញ្ហា ចូរផ្តល់សេវាថែទាំ ឬប្តូរចោល។

CP00834,0008B3C-KM-12MAR21

## គ្រប់គ្រង និងចាត់ចែងធាតុរាវដោយសុវត្ថិភាព—ជៀសវាងអគ្គីភ័យ



TS227—UN—15APR13

នៅពេលអ្នកធ្វើការនៅជុំវិញប្រេងឥន្ធនៈ កុំដក់បារី ឬធ្វើការនៅជិតគ្រឿងកម្តៅ ឬគ្រោះថ្នាក់អគ្គីភ័យផ្សេងៗ។


រក្សាធាតុរាវដែលងាយឆាបឆេះនៅឆ្ងាយពីគ្រោះថ្នាក់អគ្គីភ័យ។ កុំដុតរំលាយ ឬចាក់ទម្លុះកំប៉ុងដែលបានបញ្ចូលសម្ពាធ។

ធ្វើឱ្យប្រាកដថា គ្រឿងចក្រគ្មានសំរាម ខ្លាញ់គោ និងកំទេចកំទី។

កុំរក្សាទុកកន្ទបជូតប្រេង វាអាចឆាបឆេះដោយឯកឯង។

DX,FLAME-KM-29SEP98

## ត្រៀមសម្រាប់គ្រោះអាសន្ន



TS291—UN—15APR13

ត្រូវមានការត្រៀមខ្លួន ប្រសិនបើអគ្គីភ័យចាប់ផ្តើមឡើង។

រក្សាទុកប្រអប់សង្គ្រោះបឋម និងបំពង់ពន្លត់អគ្គីភ័យនៅជិតខ្លួន។

រក្សាទុកលេខទូរស័ព្ទដែលត្រូវប្រើនៅគ្រាមានអាសន្នដូចជា រថយន្តពន្លិត សេវារថគិលានសង្គ្រោះ មន្ទីរពេទ្យ និងផ្ទៃកពន្លត់អគ្គីភ័យនៅជិតទូរស័ព្ទរបស់អ្នក។

DX,FIRE2-KM-03MAR93

## សម្អាតកម្ទេចកម្ទីដើមដំណាំដែលកកកុញ



TS227—UN—15APR13

គំនរអំពុកចំបើងនៅក្នុងបន្ទប់ម៉ាស៊ីន នៅលើម៉ាស៊ីន និងនៅជិតគ្រឿងមានចលនាអាចបង្ករជាអគ្គីភ័យ។ ចូរពិនិត្យ និងសម្អាតតំបន់ទាំងនេះឱ្យបានញឹកញាប់។ មុនពេលត្រួតពិនិត្យនិងផ្តល់សេវាថែទាំ ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ និងដកសោចេញ។

CP00834,0008B37-KM-11MAR21

## ទីតាំងបំពង់ពន្លត់អគ្គីភ័យ



YC21131—UN—17NOV22

គ្រឿងចក្រមានបំពាក់បំពង់ពន្លត់អគ្គីភ័យប្រើម្សៅទូទៅ។

បំពង់ពន្លត់អគ្គីភ័យស្ថិតនៅលើផ្លែតហូមជណ្តើរខាងខ។

cp00834,1668731944351-KM-17NOV22

## ករណីមានអគ្គីភ័យ



TS227—UN—15APR13

**⚠ ប្រយ័ត្ន៖ ជៀសវាងគ្រោះថ្នាក់ដល់ខ្លួនឯងនិង មនុស្សដទៃ។**

ត្រូវពន្លត់ម៉ាស៊ីនជាបន្ទាន់ នៅពេលឃើញមានសញ្ញាដំបូង នៃអគ្គីភ័យ។ អគ្គីភ័យអាចសម្គាល់ដោយក្លិនឈ្ងៀម ផ្សែង ឬឃើញមានអណ្តាតភ្លើង។ ដោយសារតែភ្លើង ឆេះ និងរាលដាលឆាប់រហ័ស ត្រូវចុះពីក្រាក់ទ័រជាបន្ទាន់ ហើយរត់ទៅទីសុវត្ថិភាពចេញពីអគ្គីភ័យ។ កុំត្រឡប់ទៅរក ក្រាក់ទ័រវិញ! អាទិភាពជាចម្បងគឺ សុវត្ថិភាព។

ហៅទូរស័ព្ទទៅកាន់អ្នកពន្លត់អគ្គីភ័យ។ បំពង់ពន្លត់ អគ្គីភ័យខ្នាតតូច (យកតាមខ្លួនបាន) អាចពន្លត់ភ្លើងដែល ឆេះតិចតួច ឬបង្ក្រាបអគ្គីភ័យរហូតដល់ពេលអ្នកពន្លត់ អគ្គីភ័យមកដល់; ប៉ុន្តែសមត្ថភាពបំពង់ពន្លត់អគ្គីភ័យខ្នាត តូចគឺមានកម្រិត។ ជានិច្ចកាលត្រូវផ្តល់អាទិភាពជាចម្បង ទៅលើសុវត្ថិភាពអ្នកបើកបរ និងអ្នកនៅក្បែរ។ ប្រសិនបើព្យាយាមពន្លត់អគ្គីភ័យ អ្នកត្រូវឈរនៅលើ ខ្សាល់ ហើយត្រូវមានផ្លូវសម្រាប់រត់គេចដែលគ្មានឧបសគ្គ ដើម្បីឲ្យអ្នកអាចរត់ចេញបានឆាប់រហ័ស ប្រសិនបើពុំអាច ពន្លត់អគ្គីភ័យបាន។

សូមអានសេចក្តីណែនាំអំពីបំពង់ពន្លត់អគ្គីភ័យ និងដឹង ច្បាស់អំពីទីតាំងទុកបំពង់ និងរបៀបប្រើប្រាស់វាឲ្យបានមុន ពេល ដែលមានអគ្គីភ័យ។ នាយកដ្ឋានពន្លត់អគ្គីភ័យ ឬ អ្នកចែកចាយឧបករណ៍ពន្លត់អគ្គីភ័យក្នុងមូលដ្ឋាន អាច ផ្តល់ការបណ្តុះបណ្តាល និងការណែនាំអំពីរបៀបប្រើប្រាស់ បំពង់ពន្លត់អគ្គីភ័យ។

ប្រសិនបើបំពង់ពន្លត់អគ្គីភ័យរបស់អ្នកពុំមាន សេចក្តីណែនាំទេនោះ សូមគោរពតាមគោលការណ៍ទូទៅ ទាំងនេះ៖

1. ទាញម្ជុលគន្លឹះ។ កាន់បំពង់ពន្លត់អគ្គីភ័យ ដោយ ក្បាលទុយោពន្លត់តម្រង់ចេញឆ្ងាយពីអ្នកហើយដកគន្លឹះ សោរ។
2. តម្រង់ឲ្យទាប។ តម្រង់ក្បាលពន្លត់អគ្គីភ័យឲ្យចំនុចផ្តើម ភ្លើង។
3. ច្របាច់ដៃជាញ់របស់បំពង់ យឺតៗនិងឲ្យស្មើដៃ។
4. រក្សាលទុយោពន្លត់ពីម្ខាងទៅម្ខាង។

DX,FIRE4-KM-22AUG13

# ការសម្អាតគ្រឿងចក្រ

## ល់ណែនាំពីការសម្អាតទូទៅ

លោកអ្នកត្រូវតែធ្វើការត្រួតពិនិត្យគ្រឿងចក្រនេះតាមកាលកំណត់ពេញមួយថ្ងៃធ្វើការ។ គំនរសម្ភារដើមដំណាំ និងកម្ទេចកម្ទីដទៃទៀតត្រូវតែយកចេញ ដើម្បីឲ្យគ្រឿងចក្របំពេញមុខងារបានត្រឹមត្រូវ និងកាត់បន្ថយគ្រោះអគ្គីភ័យ។

ភាពញឹកញាប់នៃការត្រួតពិនិត្យនិងការសម្អាតនឹងប្រែប្រួលអាស្រ័យទៅលើកត្តាមួយចំនួន ដែលរួមមានលក្ខខណ្ឌប្រតិបត្តិការ ការកំណត់គ្រឿងចក្រ លក្ខខណ្ឌដើមដំណាំ ល្បឿនប្រតិបត្តិការ និងលក្ខខណ្ឌអាកាសធាតុ។ ការត្រួតពិនិត្យនិងការសម្អាតអាចត្រូវការធ្វើឡើងច្រើនដងនៅក្នុងរដូវប្រមូលផល ជាពិសេសនៅពេលអាកាសធាតុស្ងួត ក្តៅ ហើយមានខ្យល់។

**សំខាន់៖ ការសម្អាតគ្រឿងចក្របានហ្មត់ចត់និងទៀងទាត់គួបផ្សំនិងទម្រង់ការថែទាំតាមទម្លាប់ដទៃទៀតដែលបានរៀបរាប់នៅក្នុងសៀវភៅណែនាំប្រើប្រាស់នេះ ជួយកាត់បន្ថយគ្រោះអគ្គីភ័យ ឱកាសខូចខាតដែលនាំឲ្យចំណាយប្រាក់កាសច្រើន ហើយជួយបង្កើនប្រសិទ្ធពលរបស់គ្រឿងចក្រ។**

**សម្ភារដើមដំណាំនិងកម្ទេចកម្ទីដទៃទៀតអាចកកនៅក្នុងកន្លែងផ្សេងៗ។ ទិសដៅខ្យល់ ប្រភេទដើមដំណាំ និងចំណុះសំណើមដើមដំណាំ អាចប៉ះពាល់ដល់ទីកន្លែងនិងបរិមាណដែលសម្ភារដើមដំណាំនិងកម្ទេចកម្ទីអាចកកកុញលើគ្រឿងចក្រ។ សូមយល់ដឹងពីស្ថានភាពច្រូតកាត់ និងកែតម្រូវកាលវិភាគសម្អាតរបស់អ្នក ដើម្បីប្រាកដថាមុខងារគ្រឿងចក្រដំណើរការត្រឹមត្រូវ និងដើម្បីកាត់បន្ថយពិហានីភ័យដោយអគ្គីភ័យ។ ពិនិត្យនិងសម្អាតតំបន់ទាំងនេះតាមចាំបាច់ពេញមួយថ្ងៃច្រូតកាត់។**

**ការសម្អាតតាមតំបន់៖**

- បន្ទប់ម៉ាស៊ីន
- ប្រព័ន្ធបញ្ចេះកម្តៅម៉ាស៊ីន
- ធុងប្រេងឥន្ធនៈ
- កង្ហារសម្អាត
- ឧបករណ៍បំបែក
- ប្រអប់លេខប្រអប់ស្តី

**សំខាន់៖ តំបន់ទាំងនេះអាចតម្រូវឲ្យសម្អាតញឹកញាប់សូម្បីតែច្រើនដងក្នុងមួយថ្ងៃក៏ដោយ ដោយអាស្រ័យលើស្ថានភាពច្រូតកាត់។ សូមយល់ដឹងពីស្ថានភាពច្រូតកាត់ និងកែតម្រូវកាលវិភាគសម្អាតរបស់អ្នក ដើម្បីប្រាកដថាមុខងារគ្រឿងចក្រដំណើរការត្រឹមត្រូវ និងដើម្បីកាត់បន្ថយពិហានីភ័យដោយអគ្គីភ័យ។**


**តំបន់ផ្សេងៗទៀតដែលមិនមាននៅក្នុងផ្នែកនេះក៏អាចប្រមូលកម្ទេចកម្ទីដំណាំបានផងដែរ ហើយត្រូវតែសម្អាតតាមពេលកំណត់ ដើម្បីមុខងារ និងរូបរាងគ្រឿងចក្រ។ ត្រួតពិនិត្យដោយយកចិត្តទុកដាក់ចំពោះគ្រឿងចក្រទាំងឲ្យបានទៀងទាត់ពេញមួយរដូវច្រូតកាត់។**

តំបន់ទាំងនេះនៅលើគ្រឿងចក្រទាមទារការពិនិត្យនិងសម្អាតឲ្យបានទៀងទាត់។ នៅពេលមានផ្នែកផ្សេងដែលតម្រូវឲ្យសម្អាតយ៉ាងទៀងទាត់ ជារឿយៗយកចិត្តទុកលើតំបន់ទាំងនេះដែលផ្តល់ផលប៉ះពាល់ធំបំផុតអំពីការពារអគ្គីភ័យ។

ត្រូវគោរពតាមនីតិវិធីសុវត្ថិភាពទាំងអស់ ដែលបានបិទនៅលើគ្រឿងចក្រ និងរៀបរាប់ក្នុងសៀវភៅណែនាំ។ មុនពេលធ្វើការត្រួតពិនិត្យ ឬសម្អាតគ្រឿងចក្រ ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ និងដោះសោបញ្ឆោះចេញ។

cp00834,1663048433758-KM-13SEP22


## សម្អាតបន្ទប់ម៉ាស៊ីន



YC21133—UN—17NOV22

បន្ទប់ម៉ាស៊ីន (តំបន់ខាងលើ)

សម្អាតតំបន់ផ្នែកខាងលើបន្ទប់ម៉ាស៊ីនឲ្យបានហ្មត់ចត់ដោយប្រើខ្យល់សម្អាត។




YC21132—UN—17NOV22

បន្ទប់ម៉ាស៊ីន (តំបន់ខាងក្រោម)

បើកទ្វារច្រកចូលនៅក្នុងធុងគ្រាប់ធញ្ញជាតិ សម្អាតតំបន់ខាងក្រោមបន្ទប់ម៉ាស៊ីនដោយប្រើខ្យល់សម្អាតឲ្យបានញឹកញាប់។

cp00834,1668733657460-KM-17NOV22


## សម្អាតប្រព័ន្ធបញ្ចុះកម្តៅម៉ាស៊ីន




YC21163—UN—18NOV22

**A—ក្បាលឡោស៊ីមួលដោយម្រាមដៃ (ប្រើ 2)**
**B—តម្រងសំណាញ់វិល**
**C—ខ្សែពានអូស**
**D—ប៉ូលី**


1. បើករបាំងការពារចំហៀងខាងស្តាំដៃ
2. បន្ធូរ និងដោះខ្សែពានអូស (C) ចេញពីប៉ូលី (D)។




YC21164—UN—18NOV22

**E—គម្រប**
**F—ប៊ូឡុង (ប្រើ 2)**
**G—ប៊ូឡុង (ប្រើ 10)**
**H—គម្រប**

3. ដោះប៊ូឡុង (F) និងគម្រប (E) ចេញ។
4. ដោះប៊ូឡុង (G) និងគម្រប (H) ចេញ។




YC21165—UN—18NOV22

**I—ប៊ូឡុង (ប្រើ 2)**

5. បន្ធូរក្បាលឡោស៊ីមួលដោយម្រាមដៃ (A)។
6. ដោះប៊ូឡុង (I), វីស័រ និងក្បាលឡោស៊ី។
7. លើក ហើយដោះសំណាញ់វិល (B)។
8. សម្អាតធុងទឹកម៉ាស៊ីនដោយប្រើខ្យល់សម្ពាធផ្លុំបញ្ចេញពីផ្នែកខាងក្នុងទៅខាងក្រៅ។

**សំខាន់៖ នៅពេលប្រើខ្យល់បង្ហាប់បាញ់សម្អាត ប្រយ័ត្នក្រែងលោខូចព្រុយត្រជាក់។**

cp00834,1668747307380-KM-17NOV22


## សម្អាតធុងឥន្ធនៈ

សម្អាតតំបន់ជុំវិញធុងឥន្ធនៈឲ្យបានស្អាតល្អ។



YC6693—UN—14MAY14

ធុងឥន្ធនៈ (តំបន់ផ្នែកខាងលើ)



YC6672—UN—12MAY14

ធុងឥន្ធនៈ (តំបន់ខាងក្រោម)



YC6694—UN—14MAY14

ធុងឥន្ធនៈ (តំបន់ខាងក្រោម)





YC6682—UN—14MAY14

ធុងឥន្ធនៈ (តំបន់ខាងក្រោម)

cp00834,1668733369929-KM-17NOV22

## សម្អាតកង្ហារសម្អាត

សម្អាតតំបន់ជុំវិញកង្ហារសម្អាតនៅចំហៀងសងខាងគ្រឿងចក្រឲ្យបានស្អាតល្អ



YC16921—UN—15MAR21

កង្ហារសម្អាត(ចំហៀងខាងឆ្វេងដៃ)

CP00834,0008BD2-KM-29AUG21


## សម្អាតឧបករណ៍បំបែក



YC6674—UN—13MAY14

ប្រអប់ស្តី

សម្អាតតំបន់ជុំវិញប្រអប់ស្តីឲ្យបានស្អាតល្អ។



YC8893—UN—07JUL15

រ៉ូទ័រគ្រឿងបំបែក

សម្អាតតំបន់ជុំវិញរ៉ូទ័រគ្រឿងបំបែកឲ្យបានស្អាតល្អ។



YC6676—UN—13MAY14

ឧបករណ៍បំបែក (តំបន់ផ្នែកខាងលើ)

បើកទ្វារច្រកចូលនៅផ្នែកខាងលើគ្រឿងចក្រ សម្អាតតំបន់ផ្នែកខាងលើឧបករណ៍គ្រឿងបំបែកឲ្យបានស្អាតល្អ។



YC17749—UN—23JUN21

ឧបករណ៍បំបែក *(តំបន់ផ្នែកខាងក្រោម)*

បើកទ្វារច្រកចូលនៅផ្នែកខាងលើស្បែកជើងសម្អាត សម្អាតតំបន់ផ្នែកខាងក្រោមឧបករណ៍គ្រឿងបំបែកឱ្យបានស្អាតល្អ។

cp00834,1668733049256-KM-17NOV22

## សម្អាតប្រអប់លេខប្រអប់ស្តី

សម្អាតតំបន់ជុំវិញប្រអប់លេខប្រអប់ស្តីឱ្យបានស្អាតល្អ។




YC16920—UN—15MAR21

cp00834,1662712782284-KM-09SEP22


# ការដាក់ប្រេងរំអិលនិងការថែទាំ

## ទីតាំងរូបសញ្ញាដាក់ប្រេងរំអិល



YC21137—UN—21DEC22

រូបសញ្ញាដាក់ប្រេងរំអិលខាងឆ្វេងដៃ




YC21136—UN—21DEC22

រូបសញ្ញាដាក់ប្រេងរំអិលខាងស្តាំដៃ

cp00834,1668737033965-KM-17NOV22


## សញ្ញាដាក់ប្រេងរំអិល

**សំខាន់៖ ចន្លោះពេលផ្តល់សេវាតាមការណែនាំ គឺសម្រាប់លក្ខខណ្ឌមធ្យម។ ផ្តល់សេវាឱ្យបានញឹកញាប់ជាងនេះប្រសិនបើគ្រឿងចក្រត្រូវដំណើរការក្រោមលក្ខខណ្ឌមិនអំណោយផល។**



YC21134—UN—17NOV22

រូបសញ្ញាដាក់ប្រេងរំអិល (ចំហៀងខាងឆ្វេងគ្រឿងចក្រ បានបង្ហាញគ្រឿងចក្រថ្លុតប្រដាប់បញ្ចេកពេញ)




YC21135—UN—21DEC22

រូបសញ្ញាដាក់ប្រេងរំអិល (ចំហៀងខាងស្តាំគ្រឿងចក្រ បានបង្ហាញគ្រឿងចក្រច្រូតប្រដាប់បញ្ចេកពេញ)

cp00834,1668736359445-KM-21NOV22

## តារាងចន្លោះពេលដាក់ប្រេងរំអិល និងការថែទាំ

*កំណត់ចំណាំ៖ ផ្តល់សេវាថែទាំគ្រឿងចក្រនៅចន្លោះពេលដែលមានបង្ហាញនៅក្នុងតារាងនេះ។ លើសពីនេះទៀត ចូរផ្តល់សេវាលើធាតុមួយចំនួនតាមសេចក្តីតម្រូវដើមជាច្រើនដងដែរ។ ឧទាហរណ៍៖ នៅចន្លោះពេលរាល់ 200 ម៉ោង, លើសពីនេះ ចូរផ្តល់សេវាថែទាំធាតុទាំងនោះដែលមានរៀបរាប់ដងដែរនៅរាល់ 10 ម៉ោង (រាល់ថ្ងៃ), រាល់ 50 ម៉ោង និងរាល់ 100 ម៉ោង។*

| ធាតុ | រាល់ 10 ម៉ោង | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| (ប្រចាំថ្ងៃ) | (មួយឆ្នាំ) | រៀងរ-ាល់ 50 ម៉ោង ម្តង | រាល់ 100 ម៉ោង | រាល់ 200 ម៉ោង | រាល់រដូវ | រាល់ 375 ម៉ោង | រាល់ 400 ម៉ោ-ង | រាល់ 500 ម៉ោ-ង | | | | |
| រាល់ 800 ម៉ោង | | | | | | | | | | រាល់ 1000 ម៉ោ-ង (ពីរឆ្នាំ) | រាល់ 1600 ម៉ោ-ង | រាល់ 3000 ម៉ោង (៣ឆ្នាំ) |
| ដាក់ប្រេងរំអិលក្បាលតំណនៅត្រង់ប៉ូលីកណ្តាលអូសគ្រឿងប៉ះបែក | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់បាដាងកាំបិតចិញ្ចាំដើមដំណាំ | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ប៉ូលីអូសស៊ីឡាំងបោកបែន | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ប៉ូលីស៊ីឡាំងបោកបែន | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ប៉ូលីអូសឈ្នឿនប្រែប្រួលកង្ហារសម្អាតស៊ីឡាំងបោកបែន | • | | | | | | | | | | | |

| ធាតុ | រាល់ 10 ម៉ោង | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| (ប្រចាំថ្ងៃ) | (មួយឆ្នាំ) | រៀងរៀងរាល់ 50 ម៉ោង ម្តង | រាល់ 100 ម៉ោង | រាល់ 200 ម៉ោង | រាល់រដូវ | រាល់ 375 ម៉ោង | រាល់ 400 ម៉ោង | រាល់ 500 ម៉ោង | | | | |
| រាល់ 800 ម៉ោង | | | | | | | | | | រាល់ 1000 ម៉ោង (ពីរឆ្នាំ) | រាល់ 1600 ម៉ោង | រាល់ 3000 ម៉ោង (៣ឆ្នាំ) |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ប៉ូលីល្បឿនប្រែប្រួលកង្ហារសម្អាតស៊ីឡាំងបោកបែន | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលត្រង់តំណសកលប្រអប់ស្តីគ្រឿងប៉ប៉ែក | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់តំណឃ្លីស៊ីឡាំងចង្កូត | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់តំណឃ្លីដងចង្កូត | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលត្រង់ស្នូលទម្រក្លៅក្រោយ | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលគ្រឿងលើត្រង់ Posi-Torq™ (ការអូសមេកានិក) | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលរីស័រគ្រឿងក្រោមត្រង់ Posi-Torq™ (ការអូសមេកានិក) | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលកង់វិលរាងលយចេញពាក់កណ្តាលគ្រឿងក្រោមត្រង់ Posi-Torq™ (ការអូសមេកានិក) | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលលើក្បាលតំណត្រង់ជាដាងសម្បកជាតុចូលអូសឌី (ការអូសដោយមេកានិក) | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលលើក្បាលតំណត្រង់ផ្នែកបង្រួមប្រដាប់បួងទម្លាក់៖ | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលច្រវាក់អូសប្រដាប់យោងគ្រាប់ស្កក | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលច្រវាក់អូសស្បែកជើងសម្អាត | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលច្រវាក់អូសប្រដាប់បួងគ្រាប់ស្កផ្នែកខាងលើ | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលគ្រឿងរុញទម្លាក់និងច្រវាក់អូសប្រដាប់បួងខ្វែង | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលច្រវាក់អូសប្រដាប់បួងគ្រាប់ស្កផ្នែកខាងលើ | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលច្រវាក់អូសប្រដាប់បួងទម្លាក់ | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលច្រវាក់អូសប្រដាប់វាយពីលើ | • | | | | | | | | | | | |
| ពិនិត្យ និងលៃតម្រូវតំណឹងច្រវាក់អូសមាត់ច្រកបួងចូល | • | | | | | | | | | | | |
| សម្អាតស្បែតម្រងខ្យល់ទីមួយ | • | | | | | | | | | | | |
| សម្អាតធុងទឹកម៉ាស៊ីន | • | | | | | | | | | | | |
| សម្អាតតម្រងសំណាញ់រំលិ | • | | | | | | | | | | | |
| ពិនិត្យ និងចាក់កប្រេងថ្ម | • | | | | | | | | | | | |
| ពិនិត្យ និងសម្អាតខ្ទះគ្រាប់ធញ្ញជាតិខាងមុខ | • | | | | | | | | | | | |
| ពិនិត្យមើលស្ថានភាពសម្បកកង់។ | • | | | | | | | | | | | |
| ពិនិត្យ និងលៃតម្រូវចន្លោះអំជ្រាយ៉ា (ការអូសដោយមេកានិក) | • | | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ដងបញ្ឈរស្នូលទម្រក្លៅក្រោយ | | • | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ប្រដាប់ | | • | | | | | | | | | | |

| ធាតុ | រាល់ 10 ម៉ោង | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| (ប្រចាំថ្ងៃ) | (មួយឆ្នាំ) | រៀងរ-ាល់ 50 ម៉ោង ម្តង | រាល់ 100 ម៉ោង | រាល់ 200 ម៉ោង | រាល់រដូវ | រាល់ 375 ម៉ោង | រាល់ 400 ម៉ោ-ង | រាល់ 500 ម៉ោ-ង | | | | |
| រាល់ 800 ម៉ោង | | | | | | | | | | រាល់ 1000 ម៉ោ-ង (ពីរឆ្នាំ) | រាល់ 1600 ម៉ោ-ង | រាល់ 3000 ម៉ោង (៣ឆ្នាំ) |
| បន្ទឹងខ្សែពានអូសភ្ជាប់គ្រឿងបំបែក និងទម្រប្រដាប់បន្ទឹងខ្សែពាន | | | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ទម្រភ្ជាប់គ្រឿងបំបែក | | • | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ទម្រស្នប់បូមអ៊ីដ្រូលីក | | • | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ទម្រប្រដាប់បន្ទឹងខ្សែពានអូសកាំបិតចិញ្ចាំដើមដំណាំ | | • | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណនៅត្រង់ទម្របូលីកណ្តាលអូសគ្រឿងបំបែក | | • | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណនៅត្រង់ទម្រប្រដាប់បន្ទឹងខ្សែពានអូសប៉ូលីកណ្តាលអូសគ្រឿងបំបែក | | • | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ជាដាងស្តួលក្តៅក្រោយ (ដុំអូសកង់ក្រោយជាជម្រើស) | | • | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ទម្រប្រដាប់បន្ទឹងខ្សែពានអូសប្រដាប់វាយ | | • | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ទម្រប្រដាប់បន្ទឹងខ្សែពានអូសប្រព័ន្ធសម្អាត | | • | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ទម្រប្រដាប់បន្ទឹងច្រវាក់អូសស្បែកជើងសម្អាត | | • | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ទម្រគ្រឿងលើត្រង់ Posi-Torq™ (ការអូសមេកានិក) | | • | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់ទម្របំបូលីស្នប់បូមអ៊ីដ្រូស្តាទិក (ការអូសដោយអ៊ីដ្រូស្តាទិក) | | • | | | | | | | | | | |
| ដាក់ប្រេងរំអិលក្បាលតំណត្រង់តំណសកលប្រដាប់បួងទម្លាក់ | | • | | | | | | | | | | |
| សម្អាតតម្រងខ្យល់ | | • | | | | | | | | | | |
| ពិនិត្យ និងលៃតម្រូវចន្លោះគ្រឿងខាងក្រោម Posi-Torq™ (ការអូសដោយមេកានិក) | | • | | | | | | | | | | |
| ពិនិត្យនិងលៃតម្រូវប្រវែងខ្សែក្តឹង | | • | | | | | | | | | | |
*កំណត់ចំណាំ៖ ផ្តល់សេវាថែទាំគ្រឿងចក្រនៅចន្លោះពេលដែលមានបង្ហាញនៅក្នុងតារាងនេះ។ លើសពីនេះទៀត ចូរផ្តល់សេវាលើធាតុមួយចំនួនតាមសេចក្តីតម្រូវដើមជាច្រើនដងដែរ។*

| រាល់ 1000 ម៉ោងសេវា (ពីរឆ្នាំ) |
|---|
| ប្តូរបាដងគ្រឿងបំបែកខាងមុខ (សម្រាប់ទីផ្សារចិន) |


cp00834,1669017311558-KM-21NOV22

## ប្តូរបាដងគ្រឿងបំបែកខាងមុខ (សម្រាប់ទីផ្សារចិន)

| ចន្លោះពេលផ្តល់សេវា | រាល់ 1000 ម៉ោង (ពីរឆ្នាំ)* |
|---|---|

*ប្តូរបាដងគ្រឿងបំបែកខាងមុខរាល់ 1000 ម៉ោង ឬពីរឆ្នាំ ទោះជាមួយណាដល់មុនក៏ដោយ។

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**




YC16790—UN—08FEB21

**A—ជាដងគ្រឿងបំបែកខាងមុខ។**

1. បិទកុងតាក់ផ្តាច់អាគុយ។
2. រំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងសេវាថែទាំ។ (អានអំពីការរំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងផ្តល់សេវាថែទាំនៅក្នុងផ្នែកនេះ។)
3. ប្តូរបាដងគ្រឿងបំបែកខាងមុខ (A) ។
4. ត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារ។ (អានអំពីការត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារនៅក្នុងផ្នែកនេះ។)

cp00834,1669017329766-KM-21NOV22

# ការដាក់ប្រេងរំអិល និងការថែទាំ—រាល់ 1600 ម៉ោង

## តារាងថែទាំ— រាល់ 1600 ម៉ោង

*កំណត់ចំណាំ៖ ផ្តល់សេវាថែទាំគ្រឿងចក្រនៅចន្លោះពេលដែលមានបង្ហាញនៅក្នុងតារាងនេះ។ លើសពីនេះទៀត ចូរផ្តល់សេវាលើធាតុមួយចំនួនតាមសេចក្តីតម្រូវដើមជាច្រើនផងដែរ។*

| រាល់ 1600 ម៉ោងសេវា |
| --- |
| ប្តូរប្រេងភ្លៅអូសកង់ក្រោយ (ជម្រើស)<br>(អានផ្នែកសេវាអំឡុងពេលរំដាស់) |

CP00834,0008E58-KM-18AUG21

# ការដាក់ប្រេងរំអិល និងការថែទាំ—រាល់ 3000 ម៉ោង (បីឆ្នាំ)

## តារាងថែទាំ— រាល់ 3000 ម៉ោង (បីឆ្នាំ)

*កំណត់ចំណាំ៖ ផ្តល់សេវាថែទាំគ្រឿងចក្រនៅចន្លោះពេលដែលមានបង្ហាញនៅក្នុងតារាងនេះ។*

| រាល់ 3000 ម៉ោងសេវា (៣ ឆ្នាំ) |
|---|
| លាងសម្អាត និងចាក់ប្រេងបំពេញប្រព័ន្ធបញ្ចុះកម្តៅម៉ាស៊ីន |

cp00834,1668848092403-KM-19NOV22

## លាងសម្អាត និងចាក់ប្រេងបំពេញប្រព័ន្ធបញ្ចុះកម្តៅម៉ាស៊ីន

| ចន្លោះពេលផ្តល់សេវា | រាល់ 3000 ម៉ោង (៣ ឆ្នាំ)* |
|---|---|

*លាងសម្អាត និងចាក់ទឹកថ្នាំស្អំម៉ាស៊ីនចូលប្រព័ន្ធបញ្ចុះកម្តៅម៉ាស៊ីនរាល់ 3000 ម៉ោង ឬបីឆ្នាំ ទោះជាមួយណាដល់មុនក៏ដោយ។

*កំណត់ចំណាំ៖ COOL-GARD™ គឺជាទឹកថ្នាំស្អំម៉ាស៊ីនដែលគួរប្រើ។ ចន្លោះពេលបង្ហូរអាចពន្យាររហូតដល់ 5000 ម៉ោង ឬ 60 ខែ ប្រសិនបើធ្វើតេស្តទឹកថ្នាំស្អំម៉ាស៊ីនរាល់ឆ្នាំ និងថែមសារធាតុបន្ថែមតាមចាំបាច់ ដោយថែមសារធាតុបន្ថែមលើទឹកថ្នាំស្អំម៉ាស៊ីន (SCA)។*

*ប្រសិនបើមិនប្រើប្រាស់ COOL-GARD™ ទេនោះ ចន្លោះពេលបង្ហូរទឹកថ្នាំស្អំម៉ាស៊ីនត្រូវបន្តយមកត្រឹមពីរឆ្នាំ ឬ 2000 ម៉ោងប្រតិបត្តិការ។*


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**

**⚠ ប្រយ័ត្ន៖ ដោះគម្របចាក់ប្រេងធុងខ្ចោលតែនៅពេលវាត្រជាក់ល្មមដែលអាចប៉ះបានដោយដៃទទេប៉ុណ្ណោះ។ ដើម្បីបន្ធូរសម្ពាធ ចូរមូលបន្ធូរគម្របធុងខ្ចោលយឺតៗមកទល់នឹងទីនប់ទីមួយ មុននឹងដោះគម្របចេញទាំងស្រុង។**



TS281—UN—15APR13


ជាតុរាវមានសម្ពាធខ្ពស់




YC21198—UN—21DEC22


**A—គម្របធុងខ្ចោល**

1. បើកគម្របធុងខ្ចោល (A) យឺតៗដើម្បីបន្ធូរសម្ពាធ និងទុកឲ្យទឹកថ្នាំស្អំម៉ាស៊ីនហូរកាន់តែលឿន។




YC21200—UN—21DEC22

ឆ្នុកបង្ហូរទឹកថ្នាំស្អំម៉ាស៊ីនបង្គំម៉ាស៊ីន—ចំហៀងខាងស្តាំម៉ាស៊ីន





YC21199—UN—21DEC22

ឆ្នុកបង្ហូរទឹកថ្នាំស្អំម៉ាស៊ីនបង្គំម៉ាស៊ីន—ចំហៀងខាងឆ្វេងម៉ាស៊ីន

**B—ចំហៀងខាងស្តាំឆ្នុកបង្ហូរទឹកថ្នាំស្អំម៉ាស៊ីនបង្គំម៉ាស៊ីន**
**C—ចំហៀងខាងឆ្វេងឆ្នុកបង្ហូរទឹកថ្នាំស្អំម៉ាស៊ីនបង្គំម៉ាស៊ីន**

2. ដោះឆ្នុកបង្ហូរ (B និង C) ចេញ ហើយបង្ហូរទឹកថ្នាំស្អំម៉ាស៊ីនចេញពីបង្គំម៉ាស៊ីនឲ្យអស់។
3. ដាក់ និងរឹតបន្តឹងឆ្នុកបង្ហូរ។




YC21201—UN—21DEC22

**D—វ៉ាល់បង្ហូរ**

4. តទុយោសមស្របទៅនឹងវ៉ាល់បង្ហូរ (D)។
5. បើកវ៉ាល់បង្ហូរបង្ហូរទឹកស្អុំម៉ាស៊ីនចេញពីធុងទឹកម៉ាស៊ីនឲ្យអស់។
6. បិទវ៉ាល់បង្ហូរ ហើយដោះទុយោចេញ។
7. ចាក់ទឹកស្អាតចូលក្នុងប្រព័ន្ធបញ្ចុះកម្តៅតាមធុងខ្ជោល។
8. ដាក់ និងបិទគម្របធុងខ្ជោល។

**⚠ ប្រយ័ត្ន៖ កុំដំណើរការម៉ាស៊ីនលើសពី 10 នាទី។ ការធ្វើដូច្នេះអាចបណ្តាលឲ្យម៉ាស៊ីនឡើងកម្តៅខ្លាំងដែលអាចបណ្តាលឲ្យឆាបឆេះ នៅពេលអស់ទឹកពីធុងទឹកម៉ាស៊ីន។**


9. បញ្ឆេះម៉ាស៊ីននិងដំណើរការវាប្រហែល 10 នាទី។
10. ពន្លត់ម៉ាស៊ីន។
11. ធ្វើឡើងវិញពីជំហាន 1 ដល់ 6 ដើម្បីបង្ហូរទឹកចេញពីប្រព័ន្ធ។
12. ចាក់ទឹកស្អាត និងថ្នាំសម្អាតប្រព័ន្ធបញ្ចុះកម្តៅដែលធន់ដូចជា Restoreឬ Restore Plus ចូលក្នុងប្រព័ន្ធបញ្ចុះកម្តៅតាមធុងខ្ជោល។

*កំណត់ចំណាំ៖ អនុវត្តតាមការណែនាំរបស់រោងចក្រផលិតនៅលើស្លាកសញ្ញា។*

13. ដាក់ និងបិទគម្របធុងខ្ជោល។
14. បញ្ឆេះម៉ាស៊ីននិងដំណើរការវាប្រហែល 10 នាទី។
15. ពន្លត់ម៉ាស៊ីន។
16. ធ្វើឡើងវិញពីជំហាន 1 ដល់ 6 ដើម្បីបង្ហូរទឹកថ្នាំស្អុំម៉ាស៊ីននិងថ្នាំសម្អាតចេញពីប្រព័ន្ធ។
17. ធ្វើឡើងវិញពីជំហាន 7 ដល់ 11 ដើម្បីសម្អាតប្រព័ន្ធម្តងទៀតដោយប្រើទឹកស្អាត។

**⚠ ប្រយ័ត្ន៖ ហាមចាក់ទឹកចូលក្នុងប្រព័ន្ធនៅពេលម៉ាស៊ីនកំពុងក្តៅ។ រង់ចាំទាល់តែម៉ាស៊ីនចុះត្រជាក់សិន។**

*កំណត់ចំណាំ៖ ពិនិត្យមើលចំណុះទឹកថ្នាំស្អុំម៉ាស៊ីននៅក្នុងផ្នែកលក្ខណៈបច្ចេកទេស។*




YC21202—UN—21DEC22

**E—ធុងខ្ជោល**
**F—សញ្ញា MAX (អតិ.)**
**G—សញ្ញា MIN (អប្ប.)**

18. ចាក់ទឹកថ្នាំស្អុំម៉ាស៊ីនដែលបានបញ្ចាក់ចូលក្នុងប្រព័ន្ធបញ្ចុះកម្តៅ។សម្រាប់ការណែនាំ ចូរអានអំពីទឹកថ្នាំស្អុំម៉ាស៊ីនម៉ាស៊ូត (ម៉ាស៊ីនដែលមានស៊ីឡាំងប្រភេទសើម) នៅក្នុងផ្នែកទឹកថ្នាំស្អុំម៉ាស៊ីន និងប្រេងរំអិល។

    កម្រិតទឹកថ្នាំស្អុំម៉ាស៊ីនគួរតែស្ថិតនៅចន្លោះសញ្ញា "អប្ប." (G) និងសញ្ញា "អតិ." (F) នៅលើធុងខ្ជោល (E)។


19. ដំណើរការម៉ាស៊ីនរហូតទាល់តែដល់សីតុណ្ហភាពប្រតិបត្តិការ។
20. បន្ទាប់ពីដំណើរការម៉ាស៊ី ចូរពិនិត្យមើលកម្រិតទឹកថ្នាំស្អុំម៉ាស៊ីននិងប្រព័ន្ធបញ្ចុះកម្តៅម៉ាស៊ីនទាំងមូលក្រែងលោមានការលេចធ្លាយ។

cp00834,1668848098517-KM-19NOV22

## ច្រាលខ្សល់ពីប្រព័ន្ធប្រេងឥន្ធនៈ

សាប់បន្លែចេញពីប្រព័ន្ធប្រេងឥន្ធនៈនៅក្នុងស្ថានការណ៍ដូចខាងក្រោម៖

- ស្បែតម្រងប្រេងឥន្ធនៈត្រូវបានប្តូរ។
- ប្រេងឥន្ធនៈអស់ពីធុង។
- បន្ទាប់ពីជួលជុលប្រព័ន្ធឥន្ធនៈ។
- ម៉ាស៊ីនត្រូវបានការ៉ង់ទីរយៈពេលយូរ។





YC21203—UN—21DEC22

សាប់បន្លែប្រព័ន្ធឥន្ធនៈត្រង់តម្រងឥន្ធនៈទីមួយ

**A—ប៊ូឡុងសម្រាប់ការបន្លែ**
**B—តម្រងប្រេងឥន្ធនៈទីមួយ**

1. ចូរប្រាកដថាប្រេងឥន្ធនៈពេញធុង។
2. បញ្ឈប់ម៉ាស៊ីន។
3. បន្លែខ្ចៅសាប់បន្លែ (A) នៅលើតម្រងឥន្ធនៈទីមួយ (B)។
4. រឹតបន្តឹងខ្ចៅសាប់បន្លែភ្លាមបន្ទាប់ពីលំហូរប្រេងលែងមានពពុះ។




YC21204—UN—21DEC22

សាប់បន្លែប្រព័ន្ធឥន្ធនៈត្រង់តម្រងឥន្ធនៈទីពីរ

**C—ប៊ូឡុងសម្រាប់ការបន្លែ**
**D—តម្រងប្រេងឥន្ធនៈទីពីរ**

5. សាប់បន្លែប្រព័ន្ធឥន្ធនៈ (D) តាមវិធីសាស្ត្រដដែល។

cp00834,1668851417810-KM-19NOV22

# ការថែទាំប្រព័ន្ធអូសទាញតាមចាំបាច់

## ឧបករណ៍លើកកង់ (សម្រាប់ទីផ្សារនាំចេញ)




YC17363—UN—22APR21

កង់មុខ




YC17364—UN—22APR21

កង់ក្រោយ

**A—ឧបករណ៍លើក**
**B—ឧបករណ៍លើក**


ឧបករណ៍លើកឡើង (A និង B) នឹងត្រូវដំឡើងពីរោងចក្រមក។

ឧបករណ៍លើក (A និង B) នៅលើកង់នឹងត្រូវបានប្រើដើម្បីលើកម៉ាស៊ីន។

cp00834,1669016426932-KM-21NOV22


## ដួយលើកម៉ាស៊ីន—ចំណុចលើក

*កំណត់ចំណាំ៖ រូបភាពនេះបង្ហាញអំពីចំណុចលើកតាមការណែនាំសម្រាប់ការគ្រឹបលើកគ្រឿងចក្រឡើង។ ប្រើដែកគ្រឹបដែលមានល់នឹងជាមួយនឹងកម្លាំងលើកគ្រប់គ្រាន់។ អានអំពីទំហំគ្រឿងចក្រនិងដុំទម្ងន់នៅក្នុងផ្នែកលក្ខណៈបច្ចេកទេស។*




YC20448—UN—08AUG22

ចំណុចលើកស្ពៅមុខ (ចំហៀងខាងឆ្វេង)





YC20447—UN—08AUG22

ចំណុចលើកស្ពៅមុខ (ចំហៀងខាងស្តាំ)




YC20449—UN—08AUG22

ចំណុចលើកស្ពៅក្រោយ




YC20450—UN—08AUG22
ចំណុចលើកភ្លៅក្រោយ (ការអូសដោយកង់ក្រោយ)

**A—ស្លាកចំណុចលើកភ្លៅមុខ (ប្រើ 2)**
**B—ស្លាកចំណុចលើកភ្លៅក្រោយ (ប្រើ 2)**


ចំណុចលើកស្ថិតនៅក្រោមស្លាក។

ដួយលើកភ្លៅមុខ ឬភ្លៅក្រោយដោយប្រើឧបករណ៍លើកដែលអនុញ្ញាតឲ្យប្រើនៅក្រោមចំណុចលើក។

cp00834,1659938959504-KM-08AUG22


## លៃតម្រូវខ្សែគ្រប់គ្រងចង្កឹះលេខ

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**



YC18526—UN—06SEP21

1. ដាក់ចង្កឹះប្តូរលេខនៅក្នុងទីតាំងនឺងចន្លោះស្តីហ្គែរលេខមួយ និងលេខពីរ។




YC18354—UN—02SEP21

**A—ប្រអប់ស្តី**
**B—ក្បាលឡោស៊ុី (ប្រើ 4)**
**C—ខ្សែគ្រប់គ្រង**
**D—ខ្សែគ្រប់គ្រង**
**E—ទម្រ**
**F—ទំហំ**
**G—ទំហំ**

2. បន្ធូរក្បាលឡោស៊ុី (B) ។
3. វាស់ទំហំ (F និង G) ទៅតាមលក្ខណៈបច្ចេកទេស។

**លក្ខណៈបច្ចេកទេស**

| | |
|---|---|
| ទំហំ (F) នៅចន្លោះចុងដង និង ទម្រ (E)—បណ្តោយ | 11 ម.ម |
| ទំហំ (G) នៅចន្លោះចុងដង និង ទម្រ (E)—បណ្តោយ | 48 ម.ម |


*កំណត់ចំណាំ៖ មុនដំបូង លៃតម្រូវខ្សែគ្រប់គ្រងមួយ បន្ទាប់មកទៀតចូរលៃតម្រូវខ្សែគ្រប់គ្រងម្ខាងទៀត។*

4. ប្រសិនបើមិនឆ្លើយតបតាមលក្ខណៈបច្ចេកទេសទេ ចូរលៃតម្រូវទំហំនេះតាមក្បាលឡោស៊ុី(B)។
5. រឹតបន្តឹងក្បាលឡោស៊ុីក្រោយពីលៃតម្រូវរួច។

CP00834,0008FDA-KM-12OCT21

## ការលៃតម្រឹមគ្រឿងលើ Posi-Torq™ (ការអូសដោយមេកានិក)

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21205—UN—21DEC22

**A—ប៉ូលីបញ្ចេញថាមពល**
**B—ខ្សែពានអូស**
**C—ចំណុច (ប្រើ 3)**
**D—ដង**
**E—ដង**
**F—ប៉ូលីអូស**


ជ្រើសរើសចំណុចបី (C) នៅផ្នែកខាងក្រៅប៉ូលីអូស (F) ឱ្យស៊ីមេទ្រីគ្នា។ រាស់ចម្ងាយរវាងចំណុចទាំងបី និងជញ្ជាំងចំហៀង។ លំងាកគួរតែតិចជាង 3 ម.ម, ដែលប៉ូលីអូសតម្រឹមជាមួយប៉ូលបញ្ចេញថាមពលម៉ាស៊ីន (A)។

ប្រសិនបើលំងាកលើសពី 3 ម.ម ចូរលៃតម្រូវប្រវែងដង (D និង E) ដោយមួលក្បាលឡោស៊ី។

cp00834,1668854041437-KM-19NOV22

## ការលៃតម្រឹមប៉ូលីអូសស្នប់បូមអ៊ីដ្រូស្តាទិក (ការអូសដោយអ៊ីដ្រូស្តាទិក)

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21206—UN—21DEC22

**A—ប៉ូលីបញ្ចេញថាមពល**
**B—ខ្សែពានអូស**
**C—ប៉ូលីអូស**
**D—ដង**
**E—ដង**


ជ្រើសរើសចំណុចបីនៅផ្នែកខាងក្រៅប៉ូលីអូស (C) ឱ្យស៊ីមេទ្រីគ្នា។ រាស់ចម្ងាយរវាងចំណុចទាំងបី និងជញ្ជាំងចំហៀង។ លំងាកគួរតែតិចជាង 3 ម.ម, ដែលប៉ូលីអូសតម្រឹមជាមួយប៉ូលបញ្ចេញថាមពលម៉ាស៊ីន (A)។

ប្រសិនបើលំងាកលើសពី 3 ម.ម ចូរលៃតម្រូវប្រវែងដង (D និង E) ដោយមួលក្បាលឡោស៊ី។


cp00834,1668854714874-KM-19NOV22

## ប្រព័ន្ធបញ្ចេញខ្សល់ពីប្រេងហ្វ្រាំង

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21207—UN—21DEC22




YC21208—UN—21DEC22

ស៊ីឡាំងហ្វ្រាំងខាងឆ្វេង

**A—ធុងប្រេងហ្វ្រាំង**
**B—ប៊ូឡុងសម្រាប់ការបន្ធូរ**
**C—ប្រអប់ហ្វ្រាំង**
**D—ស៊ីឡាំងជំនួយហ្វ្រាំង (ប្រើ 2)**
**E—ឆ្នុកបង្ហូរ (ប្រើ 2)**


បន្ធូរខ្យល់ពីប្រព័ន្ធហ្វ្រាំង បន្ទាប់ពីថែទាំប្រព័ន្ធហ្វ្រាំងរួច។

*កំណត់ចំណាំ៖ ការសាប់បន្ធូរអាចធ្វើឡើងនៅត្រង់ស៊ីឡាំងជំនួយហ្វ្រាំងណាមួយក៏បាន។*


1. បន្ធូរខ្ចៅសាប់បន្ធូរ (B) និងឆ្នុកបង្ហូរ (E) នៅត្រង់ស៊ីឡាំងជំនួយហ្វ្រាំង។
2. ខ្ចាស់ឈ្នាន់ហ្វ្រាំងទាំងពីររួមគ្នា ហើយសង្កត់ឈ្នាន់ហ្វ្រាំងជាច្រើនដងរហូតទាល់តែលែងមានពពុះខ្យល់ចេញពីឆ្នុកបង្ហូរ។
3. រឹតបន្តឹងខ្ចៅសាប់បន្ធូរ និងឆ្នុកបង្ហូរ។

cp00834,1668854862001-KM-19NOV22

## ចាក់ប្រេងហ្វ្រាំងចូល




YC18043—UN—16JUL21




YC21209—UN—21DEC22

**A—ភ្លើងសញ្ញាកម្រិតប្រេងហ្វ្រាំង**
**B—គម្រប**

ប្រសិនបើកម្រិតប្រេងហ្វ្រាំងទាប នោះភ្លើងសញ្ញាកម្រិតប្រេងហ្វ្រាំង (A) នឹងភ្លឺឡើង។

ដោះគម្រប (B) ចេញដើម្បីចាក់ប្រេងហ្វ្រាំងចូលធុងស្តុកតាមចាំបាច់។

cp00834,1668854986001-KM-19NOV22


# ការថែទាំក្បាលឧបករណ៍កាត់ និងមាត់ច្រកបួងចូលតាមចាំបាច់

## ចាក់ខ្នាស់ទំនប់សុវត្ថិភាពមាត់ច្រកបួងចូល

**⚠ ប្រយ័ត្ន៖ នៅពេលដឹកជញ្ជូនដោយក្បាលឧបករណ៍កាត់ ឬកំពុងបំពេញការងារនៅក្រោមមាត់ច្រកបួងចូល ចូរចាក់ខ្នាស់ទំនប់សុវត្ថិភាពមាត់ច្រកបួងចូល។**


**សំខាន់៖ ដោះខ្នាស់ទំនប់សុវត្ថិភាពមុននឹងប្រតិបត្តិការគ្រឿងចក្រ។**

*កំណត់ចំណាំ៖ មានតែស៊ីឡាំងអ៊ីដ្រូលិកចំហៀងខាងឆ្វេងប៉ុណ្ណោះដែលបំពាក់ទំនប់សុវត្ថិភាព។*




YC19411—UN—09JAN22

ទំនប់សុវត្ថិភាពមាត់ច្រកបួងចូលដែលដោះខ្នាស់




YC19412—UN—09JAN22

ទំនប់សុវត្ថិភាពមាត់ច្រកបួងចូលដែលចាក់ខ្នាស់

**A—កន្លាស់ខ្នាស់ (ប្រើ 2)**
**B—មួលខ្នាស់**
**C—ទំនប់សុវត្ថិភាព**
**D—ស៊ីឡាំងអ៊ីដ្រូលិក**

1. លើកក្បាលកាត់ទៅទីតាំងខ្ពស់បំផុត។
2. ដោះកន្លាស់ខ្នាស់ (A) និងមួលខ្នាស់ (B)។
3. បន្ទាបទំនប់សុវត្ថិភាព (C) លើស៊ីឡាំងអ៊ីដ្រូលិក (D)។
4. ស៊កមួលខ្នាស់ក្នុងរន្ធខាងក្រោម ហើយដាក់កន្លាស់ខ្នាស់។


*កំណត់ចំណាំ៖ ស៊កមួលខ្នាស់ក្នុងរន្ធខាងលើ ដើម្បីដោះខ្នាស់មាត់ច្រកបួងចូល។*

5. បន្ទាបក្បាលឧបករណ៍កាត់បន្តិចរហូតទាល់តែទំនប់សុវត្ថិភាពទ្រមាត់ច្រកបួងចូល។

CP00834,0008DAC-KM-28DEC21

## ពិនិត្យ និងលៃតម្រូវតំណឹងខ្សែពានអូសមាត់ច្រកបួងចូល

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**




YC21210—UN—21DEC22

**A—ក្បាលឡោស៊ីមានឡក់**
**B—ទម្រ**
**C—វង**
**D—រីស័រ**
**E—ខ្សែពានអូស**
**F—បំពង**
**X—ចម្ងាយ**

ភ្ជាប់ដុំអូសក្បាលឧបករណ៍កាត់ វាស់ចម្ងាយ (X) រវាងផ្នែកខាងក្នុងនៃទម្រ (B) និងវង (C), ចម្ងាយគួរមានប្រវែងពី 7 ដល់ 12 ម.ម។

ប្រសិនបើចម្ងាយស្ថិតនៅក្រៅកម្រិតណែនាំ ចូរលៃតម្រូវចម្ងាយ៖

- បន្ធូរក្បាលឡោស៊ីមានឡក់ (A) ហើយរឹតបន្តឹងបំពង់ (F) ដើម្បីបន្តយចម្ងាយ។
- បន្ធូរបំពង់ ហើយរឹតបន្តឹងក្បាលឡោស៊ីមានឡក់ដើម្បីបង្កើនចម្ងាយ។

*កំណត់ចំណាំ៖ ប្រើប្រាស់ឧបករណ៍សមស្របដើម្បីមួលបំពង់នោះ។*


*កំណត់ចំណាំ៖ មុននឹងលៃតម្រូវ ចូរប្រាកដថាដុំអូសក្បាលឧបករណ៍កាត់ត្រូវបានភ្ជាប់។*

cp00834,1668855846172-KM-19NOV22

## ការលៃតម្រូវពង្រាបក្បាលឧបករណ៍កាត់

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

*កំណត់ចំណាំ៖ ការលៃតម្រូវអាចធ្វើទៅបានតែនៅចំហៀងខាងស្តាំមាត់ច្រកបួងចូលប៉ុណ្ណោះ។*




YC21212—UN—21DEC22


**A—ក្បាលឡោស៊ី (ប្រើ 3)**
**B—ក្បាលឡោស៊ី (ប្រើ 2)**
**C—ប៊ូឡុង**

បន្ធូរក្បាលឡោស៊ី (A) និងប៊ូឡុង (C), លៃតម្រូវក្បាលឡោស៊ី (B) ដើម្បីធ្វើឲ្យក្បាលឧបករណ៍កាត់ស្របទៅនឹងស្តៅខាងមុខ។

cp00834,1668855934053-KM-19NOV22

## សម្អាតការកកស្ទះមាត់ច្រកបួងចូល

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21211—UN—21DEC22
បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ

**A—ក្បាលឡោស៊ីរឹតដោយដៃ (ប្រើ 2)**
**B—គម្របពិនិត្យ**

បន្ធូរក្បាលឡោស៊ីរឹតដោយដៃ (A) នៅចំហៀងសងខាង ហូតចូលក្នុងរួមជាមួយគន្លឹះ ហើយដោះគម្របពិនិត្យ (B) ចេញ ដើម្បីសម្អាតការកកស្ទះ។

cp00834,1668855919588-KM-19NOV22


# ការថែទាំប្រព័ន្ធបោកបែន និងបំបែកតាមចាំបាច់

## ការកំណត់មូលដ្ឋានគ្រឹះនៃចន្លោះប្រអប់កង្ហែង (ស្ក្រូវសាឡ្យ)

*កំណត់ចំណាំ៖ ការកំណត់មូលដ្ឋានត្រូវបានកំណត់នៅរោងចក្រ។ ចន្លោះចូលគឺ 7—8 ម.ម ចន្លោះចេញគឺ 4—5 ម.ម។*

*កំណត់ចន្លោះប្រអប់កង្ហែងឡើងវិញរៀងរាល់ពេលប្តូរប្រអប់កង្ហែង។ ពិនិត្យមើលការកំណត់មូលដ្ឋានយ៉ាងតិចម្តងរៀងរាល់ដូវប្រមូលផល។*

*ប្រោកដថាប្រអប់កង្ហែងស្របទៅនឹងស៊ីឡាំងបោកបែនពីម្ខាងទៅម្ខាង។*





YC18045—UN—16JUL21

**A—ដៃលៃតម្រូវចន្លោះប្រអប់កង្ហែង**
**B—ផ្នែក**

1. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
2. ដោះគម្របវិនីលនៅលើដៃបញ្ជា។
3. ទាញដៃលៃតម្រូវចន្លោះប្រអប់កង្ហែង (A) ឡើងលើយឺតៗរហូតទាល់តែវាភ្ជាប់នឹងគន្លាក់ទីពីរពីផ្នែកខាងលើ។

*កំណត់ចំណាំ៖ កុំកំណត់ទៅគន្លាក់ទីពីរដោយរុញចង្កឹះលេខចុះក្រោម។*

4. ពិនិត្យមើលក្រែងលោដៃមិនទ្របន្តកប្រអប់កង្ហែងដោយរំកិលវាពីម្ខាងទៅម្ខាង។មិនគួរមានដំណើរនៅក្នុងដៃបញ្ជាឡើយ។




YC18046—UN—16JUL21

**C—ចន្លោះចូល**
**D—ចន្លោះចេញ**


5. ដោះបង្ហួចពិនិត្យប្រអប់កង្ហែងដែលគ្របនៅលើផ្នែកសងខាងនៃគ្រឿងចក្រចេញ។
6. សម្អាតសម្ភារដែលពេញហៀរប្រអប់កង្ហែង។
7. រកមើលរបារខ្ពស់ដែលមានសញ្ញាដែលបង្កើតឡើងនៅរោងចក្រ។

   បង្វិលស៊ីឡាំងបោកបែនប្រសិនបើសញ្ញានោះសឹកដាច់ ចូរបង្វិលស៊ីឡាំងបោកបែនដោយដៃយឺតៗដើម្បីពិនិត្យមើលចន្លោះរវាងស៊ីឡាំង និងប្រអប់កង្ហែងរហូតទាល់តែរបារខ្ពស់ត្រូវបានកំណត់។ សម្គាល់របារខ្ពស់ដែលមានសញ្ញាសម្គាល់ដូចជាចំណុចថ្មាំលាប ឬការចោះកណ្តាល។

*កំណត់ចំណាំ៖ មុននឹងវាស់ ចូរប្រោកដថាកង្ហែងប្រអប់កង្ហែងតឹងណែន។ ប្រសិនបើចាំបាច់ ចូរសឹករបារគាស់នៅចន្លោះរបាររូស និងប្រអប់កង្ហែង ហើយគាស់វាទម្លាក់។*

8. វាស់ចន្លោះដែលបានប្រដាប់វាស់កម្រាស់នៅចន្លោះរបារខ្ពស់នៃរបាររូសនិងរបារប្រអប់កង្ហែងនៅចំហៀងសងខាងគ្រឿងចក្រ។
   - **ចន្លោះចូល (C)៖** វាស់ត្រង់របារប្រអប់កង្ហែងទីពីរពីផ្នែកខាងមុខ។
   - **ចន្លោះចេញ (D)៖** វាស់ត្រង់របារប្រអប់កង្ហែងទីមួយពីផ្នែកខាងក្រោយ។

   ប្រសិនបើរង្វាស់មិនស្ថិតនៅចន្លោះពី 7 ទៅ 8 ម.ម នៅផ្នែកខាងមុខ និងពី 4 ទៅ 5 ម.មនៅផ្នែកខាងក្រោយទេ ចូរចូលទៅដំហានបន្ទាប់។




YC21219—UN—21DEC22

បានបង្ហាញយន្តការលៃតម្រូវចន្លោះប្រអប់កង្ហែងចំហៀងខាងឆ្វេង

**E—ក្បាលឡោស៊ី**
**F—ប៊ូឡុងក្បាលកង**
**G—ប៊ូឡុងក្បាលកង**
**H—ក្បាលឡោស៊ី**
**I—ក្បាលឡោស៊ី**
**J—បន្ទះខ្សែ**
**K—បន្ទះខ្សែ**

**L—ក្បាលឡោស៊ី**

9. លៃតម្រូវកញ្ជែងប្រអប់កញ្ជែង (J និង K) ដើម្បីទទួលបានចន្លោះតាមចង់បាន។
   - លៃតម្រូវចន្លោះចូលដោយមួលក្បាលឡោស៊ី (E និង L) នៅចំហៀងសងខាងគ្រឿងចក្រ។
   - លៃតម្រូវចន្លោះចេះដោយមួលក្បាលឡោស៊ី (H និង I) នៅចំហៀងសងខាងគ្រឿងចក្រ។

*កំណត់ចំណាំ៖ នៅពេលបង្កើនចន្លោះ ចូរស៊ីករបារគាស់ចន្លោះស៊ីឡាំងបោកបែន និងប្រអប់កញ្ជែង ហើយគាស់វាចុះក្រោម។*

10. ពិនិត្យមើលក្រែងលោក្បាលឡោស៊ី (E, H, I, និង L) នៅលើប៊ូឡុងក្បាលកងលៃតម្រូវមិនតឹងណែន។
11. បង្វិលប្រអប់កញ្ជែងម្តងមួយដុំពេញ ហើយកំណត់ដៃលៃតម្រូវចន្លោះប្រអប់កញ្ជែងទៅកាន់គន្លាក់ទីពីរពីផ្នែកខាងលើ។ពិនិត្យមើលចន្លោះប្រអប់កញ្ជែងឡើងវិញ។
12. ដំឡើងបង្ហួចពិនិត្យប្រអប់កញ្ជែងដែលគ្របនៅលើផ្នែកសងខាងនៃគ្រឿងចក្រវិញ។ប្រាកដថាក្បាលឡោស៊ីស្អាបតឹងណែន។


cp00834,1668907666389-KM-19NOV22

## ការកំណត់មូលដ្ឋានគ្រឹះនៃចន្លោះប្រអប់កញ្ជែង (ស្រូវ)

*កំណត់ចំណាំ៖ ការកំណត់មូលដ្ឋានត្រូវបានកំណត់នៅរោងចក្រ។ ចន្លោះចូលគឺ 17—18 ម.ម ចន្លោះចេញគឺ 14—15 ម.ម។*

*កំណត់ចន្លោះប្រអប់កញ្ជែងឡើងវិញរៀងរាល់ពេលប្តូរប្រអប់កញ្ជែង។ ពិនិត្យមើលការកំណត់មូលដ្ឋានយ៉ាងតិចម្តងរៀងរាល់រដូវប្រមូលផល។*

*ប្រាកដថាប្រអប់កញ្ជែងស្របទៅនឹងស៊ីឡាំងបោកបែនពីម្ខាងទៅម្ខាង។*





YC18045—UN—16JUL21

**A—ដៃលៃតម្រូវចន្លោះប្រអប់កញ្ជែង**
**B—ផ្នែក**

1. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
2. ដោះគម្របវិនីលនៅលើដៃបញ្ជា។
3. ទាញដៃលៃតម្រូវចន្លោះប្រអប់កញ្ជែង (A) ឡើងលើយឺតៗរហូតទាល់តែវាភ្ជាប់នឹងគន្លាក់ទីពីរពីផ្នែកខាងលើ។

*កំណត់ចំណាំ៖ កុំកំណត់ទៅគន្លាក់ទីពីរដោយរុញចង្អុលចុះក្រោម។*

4. ពិនិត្យមើលក្រែងលោដៃមិនទ្របន្តុកប្រអប់កញ្ជែងដោយរំកិលវាពីម្ខាងទៅម្ខាង។មិនគួរមានដំណើរនៅក្នុងដៃបញ្ជាឡើយ។




YC18048—UN—12SEP21

**C—ចន្លោះចូល**
**D—ចន្លោះចេញ**


5. ដោះបង្ហួចពិនិត្យប្រអប់កញ្ជែងដែលគ្របនៅលើផ្នែកសងខាងនៃគ្រឿងចក្រចេញ។
6. សម្អាតសម្ភារដែលពេញហៀរប្រអប់កញ្ជែង។
7. រកមើលរបារខ្ពស់ដែលមានសញ្ញាដែលបង្កើតឡើងនៅរោងចក្រ។

   បង្វិលស៊ីឡាំងបោកបែនប្រសិនបើសញ្ញានោះសឹកដាច់ ចូរបង្វិលស៊ីឡាំងបោកបែនដោយដៃយឺតៗដើម្បីពិនិត្យមើលចន្លោះរវាងស៊ីឡាំង និងប្រអប់កញ្ជែងរហូតទាល់តែរបារខ្ពស់ត្រូវបានកំណត់។ សម្ភារៈរបារខ្ពស់ដែលមានសញ្ញាសម្គាល់ដូចជាចំណុចថ្នាំលាប ឬការចោះកណ្តាល។

*កំណត់ចំណាំ៖ មុននឹងវាស់ ចូរប្រាកដថាកញ្ជែងប្រអប់កញ្ជែងតឹងណែន។ ប្រសិនបើចាំបាច់ ចូរស៊ីករបារគាស់នៅចន្លោះរបាររូស និងប្រអប់កញ្ជែង ហើយគាស់វាទម្លាក់។*

8. វាស់ចន្លោះដែលបានប្រដាប់វាស់កម្រាស់នៅចន្លោះរបារខ្ពស់នៃរបាររូសនិងរបារប្រអប់កញ្ជែងនៅចំហៀងសងខាងគ្រឿងចក្រ។
   - **ចន្លោះចូល (C)៖** វាស់ត្រង់របារប្រអប់កញ្ជែងទីពីរពីផ្នែកខាងមុខ។
   - **ចន្លោះចេញ (D)៖** វាស់ត្រង់របារប្រអប់កញ្ជែងទីមួយពីផ្នែកខាងក្រោយ។

   ប្រសិនបើរង្វាស់មិនស្ថិតនៅចន្លោះពី 17 ទៅ 18 ម.ម នៅផ្នែកខាងមុខ និងពី 14 ទៅ 15 ម.មនៅផ្នែកខាងក្រោយទេ ចូរចូលទៅដំហានបន្ទាប់។




YC21219—UN—21DEC22

បានបង្ហាញយន្តការលៃតម្រូវចន្លោះប្រអប់កញ្ចែងចំហៀងខាងឆ្វេង

**E—ក្បាលឡោស៊ី**
**F—ប៊ូឡុងក្បាលកង**
**G—ប៊ូឡុងក្បាលកង**
**H—ក្បាលឡោស៊ី**
**I—ក្បាលឡោស៊ី**
**J—បន្ទះខ្សែ**
**K—បន្ទះខ្សែ**
**L—ក្បាលឡោស៊ី**

9. លៃតម្រូវកញ្ចែងប្រអប់កញ្ចែង (J និង K) ដើម្បីទទួលបានចន្លោះតាមចង់បាន។
   - លៃតម្រូវចន្លោះចូលដោយមួលក្បាលឡោស៊ី (E និង L) នៅចំហៀងសងខាងគ្រឿងចក្រ។
   - លៃតម្រូវចន្លោះចេះដោយមួលក្បាលឡោស៊ី (H និង I) នៅចំហៀងសងខាងគ្រឿងចក្រ។

*កំណត់ចំណាំ៖ នៅពេលបង្កើនចន្លោះ ចូរស៊ីករបារគាស់ចន្លោះស៊ីឡាំងបោកបែន និងប្រអប់កញ្ចែង ហើយគាស់វាចុះក្រោម។*

10. ពិនិត្យមើលក្រែងលោក្បាលឡោស៊ី (E, H, I, និង L) នៅលើប៊ូឡុងក្បាលកងលៃតម្រូវមិនតឹងណែន។
11. បង្វិលប្រអប់កញ្ចែងម្តងមួយដុំពេញ ហើយកំណត់ដៃលៃតម្រូវចន្លោះប្រអប់កញ្ចែងទៅកាន់គន្លាក់ទីពីរពីផ្នែកខាងលើ។ពិនិត្យមើលចន្លោះប្រអប់កញ្ចែងឡើងវិញ។
12. ដំឡើងបង្ហួចពិនិត្យប្រអប់កញ្ចែងដែលគ្របនៅលើផ្នែកសងខាងនៃគ្រឿងចក្រវិញ។ប្រាកដថាក្បាលឡោស៊ីស្លាបតឹងណែន។


cp00834,1668907677142-KM-19NOV22

## ការកំណត់មូលដ្ឋានគ្រឹះនៃចន្លោះប្រអប់កញ្ចែង (ពោត)

*កំណត់ចំណាំ៖ ការកំណត់មូលដ្ឋានត្រូវបានកំណត់នៅរោងចក្រ។ ចន្លោះចូលគឺ 22—23 ម.ម ចន្លោះចេញគឺ 19—20 ម.ម។*

*កំណត់ចន្លោះប្រអប់កញ្ចែងឡើងវិញរៀងរាល់ពេលប្តូរប្រអប់កញ្ចែង។ ពិនិត្យមើលការកំណត់មូលដ្ឋានយ៉ាងតិចម្តងរៀងរាល់រដូវប្រមូលផល។*

*ប្រាកដថាប្រអប់កញ្ចែងស្របទៅនឹងស៊ីឡាំងបោកបែនពីម្ខាងទៅម្ខាង។*





YC18045—UN—16JUL21

**A—ដៃលៃតម្រូវចន្លោះប្រអប់កញ្ចែង**
**B—ផ្នែក**

1. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
2. ដោះគម្របវិនីលនៅលើដៃបញ្ជា។
3. ទាញដៃលៃតម្រូវចន្លោះប្រអប់កញ្ចែង (A) ឡើងលើយឺតៗរហូតទាល់តែវាភ្ជាប់នឹងគន្លាក់ទីពីរពីផ្នែកខាងលើ។

*កំណត់ចំណាំ៖ កុំកំណត់ទៅគន្លាក់ទីពីរដោយរុញចង្អឹះលេខចុះក្រោម។*

4. ពិនិត្យមើលក្រែងលោដៃមិនទ្របន្ទុកប្រអប់កញ្ចែងដោយរំកិលវាពីម្ខាងទៅម្ខាង។មិនគួរមានដំណើរនៅក្នុងដៃបញ្ជាឡើយ។




YC18046—UN—16JUL21

**C—ចន្លោះចូល**
**D—ចន្លោះចេញ**

5. ដោះបង្ហួចពិនិត្យប្រអប់កញ្ចែងដែលគ្របនៅលើផ្នែកសងខាងនៃគ្រឿងចក្រចេញ។
6. សម្អាតសម្ភារដែលពេញហៀរប្រអប់កញ្ចែង។

7. រកមើលរបារខ្ពស់ដែលមានសញ្ញាដែលបង្កើតឡើងនៅរោងចក្រ។


   បង្វិលស៊ីឡាំងបោកបែនប្រសិនបើសញ្ញានោះសឹកដាច់ ចូរបង្វិលស៊ីឡាំងបោកបែនដោយដៃយឺតៗដើម្បីពិនិត្យមើលចន្លោះរវាងស៊ីឡាំង និងប្រអប់កញ្ជ្រែង រហូតទាល់តែរបារខ្ពស់ត្រូវបានកំណត់។ សម្គាល់របារខ្ពស់ដែលមានសញ្ញាសម្គាល់ដូចជាចំណុចថ្មាំលាប ឬការចោះកណ្តាល។

*កំណត់ចំណាំ៖ មុននឹងវាស់ ចូរប្រាកដថាកញ្ជ្រែងប្រអប់កញ្ជ្រែងតឹងណែន។ ប្រសិនបើចាំបាច់ ចូរសឹករបារគាស់នៅចន្លោះរបាររូស និងប្រអប់កញ្ជ្រែង ហើយគាស់វាទម្លាក់។*

8. វាស់ចន្លោះដែលបានប្រដាប់វាស់កម្រាស់នៅចន្លោះរបារខ្ពស់នៃរបាររូសនិងរបារប្រអប់កញ្ជ្រែងនៅចំហៀងសងខាងគ្រឿងចក្រ។

   - **ចន្លោះចូល (C)៖** វាស់ត្រង់របារប្រអប់កញ្ជ្រែងទីពីរពីផ្នែកខាងមុខ។
   - **ចន្លោះចេញ (D)៖** វាស់ត្រង់របារប្រអប់កញ្ជ្រែងទីមួយពីផ្នែកខាងក្រោយ។

   ប្រសិនបើរង្វាស់មិនស្ថិតនៅចន្លោះពី 22 ទៅ 23 ម.ម នៅផ្នែកខាងមុខ និងពី 19 ទៅ 20 ម.មនៅផ្នែកខាងក្រោយទេ ចូរចូលទៅជំហានបន្ទាប់។




YC21219—UN—21DEC22

បានបង្ហាញយន្តការលៃតម្រូវចន្លោះប្រអប់កញ្ជ្រែងចំហៀងខាងឆ្វេង

**E—ក្បាលឡោស៊ី**
**F—ប៊ូឡុងក្បាលកង**
**G—ប៊ូឡុងក្បាលកង**
**H—ក្បាលឡោស៊ី**
**I—ក្បាលឡោស៊ី**
**J—បន្ទះខ្សៀ**
**K—បន្ទះខ្សៀ**
**L—ក្បាលឡោស៊ី**

9. លៃតម្រូវកញ្ជ្រែងប្រអប់កញ្ជ្រែង (J និង K) ដើម្បីទទួលបានចន្លោះតាមចង់បាន។

   - លៃតម្រូវចន្លោះចូលដោយមួលក្បាលឡោស៊ី (E និង L) នៅចំហៀងសងខាងគ្រឿងចក្រ។
   - លៃតម្រូវចន្លោះចេះដោយមួលក្បាលឡោស៊ី (H និង I) នៅចំហៀងសងខាងគ្រឿងចក្រ។

*កំណត់ចំណាំ៖ នៅពេលបង្កើនចន្លោះ ចូរសឹករបារគាស់ចន្លោះស៊ីឡាំងបោកបែន និងប្រអប់កញ្ជ្រែង ហើយគាស់វាចុះក្រោម។*

10. ពិនិត្យមើលក្រែងលោក្បាលឡោស៊ី (E, H, I, និង L) នៅលើប៊ូឡុងក្បាលកងលៃតម្រូវមិនតឹងណែន។


11. បង្វិលប្រអប់កញ្ជ្រែងម្តងមួយដុំពេញ ហើយកំណត់ដៃលៃតម្រូវចន្លោះប្រអប់កញ្ជ្រែងទៅកាន់គន្លាក់ទីពីរពីផ្នែកខាងលើ។ពិនិត្យមើលចន្លោះប្រអប់កញ្ជ្រែងឡើងវិញ។

12. ដំឡើងបង្ហួចពិនិត្យប្រអប់កញ្ជ្រែងដែលគ្របនៅលើផ្នែកសងខាងនៃគ្រឿងចក្រវិញ។ប្រាកដថាក្បាលឡោស៊ីស្លាបតឹងណែន។

cp00834,1668907687750-KM-19NOV22


## ការលៃតម្រូវពង្រាបប្រអប់កញ្ជ្រែង

**សំខាន់៖ ការលៃតម្រូវគួរធ្វើឡើងនៅចំហៀងសងខាងក្នុងពេលជាមួយគ្នា។**




YC21220—UN—21DEC22

បានបង្ហាញចំហៀងខាងឆ្វេងនៃគ្រឿងចក្រ



YC21221—UN—21DEC22

**A—ក្បាលឡោស៊ី (ប្រើ 2)**
**B—ក្បាលឡោស៊ី (ប្រើ 2)**

ប្រអប់កញ្ជ្រែងគួរស្របគ្នានឹងស៊ីឡាំងបោកបែន។ ប្រអប់កញ្ជ្រែងត្រូវបានលៃតម្រូវនៅរោងចក្រ។

ពិនិត្យមើលការពង្រាបប្រអប់កញ្ជ្រែងឲ្យបានញឹកញាប់ ហើយលៃតម្រូវដោយមួលក្បាលឡោស៊ី (A និង B) នៅចំហៀងសងខាងតាមចាំបាច់។


*កំណត់ចំណាំ៖*

- លៃតម្រូវចន្លោះចូលដោយមួលក្បាលឡោស៊ី *(B)* នៅចំហៀងសងខាងគ្រឿងចក្រ។
- លៃតម្រូវចន្លោះចេះដោយមួលក្បាលឡោស៊ី *(A)* នៅចំហៀងសងខាងគ្រឿងចក្រ។

cp00834,1668908392880-KM-19NOV22

## ពិនិត្យ និងលៃតម្រូវតំណឹងខ្សែពានអូសប្រព័ន្ធបោកបែន

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**




YC21222—UN—21DEC22

**A—វីសលៃតម្រូវ**
**B—វីស័រ**
**C—ក្បាលឡោស៊ីមានឡក់ (ប្រើ 2)**
**D—បង្គុំប្រដាប់ចង្អុល**
**X—ចម្ងាយ**

ភ្ជាប់ប្រព័ន្ធបោកបែន វាស់ចម្ងាយ (X) រវាងផ្ទៃខ្ចៅលៃតម្រូវ (A) និងបង្គុំប្រដាប់ចង្អុល (D), ចម្ងាយគួរតែមានប្រវែងពី 23 ដល់ 27 ម.ម។


ប្រសិនបើចម្ងាយមិនស្ថិតនៅក្នុងកម្រិតដែលបានណែនាំទេ ចូរបន្ធូរក្បាលឡោស៊ីមានឡក់ (C) ហើយមួលខ្ចៅលៃតម្រូវដើម្បីលៃតម្រូវចម្ងាយ។ រឹតបន្តឹងឡោស៊ីមានឡក់បន្ទាប់ពីលៃតម្រូវរួច។

*កំណត់ចំណាំ៖ មុននឹងលៃតម្រូវ ចូរប្រាកដថាប្រព័ន្ធបោកបែនត្រូវបានភ្ជាប់។*

cp00834,1668908732087-KM-19NOV22

## លៃតម្រូវខ្សែពានអូសប្រព័ន្ធបោកបែន និងចន្លោះប្រដាប់នាំផ្លូវខ្សែពាន

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21223—UN—21DEC22

**A—ប៊ូឡុង (ប្រើ 3)**
**B—ខ្សែពានអូស**
**C—ប្រដាប់នាំផ្លូវខ្សែពាន**


ភ្ជាប់ប្រព័ន្ធបោកបែន ចន្លោះរវាងខ្សែពានអូស (B) និងប្រដាប់នាំផ្លូវខ្សែពាន (C) គួរតែមានប្រវែងពី 2 ដល់ 5 ម.ម។

លៃតម្រូវចន្លោះដោយមួយប៊ូឡុងបីគ្រាប់ (A)។ ពិនិត្យមើលចន្លោះឲ្យបានញឹកញាប់។

cp00834,1668908774767-KM-19NOV22

## ពិនិត្យមើលការកកស្ទះស៊ីឡាំងបោកបែន

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21224—UN—21DEC22

បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ

**A—ក្បាលឡោស៊ីរឹតដោយដៃ (ប្រើ 2)**
**B—គម្របពិនិត្យ**


បន្ធូរក្បាលឡោស៊ីរឹតដោយដៃ (A) នៅចំហៀងសងខាង ហូតចូលក្នុងរួមជាមួយគន្លឹះ ហើយដោះគម្របពិនិត្យ (B) ចេញ ដើម្បីពិនិត្យមើលការកកស្ទះ។

cp00834,1668908809681-KM-19NOV22

## សម្អាតការកកស្ទះស៊ីឡាំងបោកបែន


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

**សំខាន់៖ មុននឹងសម្អាតការកកស្ទះ ចូរលែតម្រូវចន្លោះប្រអប់កង្ហែងទៅដល់តម្លៃអតិបរមា។**




YC21224—UN—21DEC22

បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ




YC21225—UN—21DEC22

បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ


**A—ក្បាលឡោស៊ីរីតដោយដៃ (ប្រើ 2)**
**B—គម្របពិនិត្យខាងមុខ**
**C—គម្របពិនិត្យចំហៀង (ប្រើ 2)**

បន្ធូរក្បាលឡោស៊ីរីតដោយដៃ (A) នៅចំហៀងសងខាង ហូតចូលក្នុងរួមជាមួយគន្លឹះ ហើយដោះគម្របពិនិត្យខាងមុខ (B) ចេញ ដើម្បីសម្អាតការកកស្ទះ។

ដោះគម្របពិនិត្យចំហៀង (C) នៅចំហៀងសងខាងចេញ ដើម្បីសម្អាតការកកស្ទះ។

cp00834,1668908846335-KM-19NOV22

## សម្អាតការកកស្ទះស៊ីឡាំងបោកបែនដោយបង្ខិលស៊ីឡាំងបោកបែនបញ្ច្រាស





YC21226—UN—21DEC22

បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ


**A—ក្បាលឡោស៊ីរីតដោយដៃ (ប្រើ 2)**
**B—គម្របពិនិត្យ**
**C—គម្របពិនិត្យ**
**D—ក្បាលឡោស៊ីរីតដោយដៃ (ប្រើ 2)**

1. ផ្តាច់ប្រព័ន្ធបោកបែន
2. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
3. បន្ធូរក្បាលឡោស៊ីរីតដោយដៃ (A និង D) នៅចំហៀងសងខាង ហូតចូលក្នុងរួមជាមួយគន្លឹះហើយដោះគម្របពិនិត្យ (B និង C) ចេញ។




YC21227—UN—21DEC22

ស៊ីឡាំងបោកបែន(ដែលមិនមានស្តីបន្ថយល្បឿនស៊ីឡាំងបោកបែន ចំហៀងខាងស្តាំ)




YC21228—UN—21DEC22

**E—ដុំកង**
**F—ដែកគាស់**
**G—ប៉ូលីអូស**
**H—ដែកគាស់**

**ស៊ីឡាំងបោកបែនដោយមិនចាំបាច់កាត់បន្ថយស៊ីឡាំង៖** ប្តូរទិសដៅស៊ីឡាំងបោកបែនបញ្ច្រាស់ដោយការបង្វិលដុំ (E) ផ្គួយទៅនឹងទ្រនិចនាឡិកាដោយដែកគាស់ (F)។


**ស៊ីឡាំងបោកបែនដោយត្រូវបន្ថយស៊ីឡាំង៖** ប្តូរទិសដៅស៊ីឡាំងបោកបែនបញ្ច្រាស់ដោយការបង្វិលប៉ូលីដុំអូស (G) តាមទិសដៅទ្រនិចនាឡិកាដោយដែកគាស់ (H)។

*កំណត់ចំណាំ៖ អាចប្រើដែកគាស់ដើម្បីជួយត្រឡប់ស៊ីឡាំងបោកបែន។*

cp00834,1668908892001-KM-19NOV22

## ប្តូររបាររូស

*កំណត់ចំណាំ៖ របាររូសអាចប្តូរដោយមិនចាំបាច់ដោះស៊ីឡាំងបោកបែនឡើយ។*





YC21224—UN—21DEC22
បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ

**A—ក្បាលឡោស៊ីរីតដោយដៃ (ប្រើ 2)**
**B—គម្របពិនិត្យ**

1. ផ្តាច់ប្រព័ន្ធបោកបែន។
2. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
3. បន្ធូរក្បាលឡោស៊ីរីតដោយដៃ (A) នៅចំហៀងសងខាង ហូតចូលក្នុងរួមជាមួយគន្លឹះហើយដោះគម្របពិនិត្យ (B) ចេញ។

*កំណត់ចំណាំ៖ ស៊ីឡាំងបោកបែនមានបំពាក់របាររូសដែលមានធ្មេញខាងស្តាំ និងខាងឆ្វេងដែលដំឡើងជាជម្រើស។*




YC21229—UN—21DEC22

**C—របាររូស**


4. ប្តូររបាររូសដែលសឹករេចរឺ និងរបាររូសបន្សុីនៅចំហៀងម្ខាងទៀតនៃស៊ីឡាំងបោកបែនក្នុងពេលជាមួយគ្នា។
5. រឹតបន្តឹងប៊ូឡុងចាប់របាររូស។

**សំខាន់៖ រឹតបន្តឹងប៊ូឡុងរបាររូសដែលបានប្តូរឡើងវិញបន្ទាប់ពីដំណើរការបាន 10 ម៉ោងដំបូង។**

cp00834,1668909430430-KM-19NOV22

## ប្តូរធ្មេញវែង

*កំណត់ចំណាំ៖ ធ្មេញវែងអាចប្តូរដោយមិនចាំបាច់ដោះស៊ីឡាំងបោកបែនឡើយ។*





YC21224—UN—21DEC22
បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ

**A—ក្បាលឡោស៊ីរីតដោយដៃ (ប្រើ 2)**
**B—គម្របពិនិត្យ**

1. ផ្តាច់ប្រព័ន្ធបោកបែន។
2. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
3. បន្ធូរក្បាលឡោស៊ីរីតដោយដៃ (A) នៅចំហៀងសងខាង ហូតចូលក្នុងរួមជាមួយគន្លឹះហើយដោះគម្របពិនិត្យ (B) ចេញ។

**សំខាន់៖ យកចិត្តទុកដាក់ចំពោះទិសដៅធ្មេញវែងនៅពេលដំឡើងធ្មេញវែងថ្មី។**




YC21230—UN—21DEC22

**C—ធ្មេញវែង**

4. ប្តូរធ្មេញវែងដែលសឹករេចរឹល ហើយរឹតបន្តឹងប៊ូឡុងភ្ជាប់ធ្មេញទាំងនោះ។


*កំណត់ចំណាំ៖ អាចប្រើញញួរដើម្បីជួយប្តូរធ្មេញវែង។*

cp00834,1668909576085-KM-19NOV22

## រំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងផ្តល់សេវាថែទាំ

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

1. បិទកុងតាក់ផ្តាច់អាគុយ។





YC20561—UN—02SEP22

ផ្តាច់តំណអគ្គិសនី

**A—ចង្វាយខ្សែភ្លើង**
**B—អង្គញ្ជាណ**


2. ផ្តាច់តំណអគ្គិសនីពីអង្គញ្ជាណ (B)។
3. ផ្តាច់ចង្វាយខ្សែភ្លើង (A) ចេញពីគម្របក្រោយ។




YC21231—UN—21DEC22

**C—គម្របខាងក្រោយ**
**D—ទម្រ**
**E—គម្របខាងក្រោយ**
**F—ប៊ូឡុង (ប្រើ 2)**


4. ដោះប៊ូឡុង (F) និងគម្របក្រោយ (C) ចេញ។
5. ដោះប៊ូឡុង និងគម្របក្រោយ (E) ចេញ។
6. ចូរដោះប៊ូឡុង និងដោះទម្រ (D)។




YC21232—UN—21DEC22

**G—ប៊ូឡុង (ប្រើ 4)**
**H—អង្គបង្ហែរ**

7. ដោះប៊ូឡុង (G) និងអង្គបង្ហែរ (H) ចេញ។





YC21233—UN—21DEC22

ដោះតំណសកល

**I—ប៊ូឡុង (ប្រើ 3)**
**J—តំណសកល**
**K—ប៊ូឡុង (ប្រើ 4)**

8. ដោះប៊ូឡុង (I) និងតំណសកល (J)។
9. ដោះប៊ូឡុង (K) នៅចំហៀងសងខាង។





YC21234—UN—21DEC22

បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ

**L—ប៊ូឡុង (ប្រើ 2)**
**M—ប៊ូឡុង (ប្រើ 2)**

10. ដោះប៊ូឡុង (L និង M) ចេញពីចំហៀងទាំងសងខាងគ្រឿងចក្រ។




YC21235—UN—21DEC22

**N—ទ្វារច្រកចូលផ្នែកខាងក្រោយ**
**O—ប៊ូឡុង (ប្រើ 6)**
**P—បន្ទះ (ប្រើ 2)**
**Q—ឆ្នង**
**R—បំពង់ (ប្រើ 2)**
**S—ប៊ូឡុង**

11. បើកទ្វារច្រកចូលខាងក្រោយ (N) នៅលើគ្រឿងចក្រ។
12. ដោះប៊ូឡុង (O) និងបន្ទះ (P) នៅចំហៀងសងខាង។
13. ដោះប៊ូឡុង (S) ចេញ។
14. សឹកដែកគាស់ចំនួនពីរនៅក្នុងបំពង់ (R) ពីរ។


**⚠ ប្រយ័ត្ន៖ គ្រឿងបំបែកមានទម្ងន់ធ្ងន់។ ទ្រគ្រឿងបំបែកនៅពេលវាស្ថិតនៅត្រង់ទីតាំងផ្តល់សេវា។**

15. គាស់ដែកគាស់ដើម្បីរំកិលគ្រឿងបំបែកចេញទៅកាន់ទីតាំងផ្តល់សេវា។


*កំណត់ចំណាំ៖ រមៀលគ្រឿងបំបែកចេញរហូតទាល់តែវាប៉ះនឹងទំនប់។*

cp00834,1668909769039-KM-19NOV22

## ត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារ។




YC20565—UN—02SEP22




YC20566—UN—02SEP22


**A—បំពង់ (ប្រើ 2)**
**B—ប៊ូឡុង (ប្រើ 3)**
**C—ឧបករណ៍ពិសេស**
**D—ឧបករណ៍ពិសេស**

1. សឹកដែកគាស់ចំនួនពីរនៅក្នុងបំពង់ (A) ចំនួនពីរ។

2. គាស់ដែកគាស់ដើម្បីរំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារ។
3. ដំឡើងឧបករណ៍ពិសេស (C និង D)។

*កំណត់ចំណាំ៖ រំកិលម៉ូឌុលគ្រឿងបំបែកដើម្បីឲ្យស៊ីគ្នាជាមួយដងទាំងពីរតាមចាំបាច់។*


4. ចាប់ប៊ូឡុង (B) ហើយរឹតបន្តឹង។




YC21236—UN—21DEC22

**E—ទ្វារច្រកចូលផ្នែកខាងក្រោយ**
**F—ប៊ូឡុង (ប្រើ 6)**
**G—បន្ទះ (ប្រើ 2)**
**H—ដង**
**I—ប៊ូឡុង**


5. ចាប់ប៊ូឡុង (I) ហើយរឹតបន្តឹងវា។
6. ដំឡើងបន្ទះ (G) ហើយរឹតបន្តឹងប៊ូឡុង (F) នៅចំហៀងសងខាង។
7. បិទទ្វារច្រកចូលផ្នែកខាងក្រោយ (E)។




YC21237—UN—21DEC22

**J—ប៊ូឡុង (ប្រើ 2)**
**K—ប៊ូឡុង (ប្រើ 2)**


8. ចាប់ប៊ូឡុង (J និង K) ហើយរឹតបន្តឹងពួកវានៅចំហៀងសងខាងគ្រឿងចក្រ។




YC21238—UN—21DEC22

**L—ប៊ូឡុង (ប្រើ 3)**
**M—តំណសកល**
**N—ប៊ូឡុង (ប្រើ 4)**


9. ចាប់ប៊ូឡុង (N) ហើយរឹតបន្តឹងពួកវានៅចំហៀងសងខាង។
10. ដោះប៊ូឡុងទាំងបីគ្រាប់ និងឧបករណ៍ពិសេស។
11. ដំឡើងតំណសកល (M)។
12. ចាប់ប៊ូឡុង (L) ហើយរឹតបន្តឹង។




YC21239—UN—21DEC22

**O—ប៊ូឡុង (ប្រើ 4)**
**P—អង្គបង្វែរ**


13. ដំឡើងអង្គបង្វែរ (P) ហើយរឹតបន្តឹងប៊ូឡុង (O)។




YC21240—UN—21DEC22

**Q—គម្របខាងក្រោយ**
**R—ទម្រ**
**S—គម្របខាងក្រោយ**
**T—ប៊ូឡុង (ប្រើ 2)**

14. ដំឡើងទម្រ (R) ដោយប្រើប៊ូឡុង។
15. ដំឡើងគម្របក្រោយ (S និង Q) ដោយប្រើប៊ូឡុង។




YC21241—UN—21DEC22

**U—ចង្វាយខ្សែក្រឹង**
**V—អង្គញ្ជាណ**

16. តភ្ជាប់ចង្វាយខ្សែក្រឹង។ (U) ទៅកាន់គម្របខាងក្រោយ។
17. ភ្ជាប់តំណអគ្គិសនីទៅកាន់អង្គញ្ជាណ (B)។

cp00834,1668911293604-KM-19NOV22

## សម្អាតការកកស្ទះគ្រឿងបំបែក

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

1. បិទកុងតាក់ផ្តាច់អាគុយ។
2. រំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងសេវាថែទាំ។ (អានអំពីការរំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងផ្តល់សេវាថែទាំនៅក្នុងផ្នែកនេះ។)



YC21242—UN—21DEC22


3. សម្អាតការកកស្ទះ។
4. ត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារ។ (អានអំពីការត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារនៅក្នុងផ្នែកនេះ។)

cp00834,1668911397460-KM-19NOV22

## សម្អាតស្មៀតគ្រឿងបំបែក

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

**ដើម្បីបង្ការការរងរបួសផ្ទាល់ខ្លួន ត្រូវដឹងអំពីនីតិនិងកម្មេចដែលធ្លាក់ នៅពេលដោះបន្ទះចេញ។**




YC21243—UN—21DEC22

**A—បន្ទះ (ប្រើ 2)**
**B—ក្បាលឡោស៊ុស្លាប (ប្រើ 8)**


ពិនិត្យមើលស្មៀតគ្រឿងបំបែកឱ្យបានទៀងទាត់។ សម្អាតការកកស្ទះតាមចាំបាច់។

ដោះក្បាលឡោស៊ុស្លាប (B) និងបន្ទះ (A) ចេញដើម្បីសម្អាតការកកស្ទះ។

cp00834,1668912793249-KM-19NOV22

## លៃតម្រូវតំណឹងខ្សែពានអូសគ្រឿងបំបែក

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21245—UN—21DEC22

**A—ប្រដាប់បន្តឹងខ្សែពាន**
**B—ខ្សែពានអូស**
**C—រីស័រ**
**D—ក្បាលឡោស៊ី (ប្រើ 2)**

ខ្សែពានអូសគ្រឿងបំបែក (B) ត្រូវបានបន្តឹងដោយស្វ័យប្រវត្តិដោយប្រដាប់បន្តឹងខ្សែពាន (A) តាមរយៈសកម្មភាពរបស់រីស័រ (C)។


លៃតម្រូវប្រវែងរីស័រទៅកាន់ប្រវែងពី 130 ដល់ 160 ម.ម ដោយមួលក្បាលឡោស៊ី (D)។

cp00834,1668913080270-KM-19NOV22

## ប្តូរគ្រឿងសម្រាប់គ្រឿងបំបែក (គ្រឿងបំបែកដែលមានធ្មេញបែបបំពង)

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

1. បិទកុងតាក់ផ្គាច់អាគុយ។
2. រំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងសេវាថែទាំ។ (អានអំពីការរំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងផ្តល់សេវាថែទាំនៅក្នុងផ្នែកនេះ។)




YC21244—UN—21DEC22
គ្រឿងបំបែកដែលមានធ្មេញបែបបំពង

**A—ធ្មេញសម**
**B—ប្រដាប់ញែកលំហូរ**

3. ប្តូរធ្មេញដែលសឹក (A) និងប្រដាប់ញែកលំហូរ (B) តាមចាំបាច់។

*កំណត់ចំណាំ៖ ដោះគម្របខាងលើគ្រឿងបំបែកចេញតាមចាំបាច់។*

*កំណត់ចំណាំ៖ ដើម្បីឲ្យមានលំនឹង ចូរប្តូរគ្រឿងសម្រាប់គ្រឿងបំបែកម្ខាងទៀតក្នុងពេលជាមួយគ្នា។*


4. ត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារ។ (អានអំពីការត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារនៅក្នុងផ្នែកនេះ។)

cp00834,1669007170927-KM-20NOV22

## ប្តូរបន្ទះដែលសឹក (គ្រឿងបំបែកមានធ្មេញបែបទ្រុង)

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

1. បិទកុងតាក់ផ្គាច់អាគុយ។
2. រំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងសេវាថែទាំ។ (អានអំពីការរំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងផ្តល់សេវាថែទាំនៅក្នុងផ្នែកនេះ។)




YC8343—UN—25MAR15
គ្រឿងបំបែកដែលមានធ្មេញបែបទ្រុង

**A—ប៊ូឡុង (ប្រើ 4)**
**B—បន្ទះការពារសំណឹក**

3. ដោះប៊ូឡុង (A) ចេញ ។
4. ប្តូរបន្ទះដែលសឹក (B) នៅពេលវាសឹកខ្លាំង។

*កំណត់ចំណាំ៖ ដោះគម្របខាងលើគ្រឿងបំបែកចេញតាមចាំបាច់។*


5. ត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារ។ (អានអំពីការត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារនៅក្នុងផ្នែកនេះ។)

cp00834,1669007464510-KM-20NOV22

# ការថែទាំប្រព័ន្ធសម្អាតតាមចាំបាច់

## លៃតម្រូវតំណឹងខ្សែពានអូសប្រព័ន្ធសម្អាត

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21214—UN—21DEC22

**A—ខ្សែពានអូស**
**B—ប្រដាប់បន្តឹងខ្សែពាន**
**C—រ៉ឺស័រ**
**D—ប៉ូលីអូស**


ខ្សែពានអូស (A) ត្រូវបានបន្តឹងដោយស្វ័យប្រវត្តិដោយប្រដាប់បន្តឹងខ្សែពាន (B) តាមរយៈសកម្មភាពរបស់រ៉ឺស័រ (C)។

លៃតម្រូវប្រវែងរ៉ឺស័រ 75 ម.ម។

cp00834,1668856357856-KM-19NOV22

## លៃតម្រូវតំណឹងច្រវាក់អូសស្បែកជើងសម្អាត

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21215—UN—21DEC22

**A—រ៉ឺស័រ**
**B—ទ្រនាប់កៅស៊ូ**
**C—ក្បាលឡោស៊ី**
**D—ក្បាលឡោស៊ី**
**E—ប្រដាប់បន្តឹងខ្សែពាន**


ដុំអូសច្រវាក់ស្បែកជើងសម្អាតត្រូវបានបន្តឹងដោយស្វ័យប្រវត្តិដោយប្រដាប់បន្តឹងខ្សែពាន (E) តាមរយៈសកម្មភាពរបស់រ៉ឺស័រ (A)។

លៃតម្រូវប្រវែងរ៉ឺស័រដោយមូលក្បាលឡោស៊ី (C និង D) ដើម្បីកាត់បន្ថយផលប៉ះពាល់លើយន្តការលៃតម្រូវនៅក្នុងលក្ខខណ្ឌបំពេញការងារជាអតិបរមា។

cp00834,1668856336170-KM-19NOV22

## លៃតម្រូវការអូសកង្ហារសម្អាត

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21216—UN—21DEC22

**A—ប្រដាប់ទប់រ៉ឺស័រ**
**B—ប៉ូលី**
**C—ប៉ូលី**
**D—ប៊ូឡុង (ប្រើ 3)**
**X—ទំហំ**

រឹតបន្តឹងប៊ូឡុងទាំងបី (D) ដើម្បីបង្កើតទំហំ (X) ពី 103 ដល់ 105 ម.ម នៅពេលប៉ូលី (B និង C) ត្រូវបានបិទទាំងស្រុង។


*កំណត់ចំណាំ៖ វាស់ទំហំពីផ្នែកខាងក្រៅប្រដាប់ទប់រ៉ឺស័រ (A) ទៅដល់ផ្នែកខាងក្រៅប៉ូលី (B)។*

cp00834,1668856370296-KM-19NOV22

## ប្តូរសម្រាបកៅស៊ូ

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

*កំណត់ចំណាំ៖ ប្តូរសម្រាបកៅស៊ូម្ខាងទៀតនៅពេលប្តូរសម្រាបកៅស៊ូដែលសឹក ឬបាក់។*




YC21217—UN—21DEC22

សម្រាបកៅស៊ូ (បានបង្ហាញចំហៀងខាងឆ្វេងគ្រឿងចក្រ)

**A—ដំបងស្បែកជើងសម្អាត**
**B—ប្រដាប់រវៃ**
**1—សម្រាបកៅស៊ូ**
**2—សម្រាបកៅស៊ូ**
**3—សម្រាបកៅស៊ូ**
**4—សម្រាបកៅស៊ូ**
**5—សម្រាបកៅស៊ូ**
**6—សម្រាបកៅស៊ូ**
**7—សម្រាបកៅស៊ូ**
**8—សម្រាបកៅស៊ូ**
**9—សម្រាបកៅស៊ូ**
**10—សម្រាបកៅស៊ូ**
**11—សម្រាបកៅស៊ូ**
**12—សម្រាបកៅស៊ូ**
**13—សម្រាបកៅស៊ូ**

បន្ទាប់ពីប្តូរសម្រាបកៅស៊ូនៅលើដំបងស្បែកជើងសម្អាត (A) និងប្រដាប់ញ្ឆរ ចូរត្រឡប់ប៉ូលីអូសចម្បងដោយដៃរហូតទាល់តែបន្ទាត់កណ្តាលតាមដំបងស្បែកជើងបង្កើតបានមុំ 90° ជាមួយបន្ទាត់ដែលភ្ជាប់ដុំដងស្គួល និងចំណុចកណ្តាលនៃប្រដាប់រវៃ (B), បន្ទាប់មកវិតបន្តឹងក្បាលឡោស៊ីទាំងអស់។


អនុវត្តតាមលំដាប់ (1 ដល់ 13) ដើម្បីប្តូរសម្រាបកៅស៊ូទាំងអស់។

cp00834,1668856740209-KM-19NOV22

# ការថែទាំប្រព័ន្ធបួងទម្លាក់ និងប្រដាប់យោងតាមចាំបាច់

## លៃតម្រូវតំណឹងខ្សែពានប្រដាប់យោងគ្រាប់ធញ្ញជាតិ

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21246—UN—21DEC22

**A—ប្រដាប់យោងគ្រាប់ធញ្ញជាតិ**
**B—ខ្សែពានអូស**
**C—ប្រដាប់បន្តឹងខ្សែពាន**
**D—រីស័រ**


ខ្សែពានអូស (B) ត្រូវបានបន្តឹងដោយស្វ័យប្រវត្តិដោយប្រដាប់បន្តឹងខ្សែពាន (C) តាមរយៈសកម្មភាពរបស់រីស័រ (D)។

លៃតម្រូវប្រវែងរីស័រពី 79 ដល់ 81 ម.ម។

cp00834,1668914195212-KM-19NOV22

## លៃតម្រូវតំណឹងច្រវាក់អូសប្រដាប់យោងគ្រាប់ស្កក

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21247—UN—21DEC22

**A—ក្បាលឡោស៊ី**
**B—ប្រដាប់បន្តឹងខ្សែពាន**
**C—បន្ទាបដងប្រដាប់បួងគ្រាប់ស្កក**
**D—ច្រវាក់អូស**
**E—បន្ទាបដងប្រដាប់បួងគ្រាប់ធញ្ញជាតិ**


បន្ទរក្បាលឡោស៊ី (A), រំកិលប្រដាប់បន្តឹងខ្សែពាន (B) ឡើងលើដើម្បីបន្តឹងច្រវាក់អូស (D)។ រឹតបន្តឹងឡោស៊ីបន្ទាប់ពីលៃតម្រូវរួច។

cp00834,1668914256573-KM-19NOV22

## ពិនិត្យមើលតំណឹងច្រវាក់គ្រឿងបញ្ជូនប្រដាប់យោង

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

**សំខាន់៖ ពិនិត្យមើលចន្លោះរៀបរាល់ថ្ងៃ។**



YC21248—UN—21DEC22

នៅពេលច្រវាក់គ្រឿងបញ្ជូនប្រដាប់យោងតឹង អាចរំកិលតំណច្រវាក់ដោយដៃទៅឆ្វេង និងស្តាំនៅលើកង់ច្រវាក់។


ជាធម្មតា តំណច្រវាក់ទីមួយនៅក្រោយកង់ច្រវាក់អាចលើកបានពី 6 ដល់ 10 ម.ម។ លៃតម្រូវភាពតឹងច្រវាក់គ្រឿងបញ្ជូនប្រដាប់យោងតាមចាំបាច់។

cp00834,1668914306285-KM-19NOV22

## លៃតម្រូវតំណឹងច្រវាក់គ្រឿងបញ្ជូនប្រដាប់យោងគ្រាប់ធញ្ញជាតិ

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

*កំណត់ចំណាំ៖ ធ្វើការលៃតម្រូវនៅចំហៀងសងខាងក្នុងពេលជាមួយគ្នា។*




YC8247—UN—05FEB15

**A—ប៊ូឡុង (ប្រើ 2)**
**B—ក្បាលឡោស៊ុ (ប្រើ 6)**
**C—ប្រដាប់បន្ថឹងខ្សែពាន**
**D—ឡោស៊ុ (ប្រើ 4)**
**E—សម្បកបាដាង (ប្រើ 2)**
**F—ច្រវាក់អូស**


1. បន្ធូរប្រដាប់បន្ថឹង (C) ដើម្បីបន្ធូរច្រវាក់អូស (F)។
2. បន្ធូរក្បាលឡោស៊ុ (D) ដើម្បីលៃតម្រូវទីតាំងសម្បកបាដាង (E) ដោយមួលក្បាលឡោស៊ុ(B) នៅចំហៀងសងខាង។
3. រឹតបន្ថឹងក្បាលឡោស៊ុ (B និង D) ហើយពិនិត្យមើលតំណឹងច្រវាក់គ្រឿងបញ្ជូន។
4. បន្ថឹងច្រវាក់អូស និងរឹតបន្ថឹងប្រដាប់បន្ថឹង (C)។

cp00834,1669008221194-KM-21NOV22

## លៃតម្រូវតំណឹងច្រវាក់គ្រឿងបញ្ជូនប្រដាប់យោងគ្រាប់ស្កក

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

*កំណត់ចំណាំ៖ ធ្វើការលៃតម្រូវនៅចំហៀងសងខាងក្នុងពេលជាមួយគ្នា។*




YC21289—UN—21DEC22
ផ្នែកខាងក្រៅប្រដាប់យោងគ្រាប់ស្កក


**A—សម្បកបាដាង (ប្រើ 2)**
**B—ក្បាលឡោស៊ុ (ប្រើ 6)**
**C—ប៊ូឡុង (ប្រើ 2)**
**D—ក្បាលឡោស៊ុ**
**E—ប្រដាប់បន្ថឹងខ្សែពាន**
**F—ច្រវាក់អូស**
**G—ក្បាលឡោស៊ុ (ប្រើ 4)**

1. បន្ធូរក្បាលឡោស៊ុ (D) នៅលើប្រដាប់បន្ថឹង (E) ដើម្បីបន្ធូរច្រវាក់អូស(F)។
2. បន្ធូរក្បាលឡោស៊ុ (G) ដើម្បីលៃតម្រូវទីតាំងសម្បកបាដាង (A) ដោយមួលក្បាលឡោស៊ុ(B) នៅចំហៀងសងខាង។
3. រឹតបន្ថឹងក្បាលឡោស៊ុ (B និង G) ហើយពិនិត្យមើលតំណឹងច្រវាក់គ្រឿងបញ្ជូន។
4. រឹតបន្ថឹងច្រវាក់ និងរឹតបន្ថឹងក្បាលឡោស៊ុ (D)។

cp00834,1669008791256-KM-21NOV22

## លៃតម្រូវតំណឹងច្រវាក់អូសប្រដាប់បួងពង្រាបគ្រាប់ធញ្ញជាតិ

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21290—UN—21DEC22


**A—ប្រដាប់បន្ថឹងខ្សែពាន**
**B—ក្បាលឡោស៊ុ**
**C—ច្រវាក់អូស**

បន្ធូរក្បាលឡោស៊ុ (B) នៅលើប្រដាប់បន្ថឹង (A), រឹតបន្ថឹងច្រវាក់អូស (C), ហើយរឹតបន្ថឹងក្បាលឡោស៊ុ។

cp00834,1669008868397-KM-21NOV22

## លៃតម្រូវតំណឹងច្រវាក់អូសប្រដាប់បួងគ្រាប់ស្កកខាងលើ

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21291—UN—21DEC22


**A—ក្បាលឡោស៊ី**
**B—ប្រដាប់បន្ទឹងខ្សែពាន**
**C—ច្រវាក់អូស**

បន្ធូរក្បាលឡោស៊ី (A) នៅលើប្រដាប់បន្ទឹង (B), រឹតបន្ទឹងច្រវាក់អូស (C), ហើយរឹតបន្ទឹងក្បាលឡោស៊ី។

cp00834,1669009405434-KM-21NOV22

## សម្អាតប្រដាប់យោង

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21292—UN—21DEC22

**A—ដង**
**B—ទ្វារប្រដាប់យោងគ្រាប់ធញ្ញជាតិ**
**C—ដង**
**D—ទ្វារប្រដាប់យោងគ្រាប់ស្កុក**


មុននឹងប្រតិបត្តិការគ្រឿងចក្រជារៀងរាល់ថ្ងៃ ឬប្តូរដំណាំប្រមូលផល ចូរសម្អាតប្រដាប់យោង។

បើកទ្វារប្រដាប់យោងគ្រាប់ធញ្ញជាតិ (B) និងទ្វារប្រដាប់យោងគ្រាប់ស្កុក (D) ដោយរំកិលដង (A និង C)។

cp00834,1669009889101-KM-21NOV22

## សម្អាតប្រដាប់បួងគ្រាប់ធញ្ញជាតិនិងគ្រាប់ស្កុកខាងក្រោម

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC8552—UN—24APR15

**A—កន្លាស់ខ្ចាស់ទប់គម្រប (ប្រើ 2)**
**B—ក្បាលឡោស៊ី (ប្រើ 2)**
**C—ប្រដាប់បួងគ្រាប់ធញ្ញជាតិ**
**D—ប្រដាប់បួងគ្រាប់ស្កុក**
**E—គម្របប្រដាប់បួង (ប្រើ 2)**


បន្ទាប់ពីដំណើរការគ្រឿងចក្រមួយរយៈពេលមក ឬដំណាំប្រមូលផលប្តូរ ចូរសម្អាតប្រដាប់បួងខាងក្រោម។

ដោះក្បាលឡោស៊ី (B) និងតង្កៀបទប់ (A), បើកគម្របប្រដាប់បួង (E) ដើម្បីសម្អាតប្រដាប់បួងគ្រាប់ស្កុក (D) និងប្រដាប់បួងគ្រាប់ធញ្ញជាតិ (C)។

cp00834,1669009982875-KM-21NOV22

## លៃតម្រូវខ្សែពានអូសប្រព័ន្ធបួងទម្លាក់ និងចន្លោះប្រដាប់នាំផ្លូវខ្សែពាន

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21293—UN—22NOV22

**A—ខ្សែពានអូស**
**B—ក្បាលឡោស៊ី (ប្រើ 2)**
**C—ប្រដាប់នាំផ្លូវខ្សែពាន**


នៅពេលភ្ជាប់ប្រព័ន្ធបួងទម្លាក់ ចន្លោះរវាងខ្សែពានអូស (A) ប្រដាប់នាំផ្លូវខ្សែពាន (C) គួរមានប្រវែងពី 3 ដល់ 5 ម.ម (0.12 ដល់ 0.20 អ៊ីញ)។

ប្រសិនបើតម្លៃចន្លោះមិនស្ថិតនៅក្នុងកម្រិតណែនាំទេ ចូរបន្ធូរក្បាលឡោស៊ី (B) និងលៃតម្រូវប្រដាប់នាំផ្លូវខ្សែពាន។ រឹតបន្តឹងក្បាលឡោស៊ីក្រោយពីលៃតម្រូវរួច។

cp00834,1669010268088-KM-21NOV22

## លៃតម្រូវតំណឹងច្រវាក់អូសប្រដាប់បួងខ្វែង/ប្រដាប់រុញទម្លាក់

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21295—UN—21DEC22


**A—ក្បាលឡោស៊ី**
**B—ប្រដាប់បន្តឹងខ្សែពាន**
**C—ក្បាលឡោស៊ី**
**D—ប្រដាប់បន្តឹងខ្សែពាន**

បន្ធូរក្បាលឡោស៊ី (A និង C), រឹតបន្តឹងច្រវាក់អូស ហើយរឹតបន្តឹងក្បាលឡោស៊ី។


cp00834,1669011003707-KM-21NOV22

## លៃតម្រូវតំណឹងច្រវាក់អូសប្រដាប់បួងទម្លាក់

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC10851—UN—08DEC16




YC21296—UN—21DEC22


**A—ប៊ូឡុង (ប្រើ 2)**
**B—គម្រប**
**C—ក្បាលឡោស៊ី (ប្រើ 3)**
**D—ក្បាលឡោស៊ី (ប្រើ 2)**

1. ដោះប៊ូឡុង (A) និងគម្រប (B) ចេញ។
2. បន្ធូរក្បាលឡោស៊ី (C និង D), រឹតបន្តឹងច្រវាក់អូស ហើយរឹតបន្តឹងក្បាលឡោស៊ី។

cp00834,1669011322503-KM-21NOV22

## ប្តូរប៊ូឡុងមូលផ្តាច់ដុំអូសប្រដាប់បួងទម្លាក់គ្រាប់

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC21294—UN—21DEC22

**A—ប៊ូឡុងមូលផ្តាច់**

ប៊ូឡុងមូលផ្តាច់ (A) ការពារប្រព័ន្ធទម្លាក់។

ប្រើតែប៊ូឡុងមូលផ្តាច់របស់ John Deere ប៉ុណ្ណោះ ចូរទាក់ទងអ្នកចែកចាយ John Deere ដែលទទួលសិទ្ធដើម្បីទិញប៊ូឡុងមូលផ្តាច់។


**លក្ខណៈបច្ចេកទេស**

| | |
|---|---|
| ប៊ូឡុងមូលផ្តាច់ប្រព័ន្ធទម្លាក់— | |
| កម្លាំងបង្វិល | 15 ញូតុនម៉ែត្រ (11 ផោនហ្វីត) |

cp00834,1669010796871-KM-21NOV22

## លៃតម្រូវឧបករណ៍ផ្តាច់ប្រដាប់បួងទម្លាក់ស្វ័យប្រវត្តិ

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**




YC8298—UN—06FEB15


**A—ក្រចាប់រឹត**
**B—ប៉ូលី**
**C—ខ្សែក្រឹង**
**D—ប៉ូលីប្រដាប់នាំផ្លូវ**
**E—ឡោស៊ុំ (ប្រើ 2)**
**F—រីស័រ**
**G—ប្រវែង (39 ម.ម)**

យោលប្រដាប់បួងទម្លាក់។ លៃតម្រូវឡោស៊ុំ (E) ដើម្បីប្តូរប្រវែងរីស័រ (F) រហូតដល់ប្រវែង (X) 39 ម.ម។ ប្រសិនបើខ្សែយារខ្លាំងពេក ចូរលៃតម្រូវក្រចាប់រឹត (A) ដើម្បីឱ្យខ្លី។

cp00834,1669012327255-KM-21NOV22

# ការថែទាំកាកសំណល់តាមចាំបាច់

## លៃតម្រូវតំណឹងខ្សែពានអូសកាំបិតចិញ្ច្រាំដើមដំណាំ




YC21213—UN—21DEC22

**A—ខ្សែពានអូស**
**B—រីស័រ**
**C—ប៉ូលីអូស**

ខ្សែពានអូសកាំបិតចិញ្ច្រាំដើមដំណាំ (A) តឹងដោយស្វ័យប្រវត្តិដោយប្រដាប់បន្ទឹងខ្សែពានតាមរយៈសកម្មភាពរបស់រីស័រ (B)។ លៃតម្រូវប្រវែងរីស័រទៅតាមស្ថានភាពបំពេញការងារ។

គោលការណ៍លៃតម្រូវគឺថាខ្សែពានអូសមិនក្តៅខ្លាំងនៅក្រោមបន្ទុកការងារធម្មតាឡើយ។

cp00834,1668856177284-KM-19NOV22

## ប្តូរផ្លែវិលកាំបិតចិញ្ច្រាំដើមដំណាំ


**ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

**ដើម្បីបង្ការការរងរបួស ចូរធានាសុវត្ថិភាពរ៉ូទ័រមុននឹងប្តូរផ្លែកាំបិតចិញ្ច្រាំ។**

**សំខាន់៖ កាំបិតចិញ្ច្រាំដែលបាក់អាចបណ្តាលឱ្យមានរំញ័រ។**

**ហាមប្រើផ្លែដែលសំលៀង។**

**ហាមប្រើផ្លែដែលរីល។**




YC8240—UN—28JAN15

**A—ក្បាលទ្បោស៊ីចាក់ខ្ចាស់ខ្លួនឯង (ចំណាត់ថ្នាក់ 10.9, M10×50)**
**B—ផ្លែវិល**

ប្តូរផ្លែដែលបាក់ និងផ្លែនៅផ្នែកម្ខាងទៀតដោយដាក់ផ្លែថ្មីដែលមានទម្ងន់ស្មើដូចគ្នានៅពេលជាមួយគ្នា។

ដោះប៊ូឡុងនិងក្បាលទ្បោស៊ីចាក់ខ្ចាស់ខ្លួនឯង (A), ប្តូរផ្លែដាក់ផ្លែថ្មី ហើយរឹតបន្តឹងប៊ូឡុងទៅតាមបច្ចេកទេស។

**លក្ខណៈបច្ចេកទេស**


ប៊ូឡុងរឹតផ្លែវិលកាំបិតចិញ្ច្រាំដើមដំណាំ—កម្លាំងបង្វិល . . . . . 50 ញូតុនម៉ែត្រ

cp00834,1659688542788-KM-05AUG22

## ប្តូរផ្លែបញ្ច្រាស់ថេរកាំបិតចិញ្ច្រាំដើមដំណាំ

**ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

**ប្រយ័ត្នផ្លែបញ្ច្រាសថេរមុត។**




YC8244—UN—04FEB15

**A—ដងរឹតទប់**
**B—ផ្លែថេរ**
**C—កន្លាស់ខ្ចាស់(ប្រើ 2)**

1. ដោះកន្លាស់ខ្ចាស់ (C) ចេញ។
2. ទាញដងទប់ (A) ចេញ។
3. ប្តូរផ្លែដែលបាក់និងរីលដាក់ផ្លែថ្មី។
4. ដំឡើងដងទប់ និងកន្លាស់ខ្ចាស់។

cp00834,1659688548302-KM-05AUG22

## មាត់ច្រកបួងចូល

| អោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **ការច្រកបញ្ចូលដើមដំណាំទៅកាន់ស៊ីឡាំងមិនរាបស្មើ ឬលោត** | ប្រដាប់បួងក្បាលឧបករណ៍កាត់ខ្ពស់ពេក។ | លៃតម្រូវប្រដាប់បួងចុះក្រោមនិងថយក្រោយ។<br>ចូរអានសៀវភៅណែនាំប្រើប្រាស់ក្បាលឧបករណ៍កាត់។ |
| | គំនរគ្រាប់ធញ្ញជាតិនៅលើរបារកាត់ | បន្ទាបកង់រ៉ក ហើយកំណត់ទីតាំងមុខនិងក្រោយឲ្យកៀកទៅនឹងរបារកាត់និងប្រដាប់បួងតាមដែលអាចធ្វើទៅបាន។<br>ចូរអានសៀវភៅណែនាំប្រើប្រាស់ក្បាលឧបករណ៍កាត់។ |
| | ដៃស្មុរអណ្តែតបត់ឡើងទៅសន្លឹកចំហៀងនៅចំហៀងម្ខាង។ | បន្ធូរនិងរឹតបន្តឹងច្រវាក់ម្តងទៀត។ ពន្លាឲ្យត្រង់ ឬប្តូរផ្នែកដែលកោងចេញ។ |
| | ច្រវាក់អូសប្រដាប់ច្រកបញ្ចូលខ្ពស់ពេកនិងទប់ស្មុរអណ្តែតមិនឲ្យចុះក្រោម។ | លៃតម្រូវច្រវាក់ដឹកនាំឲ្យដល់តំណឹងត្រឹមត្រូវ។ |
| | ការរអិលខ្សែពានអូសក្បាលឧបករណ៍កាត់។ | លៃតម្រូវកង់ដើម្បីបន្តឹងខ្សែពានអូស។ |
| | ប្រដាប់បួងនៅខាងមុខឆ្ងាយពីប្រដាប់ច្រៀកពេក។ | លៃតម្រូវប្រដាប់បួងត្រលប់ទៅកាន់ប្រដាប់ច្រៀក។<br>ចូរអានសៀវភៅណែនាំប្រើប្រាស់ក្បាលឧបករណ៍កាត់។ |
| | ច្រវាក់គ្រឿងបញ្ជូនប្រដាប់ច្រកបញ្ចូលស្ថិតនៅលើកង់ត្រឹមត្រូវ។ | ដាក់ច្រវាក់នៅលើកង់មានធ្មេញត្រឹមត្រូវ។ |
| | បន្ទះប្រដាប់អូសប្រដាប់ច្រកបញ្ចូលបានដើយឡើង។ | ពន្លាឲ្យត្រង់ ឬប្តូរបន្ទះដែលកោងចេញ។ |
| | កម្ទេចកម្ទីនិងដំរកកក្តាំពនៅលើបាតមាត់ច្រកបួងចូល។ | សម្អាតបាតមាត់ច្រកបួងចូល។ |
| | គម្លាតធំពេករវាងប្រដាប់បួងផ្លែតហ្វូមនិងស្មុរខាងមុខមាត់ច្រកបួងចូល។ | បន្ថែមតំណទៅលើច្រវាក់មាត់ច្រកបួងចូល។ |
| **ក្បាលឧបករណ៍កាត់ឬកង់រ៉កនឹងមិនលើកដោយត្រឹមត្រូវឡើយ** | ខ្យល់នៅក្នុងប្រព័ន្ធអ៊ីដ្រូលិក។ | រឹតបន្តឹងក្រចាប់រឹតនៅលើទុយោ ឬប៉ពង់ដែលធ្លាយ។ ច្រាលខ្យល់ចេញពៅប្រព័ន្ធលើកកង់រ៉ក។<br>ចូរអានសៀវភៅណែនាំប្រើប្រាស់ក្បាលឧបករណ៍កាត់។ |



## ប្រព័ន្ធបោកបែន និងប្រព័ន្ធសម្អាត

| អោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **គ្រាប់ដែលមិនរលេះ** | ល្បឿនបើកបែនយឺតពេកសម្រាប់ដំណាំ។ | បង្កើនល្បឿនបោកបែន។ បន្ទាប់ពីលៃតម្រូវរួច ចូរពិនិត្យមើលគុណភាពគ្រាប់ធញ្ញជាតិ។ |

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| | ចន្លោះប្រអប់កញ្ជ្រែងធំទូលាយពេក។ | បន្តយចន្លោះប្រអប់កញ្ជ្រែង។ បន្ទាប់ពីលៃតម្រូវរួច ចូរពិនិត្យមើលគុណភាពគ្រាប់ធញ្ញជាតិ។ |
| | ចន្លោះប្រអប់កញ្ជ្រែងមិនស្មើគ្នាចាប់ពីមុខទៅដល់ក្រោយ។ | លៃតម្រូវការពង្រាបប្រអប់កញ្ជ្រែង។ |
| | មិនមានសម្ពាធគ្រប់គ្រាន់ចូលទៅក្នុងគ្រឿងចក្រច្រូតកាត់សម្រាប់បោកបែនឱ្យបានត្រឹមត្រូវ។ | បង្កើនល្បឿនលើដី។ |
| **គ្រាប់ធញ្ញជាតិនៅក្នុងធុងជាក់ច្រើនពេក** | ល្បឿនបើកបែនលឿនពេកសម្រាប់ដំណាំ។ | បន្តយល្បឿនបោកបែន។ បន្ទាប់ពីលៃតម្រូវរួច ចូរពិនិត្យមើលគុណភាពគ្រាប់ធញ្ញជាតិ។ |
| | ចន្លោះប្រអប់កញ្ជ្រែងតូចពេក។ | បង្កើនចន្លោះប្រអប់កញ្ជ្រែង។ បន្ទាប់ពីលៃតម្រូវរួច ចូរពិនិត្យមើលគុណភាពគ្រាប់ធញ្ញជាតិ។ |
| | គ្រាប់ច្រើនពេកនៅក្នុងបន្ទះបិទបើកខាងក្រោយ។ | បង្កើនប្រឡោះកន្ត្រែងបន្តិច។ |
| | មិនមានសម្ពាធគ្រប់គ្រាន់ចូលទៅក្នុងគ្រឿងចក្រ។ | បង្កើនល្បឿនលើដី។ |
| **ធុងគ្រាប់ធញ្ញជាតិកខ្វក់** | ការបោកបែនមិនគ្រប់គ្រាន់។ | បង្កើនល្បឿនបោកបែន។ បន្ទាប់ពីលៃតម្រូវរួច ចូរពិនិត្យមើលគុណភាពគ្រាប់ធញ្ញជាតិ។ |
| | | បន្តយចន្លោះប្រអប់កញ្ជ្រែង។ បន្ទាប់ពីលៃតម្រូវរួច ចូរពិនិត្យមើលគុណភាពគ្រាប់ធញ្ញជាតិ។ |
| | | ពិនិត្យមើលការពង្រាបប្រអប់កញ្ជ្រែង។ |
| | ល្បឿនកង្ហារសម្អាតយឺតពេក។ | បង្កើលុបឿនកង្ហារសម្អាត។ |
| **ការជាត់បង់គ្រាប់ធញ្ញជាតិទៅលើស្បែកជើងសម្អាត** | ពិនិត្យមើលប្រឡោះធ្មេញកញ្ជ្រែង/កន្ត្រែង | ពិនិត្យនិងក្រិតប្រឡោះធ្មេញ/កន្ត្រែងតាមខ្នាត។ |
| | ការបែងចែកដើមដំណាំ/គ្រាប់នៅលើការសម្អាតប្រអប់ជើងមិនត្រឹមត្រូវ។ | កែតម្រូវល្បឿនកង្ហារសម្អាត។ |

CP00834,0008B72-KM-17MAR21

## ប្រព័ន្ធអូសលើដី (ការអូសដោយមេកានិក)

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **គ្រឿងចក្រនឹងមិនដំណើរការទៅមុខ ឬថយក្រោយឡើយ** | ប្រអប់លេខស្ថិតនៅក្រៅស្តីប្លែរ។ | ប្តូរប្រអប់លេខ។ |
| | គ្រឿងក្រោម Posi-Torq™ មិនដំណើរការ។ | ដាក់ប្រេងរំអិលគ្រឿងខាងក្រោម Posi-Torq™។ |

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **ប្រអប់លេខពិបាកប្តូរ ឬមិនប្តូរ។** | អំប្រាយ៉ាមិនភ្ជាប់។ | លៃតម្រូវចន្លោះអំប្រាយ៉ា។ |
| | ខ្សែគ្រប់គ្រងចង្កឹះលេខមិនអាចលៃតម្រូវបាន។ | លៃតម្រូវខ្សែគ្រប់គ្រងចង្កឹះលេខ។ |
| | ខ្សែគ្រប់គ្រងចង្កឹះលេខដែលខូច កខ្វក់ច្រេះស៊ី ឬកំពិត។ | ពិនិត្យ សម្អាត លៃតម្រូវ ឬប្តូរខ្សែគ្រប់គ្រងចង្កឹះលេខ។ |
| | បញ្ហាប្រអប់លេខខាងក្នុង។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ល្បឿនធ្វើដំណើរលើដីប្រែប្រួល** | ប្រេងអ៊ីដ្រូលីកទាប។ | ពិនិត្យមើលការលេចធ្លាយហើយជួសជុល។ ចាក់ប្រេងអ៊ីដ្រូលីកចូលធុងស្តុក។ |



## ប្រព័ន្ធអូសទាញលើដី (ការអូសដោយអ៊ីដ្រូស្តាទិក)

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **នៃបញ្ហាអូសដោយអ៊ីដ្រូស្តាទិកនឹងមិនត្រឡប់ក្រោយ។** | ផ្នែកដែកកោងឬបែកបាក់នៅក្នុងតំណប្រដាប់បញ្ជា។ | ចូរប្តូរនិងជួសជុលវាតាមចាំបាច់។ |
| **ការជាប់ជំពាក់តំណ** | តំណឃ្លីនៅលើខ្សែឧបករណ៍បញ្ជាកកឬខូច។ | ដាក់ប្រេងរំអិល ឬប្តូរចេញ។ |
| | កណ្តឹងរវៃ ឬការចងស្តួល។ | ដាក់ប្រេងរំអិល ឬប្តូរចេញ។ |
| | ខ្សែឧបករណ៍បញ្ជាកួច ឬកក។ | ចូរប្តូរចេញប្រសិនបើចាំបាច់។ |
| **ប្រព័ន្ធឡើងកម្តៅខ្លាំង** | ឧបករណ៍បញ្ជុះកម្តៅប្រេង ឬធុងទឹកម៉ាស៊ីនស្ទះ។ | ជាញ់ខ្យល់កាត់តាមស្តួល និងសម្អាត។ |
| | កង្វះលំហូរប្រេងចូល។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ខ្សែពានកង្ហារម៉ាស៊ីនរអិល ឬដាច់។ | ពិនិត្យខ្សែពានក្រែងលោសឹក ឬដាច់។ |
| | តម្រងប្រេងស្ទះ។ | ប្តូរតម្រងប្រេង។ |
| | លើសសម្ពាធវ៉ាល់សុវត្ថិភាព។ | ប្តូរទៅស្តីហ្គ្រែទាប។ |
| | វ៉ាល់សុវត្ថិភាពស្ទះជិត។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | វ៉ាល់ឆ្លងកាត់បិទមិនបិទ។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ការជាត់បង់ប្រេងច្រើន** | បន្ទះតំណ ឬទុយោអ៊ីដ្រូលីកលេចធ្លាយទុយោ ឬកងមូល។ | រឹតបន្តឹងតំណ ឬប្តូរទុយោដែលខូចទុយោ ឬកងមូល។ |
| | ការលេចធ្លាយប្រេងពីដងស្នប់បូមអ៊ីដ្រូស្តាទិក។ | ប្តូរហ្វឺតដងស្នប់បូមអ៊ីដ្រូស្តាទិក។ |

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **ក្រឿងចក្រនឹងមិនដំណើរការទៅមុខ ឬថយក្រោយឡើយ** | ប្រអប់លេខស្ថិតនៅក្រៅស្តីព្លែរ។ | ប្តូរប្រអប់លេខ។ |
| | កម្រិតប្រេងម៉ាស៊ីនទាប | ពិនិត្យមើលការលេចធ្លាយហើយជួសជុល។ ចាក់ប្រេងបំពេញធុងស្តុកអ៊ីដ្រូលិក។ |
| | ការធ្លាយខ្យល់នៅក្នុងប្រព័ន្ធ។ | រឹតបន្តឹងតំណ។ |
| | តំណឧបករណ៍បញ្ជាបាក់ ឬរលុង។ | រឹតបន្តឹងតំរលុង ឬប្តូរចេញតាមចាំបាច់។ |
| | កង្វះលំហូរចូល ឬសម្ពាធសាកបញ្ចូល។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | តម្រងប្រេងស្ទះ។ | ប្តូរតម្រងប្រេង។ |
| | លើសការកំណត់សម្ពាធប្រតិបត្តិការអតិបរមា។ | ប្តូរទៅស្តីព្លែរទាប។ |
| | ប្រព័ន្ធអូសទាញមិនអាចបង្កើនសម្ពាធបានឡើយ។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ការបើកវ៉ាល់សុវត្ថិភាព។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ប្រអប់លេខពិបាកប្តូរ ឬមិនប្តូរ។** | ដៃបញ្ជាអូសអ៊ីដ្រូស្តាទិកមិននៅក្នុងទីតាំងនឹង។ | រំកិលដៃបញ្ជាអូសអ៊ីដ្រូស្តាទិកទៅទីតាំងនឹង។ |
| | ខ្សែគ្រប់គ្រងចង្កឹះលេខមិនអាចលៃតម្រូវបាន។ | លៃតម្រូវខ្សែគ្រប់គ្រងចង្កឹះលេខ។ |
| | ខ្សែគ្រប់គ្រងចង្កឹះលេខដែលខូច កខ្វក់ច្រេះស៊ី ឬកំពិត។ | ពិនិត្យ សម្អាត លៃតម្រូវ ឬប្តូរខ្សែកាប។ |
| | បញ្ហាប្រអប់លេខខាងក្នុង។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ល្បឿនធ្វើដំណើរលើដីប្រែប្រួល** | ប្រេងអ៊ីដ្រូលិកទាប។ | ពិនិត្យមើលការលេចធ្លាយហើយជួសជុល។ ចាក់ប្រេងបំពេញធុងស្តុកអ៊ីដ្រូលិក។ |
| | តម្រងប្រេងស្ទះ។ | ប្តូរតម្រងប្រេងសាកអ៊ីដ្រូលិក។ |
| | លើសការកំណត់សម្ពាធប្រតិបត្តិការអតិបរមា។ | ប្តូរទៅស្តីព្លែរទាបជាង ឬភ្ជាប់ការអូសដោយកង់ក្រោយ។ |
| | ដៃបញ្ជាអូសអ៊ីដ្រូស្តាទិករំកិលតិចៗទៅកាន់ទីតាំងនឹង។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ប្រព័ន្ធមិនអាចរក្សាសម្ពាធសាកបាន។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ម៉ាស៊ីននឹងមិនឈប់ដំណើរការនៅពេលដៃបញ្ជាអូសដោយអ៊ីដ្រូស្តាទិកនៅក្នុងទីតាំងនឹង។** | ខ្សែឧបករណ៍បញ្ជាមិនអាចលៃតម្រូវបាន។ | លៃតម្រូវខ្សែទៅកាន់ទីតាំងដោះលេខ។ |

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **ខ្ទុះថ្មពេល ឬបាត់បង់ថ្មពេល។ ម៉ាស៊ីនមិនមានការឆ្លើយតបទៅនឹងចង្កឹះបញ្ជាអូសដោយអ៊ីដ្រូស្តាទិក។** | កម្រិតប្រេងអ៊ីដ្រូលីកទាប។ | ពិនិត្យមើលការលេចធ្លាយហើយជួសជុល។ ចាក់ប្រេងបំពេញធុងស្តុកអ៊ីដ្រូលីក។ |
| | តម្រងប្រេងស្ទះ។ | ប្តូរតម្រងប្រេងសាកអ៊ីដ្រូលីក។ |
| | កង្វះលំហូរចូល ឬសម្ពាធសាកបញ្ឈរ។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ប្រព័ន្ធអូសទាញមិនអាចរក្សា ឬបង្កើនសម្ពាធបានឡើយ។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ប្រព័ន្ធចាប់សញ្ញាកំហុសដុំអូសលើដី។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |

CP00834,0008B74-KM-17MAR21

## ប្រព័ន្ធចង្កូត

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **កង់ក្រោយរើចុះឡើងពេលស្ថិតក្នុងល្បឿនដឹកជញ្ជូន** | មិនអាចលៃតម្រូវកង់កន្ទែកចូលបាន។ | លៃតម្រូវការកន្ទែកចូលនៃកង់។ |
| **ដៃចង្កូតមិនប៉ះទង្គិចនៅពេលបត់ពេញ** | ស៊ីឡាំងចង្កូតមិនអាចលៃតម្រូវបាន។ | លៃតម្រូវស៊ីឡាំងចង្កូត។ |
| **ចង្កូតតឹង** | កម្រិតប្រេងទាបនៅក្នុងធុងស្តុកអ៊ីដ្រូលីក។ | ថែមប្រេងអ៊ីដ្រូលីក។ |

CP00834,0008B75-KM-17MAR21

## ប្រព័ន្ធហ្វ្រាំង

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **សម្ពាធឈ្មាន់ហ្វ្រាំងស្បឹត** | កម្រិតប្រេងហ្វ្រាំងទាប។ | បន្ថែមប្រេងហ្វ្រាំង។ |
| | មានខ្យល់នៅក្នុងប្រព័ន្ធ។ | សាប់បន្ទូរប្រព័ន្ធហ្វ្រាំង។ |
| **បាត់បង់ថ្មពលហ្វ្រាំង** | ហ្វ្រាំងដើងមិនបានលៃតម្រូវឲ្យបានត្រឹមត្រូវ។ | លៃតម្រូវហ្វ្រាំងដើង។ |
| **ហ្វ្រាំងដៃចាប់មិនស៊ី** | ហ្វ្រាំងដៃមិនបានលៃតម្រូវឲ្យបានត្រឹមត្រូវ។ | លៃតម្រូវហ្វ្រាំងដៃ។ |

CP00834,0008B76-KM-17MAR21

## ម៉ាស៊ីន

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **ម៉ាស៊ីននឹងមិនវៃបញ្ឆោះ** | អាគុយខ្សោយ។ | សាក ឬប្តូរអាគុយ |
| | តំណអាគុយធូរលុង ឬច្រេះស៊ី។ | សម្អាតក្បាលតំណអាគុយនិងតំណ។ |

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| | កុងតាក់ផ្តាច់អាគុយ ឬកុងតាក់សុវត្ថិភាពបញ្ឆេះមានបញ្ហា។ | ជួសជុលកុងតាក់តាមចាំបាច់។ |
| | ដេម៉ារ៉ែរមានបញ្ហា។ | ប្តូរដាម៉ារ៉ែរ។ |
## ការបង្ហាញការព្រមានអំពីកំហុសនៃអេក្រង់បង្ហោលកាច់ជ្រុង

តទៅទំព័របន្ទាប់

CP00834,1668585160989-KM-16NOV22-1/3

1. កាច់កុងតាក់ទៅទីតាំងដំណើរការ។ ជ្រាប់ម៉ែត្រនិងភ្លើងសញ្ញាទាំងអស់បើក។

   ទំព័រដើមរបស់អេក្រង់បង្ហោលកាច់ជ្រុងប្តូរទៅទំព័រទី 2 ពីទំព័រទី 1 ។





ទំព័រដើមរបស់អេក្រង់បង្ហោលកាច់ជ្រុង

CP00834,1668585160989-KM-16NOV22-2/3

2. ប្រសិនបើមានលេខកូដកំហុសសកម្ម ទំព័រដើមរបស់អេក្រង់បង្ហោលកាច់ជ្រុងប្តូរទៅទំព័រទី2 ពីទំព័រទី 1 ព័ណ៌មាន DTCs និង DTCs នឹងបង្ហាញគ្រប់ពេល។

   នៅពេលកំហុសត្រូវបានដោះស្រាយ និងចុចប៊ូតុងនៅខាងស្តាំ នៅត្រង់ផ្នែកខាងក្រោមអេក្រង់បង្ហោលកាច់ជ្រុង នោះការព្រមានអំពីកំហុសនឹងរលត់ទៅវិញ។

កំណត់ចំណាំ៖ លុបជម្រះការព្រមានកំហុសនីមួយៗ។




CP00834,1668585160989-KM-16NOV22-3/3

## តារាងពិនិត្យមើលមុនពេលបញ្ជោះ

រាល់ថ្ងៃមុននឹងបញ្ជោះម៉ាស៊ីន ចូរពិនិត្យមើលធាតុទាំងអស់នៅក្នុងតារាងនេះ។

| |
|---|
| ពិនិត្យមើល និងចាក់ប្រេងម៉ាស៊ីនចូល |
| ពិនិត្យមើល និងចាក់ទឹកថ្នាំស្អុំម៉ាស៊ីនចូល |
| ពិនិត្យមើល និងចាក់ប្រេងអ៊ីដ្រូលីកចូល |
| ពិនិត្យមើល និងចាក់ប្រេងអ៊ីដ្រូស្តាទិកចូល (ការអូសដោយអ៊ីដ្រូស្តាទិក) |
| ពិនិត្យមើល និងចាក់ប្រេងឥន្ធនៈចូល |
| បង្ហូរទឹកចេញពីតម្រងឥន្ធនៈទីមួយ |
| ពិនិត្យមើល និងសម្អាតតម្រងសំណាញ់រំលេងនៅរដូវត្រជាក់ |

CP00834,1668587107376-KM-16NOV22-1/1

## ពិនិត្យមើល និងចាក់ប្រេងម៉ាស៊ីនចូល

**សំខាន់៖ ការរក្សាកម្រិតប្រេងម៉ាស៊ីនឱ្យបានត្រឹមត្រូវគឺចាំបាច់សម្រាប់អាយុកាលថែទាំរបស់ម៉ាស៊ីន។ ពិនិត្យកម្រិតប្រេងម៉ាស៊ីននៅពេលដែលគ្រឿងចក្រចតនៅលើដីរាបស្មើ។**

**សំខាន់៖ ហាមចាក់ប្រេងម៉ាស៊ីនចូល មុននឹងកម្រិតប្រេងធ្លាក់ក្រោមសញ្ញា "ADD" នៅលើម៉ាក្ទែរ។**

**សំខាន់៖ ហាមចាក់ប្រេងចូលលើផ្នែកខាងលើតំបន់គំនូសខ្វែង (B) នៅលើម៉ាក្ទែរប្រេង។ ហាមដំណើរការម៉ាស៊ីននៅពេលកម្រិតប្រេងម៉ាស៊ីនស្ថិតនៅក្រោមគំនូសសញ្ញា "ADD" នៅលើម៉ាក្ទែរ។**

CP00834,1668585815853-KM-16NOV22-1/3


ពិនិត្យកម្រិតប្រេងម៉ាស៊ីនដោយប្រើម៉ាក្ទែរប្រេងរាល់ថ្ងៃ (A) ។ ហាមដំណើរការម៉ាស៊ីននៅពេលកម្រិតប្រេងម៉ាស៊ីនស្ថិតនៅក្រោមគំនូសសញ្ញា "ADD" នៅលើម៉ាក្ទែរ។

កំណត់ចំណាំ៖ ផ្ទៀងផ្ទាត់ថាម៉ាក្ទែរប្រេងត្រូវបានមួល និងរុញចូលសម្បកទាំងស្រុងមុនពេលដោះចេញ ដើម្បីពិនិត្យមើលកម្រិតប្រេងម៉ាស៊ីន។

ដោះម៉ាក្ទែរប្រេងចេញ ហើយពិនិត្យមើលកម្រិតប្រេង។ កម្រិតប្រេងម៉ាស៊ីនគួរតែស្ថិតនៅក្នុងតំបន់គំនូសខ្វែង (B) នៅលើម៉ាក្ទែរ។


**A—ម៉ាក្ទែរ**

**B—តំបន់គូសខ្វែង**




YC20973—UN—07DEC22

YC20975—UN—21DEC22




ម៉ាក្ទែរប្រេងម៉ាស៊ីន


**តទៅទំព័របន្ទាប់**

CP00834,1668585815853-KM-16NOV22-2/3

ប្រសិនបើកម្រិតប្រេងម៉ាស៊ីនស្ថិតក្រោមសញ្ញា “ADD” នៅលើម៉ាក្រេវ៍ ចូរដោះគម្របចាក់ប្រេង (C) ចេញដើម្បីថែមប្រេងចូលតាមចាំបាច់។

ម៉ាស៊ីនថ្មីត្រូវបានចាក់ប្រេង John Deere Break-In ពីរោងចក្រ។ នៅអំឡុងពេលប្រើប្រាស់ដំបូង សូមបន្ថែមប្រេងម៉ាស៊ីនម៉ាក John Deere Break-In តាមតម្រូវការដើម្បីរក្សាកម្រិតប្រេងតាមលក្ខណៈបច្ចេកទេស។ សម្រាប់ការណែនាំ ចូរអានផ្នែកប្រេងម៉ាស៊ីនម៉ាស៊ូតដែលទើបប្រើថ្មី — គ្មានការភាយឧស្ម័ន ថ្នាក់ទី 1 ថ្នាក់ទី 2 ថ្នាក់ទី 3 ដំណាក់កាលទី I ដំណាក់កាលទី II និងដំណាក់កាលទី III នៅក្នុងផ្នែកប្រេងឥន្ធនៈ ទឹកស៊ុំ និងប្រេងរំអិល។

បន្ទាប់ពីរយៈពេលរ៉ូដាស់, យកល្អគួរប្រើប្រេងម៉ាស៊ីន John Deere Plus-50™ II ។ សម្រាប់ការណែនាំ ចូរអានអំពីប្រេងម៉ាស៊ីនម៉ាស៊ូត — ចំណាត់ថ្នាក់ 3 និងដំណាក់កាល IIIA នៅផ្នែកប្រេងឥន្ធនៈ ប្រេងរំអិល និងទឹកថ្នាំស៊ុំម៉ាស៊ីន។




ចាក់ប្រេងម៉ាស៊ីនចូល

**C—គម្របចាក់ប្រេង**

CP00834,1668585815853-KM-16NOV22-3/3

## ពិនិត្យមើល និងចាក់ទឹកថ្នាំស៊ុំម៉ាស៊ីនចូល

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។ ប្រយ័ត្នរលាកទឹកក្តៅ នៅពេលបើកគម្របធុងខ្ពោល។ ហាមបើកគម្របពេលម៉ាស៊ីនកំពុងក្តៅ។ បើកគម្របយឺតៗ ដើម្បីបន្ធូរសម្ពាធ។**

**សំខាន់៖ គម្របពិសេសត្រូវប្រើនៅលើធុងខ្ពោល។ ប្រសិនបើគម្របខូច ឬបាត់ត្រូវតែប្តូរដាក់គម្របថ្មី។**


CP00834,1668586765298-KM-16NOV22-1/2

ទុកឲ្យម៉ាស៊ីនចុះត្រជាក់។ កម្រិតទឹកថ្នាំស៊ុំម៉ាស៊ីនគួរតែស្ថិតនៅចន្លោះសញ្ញា MIN (C) និងសញ្ញា MAX (B) នៅលើធុងខ្ពោល។

ប្រសិនបើទឹកថ្នាំស៊ុំម៉ាស៊ីនស្ថិតនៅក្រោម MIN សញ្ញា ចូរដោះគម្របធុងខ្ពោល (A) ចេញដើម្បីថែមទឹកថ្នាំស៊ុំម៉ាស៊ីនតាមចាំបាច់។

សម្រាប់ការណែនាំ ចូរអានអំពីទឹកថ្នាំស៊ុំម៉ាស៊ីនម៉ាស៊ូត (ម៉ាស៊ីនដែលមានស៊ីឡាំងប្រភេទសើម) នៅក្នុងផ្នែកទឹកថ្នាំស៊ុំម៉ាស៊ីន និងប្រេងរំអិល។

**A—គម្របធុងខ្ពោល**
**B—សញ្ញា MAX (អតិ.)**
**C—សញ្ញា MIN (អប្ប.)**
**D—ធុងខ្ពោល**




CP00834,1668586765298-KM-16NOV22-2/2

## ពិនិត្យមើល និងចាក់ប្រេងអ៊ីដ្រូលីកចូល


**តទៅទំព័របន្ទាប់**

CP00834,1668587072094-KM-16NOV22-1/2

បន្ទាបក្បាលឧបករណ៍កាត់ទៅដី ហើយបង្អួមស៊ីឡាំងអ៊ីដ្រូលីកទាំងអស់។ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។

1. ដោះគម្របចាក់ប្រេង (A) ចេញ។
2. ដោះនិងសម្អាតម៉ាក្កោរ៍ (B)។
3. ស៊កម៉ាក្កោរ៍ចូល ហើយពិនិត្យមើលកម្រិតប្រេងអ៊ីដ្រូលីក។ កម្រិតប្រេងគួរតែស្ថិតនៅចន្លោះសញ្ញាអប្បបរមា (D) និងសញ្ញាអតិបរមា (C) នៅលើម៉ាក្កោរ៍។
4. បន្ថែមប្រេងតាមការចាំបាច់ ប៉ុន្តែកុំឲ្យលើស។

សម្រាប់ការណែនាំ ចូរអានអំពីប្រេងអ៊ីដ្រូលីក/អ៊ីដ្រូស្តាទិកនៅក្នុងផ្នែកប្រេងឥន្ធនៈ ទឹកថ្នាំស្អុំម៉ាស៊ីន និងប្រេងរំអិល។




YC3221—UN—24DEC13

ពិនិត្យមើល និងចាក់ប្រេងអ៊ីដ្រូលីកចូល

**A—គម្របចាក់ប្រេង**
**B—ម៉ាក្កោរ៍**
**C—កំនូសសញ្ញាអតិបរមា**
**D—កំនូសសញ្ញាអប្បបរមា**

YC20977—UN—21DEC22




CP00834,1668587072094-KM-16NOV22-2/2

## ពិនិត្យមើល និងចាក់ប្រេងអ៊ីដ្រូស្តាទិកចូល (ការអូសដោយអ៊ីដ្រូស្តាទិក)

**តទៅទំព័របន្ទាប់**


CP00834,1668587492268-KM-16NOV22-1/2

ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។

កម្រិតប្រេងត្រូវតែស្ថិតនៅផ្នែកខាងលើនៃកែវមើលឃើញ (B)។ ដោះគម្របចាក់ប្រេង (C) ដើម្បីថែមប្រេងអ៊ីដ្រូស្តាទិកចូលតាមចាំបាច់ ប៉ុន្តែកុំចាក់ឲ្យហៀរ។

សម្រាប់ការណែនាំ ចូរអានអំពីប្រេងអ៊ីដ្រូលីក/អ៊ីដ្រូស្តាទិក នៅក្នុងផ្នែកប្រេងឥន្ធនៈ ទឹកថ្នាំស្អំម៉ាស៊ីន និងប្រេងរំអិល។

**A—ធុងស្តុកអ៊ីដ្រូស្តាទិក**
**B—កញ្ចក់មើលឃើញ**
**C—គម្របចាក់ប្រេង**




YC20978—UN—21DEC22




YC20982—UN—21DEC22

ចាក់ប្រេងអ៊ីដ្រូស្តាទិកចូល

CP00834,1668587492268-KM-16NOV22-2/2

## ពិនិត្យមើល និងចាក់ប្រេងឥន្ធនៈចូល

**តទៅទំព័របន្ទាប់**

CP00834,1668588868326-KM-16NOV22-1/2


ពិនិត្យមើលកម្រិតប្រេងឥន្ធនៈនៅត្រឹមប្រដាប់វាស់កម្រិតប្រេងឥន្ធនៈ (A) នៅលើអេក្រង់បង្គោលកាច់ជ្រុង។

ដោះគម្របចាក់ប្រេង (B) ចេញដើម្បីចាក់ប្រេងចូលធុងតាមចាំបាច់។ សម្រាប់ការណែនាំ ចូរអានអំពីប្រេងម៉ាស៊ូត នៅក្នុងផ្នែកប្រេងឥន្ធនៈ ទឹកថ្នាំសំរាប់ម៉ាស៊ីន និងប្រេងរំអិល។

ប្រសិនបើម៉ាស៊ីនមិនដំណើរការក្នុងរយៈពេលយូរ ចូរបើកវ៉ាល់បង្ហូរ (C) ដើម្បីបង្ហូរទឹកចេញពីធុងប្រេង ហើយចាក់ប្រេងចូលធុង។


**សំខាន់ៈ ប្រេងឥន្ធនៈគឺងាយឆេះខ្លាំង ហើយអាចបណ្តាលឱ្យរងរបួសធ្ងន់ធ្ងរ ឬស្លាប់បាន។ ចូរកុំចាក់ប្រេងចូលគ្រឿងចក្រខណៈពេលកំពុងជក់បារី ឬពេលស្ថិតនៅជិតអណ្តាតភ្លើង ឬផ្កាភ្លើង។ ជានិច្ចកាល ត្រូវពន្លត់ម៉ាស៊ីនមុននឹងចាក់ប្រេងគ្រឿងចក្រ។ ចាក់ប្រេងចូលធុងប្រេងឥន្ធនៈនៅទីវាលជានិច្ច។ ត្រូវប្រាកដថាមួលគម្របចាក់ប្រេងធុងប្រេង និងតម្រងសំណាញ់ខាងក្រោយវិញ បន្ទាប់ពីចាក់បំពេញ។ ត្រូវជូតសម្អាតប្រេងដែលហៀរកំពប់ជានិច្ច។ កុំចាក់ឱ្យពេញហៀរ។**

A—ប្រដាប់វាស់កម្រិតប្រេងឥន្ធនៈ
B—គម្របចាក់ប្រេង
C—វ៉ាល់បង្ហូរ




YC20979—UN—21DEC22

ពិនិត្យកម្រិតប្រេងឥន្ធនៈ



YC20984—UN—21DEC22



YC20985—UN—21DEC22

CP00834,1668588868326-KM-16NOV22-2/2

## បង្ហូរទឹកចេញពីតម្រងឥន្ធនៈទីមួយ

**⚠ ប្រយ័ត្នៈ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញមុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**


តទៅទំព័របន្ទាប់

CP00834,1668589283494-KM-16NOV22-1/2

អង្គញ្ជាណចាប់សញ្ញាទឹកនៅក្នុងតន្ទន:ស្ងិតនៅក្នុងចានចម្រោះទឹក (B)។ នៅពេលតម្រងប្រេងតន្ទន:ទីមួយ (A) មានទឹកនៅក្នុងប្រព័ន្ធប្រេងតន្ទន: លេខកូដវិនិច្ឆ័យត្រូវបានបង្កើតឡើង។ ប្រសិនបើកូដបញ្ហារោគវិនិច្ឆ័យជុសឡើង ចូរបន្លូរវ៉ាល់បង្ហូរ (C) ដើម្បីបង្ហូរទឹកចេញ។

រាល់ថ្ងៃមុននឹងបញ្ជោះម៉ាស៊ីន ចូរពិនិត្យមើលចានចម្រោះទឹកនិងបង្ហូរទឹកចេញតាមចាំបាច់។

**A—តម្រងប្រេងតន្ទន:ទីមួយ**
**B—ចានចម្រោះទឹក**
**C—វ៉ាល់បង្ហូរ**




YC20980—UN—21DEC22

CP00834,1668589283494-KM-16NOV22-2/2

## ពិនិត្យមើល និងសម្អាតតម្រងសំណាញ់វិលនៅរដូវត្រជាក់

**⚠ ប្រយ័ត្ន: ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញមុននឹងធ្វើការថែទាំនៅលើតម្រងប្រេងតន្ទន:។**

**សំខាន់: នៅរដូវត្រជាក់មុននឹងបញ្ជោះម៉ាស៊ីន ចូរពិនិត្យ និងសម្អាតទឹកក ឬសំណើមកកនៅលើតម្រងសំណាញ់វិល។**


CP00834,1668589293711-KM-16NOV22-1/2

សម្អាតតម្រងសំណាញ់វិល (A) នៅផ្នែកខាងលើគ្រឿងចក្រ។


បើករបាំងការពារខាងស្តាំដើម្បីសម្អាតតម្រងសំណាញ់វិល។

ចូរប្រាកដថាខ្សែពានអូស (B) មិនរឹងកំព្រឹសមុននឹងបញ្ជោះម៉ាស៊ីននៅសីតុណ្ហភាពក្រោម 0°C។

**A—តម្រងសំណាញ់វិល**
**B—ខ្សែពានអូស**




YC20983—UN—21DEC22




YC20981—UN—21DEC22

CP00834,1668589293711-KM-16NOV22-2/2

## បើកដំណើរការកុងតាក់សោ


CP00834,0008F85-KM-12JUL21-1/2

**ទីតាំងគ្រឿងបន្ទាប់បន្សំ (A)៖** រុញចូល និងកាច់សោទៅទីតាំង "ACCESSORY" ដើម្បីបើកដំណើរការមុខងារអគ្គិសនី។

**ទីតាំងឈប់ (B)៖** កាច់សោទៅទីតាំងឈប់ដើម្បីពន្លត់ម៉ាស៊ីន និងបិទមុខងារអគ្គិសនី។

**ទីតាំងប្រតិបត្តិការ (C)៖** កាច់សោទៅទីតាំងប្រតិបត្តិការ (RUN) ។ ពិនិត្យមើលប្រដាប់វាស់ និងពន្លឺភ្លើងសញ្ញាមុននឹងបញ្ឆេះម៉ាស៊ីន។

**ទីតាំងបញ្ឆេះ (D)៖** កាច់សោទៅទីតាំងបញ្ឆេះ (បញ្ឆេះ) ដើម្បីបញ្ឆេះម៉ាស៊ីន។ សោនឹងត្រឡប់ទៅកាន់ទីតាំង RUN វិញនៅពេលលែងវា។




YC17947—UN—12JUL21

**A—ទីតាំងគ្រឿងបន្ទាប់បន្សំ**
**B—ទីតាំងឈប់**
**C—ទីតាំងប្រតិបត្តិការ**
**D—ទីតាំងបញ្ឆេះ**

CP00834,0008F85-KM-12JUL21-2/2

## បញ្ឆេះម៉ាស៊ីន

**ប្រយ័ត្ន៖ មុននឹងបញ្ឆេះម៉ាស៊ីននៅក្នុងកន្លែងចង្អៀត ចូរដំឡើងគ្រឿងបរិក្ខារបញ្ចេញឧស្ម័យឲ្យបានត្រឹមត្រូវ។ ជានិច្ចកាល ចូរអនុវត្តការទុកដាក់ និងការតទុយោគន្ធៈដែលអនុញ្ញាតដើម្បីសុវត្ថិភាព។**

**មុននឹងបញ្ឆេះម៉ាស៊ីន ចូរប្រាកដថាមិនមានអ្នកណានៅជិតគ្រឿងចក្រឡើយ។ បន្លឺស៊ីផ្លេដើម្បីជូនដំណឹងដល់អ្នកដទៃ។**

**តទៅទំព័របន្ទាប់**

CP00834,1668646376592-KM-16NOV22-1/2

1. សម្រាប់គ្រឿងចក្រអូសដោយអ៊ីដ្រូស្តាទិក ចូរដាក់ដៃបញ្ជាពហុមុខងារ (B) នៅក្នុងទីតាំងនឺង។
2. ពិនិត្យមើលចង្កឹះលេខ (A) ក្រែងលោមិនស្ថិតនៅក្នុងទីតាំងនឺង។
3. ពិនិត្យមើលក្រែងលោដៃភ្ជាប់ប្រព័ន្ធបោកបែន ដៃភ្ជាប់ក្បាលឧបករណ៍កាត់ និងដៃភ្ជាប់ប្រដាប់បួងទម្លាក់ផ្តាច់ចេញ។
4. កាច់សោបញ្ឆោះទៅទីតាំង RUN (D), ពិនិត្យមើល និងលុបជម្រះ DTC នៅលើអេក្រង់បង្ហោលកាច់ជ្រុង។


កំណត់ចំណាំ៖ កូដបង្ហាញឡើងរហូតទាល់តែបញ្ហាត្រូវបានដោះស្រាយរួច។ ប្រសិនបើមិនអាចដោះស្រាយបញ្ហាបានទេ ចូរពិគ្រោះជាមួយអ្នកចែកចាយក្រុមហ៊ុន *John Deere* របស់លោកអ្នក។

**⚠ ប្រយ័ត្ន៖ ដើម្បីកុំឲ្យមានគ្រោះថ្នាក់រងរបួស ឬការស្លាប់ជាត់បង់ជីវិតជាយថាហេតុ ចូរបញ្ឆោះម៉ាស៊ីនតែពីកៅអីប្រតិបត្តិករប៉ុណ្ណោះ។ ហាមបញ្ឆោះម៉ាស៊ីនដោយការចម្លងអគ្គិសនីកាត់តាមក្បាលតំណដេម៉ារ៉ែ។ ម៉ាស៊ីនឆេះនៅពេលចូលលេខ ប្រសិនបើឆ្លងកាត់ (bypass)។**

**សំខាន់៖ ដើម្បីកុំឲ្យខូចដេម៉ារ៉ែ ចូរកុំប្រតិបត្តិការដេម៉ារ៉ែលើសពី 30 វិនាទី ក្នុងមួយលើក។ ប្រសិនបើម៉ាស៊ីនមិនឆេះទេនោះ រង់ចាំយ៉ាងហោចណាស់ពីរនាទី មុននឹងបញ្ឆោះម្តងទៀត។ ប្រសិនបើម៉ាស៊ីនមិនឆេះបន្ទាប់ពីព្យាយាមបញ្ឆោះចំនួនបួនដង ចូរអានអំពីដំណោះស្រាយបញ្ហាម៉ាស៊ីននៅក្នុងផ្នែកដំណោះស្រាយបញ្ហា។**


កំណត់ចំណាំ៖ នៅពេលកាច់សោបញ្ឆោះទៅទីតាំងបញ្ឆោះ នោះនឹងមានការពន្យារយៈពេលពីរបីនាទី។ ប្រការនេះអនុញ្ញាតឲ្យប្រអប់បញ្ហាឡើងថាមពលរីឡើងវិញ ហើយសូលេណូអ៊ីតដេម៉ារ៉ែផ្តល់ថាមពល។

5. កំណត់កុងតាក់ប្តូរ (C) នៅត្រង់ទីតាំង “អណ្តើក” បន្ទឺស៊ីឡែ និងកាច់សោបញ្ឆោះទៅទីតាំងបញ្ឆោះ (E) ដើម្បីបញ្ឆោះម៉ាស៊ីន។



YC20986—UN—21DEC22

ឧបករណ៍បញ្ជា និងឧបករណ៍ (ការអូសដោយអ៊ីដ្រូស្តាទិក)



YC17959—UN—14JUL21

**A—ចង្កឹះលេខ**
**B—ដៃបញ្ជាពហុមុខងារ**
**C—កុងតាក់ប្តូរ**
**D—ទីតាំងប្រតិបត្តិការ**
**E—ទីតាំងបញ្ឆោះ**

6. ការ៉ង់ទីម៉ាស៊ីនរយៈពេលពី 1 ដល់ 2 នាទីដើម្បីកម្តៅម៉ាស៊ីនជាមុន។

**សំខាន់៖ ហាមដំណើរការម៉ាស៊ីនក្នុងការ៉ង់ទីទាបលើសពី 5 នាទី។**

CP00834,1668646376592-KM-16NOV22-2/2

## បញ្ឆោះពេលអាកាសធាតុត្រជាក់

**⚠ ប្រយ័ត្ន៖ មុននឹងបញ្ឆោះម៉ាស៊ីន ចូរប្រាកដថាមិនមានអ្នកណានៅជិតគ្រឿងចក្រឡើយ។ បន្ទឺស៊ីឡែដើម្បីជូនដំណឹងដល់អ្នកដទៃ។**

**អេទែរងាយនឹងឆាបឆេះបំផុត។ កុំប្រើអេទែរនៅពេលណាដែលបញ្ឆោះម៉ាស៊ីនដែលមានបំពាក់ឧបករណ៍កម្តៅខ្យល់ចូល។**

**តទៅទំព័របន្ទាប់**


CP00834,1668646437316-KM-16NOV22-1/3

ជំនួយបញ្ជោះគឺចាំបាច់នៅពេលសីតុណ្ហភាពក្រោម 0°C (32°F) ។

ត្រូវការប្រើជំនួយបញ្ជោះនៅក្នុងអាកាសធាតុត្រជាក់ផ្សេងទៀត នៅសីតុណ្ហភាព -25°C (-13°F) ឬរយៈកម្ពស់លើ 1500 ម (5000 ហ្វីត)។ អានអំពីការប្រើប្រាស់អាគុយកូវ ឬប្រដាប់សាកដើម្បីបញ្ជោះម៉ាស៊ីននៅក្នុងផ្នែកនេះ។

1. កាច់កុងតាក់សោបញ្ជោះទៅទីតាំង RUN (C) ដើម្បីកម្តៅម៉ាស៊ីនជាមុន។ វានឹងចំណាយពេលពី 15 ដល់ 20 វិនាទីដើម្បីបញ្ចប់ការកម្តៅជាមុន។

កំណត់ចំណាំ៖ ហាមបញ្ជោះម៉ាស៊ីនមុននឹងការកម្តៅជាមុនត្រូវបានបញ្ចប់។



YC17947—UN—12JUL21

**A—ទីតាំងគ្រឿងបន្ទាប់បន្សំ**
**B—ទីតាំងឈប់**
**C—ទីតាំងប្រតិបត្តិការ**
**D—ទីតាំងបញ្ជោះ**


CP00834,1668646437316-KM-16NOV22-2/3

2. កំណត់កុងតាក់ហ្គែរ (E) នៅត្រង់ទីតាំង “អណ្តើក” បន្ទឺស៊ីឡេនិងកាច់សោបញ្ជោះទៅទីតាំងបញ្ជោះ (D) ដើម្បីបញ្ជោះម៉ាស៊ីន។

3. ការ៉ង់ទីម៉ាស៊ីនរយៈពេលពី 2 ដល់ 4 នាទីដើម្បីកម្តៅម៉ាស៊ីនជាមុន។

**សំខាន់៖ ហាមដំណើរការម៉ាស៊ីនក្នុងការ៉ង់ទីទាបលើសពី 5 នាទី។**

**E—កុងតាក់ហ្គែរ**



YC17948—UN—12JUL21

កុងតាក់ហ្គែរ (មានបង្ហាញការអូសដោយអ៊ីដ្រូស្តាទិក)

CP00834,1668646437316-KM-16NOV22-3/3

## អានអំពីការប្រើប្រាស់អាគុយកូវ ឬប្រដាប់សាកដើម្បីបញ្ជោះម៉ាស៊ីន។

**ប្រយ័ត្ន៖ ឧស្ម័នដែលបញ្ចេញពីអាគុយអាចផ្ទុះបាន។ រក្សាឲ្យផ្កាភ្លើង និងអណ្តាតភ្លើងស្ថិតនៅឆ្ងាយពីអាគុយ។ មុនពេលត ឬផ្តាច់ឧបករណ៍សាកអាគុយចេញ ចូរបិទវាសិន។ ដំបូងផ្តាច់ចេញ ហើយតភ្ជាប់ពេលចុងក្រោយនៅចំណុចដែលឆ្ងាយពីអាគុយ។ ជានិច្চកាល ចូរភ្ជាប់ខ្សែអវិជ្ជមានចុងក្រោយ និងផ្តាច់ខ្សែនេះចេញមុនគេ។**

តទៅទំព័របន្ទាប់

CP00834,0008DDA-KM-29AUG21-1/2

ត្រូវការប្រើជំនួយបញ្ជោះនៅសីតុណ្ហភាព -25°C (-13°F) ឬ រយៈកម្ពស់លើ 1500 ម (5000 ហ្វីត)។

អាគុយកូវ ឬប្រដាប់សាកកម្លាំង 12 V អាចតភ្ជាប់ស្របគ្នាជាមួយអាគុយនៅលើគ្រឿងដើម្បីជួយបញ្ជោះក្នុងអាកាសធាតុត្រជាក់។ ជានិច្ចកាល ចូរប្រើខ្សែកូវបញ្ជោះដែលធន់។

**⚠ ប្រយ័ត្ន: ក្បាល និងក្រចាប់អាគុយ និងគ្រឿងដែលពាក់ព័ន្ធ មានផ្ទុកជាតិសំណ និងសមាសភាគសំណដែលគេនឹងនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាថាបណ្តាលឲ្យកើតជាជំងឺមហារីក និងគ្រោះថ្នាក់ចំពោះសុខភាពបន្តពូជ។ លាងសម្អាតដៃក្រោយពេលធ្វើការជាមួយនឹងវា។**

**សំខាន់: បិទកុងតាក់ផ្តាច់អាគុយមុននឹងភ្ជាប់ខ្សែកាបកូវបញ្ជោះ។ ចូរកុំកូវបញ្ជោះជាមួយអាគុយដែលមានកម្លាំងលើសពី 12 វ៉ូលត៍។**

**ត្រូវចំណាំប៉ូលអាគុយឲ្យបានច្បាស់មុននឹងធ្វើការតភ្ជាប់។ ការតបញ្ច្រាស់ធ្វើឲ្យខូចប្រព័ន្ធអគ្គិសនី។ ជានិច្ចកាល ចូរភ្ជាប់ខ្សែវិជ្ជមានទៅកាន់វិជ្ជមាន និងអវិជ្ជមានទៅកាន់ម៉ាស។ ប្រើអាគុយកូវកម្លាំង 12 វ៉ូលត៍សម្រាប់ប្រព័ន្ធអគ្គិសនី 12 វ៉ូលត៍។**

1. ដោះគម្របការពារចេញ។


   កំណត់ចំណាំ: ដើម្បីបង្ការនូវផ្កាភ្លើង ចូរកុំទុកឲ្យចុងខ្សែកូវទទេប៉ះម៉ាស៊ីន។

2. តភ្ជាប់ខ្សែកូវទីមួយទៅកាន់ខ្សែវិជ្ជមាននៃអាគុយកូវ និងចុងម្ខាងទៀតទៅកាន់ខ្សែវិជ្ជមាននៃអាគុយគ្រឿងចក្រ។

3. តភ្ជាប់ខ្សែកូវទីពីទៅកាន់ខ្សែអវិជ្ជមាននៃអាគុយកូវ និងចុងម្ខាងទៀតទៅកាន់ខ្សែអវិជ្ជមាននៃអាគុយគ្រឿងចក្រ ឬទៅកាន់តំណម៉ាស។



TS204—UN—15APR13




RG4678—UN—14DEC88

**A—អាគុយគ្រឿងចក្រកម្លាំង 12 V**
**B—អាគុយកូវកម្លាំង 12 V**
**C—ខ្សែកូវបញ្ជោះ**
**D—ខ្សែកាបដេម៉ាវ័រ**

4. បញ្ជោះម៉ាស៊ីន។ ផ្តាច់ខ្សែកូវបញ្ជោះភ្លាមបន្ទាប់ពីម៉ាស៊ីនឆេះ។ ជានិច្ចកាល ចូរផ្តាច់ខ្សែអវិជ្ជមានចេញមុនគេ។

CP00834,0008DDA-KM-29AUG21-2/2

## ចៀសវាងការ៉ងទីម៉ាស៊ីនយូរពេក

ចៀសវាងការ៉ងទីម៉ាស៊ីនយូរពេក។ ការនៅបន្តការ៉ងទីម៉ាស៊ីនទៀតអាចធ្វើឲ្យសីតុណ្ហភាពទឹកផ្ទៃស្ទះម៉ាស៊ីនធ្លាក់ចុះក្រោមកម្រិតធម្មតារបស់វា។ ផ្ទុយទៅវិញ ការធ្វើដូច្នេះបណ្តាលឲ្យប្រេងរាវប្រអប់រំ ដោយសារតែការដុតប្រេងឥន្ធនៈមិនពេញលេញ និងបណ្តាលឲ្យមានកំណស្ទឹតនៅលើស៊ូប៉ាប់ ពីស្តង និងក្រវាត់ពីស្តង។ វាក៏បង្កឲ្យមាននូវកំណខាប់ក្នុងម៉ាស៊ីនយ៉ាងឆាប់រហ័ស និងឥន្ធនៈឆេះមិនអស់នៅក្នុងប្រព័ន្ធបំពង់ផ្សែង។

នៅពេលម៉ាស៊ីនឡើងកម្តៅទៅដល់សីតុណ្ហភាពប្រតិបត្តិការធម្មតា ម៉ាស៊ីនគួរតែការ៉ងទីនៅល្បឿនការ៉ងទីទាប។ ប្រសិនបើម៉ាស៊ីននឹងការ៉ងទីលើសពីប្រាំនាទី ចូរពន្លត់ ហើយបញ្ជោះឡើងវិញនៅពេលក្រោយ។

ដើម្បីកាត់បន្ថយកំណម្រែងភ្លើងខណៈពេលដំណើរការនៅល្បឿនការ៉ងទីទាប ECU បង្កើនល្បឿនប្រតិបត្តិការទៅដល់ល្បឿនកម្រិតអត្រានៅពេលណាដែលការដោតមុខ DOC អាចធ្វើទៅបាន។ ល្បឿនប្រតិបត្តិការម៉ាស៊ីនកើនឡើងបង្កើនសីតុណ្ហភាពបញ្ចេញ និងលទ្ធភាពឆេះម្រែងភ្លើងពីមុខ DOC ។


CP00834,0008DDB-KM-26MAY21-1/1

## ពន្លត់ម៉ាស៊ីន

**តទៅទំព័របន្ទាប់**

CP00834,1668646812486-KM-16NOV22-1/2

1. សម្រាប់គ្រឿងចក្រអូសដោយអ៊ីដ្រូស្តាទិក ចូររំកិលដៃបញ្ជាពហុមុខងារ (B) ទៅក្នុងទីតាំងនឺង។
2. សម្រាប់គ្រឿងចក្រអូសដោយមេកានិក ចូរពិនិត្យមើលចង្កឹះលេខ (A) ក្រែងលោមិនស្ថិតនៅក្នុងទីតាំងនឺង។
3. ដាក់កុងតាក់ហ្គែរ (C) ក្នុងទីតាំង "អណ្តើក"។
4. បន្ទាបក្បាលកាត់ទៅដី។
5. ពិនិត្យមើលក្រែងលោដៃភ្ជាប់ប្រព័ន្ធបោកបែន ដៃភ្ជាប់ក្បាលឧបករណ៍កាត់ និងដៃភ្ជាប់ប្រដាប់បួងទម្លាក់ផ្តាច់ចេញ។
6. ទាញចង្កឹះហ្វ្រាំងដៃ (D) ឡើងលើដើម្បីភ្ជាប់ហ្វ្រាំងដៃ។
7. ការ៉ងទីម៉ាស៊ីនពីរបីនាទីដើម្បីឲ្យតួបឺនចុះត្រជាក់។
8. ពន្លត់ម៉ាស៊ីន។



YC20987—UN—21DEC22

ឧបករណ៍បញ្ជា និងឧបករណ៍ *(ការអូសដោយអ៊ីដ្រូស្តាទិក)*

**A—ចង្កឹះលេខ**
**B—ដៃបញ្ជាពហុមុខងារ**
**C—កុងតាក់ហ្គែរ**
**D—ចង្កឹះហ្វ្រាំងដៃ**

CP00834,1668646812486-KM-16NOV22-2/2

# សេវាអំឡុងពេលរ៉ូដាស់

## ម៉ាស៊ីនពេលរ៉ូដាស់

ការថែទាំបន្ថែមក្នុងអំឡុងពេលប្រតិបត្តិការ 100 ម៉ោងដំបូង នឹងផ្តល់នូវលទ្ធផលល្អ និងដំណើរការបានយូរអង្វែងរបស់ម៉ាស៊ីន។

1. ម៉ាស៊ីននេះត្រូវបានចាក់ប្រេងម៉ាស៊ីន John Deere Break-In មកពីរោងចក្រ។ ប្រតិបត្តិការម៉ាស៊ីនដោយផ្ទុកធ្ងន់ជាមួយនឹងការការ៉ង់ទីម៉ាស៊ីនតិចតួចបំផុតក្នុងអំឡុងពេលរ៉ូដាស់ម៉ាស៊ីន។
2. ប្រសិនបើម៉ាស៊ីនមានពេលវេលាប្រតិបត្តិការគួរឱ្យកត់សម្គាល់នៅឈ្នឿនការ៉ង់ទី ឈ្នឿនថេរ និង/ឬការប្រើប្រាស់បន្តក្រាលឬចាំបាច់ត្រូវការប្រេងថ្មែមក្នុងរយៈពេល 100 ម៉ោងដំបូង រយៈពេលរ៉ូដាស់យូរជាងនេះអាចមានភាពចាំបាច់។ ក្នុងស្ថានភាពទាំងនេះ យកល្អគួរតែរ៉ូដាស់ម៉ាស៊ីន 100 ម៉ោងបន្ថែមទៀត ដោយប្តូរប្រេងម៉ាស៊ីនថ្មីរបស់ John Deere Break-In និងតម្រងប្រេងថ្មីរបស់ John Deere ។
3. ពិនិត្យមើលកម្រិតប្រេងឲ្យបានញឹកញាប់ជាងនេះក្នុងអំឡុងពេលរ៉ូដាស់ម៉ាស៊ីន។ ប្រសិនបើត្រូវតែបន្ថែមប្រេងក្នុងកំឡុងពេលនេះ សូមប្រើប្រាស់ប្រេងម៉ាស៊ីន John Deere Break-In។ (សូមអានផ្នែកប្រេងម៉ាស៊ីនម៉ាស៊ូតដែលទើបប្រើថ្មី — គ្មានការភាយឧស្ម័ន ថ្នាក់ទី 1 ថ្នាក់ទី 2 ថ្នាក់ទី 3 ដំណាក់កាលទី I ដំណាក់កាលទី II និងដំណាក់កាលទី III នៅក្នុងផ្នែកប្រេងឥន្ធនៈ: ទឹកស៊ុំ និងប្រេងរំអិល។)

**សំខាន់៖ កុំបន្ថែមប្រេងសម្រួលរហូតដល់កម្រិតប្រេងស្ថិតក្រោមសញ្ញា "ADD" នៅលើម៉ាក្រេវប្រេង។ ប្រេងម៉ាស៊ីន John Deere Break-In គួរត្រូវបានប្រើប្រាស់ដើម្បីសម្រួលដល់ប្រេងមួយចំនួនបានប្រើប្រាស់ក្នុងអំឡុងពេលនេះ។**

**ហាមប្រើប្រាស់ប្រេងម៉ាស៊ីន Plus-50™ នៅអំឡុងពេលរ៉ូដាស់របស់ម៉ាស៊ីនថ្មី ឬម៉ាស៊ីនដែលរើសជួសជុលធំ។ ប្រេងទាំងនេះនឹងមិនធ្វើឲ្យម៉ាស៊ីនថ្មី ឬបានជួសជុលសឹកក្នុងកំឡុងពេលរ៉ូដាស់នេះទេ។**

**ហាមចាក់ប្រេងចូលលើសញ្ញាខ្វែងនៅលើម៉ាក្រេវ។**

4. អំឡុងពេល 20 ម៉ោងដំបូង ហាមការ៉ង់ទីម៉ាស៊ីនរយៈពេលយូរ។ ប្រសិនបើម៉ាស៊ីនការ៉ងទីលើសពី 5 នាទី ចូរពន្លត់ម៉ាស៊ីនភ្លាម។
5. អំឡុងពេលប្រតិបត្តិការម៉ាស៊ីនថ្មី ឬម៉ាស៊ីនជួសជុលរួចលើកដំបូង ដោយប្រើប្រេងម៉ាស៊ីន John Deere Break-In ចូរប្តូរប្រេងនិងតម្រងក្នុងចន្លោះពេលជាអប្បបរមាចំនួន 100 ម៉ោងរហូតដល់អតិបរមាចំនួន 375 ម៉ោងសម្រាប់ប្រេងម៉ាស៊ីន John Deere Plus-50™។ (សូមអានអំពីប្រេងម៉ាស៊ីនម៉ាស៊ូត — ចំណាត់ថ្នាក់ 3 និងដំណាក់កាល IIIA នៅផ្នែកប្រេងឥន្ធនៈ: ប្រេងរំអិល និងទឹកថ្នាំស៊ុំម៉ាស៊ីន។)
6. មើលភ្លើងសញ្ញាសីតុណ្ហភាពទឹកថ្នាំស៊ុំម៉ាស៊ីននៅលើអេក្រង់បង្ហោលកាច់ជ្រុងឲ្យបានដិតដល់នៅអំឡុងពេលប្រតិបត្តិការម៉ាស៊ីន។ ប្រសិនបើប្រដាប់វាស់រំកិលចូលតំបន់ពណ៌ក្រហម ចូរកាត់បន្ថយបន្ទុកនៅលើម៉ាស៊ីន និងកំណត់បញ្ហាមុននឹងបន្តប្រតិបត្តិការ។
7. ពិនិត្យមើលកម្រិតទឹកថ្នាំស៊ុំឲ្យបានទៀងទាត់ ហើយមើលសញ្ញាលេចធ្លាយ។ ចាក់ទឹកថ្នាំស៊ុំម៉ាស៊ីនចូលក្នុងធុងខ្ពោលទៅដល់បន្ទាត់ Max Cold។

CP00834,1668646964359-KM-16NOV22-1/1

## គ្រឿងចក្ររ៉ូដាស

1. បន្ទាប់ពីម៉ាស៊ីនដំណើរការបាន 15 នាទី ចូរភ្ជាប់/ផ្តាច់ប្រព័ន្ធបោកបែន។ ប្រសិនមើលឃើញសំឡេងខុសប្រក្រតី ចូរផ្តាច់ប្រព័ន្ធបោកបែនជាបន្ទាន់ ហើយពន្លត់ម៉ាស៊ីន។ ពិនិត្យកូដបញ្ហារោគវិនិច្ឆ័យនិងជួសជុល។
2. បន្ទាប់ពីគ្រឿងចក្រដំណើរការបានពី 15 ទៅ 30 នាទី ចូរផ្តាច់ប្រព័ន្ធបោកបែន ហើយពន្លត់ម៉ាស៊ីន។ ពិនិត្យមើលជាដងទាំងអស់ក្រែងលោក្តៅខ្លាំង។
3. បន្ទាប់ពីម៉ាស៊ីនដំណើរការបានពីរបីម៉ោង ចូរពិនិត្យមើលនិងរឹតបន្តឹងខ្សែពាន និងច្រវាក់ទាំងអស់។

CP00834,0008FEB-KM-29AUG21-1/1

## ការថែទាំរយៈពេលរ៉ូដាស់

ក្នុងអំឡុងពេលរ៉ូដាស់, ចូរធ្វើការថែទាំនៅប៉ុន្មានម៉ោងដំបូង, ការថែទាំ 25 ម៉ោងដំបូង និងការថែទាំ 100 ម៉ោងដំបូង។ (អានតារាងថែទាំ—រយៈពេលរ៉ូដាស់នៅក្នុងផ្នែកនេះ។)

នៅអំឡុងពេលរ៉ូដាស់ ចូរធ្វើការថែទាំរាល់ 10 ម៉ោង (រាល់ថ្ងៃ) ផងដែរ ការថែទាំរាល់ 50 ម៉ោង និងរាល់ 100 ម៉ោង។

- អានតារាងដាក់ប្រេងរំអិល និងការថែទាំ—រាល់ 10 ម៉ោង (រាល់ថ្ងៃ) នៅក្នុងផ្នែកដាក់ប្រេងរំអិល និងថែទាំ—រាល់ 10 ម៉ោង (រាល់ថ្ងៃ)
- អានតារាងដាក់ប្រេងរំអិល និងការថែទាំ—រាល់ 50 ម៉ោង នៅក្នុងផ្នែកដាក់ប្រេងរំអិល និងថែទាំ—រាល់ 50 ម៉ោង
- អានតារាងដាក់ប្រេងរំអិល និងការថែទាំ—រាល់ 100 ម៉ោង នៅក្នុងផ្នែកដាក់ប្រេងរំអិល និងថែទាំ—រាល់ 100 ម៉ោង

CP00834,0008FE8-KM-05AUG21-1/1

## តារាងថែទាំ—រយៈពេលរ៉ូដាស់

កំណត់ចំណាំ៖ នៅអំឡុងពេលរ៉ូដាស់ ចូរធ្វើការថែទាំរាល់ *10* ម៉ោង *(រាល់ថ្ងៃ)* ផងដែរ ការថែទាំរាល់ *50* ម៉ោង និងរាល់ *100* ម៉ោង។

| ធាតុ | ពីរបីម៉ោងដំបូង | 25 ម៉ោងដំបូង | 100 ម៉ោងដំបូង |
|---|---|---|---|
| ពិនិត្យមើល និងរឹតបន្តឹងប៊ូឡុងកង់និងក្បាលឡោស៊ុ | • | • | |
| ពិនិត្យមើល និងរឹតបន្តឹងប៊ូឡុងភ្លៅមុខ និងក្បាលឡោស៊ុ | | • | |
| ប្តូរប្រេងម៉ាស៊ូននិងតម្រងប្រេង | | | • |
| ប្តូរតម្រងប្រេងអ៊ីដ្រូលីក | | | • |
| ប្តូរសំណាញ់តម្រងអ៊ីដ្រូស្តាទិក (ការអូសដោយអ៊ីដ្រូស្តាទិក) | | | • |
| ប្តូរប្រេងប្រអប់លេខប្រអប់ស្តី | | | • |
| ប្តូរប្រេងដុំអូសទាញខាងចុង | | | • |
| ប្តូរប្រេងរំអិលស្តីកាត់បន្ថយល្បឿនស៊ីឡាំងបោកបែន (ជម្រើស) | | | • |
| ប្តូរប្រេងហ្គ្រាំង | | | • |
| ប្តូរប្រេងប្រអប់ស្តីរ៉ូទ័រគ្រឿងបំបែក | | | • |
| ប្តូរប្រេងភ្លៅអូសកង់ក្រោយ (ជម្រើស) | | | • |
| ប្តូរប្រេងគ្រឿងបញ្ជូនខាងចុងអូសកង់ក្រោយ (ជម្រើស) | | | • |
| ប្តូរប្រេងប្រអប់ស្តីអូសកង់ក្រោយ (ជម្រើស) | | | • |

CP00834,1668647266968-KM-16NOV22-1/1

## ពិនិត្យមើល និងរឹតបន្តឹងប៊ូឡុងកង់និងក្បាលឡោស៊ុ

| ចន្លោះពេលផ្តល់សេវា |
|---|
| ពីរបីម៉ោងដំបូង |
| 25 ម៉ោងដំបូង |
| រាល់ 200 ម៉ោង (រាល់ឆ្នូវ)* |


បន្តឹងប៊ូឡុងកង់និងក្បាលឡោស៊ុរាល់ 200 ម៉ោង ឬរាល់ឆ្នូវ ទោះបីជាមួយណាដល់មុនក៏ដោយ។

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្គ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**


*បន្ទាប់ពីរយៈពេល 25 ម៉ោងដំបូង ចូរពិនិត្យមើល និងរឹត

តទៅទំព័របន្ទាប់


CP00834,1661848485905-KM-30AUG22-1/3




កង់មុខ




កង់ក្រោយ




កង់ក្រោយ (ដុំអូសកង់ក្រោយ ជម្រើស)


តទៅទំព័របន្ទាប់

ពិនិត្យ និងរឹតបន្តឹងក្បាលឡោស៊ីកង់មុខ (A) និងប៊ូឡុងកង់ក្រោយ (B) ដោយអនុវត្តលំដាប់តំណឹងទៅតាមលក្ខណៈបច្ចេកទេស។

**លក្ខណៈបច្ចេកទេស**

| | |
|---|---|
| ឡោស៊ីកង់មុខ—កម្លាំងបង្វិល | 420 ញូតុនម៉ែត្រ (310 ផោនហ្វីត) |
| ប៊ូឡុងកងក្រោយ—កម្លាំងបង្វិល | 180 ញូតុនម៉ែត្រ (133 ផោនហ្វីត) |

**A—ក្បាលឡោស៊ី (ប្រើ 8)** **B—ប៊ូឡុង (ប្រើ 8)**




YC12755—UN—06AUG18

លំដាប់កម្លាំងបង្វិល

CP00834,1661848485905-KM-30AUG22-3/3

## ពិនិត្យមើល និងរឹតបន្តឹងប៊ូឡុងភ្លៅមុខ និងក្បាលឡោស៊ី

| | |
|---|---|
| ចន្លោះពេលជ្រើសរើសថែទាំ | 25 ម៉ោងដំបូង |
| | រាល់ 200 ម៉ោង (រាល់ឆ្នូវ)* |

*បន្ទាប់ពីរយៈពេល 25 ម៉ោងដំបូង ចូរពិនិត្យមើល និងរឹត

បន្តឹងប៊ូឡុងភ្លៅមុខ និងក្បាលឡោស៊ីរាល់ 200 ម៉ោង ឬរាល់ឆ្នូវ ទោះបីជាមួយណាដល់មុនក៏ដោយ។

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញមុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**


CP00834,1661848574698-KM-30AUG22-1/2

ពិនិត្យ និងរឹតបន្តឹងប៊ូឡុងភ្ជាប់ភ្លៅមុខនិងក្បាលឡោស៊ីទៅតាមលក្ខណៈបច្ចេកទេស។

**លក្ខណៈបច្ចេកទេស**

| | |
|---|---|
| ក្បាលឡោស៊ីភ្លៅមុខ (A)—កម្លាំងបង្វិល | 240 ញូតុនម៉ែត្រ |
| ក្បាលឡោស៊ីភ្លៅមុខ (B)—កម្លាំងបង្វិល | 435 ញូតុនម៉ែត្រ |
| ប៊ូឡុងបុំងមុខ (C)—កម្លាំងបង្វិល | 435 ញូតុនម៉ែត្រ |

**A—ក្បាលឡោស៊ី (ប្រើ 2)** **C—ប៊ូឡុង (ប្រើ 8)**
**B—ក្បាលឡោស៊ី (ប្រើ 4)**




YC8202—UN—12MAR15

CP00834,1661848574698-KM-30AUG22-2/2

## ប្តូរប្រេងម៉ាស៊ីននិងតម្រងប្រេង

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 375 ម៉ោង* |

*ប្រសិនបើប្រេងម៉ាស៊ីននិងតម្រងប្រេងដែលណែនាំឲ្យប្រើមិនមែនជារបស់ John Deere ត្រូវបានប្រើប្រាស់ បន្ទាប់ពីរយៈពេលរ៉ូដាស ចូរបង្រួមចន្លោះពេលផ្តល់សេវាទៅដល់ 250 ម៉ោង។

កំណត់ចំណាំ៖ ជានិច្ចកាល ចូរប្តូរតម្រងប្រេងម៉ាស៊ីននៅពេលប្តូរប្រេងម៉ាស៊ីន។

បន្ទាប់ពីរ៉ូដាស់រួច ចូរប្តូរប្រេងម៉ាស៊ីននិងតម្រងប្រេង។ John Deere Plus-50™ គឺជាប្រេងម៉ាស៊ីនដែលគួរប្រើ។ ចូរអានអំពីចន្លោះពេលសេវាថែទាំប្រេងម៉ាស៊ីន និងតម្រងនៅក្នុងផ្នែកប្រេងឥន្ធនៈ៖ ប្រេងរំអិល និងទឹកថ្នាំស្អុំម៉ាស៊ីន។


កំណត់ចំណាំ៖ ប្រសិនបើប្តូរប្រេងម៉ាស៊ីននៅអំឡុងពេលរ៉ូដាស ចូរប្រើប្រេងម៉ាស៊ីន *John Deere John Deere Break-In* ។ សម្រាប់ការណែនាំ ចូរអានផ្នែកប្រេងម៉ាស៊ីនម៉ាស៊ូតដែលទើបប្រើថ្មី — គ្មានការភាយឧស្ម័ន ថ្នាក់ទី *1* ថ្នាក់ទី *2* ថ្នាក់ទី *3* ដំណាក់កាលទី *I* ដំណាក់កាលទី *II* និងដំណាក់កាលទី *III* នៅក្នុងផ្នែកប្រេងឥន្ធនៈ៖ ទឹកស្អុំ និងប្រេងរំអិល។

1. ដំណើរការម៉ាស៊ីនប្រហែល 5 នាទីដើម្បីកម្តៅប្រេងម៉ាស៊ីន។
2. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។

CP00834,1668647470682-KM-16NOV22-1/5

3. បើករ៉ូប៊ីណេបង្ហូរ (A) នៅផ្នែកខាងក្រោមម៉ាស៊ីន។

**A—រ៉ូប៊ីណេបង្ហូរ**





YC8631—UN—28FEB16

CP00834,1668647470682-KM-16NOV22-2/5

4. បន្លរបំពង់បង្ហូរប្រេងម៉ាស៊ីន (B) ដើម្បីបង្ហូរប្រេងម៉ាស៊ីនចូលទៅក្នុងធុងសមស្របដោយប្រើបំពង់បង្ហូរប្រេង(C)។

**B—ស្តុកបង្ហូរប្រេងម៉ាស៊ីន** **C—បំពង់បង្ហូរប្រេង**




YC20988—UN—21DEC22

**តទៅទំព័របន្ទាប់**


CP00834,1668647470682-KM-16NOV22-3/5

5. បន្ទរ និងដោះស្បែតម្រងចេញ (D) ដោយប្រើម៉ាឡេតដោះតម្រង។ បោះស្បែតម្រងប្រេងចោល
6. លាបប្រេងម៉ាស៊ីនស្អាតលើស្បែតម្រងថ្មីនៅត្រង់ហ្គឺតខាងក្នុង (F) និងហ្គឺតខាងក្រៅ (E) និងលើធ្មេញខ្ចៅតម្រង។
7. ជូតផ្ទៃហ្គឺតទាំងពីររបស់ក្បាលឧបករណ៍កាត់ (H និង I) ដោយប្រើក្រណាត់ស្អាត។ ចូរប្រាកដថាគន្លាក់ក្នុងហ្គឺតការពារធូលី (G) ត្រូវបានដំឡើងយ៉ាងត្រឹមត្រូវ នៅតាមចន្លោះនៅក្នុងសម្បក។ ប្តូរហ្គឺតធូលីចេញ ប្រសិនបើវាខូច


**សំខាន់៖ ពេលដំឡើងសំណាញ់តម្រង ត្រូវរឹតដោយដៃប៉ុណ្ណោះ។ អាចប្រើម៉ាឡេតម្រងសម្រាប់ការដោះប៉ុណ្ណោះ។ ចូរប្រាកដថាគន្លាក់ក្នុងហ្គឺតការពារធូលី (G) ត្រូវបានដំឡើងយ៉ាងត្រឹមត្រូវ នៅតាមចន្លោះនៅក្នុងសម្បក។**

8. ដំឡើង ហើយរឹតបន្តឹងស្បែតម្រងដោយដៃ រហូតដល់អឺបណែននឹងហ្គឺតការពារធូលី (G)។ ហាមរឹតន្លែម 3/4 ដុំទៅ 1-1/4 ដុំបន្ទាប់ពីប៉ះរ៉ង ដូចធ្វើជាមួយនឹងតម្រងស្តង់ដារនោះ។
9. បិទរ៉ូប៊ីណេបង្ហូរ (A) នៅផ្នែកខាងក្រោមម៉ាស៊ីន។
10. រឹតបន្តឹងឆ្នុកបង្ហូរប្រេងម៉ាស៊ីន (B)។


**D—ស្បែតម្រង**
**E—ហ្គឺតខាងក្រៅ**
**F—ហ្គឺតខាងក្នុង**
**G—ហ្គឺតការពារធូលី**
**H—ផ្ទៃបិទហ្គឺតនៅក្បាលឧបករណ៍កាត់**
**I—ផ្ទៃបិទហ្គឺតនៅក្បាលឧបករណ៍កាត់**



ប្តូរតម្រងប្រេងម៉ាស៊ីន



ហ្គឺតតម្រងប្រេង



តម្រង និងការបំបាក់ក្បាលឧបករណ៍កាត់

**តទៅទំព័របន្ទាប់**

11. ដោះគម្របចាក់ប្រេង (J) ចេញហើយចាក់ប្រេងម៉ាស៊ីនដែលបានបញ្ជាក់ចូលក្នុងប្រអប់រំអិលម៉ាស៊ីន។


កំណត់ចំណាំ៖ ពិនិត្យមើលចំណុះប្រេងម៉ាស៊ីននៅក្នុងផ្នែកលក្ខណៈបច្ចេកទេស។

12. ដោះម៉ាក្រេរ៍ប្រេងចេញ (K) ហើយពិនិត្យមើលកម្រិតប្រេង។ កម្រិតប្រេងម៉ាស៊ីនគួរតែស្ថិតនៅក្នុងតំបន់គំនូសខ្វែងនៅលើម៉ាក្រេរ៍។


13. បញ្ឆេះម៉ាស៊ីន ហើយដំណើរការ ដើម្បីពិនិត្យរកមើលការលេចធ្លាយដែលអាចកើតមាន។

14. ពន្លត់ម៉ាស៊ីន ហើយ 10 នាទីបន្ទាប់មក សូមពិនិត្យមើលកម្រិតប្រេងម៉ាស៊ីន។

**J—គម្របចាក់ប្រេង** **K—ម៉ាក្រេរ៍**




YC20993—UN—21DEC22




ម៉ាក្រេរ៍ប្រេងម៉ាស៊ីន

CP00834,1668647470682-KM-16NOV22-5/5

## ប្តូរតម្រងប្រេងអ៊ីដ្រូលីក


| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1668649506342-KM-16NOV22-1/2

ដោះស្បែតម្រងប្រេងអ៊ីដ្រូលីក (A) ចេញ ហើយប្តូរដាក់ស្បែតម្រងថ្មី។

**A—ស្បែតម្រងប្រេងអ៊ីដ្រូលីក**




CP00834,1668649506342-KM-16NOV22-2/2

## ប្តូរសំណាញ់តម្រងអ៊ីដ្រូស្តាទិក (ការអូសដោយអ៊ីដ្រូស្តាទិក)

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

**តទៅទំព័របន្ទាប់**


CP00834,1668649758942-KM-18NOV22-1/2

1. ដោះប៊ូឡុង (C) និងគម្រប (B) ចេញដើម្បីប្តូរសំណាញ់តម្រង (E)។

**សំខាន់៖ រក្សាប្រេងអ៊ីដ្រូស្តាទិកឲ្យស្អាត។**


2. លាបការបិទរ៉ងដែលមិនមានជាតិស៊ីលីកូនលើគម្រប និងប៊ូឡុង។
3. ដាក់គម្រប និងរឹតបន្តឹងប៊ូឡុង។

**A—ធុងស្តុកអ៊ីដ្រូស្តាទិក**
**B—គម្រប**
**C—ប៊ូឡុង (ប្រើ 6)**
**D—រ៉ងហ្គឺត**
**E—សំណាញ់តម្រង**




YC20995—UN—21DEC22

ធុងស្តុកអ៊ីដ្រូស្តាទិក




YC20996—UN—21DEC22

CP00834,1668649758942-KM-18NOV22-2/2

## ប្តូរប្រេងប្រអប់លេខប្រអប់ស្តី

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 500 ម៉ោង |


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញមុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**

**តទៅទំព័របន្ទាប់**

CP00834,1668655504668-KM-16NOV22-1/2

1. ដាក់ធុងត្រងសមស្របខាងក្រោមប្រអប់លេខប្រអប់ស្តីហ្គែរ។
2. ដោះឆ្នុកចាក់បំពេញ (A) និងឆ្នុកបង្ហូរ (B) ចេញដើម្បីបង្ហូរប្រេង។
3. ដំឡើង និងរឹតបន្តឹងឆ្នុកបង្ហូរប្រេង។
4. ចាក់ប្រេងជាក់លាក់ចូលក្នុងប្រអប់លេខប្រអប់ស្តី។
   - **ប្រេងស្តី៖** ប្រេងស្តី GL-5 80W/90
   - **ចំណុះប្រអប់ស្តី៖** 6.6 ល
5. ដំឡើង និងរឹតបន្តឹងឆ្នុកចាក់បំពេញរហូតដល់ប្រេងហូរចេញពីរន្ធចាក់បំពេញ។

**A—ឆ្នុកចាក់ប្រេង** **B—ឆ្នុកបង្ហូរ**




CP00834,1668655504668-KM-16NOV22-2/2

## ប្តូរប្រេងដុំអូសទាញខាងចុង


| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 500 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញមុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**

CP00834,1668655537671-KM-16NOV22-1/2

1. ដាក់ធុងត្រងសមស្របនៅក្រោមដុំអូសខាងចុង។
2. ដោះឆ្នុកចាក់បំពេញ (D) ឆ្នុកកម្រិតប្រេង (A) និងឆ្នុកបង្ហូរ (B) ចេញដើម្បីបង្ហូរប្រេង។
3. ដំឡើង និងរឹតបន្តឹងឆ្នុកបង្ហូរប្រេង។
4. ចាក់បំពេញប្រេងជាក់លាក់ចូលដុំអូសខាងចុង។
   - **ប្រេងស្តី៖** ប្រេងស្តី GL-5 80W/90
   - **ចំណុះដុំអូសខាងចុង៖** 3.1 ល
5. ដំឡើង និងរឹតបន្តឹងឆ្នុកកម្រិតប្រេងរហូតដល់ប្រេងហៀរចេញពីរន្ធ។
6. ដំឡើង និងរឹតបន្តឹងឆ្នុកចាក់ប្រេង។

**A—ឆ្នុកកម្រិតប្រេង** **C—ឆ្នុកបង្ហូរ**
**B—ឆ្នុកបង្ហូរ** **D—ឆ្នុកចាក់ប្រេង**




បានបង្ហាញដុំអូសខាងចុងចំហៀងខាងស្តាំ

CP00834,1668655537671-KM-16NOV22-2/2

## ប្តូរប្រេងរំអិលស្តីកាត់បន្ថយល្បឿនស៊ីឡាំងបោកបែន (ជម្រើស)

| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 500 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញមុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**


**សំខាន់៖ មុននឹងចាក់បំពេញស្តីបន្ថយល្បឿនស៊ីឡាំងបើកបែនឬពិនិត្យមើលកម្រិតប្រេង ចូរបិទបំលែល្បឿនប្រែប្រួល។**

**តទៅទំព័របន្ទាប់**

CP00834,1668655573735-KM-16NOV22-1/2

1. ដាក់ធុងត្រែងសមស្របខាងក្រោមស្តីបន្តុយល្បឿនស៊ីឡាំង។
2. ដោះហីយ (A), ឆ្នុកចាក់បំពេញ (B), និងឆ្នុកបង្ហូរ (C) ដើម្បីបង្ហូរប្រេងរំអិលចេញ។
3. ដំឡើង និងរឹតបន្តឹងឆ្នុកបង្ហូរប្រេង។
4. ចាក់ប្រេងរំអិលជាក់លាក់ចូលក្នុងស្តីបន្តុយល្បឿនស៊ីឡាំងបោកបែន។
   - **ប្រេងរំអិល៖** ប្រេងរំអិល MOBILITH SHC 007
   - **ចំណុះប្រេងរំអិល៖** 0.8 គ.ក
5. ដំឡើង និងរឹតបន្តឹងឆ្នុកចាក់បំពេញរហូតដល់ប្រេងហៀរចេញពីរន្ធ។
6. ដំឡើង ហើយរឹតបន្តឹងហីយ។

**សំខាន់៖ ពិនិត្យកម្រិតប្រេងម្តងទៀតបន្ទាប់ពីដំណើរការបាន 15 នាទី។ ចាក់ប្រេងចូលតាមចាំបាច់។**




YC20999—UN—21DEC22

**A—ហីយ**
**B—ឆ្នុកចាក់ប្រេង**
**C—ឆ្នុកបង្ហូរ**

CP00834,1668655573735-KM-16NOV22-2/2

## ប្តូរប្រេងហ្វ្រាំង


| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
|---|---|
| | រាល់ 500 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញមុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**


CP00834,1668655605003-KM-16NOV22-1/2

1. ដាក់ធុងត្រែងសមស្របខាងក្រោមប្រអប់លេខប្រអប់ស្តីហ្គែរ។
2. ដោះគម្រប (A)។
3. បន្ធូរក្បាលឡោស៊ីមានឡក់ (B) ដើម្បីដោះទុយោប្រេងអ៊ីដ្រូលីកចេញពីស៊ីឡាំងជំនួយហ្វ្រាំង (C)។
4. ជាន់ឈ្នាន់ហ្វ្រាំងដើម្បីបង្ហូរប្រេងហ្វ្រាំង។
5. តទុយោប្រេងអ៊ីដ្រូលីក ហើយរឹតបន្តឹងក្បាលឡោស៊ីមានឡក់។
6. ចាក់ប្រេងដែលបានបញ្ជាក់ចូលក្នុងធុងស្តុកប្រេងហ្វ្រាំង។
   - **ប្រេង៖** 10# ប្រេងអ៊ីដ្រូលីកយន្តហោះ
   - **ចំណុះប្រព័ន្ធហ្វ្រាំង៖** 3 ល
   - **ចំណុះកំប៉ុងប្រេងហ្វ្រាំង៖** 0.75 ល
7. ដាក់គម្របចូល ហើយរឹតបន្តឹងរហូតទាល់តែធុងស្តុកប្រេងហ្វ្រាំងពេញ។
8. សាប់បន្ធូរប្រព័ន្ធហ្វ្រាំង។ (អានអំពីសាប់បន្ធូរប្រព័ន្ធហ្វ្រាំងនៅក្នុងផ្នែកថែទាំប្រព័ន្ធអូសទាញ។)

**A—គម្រប**
**B—ក្បាលឡោស៊ីមានឡក់ (ប្រើ 2)**
**C—ស៊ីឡាំងជំនួយហ្វ្រាំង (ប្រើ 2)**




YC21000—UN—21DEC22




YC21101—UN—21DEC22

CP00834,1668655605003-KM-16NOV22-2/2

## ប្តូរប្រេងប្រអប់ស្តីរ៉ូទ័រគ្រឿងបំបែក


| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 500 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**


CP00834,1668658597852-KM-16NOV22-1/2

1. ដាក់ធុងត្រងសមស្របខាងក្រោមប្រអប់ស្តីហ្គែរ។
2. ដោះឆ្នុកចាក់បំពេញ (A) និងឆ្នុកបង្ហូរ (B) ចេញដើម្បីបង្ហូរប្រេង។
3. ដំឡើង និងរឹតបន្តឹងឆ្នុកបង្ហូរប្រេង (B)។
4. ចាក់ប្រេងជាក់លាក់ចូលក្នុងប្រអប់ស្តី។
   - **ប្រេង៖** John Deere Hy-Gard™
   - **ចំណុះប្រអប់ស្តីលៃតម្រូវបាន៖** 2.5 ល
   - **ចំណុះប្រអប់ស្តីមិនអាចលៃតម្រូវបាន៖** 1.6 ល
5. ដំឡើង និងរឹតបន្តឹងឆ្នុកចាក់បំពេញរហូតដល់ប្រេងហៀរចេញពីរន្ធ។

**A—ឆ្នុកចាក់ប្រេង** **B—ឆ្នុកបង្ហូរ**




ប្រអប់ស្តីលៃតម្រូវបាន




ប្រអប់ស្តីមិនអាចលៃតម្រូវបាន

CP00834,1668658597852-KM-16NOV22-2/2

## ប្តូរប្រេងភ្លៅអូសកង់ក្រោយ (ជម្រើស)


| | |
|---|---|
| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
| | រាល់ 1600 ម៉ោង |

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**

CP00834,1668658861006-KM-16NOV22-1/2

1. ដាក់ធុងត្រងសមស្របនៅក្រោមភ្លៅអូសកង់ក្រោយ។
2. ដោះឆ្នុកចាក់បំពេញ (A) និងឆ្នុកបង្ហូរ (B) ចេញដើម្បីបង្ហូរប្រេង។
3. ដំឡើង និងរឹតបន្តឹងឆ្នុកបង្ហូរប្រេង។
4. ចាក់ប្រេងដែលបានបញ្ជាក់ចូលក្នុងភ្លៅអូកង់ក្រោយ។
   - **ប្រេងស្តី៖** ប្រេងស្តី GL-5 80W/90
   - **ចំណុះប្រេង៖** 18 ល
5. ដំឡើង និងរឹតបន្តឹងឆ្នុកចាក់បំពេញរហូតដល់ប្រេងហៀរចេញពីរន្ធ។

**A—ឆ្នុកចាក់ប្រេង** **B—ឆ្នុកបង្ហូរ**




CP00834,1668658861006-KM-16NOV22-2/2

## ប្តូរប្រេងគ្រឿងបញ្ជូនខាងចុងអូសកង់ក្រោយ (ជម្រើស)


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**

| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
|---|---|
| | រាល់ 800 ម៉ោង |

CP00834,0008E77-KM-10JUN21-1/2

1. បង្វិលកង់ក្រោយដើម្បីឲ្យឆ្នុក (A) ស្ថិតនៅត្រង់ទីតាំងទាបបំផុត។
2. ដាក់ធុងសមស្របដើម្បីត្រងប្រេង។
3. ដោះឆ្នុកចេញដើម្បីបង្ហូរប្រេង។
4. បង្វិលកង់ក្រោយដើម្បីឲ្យឆ្នុកស្ថិតនៅត្រង់ទីតាំងផ្តេក។
5. ចាក់បំពេញប្រេងជាក់លាក់ចូលដុំអូសខាងចុង។
   - **ប្រេងស្តើ៖** ប្រេងស្តើ GL-5 80W/90
   - **ចំណុះប្រេង៖** 1.5 ល
6. ដំឡើង និងរឹតបន្តឹងឆ្នុករហូតដល់ប្រេងហៀរចេញពីរន្ធ។

**A—ឆ្នុក**




YC16665—UN—13JAN21

ដោតនៅត្រង់ទីតាំងទាប់បំផុត




YC17612—UN—01JUN21

ដោតនៅត្រង់ទីតាំងផ្តេក

CP00834,0008E77-KM-10JUN21-2/2

## ប្តូរប្រេងប្រអប់ស្តីអូសកង់ក្រោយ (ជម្រើស)

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**


| ចន្លោះពេលផ្តល់សេវាថែទាំ | 100 ម៉ោងដំបូង |
|---|---|
| | រាល់ 400 ម៉ោង |

**តទៅទំព័របន្ទាប់**


CP00834,1668658901044-KM-16NOV22-1/2

1. ដាក់ធុងត្រងសមស្របខាងក្រោមប្រអប់ស្តីហ្គែរ។
2. ដោះឆ្នុកចាក់បំពេញ (B) ឆ្នុកកម្រិតប្រេង (C) និងឆ្នុកបង្ហូរ (E) ចេញដើម្បីបង្ហូរប្រេង។
3. ដំឡើង និងរឹតបន្តឹងឆ្នុកបង្ហូរប្រេង។
4. ចាក់ប្រេងជាក់លាក់ចូលក្នុងប្រអប់ស្តី។
   - **ប្រេងស្តី៖** ប្រេងស្តី GL-5 80W/90
   - **ចំណុះប្រេង៖** 3.2 គ.ក
5. ដំឡើង និងរឹតបន្តឹងឆ្នុកកម្រិតប្រេងរហូតដល់ប្រេងហៀរចេញពីរន្ធ។
6. ដំឡើង និងរឹតបន្តឹងឆ្នុកចាក់ប្រេង។


**A—ប្រអប់ស្តី**
**B—ឆ្នុកចាក់ប្រេង**
**C—ឆ្នុកកម្រិតប្រេង**
**D—ហ៊ីយ**
**E—ឆ្នុកបង្ហូរ**




ផ្នែកខាងលើប្រអប់ស្តី




ចំហៀងប្រអប់ស្តី




ផ្នែកខាងក្រោមប្រអប់ស្តី

CP00834,1668658901044-KM-16NOV22-2/2

# ប្រតិបត្តិការភ្លើងបំភ្លឺនិងអគ្គិសនី

## ប្រតិបត្តិតាមការប្រុងប្រយ័ត្នអគ្គិសនី

**⚠ ប្រយ័ត្ន៖ កុំឲ្យមានផ្កាភ្លើង និងអណ្តាតភ្លើងនៅជិតអាគុយ ពីព្រោះឧស្ម័នដែលបញ្ចេញដោយអេឡិចត្រូតអាចផ្ទុះបាន។ ដើម្បីចៀសវាងផ្កាភ្លើង ត្រូវតភ្ជាប់ខ្សែកាបអវិជ្ជមាន (ម៉ាស់) ចុងក្រោយ ហើយផ្តាច់វាជាមុនសិន។ ដើម្បីចៀសវាងការឆក់ និងឆេះ កាច់បិទកុងតាក់ផ្តាច់អាគុយ មុននឹងជួសជុលផ្នែកណាមួយនៃប្រព័ន្ធអគ្គិសនី ឬនៅពេលដោះអាគុយចេញ។**

CP00834,0008ED3-KM-24JUN21-1/1

## ពិនិត្យស្ថានភាពអាគុយ

**សំខាន់៖ ហាមដាក់អេឡិចត្រូលីតទៅក្នុងអាគុយដែលមិនត្រូវការការថែទាំ។ អាគុយមិនត្រូវទម្រេត។**

CP00834,0008DEB-KM-10JAN22-1/2




ស្លាកអាគុយ

អាគុយនេះមិនចាំបាច់ថែទាំឡើយ។ ពិនិត្យពណ៌ភ្លើងសញ្ញាស្ថានភាពអាគុយនៅលើអាគុយឱ្យបានញឹកញាប់។ សាកឡើងវិញ ឬប្តូរអាគុយចេញតាមចាំបាច់។

| ពណ៌ភ្លើងសញ្ញា | ស្ថានភាពអាគុយ |
|---|---|
| បៃតង | ល្អ |
| ខ្មៅ | ប្តូរអាគុយ |
| ស | ប្តូរអាគុយ |

CP00834,0008DEB-KM-10JAN22-2/2

## ការប្រើប្រាស់កុងតាក់ផ្តាច់អាគុយ

**សំខាន់៖ កុងតាក់ផ្តាច់អាគុយមិនគ្រប់គ្រងថាមពលទៅប្រអប់បញ្ជាម៉ាស៊ីន (ECU)។ ប្រសិនបើមិនប្រើប្រាស់ម៉ាស៊ីនរយៈពេលយូរ ផ្តាច់ខ្សែម៉ាសអាគុយចេញ។**

**សំខាន់៖ ដើម្បីចៀសវាងការបាត់បង់ទិន្នន័យពី ECU រងចាំយ៉ាងតិច 30 វិនាទីមុនផ្តាច់កុងតាក់ផ្តាច់អាគុយបន្ទាប់ពីពន្លត់ម៉ាស៊ីន។**


**តទៅទំព័របន្ទាប់**

CP00834,1668658994143-KM-16NOV22-1/2

រាល់ថ្ងៃ ចូរកាច់កុងតាក់ផ្តាច់អាគុយ (A) ទៅទីតាំងបិទបន្ទាប់ពីច្រូតកាត់រួច។

មុនពេលជួសជុលសមាសធាតុអគ្គិសនី បិទកុងតាក់ផ្តាច់ចរន្តអាគុយ។

**A—កុងតាក់ផ្តាច់អាគុយ**





កុងតាក់ផ្តាច់អាគុយ (ទីតាំងបើក)

CP00834,1668658994143-KM-16NOV22-2/2

## ការកំណត់អត្តសញ្ញាណបន្ទះហ្វុយហ្សីបកាប៊ីន

CP00834,1668659495547-KM-21NOV22-1/3


**A—រីឡេភ្លើងការបារខាងក្នុងផ្នែកខាងមុខ និងកណ្តាល**
**B—រីឡេស៊ីវ៉ែ**
**C—រីឡេបើកភ្លើង**
**D—ហ្វុយហ្សីបបម្រុង**
**E—រីឡេថាមពល**
**F—រីឡេម៉ាស៊ីនប្រែងតន្លង:**
**G—រីឡេភ្លើងមុខកាំពន្លឺខ្ពស់**
**H—រីឡេភ្លើងមុខកាំពន្លឺទាប**
**I—រីឡេភ្លើងការងារខាងក្រៅផ្នែកខាងមុខ**




ហ្វុយហ្សីប និងរីឡេនៅក្នុងកាប៊ីន

**តទៅទំព័របន្ទាប់**

CP00834,1668659495547-KM-21NOV22-2/3




ហ្វ្យូសប្លឹប

| ធាតុ | ហ្វ្យូសប្លឹប | ធាតុ | ហ្វ្យូសប្លឹប | ធាតុ | ហ្វ្យូសប្លឹប | ធាតុ | ហ្វ្យូសប្លឹប |
|---|---|---|---|---|---|---|---|
| 1 | ហ្វ្យូសប្លឹបភ្លើងការងារខាងក្តងផ្នែកខាងមុខ និងកណ្តាល 25A | 2 | ហ្វ្យូសប្លឹបបម្រុង 10A | 3 | ហ្វ្យូសប្លឹបបម្រុង 25A | 4 | ភ្លើងការងារខាងក្រៅផ្នែកខាងមុខ 15A |
| 5 | ហ្វ្យូសប្លឹបស៊ីផ្លេ 10A | 6 | ហ្វ្យូសប្លឹបកុងតាក់ភ្លើងការងារខាងមុខ 10A | 7 | ហ្វ្យូសប្លឹបភ្លើងរលិ 15A | 8 | ហ្វ្យូសប្លឹបភ្លើងមុខកាំពន្លឺទាប 15A |
| 9 | ហ្វ្យូសប្លឹបភ្លើងសញ្ញាបត់ 10A | 10 | ហ្វ្យូសប្លឹបដែបញ្ញាពហុមុខងារ 10A | 11 | ហ្វ្យូសប្លឹបភ្លើងមុខកាំពន្លឺខ្ពស់ 15A | 12 | ហ្វ្យូសប្លឹបបម្រុង 10A |
| 13 | ហ្វ្យូសប្លឹបបម្រុង 15A | 14 | ហ្វ្យូសប្លឹបបម្រុង 10A | 15 | ហ្វ្យូសប្លឹបបម្រុង 25A | 16 | ហ្វ្យូសប្លឹបបម្រុង 15A |
| 17 | ហ្វ្យូសប្លឹបអេក្រង់បង្ហោលកាច់ស្រុង 10A | 18 | ហ្វ្យូសប្លឹបភ្លើងពន្លឺតិចៗនិង A/C 15A | 19 | ហ្វ្យូសប្លឹបភ្លើងថយក្រោយនិងស៊ីផ្លេ 15A | 20 | ហ្វ្យូសប្លឹបសំឡេងរោទ៍ថយក្រោយ 10A |
| 21 | ហ្វ្យូសប្លឹបម៉ូទ័រលៃតម្រូវល្បឿនកង់រ៉ក 10A | 22 | ហ្វ្យូសប្លឹបប្រអប់បញ្ជាដែបញ្ជាពហុមុខងារ 5A | | | | |

CP00834,1668659495547-KM-21NOV22-3/3

## ហ្វ្យូសប្លឹបនិងរីឡេនៅក្នុងប្រអប់អគ្គិសនី


**សំខាន់៖ ប្រសិនបើហ្វ្យូសប្លឹបនិងរីឡេនៅក្នុងប្រអប់អគ្គិសនីត្រូវការប្តូរ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់លោកអ្នក។**

**ត្រូវប្រាកដថាកុងតាក់ផ្តាច់អាគុយគឺបិទមុនពេលប្តូរហ្វ្យូសប្លឹប។**

CP00834,1668660276868-KM-16NOV22-1/2

ប្រអប់អគ្គិសនីស្ថិតនៅចំហៀងខាងឆ្វេងដៃម៉ាស៊ីន។

**A—ហ្វ្យូសប្លឹបផ្គត់ផ្គង់ថាមពលចម្បង (100 A)**
**B—ហ្វ្យូសប្លឹបគ្រឿងកម្តៅបញ្ឆោះពេលត្រជាក់ (100A)**
**C—រីឡេអង្គបញ្ឆោះ**
**D—រីឡេគ្រឿងកម្តៅបញ្ឆោះពេលត្រជាក់**
**E—ហ្វ្យូសប្លឹប (ហ្វ្យូសប្លឹប ECU 20 A និងហ្វ្យូសប្លឹបកុងតាក់សៅ 15 A)**





CP00834,1668660276868-KM-16NOV22-2/2

## ទីតាំងភ្លើងបំភ្លឺ


តទៅទំព័របន្ទាប់

CP00834,1668662516505-KM-16NOV22-1/2


A—ភ្លើងការងារ (ប្រើ 2)
B—ភ្លើងការងារ (ប្រើ 4)
C—ភ្លើងវិល (សម្រាប់ទីផ្សារនាំចេញប៉ុណ្ណោះ)
D—ភ្លើងលើកដាក់
E—ភ្លើងព្រមានគ្រោះថ្នាក់ខាងមុខ/ភ្លើងសញ្ញាបត់ខាងមុខ (ប្រើ 2)
F—ភ្លើងសញ្ញាខាងមុខ (ប្រើ 2)
G—ភ្លើងមុខ (ភ្លើងកាំពន្លឺខ្ពស់/ទាប, ប្រើ 2)
H—ភ្លើងធុងគ្រាប់ធញ្ញជាតិ
I—ភ្លើងសញ្ញាបត់ក្រោយ (ប្រើ 2)
J—ភ្លើងសម្គាល់ខាងក្រោយ (ប្រើ 2)
K—ភ្លើងហ្វ្រាំង (ប្រើ 2)



YC21109—UN—21DEC22



YC21110—UN—21DEC22



YC21111—UN—21DEC22

ទិដ្ឋភាពខាងក្រោយ

CP00834,1668662516505-KM-16NOV22-2/2

## ប្រើភ្លើងការងារ

**ប្រយ័ត្ន៖ ដើម្បីកុំឲ្យអ្នកប្រើប្រាស់យានយន្តយល់ច្រឡំ ហាមបើកភ្លើងការងារនៅពេលបើកបរលើផ្លូវសាធារណៈ។**

តទៅទំព័របន្ទាប់

CP00834,1668663033916-KM-16NOV22-1/2

កុងតាក់ភ្លើងការងារ (A) គ្រប់គ្រងភ្លើងការងារ (B និង C)។


កុងតាក់ភ្លើងការងារគឺជាកុងតាក់មានបីទីតាំង៖

- ទីតាំងខាងលើ៖ ភ្លើងការងារទាំងអស់បិទ។
- ទីតាំងខាងក្រោម៖ ភ្លើងការងារ (B) បើក។
- ទីតាំងទាបជាងគេ៖ ភ្លើងការងារ (B និង C) បើក។

**A—កុងតាក់ភ្លើងការងារ**
**B—ភ្លើងការងារ (ប្រើ 2)**
**C—ភ្លើងការងារ (ប្រើ 4)**




YC18231—UN—05AUG21




YC21112—UN—21DEC22

CP00834,16686630339l6-KM-16NOV22-2/2

## ប្រើភ្លើងមុខ និងភ្លើងអង្គសម្គាល់

**⚠ ប្រយ័ត្ន៖ ការបុកជាមួយយានយន្តផ្សេងដោយចៃដន្យអាចបង្ករឲ្យអ្នក ឬអ្នកផ្សេងមានរបួសធ្ងន់ធ្ងរ ឬដល់ស្លាប់។ តែងតែអនុលោមតាមបទបញ្ជាចរាចរណ៍ជានិច្ច នៅពេលបើកបរគ្រឿងចក្រលើផ្លូវ។**

**ភ្លើងមុខពន្លឺតិចៗទៅកាន់ភ្លើងកាំពន្លឺទាបសម្រាប់យានយន្តមកពីខាងមុខ។**

CP00834,1665381246293-KM-10OCT22-1/2

កុងតាក់ភ្លើង (A) គ្រប់គ្រងភ្លើងអង្គសម្គាល់ និងភ្លើងកាំពន្លឺទាប។

ភ្លើងកាំពន្លឺខ្ពស់ត្រូវបានគ្រប់គ្រងដោយកុងតាក់ភ្លើងកាំពន្លឺខ្ពស់ (B) រួមគ្នាជាមួយកុងតាក់ភ្លើង។

កុងតាក់ភ្លើងគឺជាកុងតាក់មានបីទីតាំង៖

- ទីតាំងខាងលើ៖ ភ្លើងមុខ និងភ្លើងអង្គសម្គាល់បិទ។
- ទីតាំងខាងក្រោម៖ ភ្លើងអង្គសម្គាល់បើក។
- ទីតាំងទាបជាងគេ៖ ភ្លើងអង្គសម្គាល់និងភ្លើងកាំពន្លឺទាបបើក។

កុងតាក់ភ្លើងកាំពន្លឺទាបគឺជាកុងតាក់មានពីរទីតាំង៖

- ទីតាំងខាងលើ៖ ភ្លើងកាំពន្លឺខ្ពស់បិទ។

កំណត់ចំណាំ៖ មុននឹងប្រើកុងតាក់ភ្លើងកាំពន្លឺខ្ពស់ កុងតាក់ភ្លើងគួរតែនៅក្នុងទីតាំងខាងក្រោមជាងនេះ។

- ទីតាំងខាងក្រោម៖ ភ្លើងកាំពន្លឺខ្ពស់បើក។




YC18233—UN—05AUG21

**A—កុងតាក់ភ្លើង**
**B—កុងតាក់ភ្លើងកាំពន្លឺខ្ពស់**

កំណត់ចំណាំ៖ នៅពេលភ្លើងកាំពន្លឺខ្ពស់បើក ភ្លើងសញ្ញាកាំពន្លឺខ្ពស់ស្ថិតនៅក្នុងអេក្រង់បង្ហោលកាច់ជ្រុងបើក។

CP00834,1665381246293-KM-10OCT22-2/2

## ប្រើប្រាស់ភ្លើងសញ្ញាបត់

កំណត់ចំណាំ៖ ភ្លើងសញ្ញាបត់ដំណើរការនៅពេលណាដែកុងតាក់សោបើក។

CP00834,0008FAD-KM-20OCT21-1/2

កុងតាក់ភ្លើងសញ្ញាបត់ (A) បញ្ជាភ្លើងសញ្ញាបត់។


កុងតាក់ភ្លើងគឺជាកុងតាក់មានបីទីតាំង៖

- ទីតាំងខាងលើ៖ ភ្លើងសញ្ញាបត់ស្តាំបើក។
- ទីតាំងនឹង៖ ភ្លើងសញ្ញាបត់ស្តាំបិទ។
- ទីតាំងទាបជាងគេ៖ ភ្លើងសញ្ញាបត់ឆ្វេងបើក។

កំណត់ចំណាំ៖ ភ្លើងសញ្ញាបត់មិនរលត់ដោយខ្លួនឯងទេ ដូច្នេះត្រូវតែកាច់កុងតាក់ទៅទីតាំងនឹងដោយដៃ។

ពន្លឺភ្លើងសញ្ញា (ឆ្វេងឬស្តាំ) នៅលើអេក្រង់បង្គោលកាច់ជ្រុងភ្លឺឡើង និងបង្ហាញការបត់។

**A—កុងតាក់ភ្លើងសញ្ញាបត់**




CP00834,0008FAD-KM-20OCT21-2/2

## ប្រើភ្លើងពន្លឺតិចៗ

CP00834,0008FAC-KM-29AUG21-1/2


ភ្លើងពន្លឺតិចៗ (A) ផ្តល់ការបំភ្លឺពីលើក្បាលសម្រាប់ការប្រើប្រាស់នៅពេលយប់ ឬនៅក្នុងលក្ខខណ្ឌពន្លឺទាប។

កុងតាក់ភ្លើង (B) គ្រប់គ្រងភ្លើងពន្លឺតិចៗ។

កុងតាក់ភ្លើងគឺជាកុងតាក់មានពីរទីតាំង៖

- **បើក**
- **បិទ**

**A—ភ្លើងពន្លឺតិចៗ** **B—កុងតាក់ភ្លើង**




CP00834,0008FAC-KM-29AUG21-2/2

## ប្រតិបត្តិការប្រព័ន្ធគ្រឿងកម្តៅ/ខ្យល់ចេញចូល/ម៉ាស៊ីនត្រជាក់ (HVAC)

**តទៅទំព័របន្ទាប់**

CP00834,0008FAF-KM-28SEP21-1/2

**កុងតាក់ម៉ូដ HVAC (A)៖** បើកដំណើរការប្រព័ន្ធម៉ាស៊ីនត្រជាក់និងប្រព័ន្ធកម្តៅ។


- ទីតាំងខាងលើ៖ ប្រព័ន្ធកម្តៅត្រូវបានបើកដំណើរការ ហើយភ្លើងសញ្ញា (C និង D) បើក។
- ទីតាំងនីង៖ ប្រព័ន្ធ HVAC បិទ ហើយភ្លើងសញ្ញាបិទ។
- ទីតាំងទាបជាងគេ៖ ប្រព័ន្ធត្រជាក់ត្រូវបានបើកដំណើរការ ហើយភ្លើងសញ្ញា (C និង E) បើក។

**ក្បាលមួលគ្រប់គ្រងល់ហូរខ្យល់ (B)៖** លៃតម្រូវល្បឿនកង្ហារនិងបរិមាណខ្យល់ដែលចេញក្រៅស្លាបព្រឹល។

- ទីតាំងបិទ - ថាមពលទាំងអស់ទៅកាន់ប្រព័ន្ធគឺបិទ។
- ទីតាំងបើក - ល្បឿនកង្ហារកើនឡើងដោយការមូលក្បាលមួយស្របទ្រនិចនាឡិកាទៅកាន់ទីតាំងមួយក្នុងចំណោមទីតាំងទាំងបី៖ ល្បឿនទាប, មធ្យម, និងខ្ពស់

**ក្បាលមួលលៃតម្រូវសីតុណ្ហភាព AC (F)៖** លៃតម្រូវសីតុណ្ហភាពកាប៊ីន។

- មូលក្បាលមួលស្របទ្រនិចនាឡិកាដើម្បីបង្កើនសីតុណ្ហភាព។
- មូលក្បាលមួលច្រាសទ្រនិចនាឡិកាដើម្បីបន្ថយសីតុណ្ហភាព។




**A—កុងតាក់ម៉ូដ HVAC**
**B—ក្បាលមួលគ្រប់គ្រងល់ហូរខ្យល់**
**C—ភ្លើងសញ្ញា**
**D—ភ្លើងសញ្ញា**
**E—ភ្លើងសញ្ញា**
**F—ក្បាលមួលលៃតម្រូវសីតុណ្ហភាព AC**

CP00834,0008FAF-KM-28SEP21-2/2

## ការប្រើប្រាស់ផ្លិតទឹក


កំណត់ចំណាំ៖ កុងតាក់សៅត្រូវតែបើក ឬបើកដំណើរការគ្រឿងចក្រដើម្បីឲ្យផ្លិតទឹកដំណើរការ។

CP00834,0008FAE-KM-15JUL21-1/2

កុងតាក់ផ្លិតទឹក (A) ប្រើដើម្បីគ្រប់គ្រងផ្លិតទឹក។

- ទាញកុងតាក់ផ្លិតទឹកចេញក្រៅទៅកាន់ទីតាំងទីមួយ នោះផ្លិតទឹកនឹងប្រតិបត្តិការបន្តបន្ទាប់នៅល្បឿនទាប។
- ទាញកុងតាក់ផ្លិតទឹកចេញក្រៅទៅកាន់ទីតាំងទីពីរ នោះផ្លិតទឹកនឹងប្រតិបត្តិការបន្តបន្ទាប់នៅល្បឿនខ្ពស់។
- រុញកុងតាក់ផ្លិតទឹកទៅផ្នែកខាងក្រោម នោះផ្លិតទឹកនឹងបិទ។

**A—កុងតាក់ផ្លិតទឹក**




CP00834,0008FAE-KM-15JUL21-2/2

## ម៉ូដផ្លូវថ្នល់/វាលស្រែ (ការអូសដោយអ៊ីដ្រូស្តាទិក)

CP00834,1668663913898-KM-16NOV22-1/2

គេប្រើកុងតាក់ផ្លូវថ្នល់/វាលស្រែ (A) នៅពេលបើកបរម៉ាស៊ីនច្រូតតាមផ្លូវថ្នល់។

ចុចផ្នែកខាងក្រោមកុងតាក់ផ្លូវថ្នល់/វាលស្រែ ពន្លឺភ្លើងសញ្ញានៅលើកុងតាក់ និងពន្លឺភ្លើង (B) នៅលើអេក្រង់បង្ហោលកាច់ជ្រុងនឹងភ្លឺឡើង ម៉ូដផ្លូវថ្នល់នឹងបើកដំណើរការ។

ម៉ូដផ្លូវថ្នល់បង្ការមុខងារដូចតទៅនេះ៖

- ក្បាលឧបករណ៍កាត់ លើកឡើង/បន្ទាប
- ការលើក/បន្ទាបកង់រ៉ក
- យោលប្រដាប់បួងលើកដាក់

នៅពេលប្រតិបត្តិការក្នុងការដ្ឋាន ចូរចុចផ្នែកខាងលើកុងតាក់ផ្លូវថ្នល់/ការដ្ឋាន ហើយភ្លើងសញ្ញានឹងរលត់។ គេអាចប្រើមុខងារខាងលើ។


កំណត់ចំណាំ៖ នៅពេលភ្លើងសញ្ញាបើក គ្រឿងចក្រស្ថិតនៅក្នុងម៉ូដផ្លូវថ្នល់។

នៅពេលភ្លើងសញ្ញាបិទ គ្រឿងចក្រស្ថិតនៅក្នុងម៉ូដវាលស្រែ។

**A—កុងតាក់លើផ្លូវទីវាល** **B—ភ្លើងសញ្ញា**




YC17949—UN—12JUL21




YC21113—UN—21DEC22

CP00834,1668663913898-KM-16NOV22-2/2

## បើកបរគ្រឿងចក្រ (ការអូសដោយមេកានិក)

**⚠ ប្រយ័ត្ន៖ មុននឹងបញ្ជោះម៉ាស៊ីន ចូរប្រាកដថាមិនមានអ្នកណានៅជិតគ្រឿងចក្រឡើយ។ បន្លឺស៊ីរ៉ែដើម្បីជូនដំណឹងដល់អ្នកដទៃ។**

**តទៅថ្ងៃបន្ទាប់**

CP00834,1668664022594-KM-16NOV22-1/2


1. ពិនិត្យមើលក្រែងលោដៃភ្ជាប់ក្បាលឧបករណ៍កាត់ (A), ដៃភ្ជាប់ប្រព័ន្ធបោកបែន (B), និងដៃភ្ជាប់ប្រដាប់បួងទម្លាក់ (C) ត្រូវបានផ្តាច់ចេញ។
2. បន្លឺស៊ីផ្លេ ហើយបញ្ឈប់ម៉ាស៊ីន។
3. លើកក្បាលឧបករណ៍កាត់ទៅទីតាំងការងារ ឬដឹកជញ្ជូន។
4. **ផ្តាច់ហ្វ្រាំងដៃ៖** ទាញដៃបញ្ជាហ្វ្រាំងដៃ (F) ឡើងលើបន្តិច, ចុចប៊ូតុង (G), រុញដៃបញ្ជាហ្វ្រាំងដៃចុះក្រោមឲ្យអស់ ហើយលែងប៊ូតុង។
5. សង្កត់ឈ្នាន់អំប្រាយ៉ា ហើយរំកិលដៃបញ្ជាស្តីលេខ (E) ទៅក្នុងទីតាំងដែលចង់បាន។

កំណត់ចំណាំ៖ នៅក្នុងកាល:ទេស:មួយចំនួន ស្តីមិនប្តូរនៅពេលព្យាយាមលើកដំបូងឡើយ ដូច្នេះព្យាយាមឲ្យបានច្រើនដងរហូតទាល់តែស្តីប្តូរ។


- ប្តូរចង្កឹះលេខទៅកាន់ស្តីលេខបួនសម្រាប់ការដឹកជញ្ជូននៅលើផ្លូវថ្នល់។
- ប្តូរចង្កឹះលេខទៅកាន់ស្តីលេខដែលចង់បានសម្រាប់ប្រតិបត្តិការក្នុងវាលស្រែ។

6. រុញចង្កឹះល្បឿនលើដី (D) ទៅមុខដើម្បីបង្កើនល្បឿនបើកបរ។

   រុញចង្កឹះល្បឿនលើដីមកក្រោយដើម្បីបន្ថយល្បឿនបើកបរ។



YC17953—UN—13JUL21



YC21114—UN—21DEC22

**A—ដៃភ្ជាប់ក្បាលឧបករណ៍កាត់**
**B—ដៃភ្ជាប់ប្រព័ន្ធបោកបែន**
**C—ដៃភ្ជាប់ប្រដាប់បួងទម្លាក់**
**D—ចង្កឹះល្បឿនលើដី**
**E—ចង្កឹះលេខ**
**F—ចង្កឹះហ្វ្រាំងដៃ**
**G—ប៊ូតុង**

CP00834,1668664022594-KM-16NOV22-2/2

## បើកបរគ្រឿងចក្រ (ការអូសដោយអ៊ុំទ្រូស្តាទិក)

**⚠ ប្រយ័ត្ន៖ មុននឹងបញ្ឈប់ម៉ាស៊ីន ចូរប្រាកដថាមិនមានអ្នកណានៅជិតគ្រឿងចក្រឡើយ។ បន្លឺស៊ីផ្លេដើម្បីជូនដំណឹងដល់អ្នកដទៃ។**

**តទៅទំព័របន្ទាប់**

CP00834,1668664118251-KM-16NOV22-1/2


1. ដាក់ចង្កឹះពហុមុខងារ (E) នៅក្នុងទីតាំងនឹង។
2. ពិនិត្យមើលក្រែងលោដៃភ្ជាប់ក្បាលឧបករណ៍កាត់ (A), ដៃភ្ជាប់ប្រព័ន្ធបោកបែន (B), និងដៃភ្ជាប់ប្រដាប់បួងទម្លាក់ (C) ត្រូវបានផ្តាច់ចេញ។
3. បន្លឺស៊ីឡេ ហើយបញ្ឆេះម៉ាស៊ីន។
4. រំកិលចង្កឹះលេខ (D) ទៅកាន់ទីតាំងដែលចង់បាន។

កំណត់ចំណាំ៖ នៅក្នុងកាល:ទេស:មួយចំនួន ស្តីមិនប្តូរនៅពេលព្យាយាមលើកដំបូងឡើយ ដូច្នេះព្យាយាមឱ្យបានច្រើនដងរហូតទាល់តែស្តីប្តូរ។


- ប្តូរចង្កឹះលេខទៅកាន់ស្តីលេខបួនសម្រាប់ការដឹកជញ្ជូននៅលើផ្លូវថ្នល់។
- ប្តូរចង្កឹះលេខទៅកាន់ស្តីលេខដែលចង់បានសម្រាប់ប្រតិបត្តិការក្នុងវាលស្រែ។

5. លើកក្បាលឧបករណ៍កាត់ទៅទីតាំងការងារ ឬដឹកជញ្ជូន។
6. **ផ្តាច់ហ្វ្រាំងដៃ៖** ទាញដៃបញ្ជាហ្វ្រាំងដៃ (F) ឡើងលើបន្តិច, ចុចប៊ូតុង (G), រុញដៃបញ្ជាហ្វ្រាំងដៃចុះក្រោមឱ្យអស់ ហើយលែងប៊ូតុង។
7. **ការបើកបរទៅមុខ៖** រុញដៃបញ្ជាពហុមុខងារទៅមុខដើម្បីបើកបរគ្រឿងចក្រទៅមុខ។ រុញដៃបញ្ជាពហុមុខងារទៅមុខថែមទៀតដើម្បីបង្កើនល្បឿនបើកបរ។

   **ការបើកបរថយក្រោយ៖** រុញដៃបញ្ជាពហុមុខងារមកក្រោយដើម្បីបើកបរគ្រឿងចក្រថយក្រោយ។ រុញដៃបញ្ជាពហុមុខងារថយក្រោយថែមទៀតដើម្បីបង្កើនល្បឿនបើកបរ។



YC17951—UN—13JUL21



YC21115—UN—21DEC22

**A—ដៃភ្ជាប់ក្បាលឧបករណ៍កាត់**
**B—ដៃភ្ជាប់ប្រព័ន្ធបោកបែន**
**C—ដៃភ្ជាប់ប្រដាប់បួងទម្លាក់**
**D—ចង្កឹះលេខ**
**E—ដៃបញ្ជាពហុមុខងារ**
**F—ចង្កឹះហ្វ្រាំងដៃ**
**G—ប៊ូតុង**

CP00834,1668664118251-KM-16NOV22-2/2

## បញ្ឈប់គ្រឿងចក្រ (ការអូសដោយមេកានិក)

**តទៅទំព័របន្ទាប់**


CP00834,1668664210284-KM-16NOV22-1/2

1. រុញចង្កឹះល្បឿនលើដី (D) មកក្រោយឲ្យអស់ទៅកាន់ទីតាំងល្បឿនទាប។
2. ជាន់ឈ្នាន់ហ្វ្រាំងជើងដើម្បីបញ្ឈប់គ្រឿងចក្រ។
3. សង្កត់ឈ្នាន់អ៊ុំប្រាយ៉ា ហើយរំកិលដៃបញ្ជាស្តីលេខ (E) ទៅក្នុងទីតាំងនឺត្រាល ហើយបន្ទរឈ្នាន់ហ្វ្រាំងជើង។


កំណត់ចំណាំ៖ នៅក្នុងកាល:ទេស:មួយចំនួន ស្តីមិនប្តូរនៅពេលព្យាយាមលើកដំបូងឡើយ ដូច្នេះព្យាយាមឲ្យបានច្រើនដងរហូតទាល់តែស្តីប្តូរ។

4. ដាក់កុងតាក់ហ្គែរ (F) ក្នុងទីតាំង "អណ្តើក"។
5. បន្ទាបក្បាលកាត់ទៅដី។
6. ផ្តាច់ដៃភ្ជាប់ក្បាលឧបករណ៍កាត់ (A), ដៃភ្ជាប់ប្រព័ន្ធបោកបែន (B), និងដៃភ្ជាប់ប្រដាប់បួងទម្លាក់ (C)។
7. ទាញចង្កឹះហ្វ្រាំងដៃ (G) ឡើងលើដើម្បីភ្ជាប់ហ្វ្រាំងដៃ។
8. ការ៉ងទីម៉ាស៊ុនពីរបីនាទីដើម្បីឲ្យតួបីនចុះត្រជាក់។
9. ពន្លត់ម៉ាស៊ុន។

**A—ដៃភ្ជាប់ក្បាលឧបករណ៍កាត់**
**B—ដៃភ្ជាប់ប្រព័ន្ធបោកបែន**
**C—ដៃភ្ជាប់ប្រដាប់បួងទម្លាក់**
**D—ចង្កឹះល្បឿនលើដី**
**E—ចង្កឹះលេខ**
**F—កុងតាក់ហ្គែរ**
**G—ចង្កឹះហ្វ្រាំងដៃ**



YC17953—UN—13JUL21



YC21116—UN—21DEC22

CP00834,1668664210284-KM-16NOV22-2/2


## បញ្ឈប់គ្រឿងចក្រ (ការអូសដោយអ៊ីដ្រូស្តាទិក)

**តទៅទំព័របន្ទាប់**


CP00834,1668664291054-KM-16NOV22-1/2

1. ជាន់ឈ្នាន់ហ្វ្រាំងជើងដើម្បីបញ្ឈប់គ្រឿងចក្រ។
2. រំកិលដៃបញ្ជាពហុមុខងារ (E) ទៅក្នុងទីតាំងនឹង ហើយបន្ធូរឈ្នាន់ហ្វ្រាំងជើង។
3. ដាក់កុងតាក់ហ្គែរ (F) ក្នុងទីតាំង "អណ្តើក"។
4. បន្ទាបក្បាលកាត់ទៅដី។
5. ផ្តាច់ដៃភ្ជាប់ក្បាលឧបករណ៍កាត់ (A), ដៃភ្ជាប់ប្រព័ន្ធបោកបែន (B), និងដៃភ្ជាប់ប្រដាប់បួងទម្លាក់ (C)។
6. ទាញចង្កឹះហ្វ្រាំងដៃ (G) ឡើងលើដើម្បីភ្ជាប់ហ្វ្រាំងដៃ។
7. ការ៉ងទីម៉ាស៊ូនពីរបីនាទីដើម្បីឲ្យតួប៊ីនចុះត្រជាក់។
8. ពន្លត់ម៉ាស៊ូន។

**A—ដៃភ្ជាប់ក្បាលឧបករណ៍កាត់**
**B—ដៃភ្ជាប់ប្រព័ន្ធបោកបែន**
**C—ដៃភ្ជាប់ប្រដាប់បួងទម្លាក់**
**D—ចង្កឹះលេខ**
**E—ដៃបញ្ជាពហុមុខងារ**
**F—កុងតាក់ហ្គែរ**
**G—ចង្កឹះហ្វ្រាំងដៃ**



YC17951—UN—13JUL21



YC21117—UN—21DEC22

CP00834,1668664291054-KM-16NOV22-2/2

## ប្រតិបត្តិការឈ្នាន់អំប្រ៉ាយ៉ា (ដុំអូសមេកានិច)

**សំខាន់៖ ដើម្បីកុំឲ្យខូចខាតដល់ប្រអប់ស្តី ចូរកុំជាន់ឈ្នាន់អំប្រ៉ាយ៉ានៅពេលកំពុងបើកបរគ្រឿងចក្រ។**

**ដើម្បីចៀសវាងសំណឹកឥតប្រយោជន៍ ហាមប្រតិបត្តិការដោយប្រដាប់គងជើងនៅលើឈ្នាន់អំប្រ៉ាយ៉ា។**

CP00834,0008FF1-KM-23JUL21-1/2

សង្កត់ឈ្នាន់អំប្រ៉ាយ៉ា (A) ឲ្យអស់ បន្ទាប់មកប្តូរចង្កឹះលេខទៅកាន់ទីតាំងដែលចង់បាន។

**A—ឈ្នាន់អំប្រ៉ាយ៉ា**



YC18072—UN—23JUL21

CP00834,0008FF1-KM-23JUL21-2/2

## ប្រតិបត្តិការឈ្នាន់ហ្វ្រាំងជើង

**សំខាន់៖ ដើម្បីបង្ការសំណឹកដោយមិនចាំបាច់ ហាមប្រតិបត្តិការដោយប្រដាប់គងជើងនៅលើឈ្នាន់ហ្វ្រាំង។**


**តទៅទំព័របន្ទាប់**

CP00834,0008F88-KM-13JUL21-1/2

- សម្រាប់ការងារនៅវាលស្រែ ចូរដោះសោឈ្នាន់ហ្វ្រាំងជើង (B)។ ជាន់ឈ្នាន់ហ្វ្រាំងខាងស្តាំជួនៗដើម្បីជួយសម្រួលដល់ការបត់ស្តាំនៅគ្រាដែលរថកែងខ្លាំង និងជាន់ឈ្នាន់ហ្វ្រាំងខាងឆ្វេងសម្រាប់ការបត់ឆ្វេង។
- មុននឹងប្រតិបត្តិការគ្រឿងចក្រនៅលើផ្លូវថ្នល់ ឬដឹកជញ្ជូន ចូរប្រើសោឈ្នាន់ហ្វ្រាំង (A) ដើម្បីទប់ឈ្នាន់ហ្វ្រាំងជើងរួមគ្នា។

**A—គន្លឹះឈ្នាន់ហ្វ្រាំង**

**B—ឈ្នាន់ហ្វ្រាំងជើង (ប្រើ 2)**




YC8055—UN—21JAN15

CP00834,0008F88-KM-13JUL21-2/2


## បម្រុងប្រយ័ត្នចំពោះការកាច់ចង្កូត

កំណត់ចំណាំ៖ កង់ក្រោយរបស់គ្រឿងចក្រគឺជាកង់កាច់ចង្កូត ចូរជ្រាកដថាមានចន្លោះគ្រប់គ្រាន់សម្រាប់កាច់ចង្កូត។

CP00834,0008DCB-KM-24MAY21-1/2

នៅពេលគ្រឿងចក្រឈប់ នឹងមានការលំបាកក្នុងការកាច់ចង្កូត។

បួងចង្កូតទៅឆ្វេងក្នុងមុំតូចជាងនេះ។ បួងចង្កូតទៅខាងស្តាំក្នុងមុំធំជាងនេះ។



YC2755—UN—29OCT12

CP00834,0008DCB-KM-24MAY21-2/2

## ប្រតិបត្តិការដែបញ្ចាំងអូសកង់ខាងក្រោយ (ជម្រើស)

**សំខាន់៖ កុំភ្ជាប់ ឬផ្តាច់ដុំអូសកង់ក្រោយខណៈពេលកំពុងបើកបរគ្រឿងចក្រ។**

**ផ្តាច់ការអូសកង់ក្រោយមុនពេលចូលដល់កម្រិតចោទខ្លាំង។**

CP00834,1660809813275-KM-18AUG22-1/2

មុននឹងភ្ជាប់ការអូសកង់ក្រោយ ចូរបញ្ឈប់គ្រឿងចក្រ និងដាក់ដែបញ្ចាពហុមុខងារ (បើមាន) និងចង្កឹះលេខនៅក្នុងទីតាំងនឹង។

- **ភ្ជាប់ការអូសកង់ក្រោយ៖** រុញដែបញ្ចាអូសកង់ក្រោយ (A) ចុះក្រោម។
- **ផ្តាច់ការអូសកង់ក្រោយ៖** ទាញដែបញ្ចាការអូសកង់ក្រោយ (A) ឡើងលើ។

**A—ដៃគ្រប់គ្រងភ្ជៅអូសកង់ខាងក្រោយ**




YC17957—UN—14JUL21

CP00834,1660809813275-KM-18AUG22-2/2


# ប្រតិបត្តិការក្បាលឧបករណ៍កាត់ និងមាត់ច្រកបួងចូល

## ព័ត៌មានទូទៅ

CP00834,1669092574913-KM-21NOV22-1/3

គ្រឿងចក្រនេះអាចមានបំពាក់ផ្លែតហ្វូមកាត់ 212R/F, 215R/F, និង 218 R/F សម្រាប់ការច្រូតកាត់ស្រូវសាឡី ស្រូវ សណ្តែកសៀង និង។ល។

កំណត់ចំណាំ៖ ផ្លែតហ្វូមកាត់ *212R/F* គឺសម្រាប់តែទីផ្សារប្រទេសចិនប៉ុណ្ណោះ។




YC17731—UN—21JUN21

CP00834,1669092574913-KM-21NOV22-2/3

គ្រឿងចក្រនេះអាចមានបំពាក់ក្បាលកាត់ពោត 206C (ចន្លោះជួរ 650 ម.ម) សម្រាប់ប្រមូលផលពោតសម្រាប់ទីផ្សារប្រទេសចិន។

គ្រឿងចក្រនេះអាចមានបំពាក់ក្បាលកាត់ពោត 204C, 205C, 206C (ចន្លោះជួរ 762 ម.ម) សម្រាប់ប្រមូលផលពោតសម្រាប់ទីផ្សារនាំចេញ។

YC17732—UN—21JUN21



CP00834,1669092574913-KM-21NOV22-3/3

## មាត់ច្រកបួងចូល និងតំណក្បាលឧបករណ៍កាត់

### តំណច្រវាក់

កំណត់ចំណាំ៖ កុំលៃតម្រូវខ្ចៅនៅលើសម្បកបាដាង *(B)* នៅផ្នែកខាងក្រោយមាត់ច្រកបួងចូល។

**តទៅទំព័របន្ទាប់**


CP00834,00020D1-KM-09MAR22-1/4

រុញដងបង្វិលទាំងពីរមកគ្នា។ បន្ទះកង់ច្រវាក់ចំនួនពីរគួរតែស្របគ្នាទាំងផ្នែក និងបញ្ឈរ។ ដើម្បីដាក់កង់ច្រវាក់ទាំងពីរនេះនៅក្នុងទីតាំងត្រឹមត្រូវ ចូរលៃតម្រូវខ្ចៅនៅលើសម្បកបាដាង (A)។


ដាក់ច្រវាក់នៅជុំវិញកង់ច្រវាក់រួមគ្នានៅពេលចុងផ្នែកនៃកង់ទាំងពីស្ថិតនៅកៀកគ្នា ឬចន្លោះរវាងផ្នែខាងចុងនៃកង់ច្រវាក់ទាំងពីរស្មើគ្នា។ រឹតច្រវាក់ឲ្យជាប់ ហើយគ្របរបាំងសុវត្ថិភាព (C)។

អនុវត្តទម្រង់ការដដែលនេះនៅជ្រុងម្ខាងទៀត។


**A—សម្បកបាដាង**
**B—សម្បកបាដាង**
**C—របាំងសុវត្ថិភាព**




YC19561—UN—26JAN22



YC7312—UN—10JUN14




YC19586—UN—26JAN22

**តទៅទំព័របន្ទាប់**

CP00834,00020D1-KM-09MAR22-2/4


កំណត់ចំណាំ៖ ការលៃតម្រូវអាចធ្វើឡើងនៅពេលលៃតម្រឹមកង់ច្រវាក់នៃមាត់ច្រកបួងចូល និងក្បាលឧបករណ៍កាត់ដូចតទៅ (លំណែនាំតទៅនេះបង្ហាញឧទាហរណ៍សម្រាប់ខាងឆ្វេងដៃ ហើយចំហៀងខាងស្តាំដៃលៃតម្រូវដូចគ្នា)៖

នៅពេលកង់ច្រវាក់ទាំងពីរត្រូវគ្នាហើយ ចូរកុំរុញកង់ច្រវាក់ទាំងពីររួមគ្នា។

នៅពេលឃើញថាភ្លៅនៃដងទាំងពីមិនអាចលៃតម្រូវបាន ចូរបន្ថយប៊ូឡុង (D និង E) នៃបន្ទះទម្រនៅផ្នែកខាងក្រោយក្បាលឧបករណ៍កាត់ ដើម្បីឲ្យកង់ច្រវាក់ទាំងពីរនៅចំចំណុចកណ្តាលចាក់ខ្វាស់ច្រវាក់ បន្ទាប់មកវិតបន្តឹងប៊ូឡុង (D និង E)។

**តំណអ៊ីដ្រូលីកនិងអគ្គិសនី**

**D—ប៊ូឡុង** **E—ប៊ូឡុង**





ការលៃតម្រូវ

CP00834,00020D1-KM-09MAR22-3/4

- ភ្ជាប់តំណអគ្គិសនីទៅនឹងសមាសភាគគ្រឿងអគ្គិសនីនៅលើក្បាលឧបករណ៍កាត់។
- ភ្ជាប់គូប្លើរអ៊ីដ្រូលីកទៅនឹងគូប្លើរអគ្គិសនីនៅលើក្បាលឧបករណ៍កាត់។

**A—តំណអគ្គិសនី** **B—គូប្លើរអ៊ីដ្រូលីក**




CP00834,00020D1-KM-09MAR22-4/4

## ប្រតិបត្តិការភ្ជាប់/ផ្តាច់ក្បាលឧបករណ៍កាត់

**ប្រយ័ត្ន៖ មុននឹងភ្ជាប់ក្បាលឧបករណ៍កាត់ ចូរប្រាកដថាមិនមានមនុស្សនៅជុំវិញគ្រឿងចក្រឡើយ។**

**ដើម្បីកុំឲ្យខូចខាតដល់គ្រឿងចក្រ មុននឹងភ្ជាប់ក្បាលឧបករណ៍កាត់ ចូរភ្ជាប់ប្រព័ន្ធបោកបែន។**

CP00834,0008F79-KM-04AUG21-1/2


ដៃភ្ជាប់ក្បាលឧបករណ៍កាត់ (A) ប្រើដើម្បីភ្ជាប់ ឬផ្តាច់ការអូសក្បាលឧបករណ៍កាត់។

ដៃភ្ជាប់ក្បាលឧបករណ៍កាត់ស្ថិតនៅចំហៀងខាងឆ្វេងដៃកៅអី។

- រុញដៃភ្ជាប់ក្បាលឧបករណ៍កាត់ឡើងលើដើម្បីភ្ជាប់ក្បាលឧបករណ៍កាត់។
- ចុចប៊ូតុង (B) ហើយរុញដៃភ្ជាប់ក្បាលឧបករណ៍កាត់ចុះក្រោមដើម្បីផ្តាច់ក្បាលឧបករណ៍កាត់។

កំណត់ចំណាំ៖ បន្ទាប់ពីចុចប៊ូតុងនេះ ដៃភ្ជាប់ក្បាលឧបករណ៍កាត់អាចធ្លាក់ចុះក្រោមដោយស្វ័យប្រវត្តិ។

**A—ដៃភ្ជាប់ក្បាលឧបករណ៍កាត់** **B—ប៊ូតុង**




ដៃភ្ជាប់ក្បាលឧបករណ៍កាត់ (ការអូសដោយមេកានិក)

CP00834,0008F79-KM-04AUG21-2/2


## ប្រតិបត្តិការលើក/បន្ទាបក្បាលឧបករណ៍កាត់ (ការអូសដោយមេកានិច)

CP00834,0008F72-KM-12JUL21-1/2

ដៃបញ្ជាលើក/បន្ទាបក្បាលឧបករណ៍កាត់ (A) អនុញ្ញាតឲ្យប្រតិបត្តិការលើក ឬបន្ទាបក្បាលឧបករណ៍កាត់។

- ទាញដៃបញ្ជាមកក្រោយដើម្បីលើកក្បាលឧបករណ៍កាត់។
- រុញដៃបញ្ជាទៅមុខដើម្បីបន្ទាបក្បាលឧបករណ៍កាត់។

**A—ដៃគ្រប់គ្រងលើក/បន្ទាបក្បាលឧបករណ៍កាត់**




YC17937—UN—11JUL21

CP00834,0008F72-KM-12JUL21-2/2

## ប្រតិបត្តិការលើក/បន្ទាបក្បាលឧបករណ៍កាត់ (ការអូសដោយអ៊ីដ្រូស្តាទិក)


CP00834,0009463-KM-20OCT21-1/2

ប៊ូតុងលើក/បន្ទាបក្បាលឧបករណ៍កាត់អនុញ្ញាតឲ្យប្រតិបត្តិការលើក ឬបន្ទាបក្បាលឧបករណ៍កាត់។

កំណត់ចំណាំ៖ មុននឹងលើក/បន្ទាបក្បាលឧបករណ៍កាត់ ចូរប្រាកដថាកុងតាក់លើផ្លូវដ្ឋល់/វាលស្រែ *(C)* ស្ថិតនៅក្នុងម៉ូដវាលស្រែ *(*ពន្លឺភ្លើងសញ្ញានៅលើកុងតាក់មិនបើកឡើយ*)*។

- ចុចទប់ប៊ូតុងលើកក្បាលឧបករណ៍កាត់ (A) ដើម្បីលើកក្បាលឧបករណ៍កាត់។
- ចុចទប់ប៊ូតុងបន្ទាបក្បាលឧបករណ៍កាត់ (D) ដើម្បីបន្ទាបក្បាលឧបករណ៍កាត់

**A—ប៊ូតុងលើកឡើងក្បាលឧបករណ៍កាត់**
**B—ដៃបញ្ជាពហុមុខងារ**
**C—កុងតាក់លើផ្លូវទីវាល**
**D—ប៊ូតុងបន្ទាបក្បាលឧបករណ៍កាត់**




YC17936—UN—11JUL21

CP00834,0009463-KM-20OCT21-2/2

## ប្រតិបត្តិការលើក/បន្ទាបកង់រ៉ក (ការអូសដោយមេកានិច)

កំណត់ចំណាំ៖ ប្រតិបត្តិការលើក/បន្ទាប់កង់រ៉កត្រូវបានធ្វើឡើងសម្រាប់តែគ្រឿងចក្រដែលមានផ្លែតហ្វមកាត់ប៉ុណ្ណោះ។


**តទៅទំព័របន្ទាប់**

CP00834,0008F74-KM-12JUL21-1/2

ដៃបញ្ជាលើក/បន្ទាបកង់រ៉ក (A) អនុញ្ញាតឲ្យប្រតិបត្តិការលើក ឬបន្ទាបកង់រ៉ក។

- ទាញដៃបញ្ជាមកក្រោយដើម្បីលើកកង់រ៉ក។
- រុញដៃបញ្ជាទៅមុខដើម្បីបន្ទាបកង់រ៉ក។

**A—ដៃគ្រប់គ្រងលើក/បន្ទាបកង់រ៉ក**




CP00834,0008F74-KM-12JUL21-2/2

## ប្រតិបត្តិការលើក/បន្ទាបកង់រ៉ក (ការអូសដោយអ៊ីដ្រូស្តាទិក)

កំណត់ចំណាំ៖ ប្រតិបត្តិការលើក/បន្ទាប់កង់រ៉កត្រូវបានធ្វើឡើងសម្រាប់តែគ្រឿងចក្រដែលមានផ្លែតហ្វមកាត់ប៉ុណ្ណោះ។


CP00834,0009464-KM-20OCT21-1/2

ប៊ូតុងលើក/បន្ទាបកង់រ៉កអនុញ្ញាតឲ្យប្រតិបត្តិការលើក ឬបន្ទាបកង់រ៉ក។

កំណត់ចំណាំ៖ មុននឹងលើក/បន្ទាបកង់រ៉ក ចូរប្រាកដថាកុងតាក់លើផ្លូវផ្តេ/វាលស្រែ *(C)* ស្ថិតនៅក្នុងម៉ូដវាលស្រែ *(ពន្លឺភ្លើងសញ្ញានៅលើកុងតាក់មិនបើកឡើយ)*។

- ចុចទប់ប៊ូតុងលើកកង់រ៉ក (A) ដើម្បីលើកកង់រ៉ក។
- ចុចទប់ប៊ូតុងបន្ទាបកង់រ៉ក (D) ដើម្បីបន្ទាបកង់រ៉ក។

**A—ប៊ូតុងលើកកង់រ៉កឡើង**
**B—ដៃបញ្ជាពហុមុខងារ**
**C—កុងតាក់លើផ្លូវទីវាល**
**D—ប៊ូតុងបន្ទាបកង់រ៉ក**




CP00834,0009464-KM-20OCT21-2/2

## លៃតម្រូវល្បឿនកង់រ៉ក

កំណត់ចំណាំ៖ ភ្ជាប់ក្បាលឧបករណ៍កាត់មុននឹងលៃតម្រូវល្បឿនកង់រ៉ក។

**តទៅទំព័របន្ទាប់**

CP00834,0008F76-KM-12JUL21-1/2

កុងតាក់ល្បឿនកង់រ៉ក (A) អនុញ្ញាតឲ្យប្រតិបត្តិករលៃតម្រូវល្បឿនកង់រ៉ក។

- ចុចទប់ផ្នែកខាងលើនៃកុងតាក់ល្បឿនកង់រ៉កដើម្បីបង្កើនល្បឿនកង់រ៉ក។
- ចុចទប់ផ្នែកខាងក្រោមនៃកុងតាក់ល្បឿនកង់រ៉កដើម្បីបន្ថយល្បឿនកង់រ៉ក។

កំណត់ចំណាំ៖ បន្ទាប់ពីប្រើប្រាស់កុងតាក់ល្បឿនកង់រ៉ក ចូរបន្ធូរកុងតាក់ ហើយកុងតាក់នឹងត្រឡប់ទៅកាន់ទីតាំងនឹងវិញ។

**A—កុងតាក់ល្បឿនកង់រ៉ក**




CP00834,0008F76-KM-12JUL21-2/2


## លៃតម្រូវកម្ពស់ស្ពររអណ្តែតនៃមាត់ច្រកបួងចូល

CP00834,1669014979019-KM-21NOV22-1/2

លៃតម្រូវប្រវែងរីស័រ (B) ដោយមួលក្បាលឡោស៊ី (A) នៅចំហៀងសងខាងនៃមាត់ច្រកបួងចូល។

- **សម្រាប់ដំណាំភាគច្រើនលើកលែងតែពោត និងគ្រាប់រ៉ែបស៊ីដក្នុងបរិមាណដ៏ច្រើន៖** រីស័រមានប្រវែង 140 ម.ម។
- **សម្រាប់ពោត៖** រីស័រមានប្រវែងពី 107 ដល់ 113 ម.ម។

**A—ក្បាលឡោស៊ី (ប្រើ 2)** **B—រីស័រ (ប្រើ 2)**




ផ្នែកខាងស្តាំនៃមាត់ច្រកបួងចូលដែលបានបង្ហាញ

CP00834,1669014979019-KM-21NOV22-2/2

# ប្រតិបត្តិការប្រព័ន្ធបោកបែន និងបំបែក

## ប្រតិបត្តិការភ្ជាប់/ផ្តាច់ប្រព័ន្ធបោកបែន

CP00834,0008F7D-KM-29AUG21-1/2

ដៃភ្ជាប់ប្រព័ន្ធបោកបែន (A) ប្រើដើម្បីភ្ជាប់ ឬផ្តាច់ការអូសប្រព័ន្ធបោកបែន។

ដៃភ្ជាប់ប្រព័ន្ធបោកបែនស្ថិតនៅចំហៀងខាងឆ្វេងដៃកៅអី។

កំណត់ចំណាំ៖ មុននឹងភ្ជាប់ប្រព័ន្ធបោកបែន ចូរដំណើរការម៉ាស៊ីននៅល្បឿនការងារទាប។

មុននឹងផ្តាច់ប្រព័ន្ធបោកបែន ចូរបន្តយល្បឿនម៉ាស៊ីនទៅកាន់ល្បឿនការងារទាប។

- ទាញដៃភ្ជាប់ប្រព័ន្ធបោកបែនឡើងលើដើម្បីភ្ជាប់ការអូសប្រព័ន្ធបោកបែន។
- រុញដៃភ្ជាប់ប្រព័ន្ធបោកបែនចុះក្រោយដើម្បីផ្តាច់ការអូសប្រព័ន្ធបោកបែន។

**A—ដៃភ្ជាប់ប្រព័ន្ធបោកបែន**




ដៃភ្ជាប់ប្រព័ន្ធបោកបែន (ការអូសដោយមេកានិក)


CP00834,0008F7D-KM-29AUG21-2/2

## អត្ថសញ្ញាណស៊ីឡាំងបោកបែន និងប្រអប់កញ្ច្រែង

CP00834,1668665378651-KM-17NOV22-1/3

ស៊ីឡាំងបោកបែនរបាររូស ប្រើសម្រាប់ស្រូវសាឡី និងដំណាំគ្រាប់ល្អិតផ្សេងទៀតដែលច្រូតកាត់រួមគ្នាដោយប្រើប្រអប់កញ្ច្រែងសរសៃលួសតូច។

ស៊ីឡាំងបោកបែនរបាររូស ប្រើសម្រាប់ពោត សណ្តែកសៀង និងដំណាំគ្រាប់ធំផ្សេងទៀតដែលច្រូតកាត់រួមគ្នាដោយប្រើប្រអប់កញ្ច្រែងសរសៃលួសធំ។





ស៊ីឡាំងបោកបែនរបាររូស និងប្រអប់កញ្ច្រែងលួសតូច/ធំ

**តទៅទំព័របន្ទាប់**

CP00834,1668665378651-KM-17NOV22-2/3

ស៊ីឡាំងបោកបែនធ្មេញវែងប្រើសម្រាប់ការច្រូតកាត់ស្រូវរួមគ្នាជាមួយប្រអប់កញ្ជែងធ្មេញវែង។




ស៊ីឡាំងបោកបែនធ្មេញវែង និងប្រអប់កញ្ជែងធ្មេញវែង

CP00834,1668665378651-KM-17NOV22-3/3

## គោលការណ៍លៃតម្រូវចន្លោះប្រអប់កញ្ជែង និងល្បឿនបោកបែន

| ល្បឿនបោកបែន | ចន្លោះប្រអប់កញ្ជែង | ឥទ្ធិពលប្រមូលផល |
|---|---|---|
| ខ្ពស់ | ចង្អៀត | សកម្មភាពបោកបែនល្អ |
| ខ្ពស់ពេក | ចង្អៀតពេក | បោកបែនជ្រុល |
| ទាប | ទូលាយ | សកម្មភាពបោកបែនមិនល្អ |
| ទាបពេក | ទូលាយពេក | ការបោកបែនមិនសូវល្អ |

- **ដើមដំណាំសើម៖** បង្កើនល្បឿនបោកបែន និងបន្តយចន្លោះប្រអប់កញ្ជែង។
- **ដើមដំណាំស្ងួត៖** បន្តយល្បឿនបោកបែន និងបង្កើនចន្លោះប្រអប់កញ្ជែង។
- **បោកបែនជ្រុល៖** បន្តយល្បឿនបោកបែនត្រឹម 5%។ ប្រសិនបើការធ្វើដូច្នេះមិនដោះស្រាយបញ្ហាបានទេ ចូរបន្តយល្បឿនបោកបែនត្រឹម 10%។ ប្រសិនបើការធ្វើដូច្នេះនៅតែមិនអាចដោះស្រាយបញ្ហាបានទៀត ចូរបង្កើនចន្លោះប្រអប់កញ្ជែងបន្តិច។ ប្រសិនបើមិនអាចកែតម្រូវការបោកបែនជ្រុលបានតាមវិធានការនេះទេ ចូរបន្តយល្បឿនលើដី។
- **ការបោកបែនមិនសូវល្អ៖** បង្កើនល្បឿនបោកបែនត្រឹម 5%។ ប្រសិនបើការធ្វើដូច្នេះមិនអាចដោះស្រាយបញ្ហាបានទៀត ចូរបន្តយចន្លោះប្រអប់កញ្ជែងបន្តិច។ ប្រសិនបើសកម្មភាពបោកបែននៅតែមិនដំណើរការស្រួលទៀត ចូរបង្កើនល្បឿនលើដី។

CP00834,0008DBE-KM-08MAR22-1/1

## លៃតម្រូវចន្លោះប្រអប់កញ្ជែង

កំណត់ចំណាំ៖ ដំណើរការម៉ាស៊ីនមុននឹងលៃតម្រូវចន្លោះប្រអប់កញ្ជែង។

កំណត់ចំណាំ៖ ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែក *120* ដើម្បីជ្រាបពីចន្លោះប្រអប់កញ្ជែងតាមការណែនាំ។

CP00834,0008F7F-KM-12JUL21-1/2

ដៃលៃតម្រូវចន្លោះប្រអប់កញ្ជែង (A) ប្រើដើម្បីលៃតម្រូវចន្លោះប្រអប់កញ្ជែង។

ចង្កឹះលៃតម្រូវចន្លោះប្រអប់កញ្ជែងគឺនៅខាងស្តាំដៃកៅអី។

- ចុចប៊ូតុង (B) ហើយទាញដៃបញ្ជាឡើងលើដើម្បីបន្តយចន្លោះប្រអប់កញ្ជែង។
- ចុចប៊ូតុង (B) ហើយរុញដៃបញ្ជាចុះក្រោមដើម្បីបង្កើនចន្លោះប្រអប់កញ្ជែង។

កំណត់ចំណាំ៖ ការប្តូរទំហំចន្លោះប្រអប់កញ្ជែងពី *2* ដល់ *3* ម.ម ដែលប្រើធ្មេញមួយ។

**A—ដៃលៃតម្រូវចន្លោះប្រអប់កញ្ជែង**

**B—ប៊ូតុង**




ដៃលៃតម្រូវចន្លោះប្រអប់កញ្ជែង *(ការអូសដោយមេកានិក)*

CP00834,0008F7F-KM-12JUL21-2/2

## លៃតម្រូវល្បឿនបោកបែន (ការអូសដោយមេកានិច)

កំណត់ចំណាំ៖ ភ្ជាប់ប្រព័ន្ធបោកបែនមុននឹងលៃតម្រូវល្បឿនបោកបែន។

កំណត់ចំណាំ៖ ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែក *120* ដើម្បីជ្រាបពីល្បឿនបោកបែនតាមការណែនាំ។


CP00834,1668666772966-KM-17NOV22-1/3

ដៃលៃតម្រូវល្បឿនបោកបែន (A) អនុញ្ញាតឲ្យប្រតិបត្តិករលៃតម្រូវល្បឿនបោកបែន។

ចង្កឹះលៃតម្រូវល្បឿនបោកបែនស្ថិតនៅខាងស្តាំដៃកៅអី។

- ទាញលៃតម្រូវល្បឿនបោកបែនឡើងលើដើម្បីបង្កើនល្បឿនបោកបែន។
- រុញលៃតម្រូវល្បឿនបោកបែនចុះក្រោមដើម្បីបន្ថយល្បឿនបោកបែន។


**A—ចង្កឹះលៃតម្រូវល្បឿនបោកបែន**




CP00834,1668666772966-KM-17NOV22-2/3

តម្លៃល្បឿនបោកបែន (B) បង្ហាញនៅអេក្រង់បង្ហោលកាច់ជ្រុង។

**B—តម្លៃល្បឿនបោកបែន**




CP00834,1668666772966-KM-17NOV22-3/3

## លៃតម្រូវល្បឿនបោកបែន (ការអូសដោយអ៊ីដ្រូស្តាទិក)

កំណត់ចំណាំ៖ ភ្ជាប់ប្រព័ន្ធបោកបែនមុននឹងលៃតម្រូវល្បឿនបោកបែន។

កំណត់ចំណាំ៖ ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែក *120* ដើម្បីជ្រាបពីល្បឿនបោកបែនតាមការណែនាំ។

**តទៅទំព័របន្ទាប់**

CP00834,1668666780974-KM-17NOV22-1/3

កុតតាក់ល្បឿនបោកបែន (A) អនុញ្ញាតឲ្យប្រតិបត្តិការលៃតម្រូវល្បឿនបោកបែន។

- ចុចទប់ផ្នែកខាងលើនៃកុងតាក់ល្បឿនបោកបែនដើម្បីបង្កើនល្បឿនបោកបែន។
- ចុចទប់ផ្នែកខាងក្រោមកុងតាក់ល្បឿនបោកបែនដើម្បីបន្ថយល្បឿនបោកបែន។

កំណត់ចំណាំ៖ បន្ទាប់ពីប្រើប្រាស់កុងតាក់ល្បឿនបោកបែន ចូរបន្ធូរកុងតាក់ ហើយកុងតាក់នឹងត្រឡប់ទៅកាន់ទីតាំងនឹងវិញ។


**A—កុងតាក់ល្បឿនបោកបែន**




CP00834,1668666780974-KM-17NOV22-2/3

តម្លៃល្បឿនបោកបែន (B) បង្ហាញនៅអេក្រង់បង្ហាលកាច់ជ្រុង។

**B—តម្លៃល្បឿនបោកបែន**





CP00834,1668666780974-KM-17NOV22-3/3

## ប្រតិបត្តិការស្តីបន្ថយល្បឿនស៊ីឡាំងបោកបែន (ជាជម្រើស)

CP00834,1668667091765-KM-17NOV22-1/2

1. បន្ធូរក្បាលឡោស៊ីមានឡក់ (C) និងប៊ូឡុង (B), បន្ទាប់មកលៃតម្រូវល្បឿនបោកបែន៖
   - រុញអង្គប្លុកប្រឡោ (D) ចូលក្នុងទៅកាន់ល្បឿនធម្មតាចន្លោះពី 350 ដល់ 1100 ជុំ/នាទី។
   - រុញអង្គប្លុកប្រឡោចេញក្រៅដើម្បីបន្ថយល្បឿនពី 130 ដល់ 390 ជុំ/នាទី។
2. រឹតបន្តឹងប៊ូឡុង និងក្បាលឡោស៊ីមានឡក់បន្ទាប់ពីលៃតម្រូវរួច។

**A—ប្រតិបត្តិការស្តីបន្ថយល្បឿនស៊ីឡាំងបោកបែន**
**B—ប៊ូឡុង (ប្រើ 2)**
**C—ក្បាលឡោស៊ីមានឡក់ (ប្រើ 2)**
**D—អង្គប្លុកប្រឡោ**




CP00834,1668667091765-KM-17NOV22-2/2

## លៃតម្រូវល្បឿនគ្រឿងបំបែក (ដែលប្រើប្រអប់ស្តីមិនអាចលៃតម្រូវបាន)


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1669170138757-KM-22NOV22-1/2


ប៉ូលីអូស (A) ត្រូវបានដំឡើងនៅរោងចក្រ ហើយល្បឿនគ្រឿងបំបែកគឺ 700 ជុំ/នាទី។

ល្បឿនគ្រឿងបំបែកផ្សេងៗ (800 ជុំ/នាទី និង 500 ជុំ/នាទី) អាចមានដោយប្តូរទៅប្រើប៉ូលីអូស (B)។

**A—ប៉ូលីអូស** **B—ប៉ូលីអូស**




YC21302—UN—21DEC22




YC9548—UN—30NOV15

CP00834,1669170138757-KM-22NOV22-2/2

## លៃតម្រូវល្បឿនគ្រឿងបំបែក (ដែលប្រើប្រអប់ស្តីដែលអាចលៃតម្រូវបាន)

**សំខាន់៖ មុនពេលប្តូរចង្កឹះលេខ ចូរដាក់ចង្កឹះលេខពីរនៅក្នុងទីតាំងនឹង។**

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

**តទៅទំព័របន្ទាប់**


CP00834,1668667537188-KM-17NOV22-1/2

ប្តូរចង្កឹះលេខ (A និង C) ទៅទីតាំងផ្សេងៗដើម្បីទទួលបានល្បឿនគ្រឿងបំបែកផ្សេង។


លើកសោ (B), ប្តូរចង្កឹះលេខ ហើយបន្ទាប់មកបន្ទូរសោ។

- ទីតាំង (D)៖ មិនជាប់លេខ
- ទីតាំង (E)៖ 500 ជុំ/នាទី
- ទីតាំង (F)៖ 800 ជុំ/នាទី
- ទីតាំង (G)៖ 700 ជុំ/នាទី

**A—ចង្កឹះប្តូរលេខ**
**B—សោ ( ប្រើ 2)**
**C—ចង្កឹះប្តូរលេខ**
**D—ទីតាំង (មិនជាប់លេខ)**
**E—ទីតាំងទី (500 ជុំ/នាទី)**
**F—ទីតាំងទី (800 ជុំ/នាទី)**
**G—ទីតាំងទី (700 ជុំ/នាទី)**




YC21122—UN—21DEC22




YC17447—UN—12MAY21

CP00834,1668667537188-KM-17NOV22-2/2

## លៃតម្រូវល្បឿនកង្ហារសម្អាត

**សំខាន់៖ ល្បឿនកង្ហារសម្អាតអាចលៃតម្រូវបានតែនៅពេលកង្ហារសម្អាតកំពុងដំណើរការ ឬគ្រឿងមួយចំនួននឹងត្រូវខូចខាត។**

កំណត់ចំណាំ៖ ជាធម្មតាល្បឿនកង្ហារសម្អាតទាបអាចបណ្តាលឱ្យបាត់បង់គ្រាប់ធញ្ញជាតិច្រើនជាងល្បឿនកង្ហារសម្អាតខ្ពស់។

CP00834,1668668576037-KM-17NOV22-1/2

មួលដៃលៃតម្រូវ (A) ស្របទ្រនិចនាឡិកាដើម្បីបង្កើនល្បឿន។

មួលដៃលៃតម្រូវ (A) ច្រាសទ្រនិចនាឡិកាដើម្បីបន្ថយល្បឿន។

តម្លៃល្បឿនកង្ហារ (B) បង្ហាញនៅអេក្រង់បង្គោលកាប៊ូជ្រុង។


ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែកតម្រុយប្រមូលផល (Harvesting Hints) ដើម្បីជ្រាបពីល្បឿនកង្ហារសម្អាតដើមដំណាំផ្សេងៗតាមការណែនាំ។

កំណត់ចំណាំ៖ ពិនិត្យមើលលទ្ធផលលៃតម្រូវចុងក្រោយមុននឹងលៃតម្រូវ។

មុននឹងលៃតម្រូវល្បឿនកង្ហារសម្អាត ចូរលៃតម្រូវប្រឡោះធ្មេញ និងតម្រងទៅតាមតម្លៃអតិបរមានៃគ្រាប់ធញ្ញជាតិផ្សេងៗតាមការណែនាំ។ បង្កើនល្បឿនកង្ហារសម្អាតបន្តិចម្តងៗពីល្បឿនអប្បបរមាដែលបានណែនាំរហូតដល់មិនមានគ្រាប់ធញ្ញជាតិត្រូវផ្លុំចេញពីគ្រឿងចក្រ ឬផ្លុំចូលទៅក្នុងបន្ទះហូតគ្រាប់។


នៅពេលល្បឿនកង្ហារសម្អាតឡើងដល់តម្លៃអតិបរមា ចូរលៃតម្រូវប្រឡោះធ្មេញបន្តិចតាមចាំបាច់ បន្ទាប់មកលៃល្បឿនកង្ហារសម្អាត។

**A—ដៃលៃតម្រូវ** **B—តម្លៃល្បឿនកង្ហារសម្អាត**




YC2414—UN—25JUL14

លៃតម្រូវល្បឿនកង្ហារសម្អាត




YC21123—UN—21DEC22

CP00834,1668668576037-KM-17NOV22-2/2

## លៃតម្រូវអង្គបង្វែរខ្យល់


កំណត់ចំណាំ៖ ដៃលៃតម្រូវ *(A)* ស្ថិតនៅទីតាំងកណ្តាលតាំងពីរោងចក្រមក។

CP00834,1668668776790-KM-17NOV22-1/2

ដាក់ដៃលៃតម្រូវនៅក្នុងទីតាំងខាងលើសម្រាប់ដំណាំគ្រាប់ល្អិត។

ដាក់ដៃលៃតម្រូវនៅក្នុងទីតាំងខាងក្រោមសម្រាប់ដំណាំគ្រាប់ធំ។

**A—ដៃលៃតម្រូវ**




YC8174—UN—25MAR15

CP00834,1668668776790-KM-17NOV22-2/2

## លៃតម្រូវប្រឡោះធ្មេញ

### ការលៃតម្រូវ

CP00834,1659687195991-KM-05AUG22-1/3


មួលដៃលៃតម្រូវ (B) ទៅខាងឆ្វេងដើម្បីបង្កើនប្រឡោះ។

មួលដៃលៃតម្រូវ (B) ទៅខាងស្តាំដើម្បីបន្ថយប្រឡោះ។

ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែកតម្រុយប្រមូលផល (Harvesting Hints) ដើម្បីជ្រាបពីប្រឡោះធ្មេញសម្រាប់គ្រាប់ធញ្ញជាតិផ្សេងៗតាមការណែនាំ។

កំណត់ចំណាំ៖ ពិនិត្យមើលលទ្ធផលលៃតម្រូវចុងក្រោយមុននឹងលៃតម្រូវ។

លៃតម្រូវប្រឡោះធ្មេញឲ្យបានតូចតាមដែលអាចធ្វើទៅបាន និងប្រាកដថាគ្រាប់ធញ្ញជាតិធ្លាក់តាមមុននឹងឆ្លងកាត់បណ្តោយធ្មេញ។




YC17148—UN—01APR21

**រង្វាស់**

**A—ធ្មេញ**

**B—ដៃលៃតម្រូវ**

CP00834,1659687195991-KM-05AUG22-2/3

វាស់ប្រឡោះធ្មេញរវាងស្លាបព្រិលដែកចំនួនពីរ។

**X—ប្រឡោះធ្មេញ**




YC1661—UN—27NOV12

CP00834,1659687195991-KM-05AUG22-3/3

## លៃតម្រូវប្រឡោះកន្ត្រង

### ការលៃតម្រូវ

**តទៅទំព័របន្ទាប់**

CP00834,1659687221945-KM-05AUG22-1/3

មួលដៃលៃតម្រូវ (B) ទៅខាងឆ្វេងដើម្បីបង្កើនប្រឡោះ។

មួលដៃលៃតម្រូវ (B) ទៅខាងស្តាំដើម្បីបន្ថយប្រឡោះ។


ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែកតម្រុយប្រមូលផល (Harvesting Hints) ដើម្បីជ្រាបពីប្រឡោះកន្ត្រែងសម្រាប់គ្រាប់ធញ្ញជាតិផ្សេងៗតាមការណែនាំ។

កំណត់ចំណាំ៖ ពិនិត្យមើលលទ្ធផលលៃតម្រូវចុងក្រោយមុននឹងលៃតម្រូវ។

លៃតម្រូវប្រឡោះកន្ត្រែងឲ្យបានធំតាមដែលអាចធ្វើទៅបាន និងប្រាកដថាអំពុកនិងដើមដំណាំមិនធ្លាក់តាមហ្នឹងឡើយ។

**រង្វាស់**

**A—កន្ត្រែង** **B—ដៃលៃតម្រូវ**




CP00834,1659687221945-KM-05AUG22-2/3

វាស់ប្រឡោះកន្ត្រែងរវាងស្លាបព្រិលដែកចំនួនពីរ។

**X—ប្រឡោះកន្ត្រែង**




CP00834,1659687221945-KM-05AUG22-3/3

## លៃតម្រូវប្រឡោះពន្លាធ្មេញកញ្ជ្រែង

**ការលៃតម្រូវ**

CP00834,1659687241866-KM-05AUG22-1/3

មួលដៃលៃតម្រូវ (B) ទៅខាងឆ្វេងដើម្បីបង្កើនប្រឡោះ។

មួលដៃលៃតម្រូវ (B) ទៅខាងស្តាំដើម្បីបន្ថយប្រឡោះ។


ប្រឡោះពន្លាធ្មេញកញ្ជ្រែងទូលាយជាងប្រឡោះធ្មេញបន្តិច។

ចូរអានការណែនាំអំពីការកំណត់ដំណាំនៅក្នុងផ្នែកតម្រុយប្រមូលផល (Harvesting Hints) ដើម្បីជ្រាបពីប្រឡោះធ្មេញសម្រាប់គ្រាប់ធញ្ញជាតិផ្សេងៗតាមការណែនាំ។

កំណត់ចំណាំ៖ លើកប្រដាប់ពង្រីធ្មេញបន្តិចដើម្បីឲ្យសំដីស្រូវស្រួលធ្លាក់កាត់តាម។

**រង្វាស់**

**A—ផ្នែកពន្លាធ្មេញកញ្ជ្រែង** **B—ដៃលៃតម្រូវ**




តទៅទំព័របន្ទាប់

CP00834,1659687241866-KM-05AUG22-2/3

វាស់ប្រឡោះពន្លាធ្មេញកញ្ជ្រែងរវាងស្លាបព្រិលដែកចំនួនពីរ។

**X—ប្រឡោះពន្លាធ្មេញកញ្ជ្រែង**




YC1661—UN—27NOV12

CP00834,1659687241866-KM-05AUG22-3/3

## ការលៃតម្រូវទីតាំងសន្ទះទ្វារក្រោយ

CP00834,1668669307283-KM-17NOV22-1/2

បន្ថយចន្លោះរវាងផ្នែកពន្លាធ្មេញកញ្ជ្រែង (C) និង ផ្ទាំងទ្វារក្រោយ (D) ដើម្បីបង្ការការបាត់បង់ច្រើនដោយសារខ្យល់។


1. បន្ធូរឡោស៊ីចាក់សោ (E)។
2. ទាញកន្លះខ្ចាស់ (A) ហើយរំកិលផ្ទាំងទ្វារក្រោយទៅទីតាំងតម្រូវ។
3. ស៊ីកកន្លាស់ខ្ចាស់ក្នុងរន្ធ។

កំណត់ចំណាំ៖ ផ្ទាំងទ្វារក្រោយ មានបួនទីតាំង។


4. រឹតបន្តឹងឡោស៊ីមានឡក់បន្ទាប់ពីលៃតម្រូវរួច។

កំណត់ចំណាំ៖ រំកិល ផ្ទាំងទ្វារក្រោយ ឡើងលើឲ្យខ្ចាយតាមដែលអាចធ្វើទៅបាន។ ប្រសិនបើចន្លោះនៅតែធំទៀត ចូររំកិលផ្នែកពន្លាធ្មេញកញ្ជ្រែង ចុះក្រោម។

**A—កន្លាស់ខ្ចាស់ (ប្រើ 2)**
**B—ទីតាំងលៃតម្រូវ (ប្រើ 4)**
**C—ផ្នែកពន្លាធ្មេញកញ្ជ្រែង**
**D—ផ្ទាំងទ្វារក្រោយ**
**E—ក្បាលឡោស៊ីមានឡក់ (ប្រើ 2)**




YC17150—UN—01APR21




YC21124—UN—21DEC22

CP00834,1668669307283-KM-17NOV22-2/2

# ប្រតិបត្តិការប្រដាប់យោង និងប្រព័ន្ធបួងទម្លាក់

## ប្រតិបត្តិការផ្តាច់/ភ្ជាប់ប្រដាប់បួងទម្លាក់

**សំខាន់៖ មុននឹងភ្ជាប់ប្រដាប់បួងទម្លាក់ ចូរប្រាកដថាប្រដាប់បួងទម្លាក់ស្ថិតនៅត្រង់ទីតាំងបួងទម្លាក់។**

**ផ្តាច់ប្រដាប់បួងទម្លាក់ចេញតែនៅពេលទម្លាក់គ្រាប់ធញ្ញជាតិអស់ទាំងស្រុង។ ចាក់គ្រាប់ចេញពីធុងគ្រាប់ធញ្ញជាតិឲ្យអស់ក្នុងប្រតិបត្តិការតែមួយដង (តែមួយលើក)។**

កំណត់ចំណាំ៖ គ្រាប់អាចត្រូវបានទម្លាក់តែមួយលើក (ខណៈដែលគ្រឿងចក្រកំពុងមានចលនា)។

CP00834,0008F7A-KM-29AUG21-1/2

ដៃភ្ជាប់ប្រដាប់បួងទម្លាក់ (A) ប្រើដើម្បីភ្ជាប់ ឬផ្តាច់ប្រព័ន្ធបួងទម្លាក់។


ដៃភ្ជាប់ប្រដាប់បួងទម្លាក់ស្ថិតនៅខាងឆ្វេងកៅអី។

- ទាញដៃឡើងលើដើម្បីភ្ជាប់ប្រព័ន្ធបួងទម្លាក់។
- ចុចប៊ូតុង (B) ហើយរុញដៃចុះក្រោមដើម្បីផ្តាច់ប្រព័ន្ធបួងទម្លាក់។

កំណត់ចំណាំ៖ បន្ទាប់ពីចុចប៊ូតុងនេះ ដៃភ្ជាប់ប្រដាប់បួងទម្លាក់អាចធ្លាក់ចុះក្រោមដោយស្វ័យប្រវត្តិ។

កំណត់ចំណាំ៖ ដើម្បីភ្ជាប់ប្រដាប់បួងទម្លាក់ ចូរទាញដៃភ្ជាប់ប្រដាប់បួងទម្លាក់យឺតៗ។ ទាញដៃភ្ជាប់ប្រដាប់បួងទម្លាក់ឲ្យលឿន នៅពេលប្រដាប់បួងទម្លាក់កំពុងរំលឹ។

**A—ដៃភ្ជាប់ប្រដាប់បួងទម្លាក់** **B—ប៊ូតុង**




ដៃភ្ជាប់ប្រដាប់បួងទម្លាក់ (ការអូសដោយមេកានិក)

CP00834,0008F7A-KM-29AUG21-2/2

## ប្រតិបត្តិការយោលប្រដាប់បួងទម្លាក់ (ការអូសដោយមេកានិក)

កំណត់ចំណាំ៖ នៅពេលមិនប្រើប្រាស់ប្រដាប់បួងទម្លាក់ យកល្អគួរបត់ប្រដាប់បួងទម្លាក់ត្រឡប់ទៅទីតាំងដឹកជញ្ជូនវិញ។

CP00834,0008F7B-KM-12JUL21-1/2

ដៃយោលប្រដាប់បួងទម្លាក់ (A) ប្រើដើម្បីយោលប្រដាប់បួងទម្លាក់ចូលក្នុង ឬចេញក្រៅ។

- ទាញដៃយោលប្រដាប់បួងទម្លាក់ឡើងលើដើម្បីយោលប្រដាប់បួងទម្លាក់ចេញក្រៅ។
- រុញដៃយោលប្រដាប់បួងទម្លាក់ចុះក្រោមដើម្បីយោលប្រដាប់បួងទម្លាក់ចូលក្នុង។

**A—ដៃយោលប្រដាប់បួងទម្លាក់**




CP00834,0008F7B-KM-12JUL21-2/2

## ប្រតិបត្តិការយោលប្រដាប់បួងទម្លាក់ (ការអូសដោយអ៊ីដ្រូស្តាទិក)

កំណត់ចំណាំ៖ នៅពេលមិនប្រើប្រាស់ប្រដាប់បួងទម្លាក់ យកល្អគួរបត់ប្រដាប់បួងទម្លាក់ត្រឡប់ទៅទីតាំងដឹកជញ្ជូនវិញ។

**តទៅទំព័របន្ទាប់**


CP00834,0008F7C-KM-20OCT21-1/2

ដៃយោលប្រដាប់បួងទម្លាក់ចេញ/ចូលប្រើដើម្បីយោលប្រដាប់បួងទម្លាក់ចូលក្នុង ឬចេញក្រៅ។

កំណត់ចំណាំ៖ មុននឹងយោលប្រដាប់បួងទម្លាក់ចេញឬចូល ចូរប្រាកដថាកុងតាក់លើដួរវង្វេល/វាលស្រែ (C) ស្ថិតនៅក្នុងម៉ូដវាលស្រែ (ពន្លឺភ្លើងសញ្ញានៅលើកុងតាក់មិនបើកឡើយ)។

- ចុចទប់ប៊ូតុងយោលប្រដាប់បួងទម្លាក់ចេញក្រៅ (A) ប្រើដើម្បីយោលប្រដាប់បួងទម្លាក់ចេញក្រៅ។
- ចុចទប់ប៊ូតុងយោលប្រដាប់បួងទម្លាក់ចូលក្នុង (B) ប្រើដើម្បីយោលប្រដាប់បួងទម្លាក់ចូលក្នុង។

**A—ប៊ូតុងយោលប្រដាប់បួងទម្លាក់ចេញក្រៅ**
**B—ប៊ូតុងយោលប្រដាប់បួងទម្លាក់ចូលក្នុង**
**C—កុងតាក់លើដួរវង្វេលវាល**
**D—ដៃបញ្ជាពហុមុខងារ**




CP00834,0008F7C-KM-20OCT21-2/2

## លៃតម្រូវប្រឡោះបួងទម្លាក់នៅក្នុងធុងគ្រាប់ធញ្ញជាតិ

**សំខាន់៖ ប្រសិនបើលើកបន្ទះទាំងនេះខ្ពស់ពេក ប៊ូឡុងសងខាងដំអូសប្រដាប់បួងអាចជាក់ម្តងហើយម្តងទៀត ឬអាចធ្វើឲ្យខូចប្រដាប់បួង ឬធុងគ្រាប់ធញ្ញជាតិ។**

CP00834,1668670051368-KM-17NOV22-1/2


បន្ទរក្បាលឡោស៊ី (A) និងរំកិលបន្ទះ (B) ឡើងលើដើម្បីបង្កើនប្រឡោះបួងទម្លាក់។ រឹតបន្តឹងក្បាលឡោស៊ីក្រោយពីលៃតម្រូវរួច។

បន្ទរក្បាលឡោស៊ី (A) និងរំកិលបន្ទះ (B) ចុះក្រោមដើម្បីបន្ថយប្រឡោះបួងទម្លាក់។ រឹតបន្តឹងក្បាលឡោស៊ីក្រោយពីលៃតម្រូវរួច។

កំណត់ចំណាំ៖ បង្កើនប្រឡោះបួងទម្លាក់សម្រាប់ដំណាំសួត។

បន្ថយប្រឡោះបួងទម្លាក់សម្រាប់ដំណាំសើម។

**A—ក្បាលឡោស៊ី (ប្រើ 12)**
**B—បន្ទះ (ប្រើ 6)**




CP00834,1668670051368-KM-17NOV22-2/2


## លៃតម្រូវប្រដែងដើមដំណាំចិញ្ច្រាំ

**សំខាន់៖ កំណត់កំបិតវិលនៅទៅតាំងប្រដែងកាត់អប្បបរមា (A) នៅពេលប្រមូលផលសណ្តែក ដែបស៊ីដ ឬដំណាំដែលស្ពក។**

CP00834,0008BD7-KM-08MAR22-1/2

បន្ទរប៊ូឡុង (C) នៅចំហៀងសងខាងរបស់គ្រឿងចក្រ។ លៃតម្រូវប្រដាប់ក្តាប់ (D) ទៅកាន់ទីតាំងដែលចង់បាន បន្ទាប់មករឹតបន្តឹងប៊ូឡុងនោះវិញ។

**A—ទីតាំងប្រដែងកាត់អប្បបរមា**
**B—ទីតាំងប្រដែងកាត់អតិបរមា**
**C—ប៊ូឡុង (ប្រើ 2)**
**D—ប្រដាប់ក្តាប់**




YC17142—UN—31MAR21

CP00834,0008BD7-KM-08MAR22-2/2

## ប្តូរទីតាំងអង្គុបង្វែរ

**ប្រយ័ត្ន៖ ចាក់ខ្ចាស់អង្គុបង្វែរនៅក្នុងទីតាំងដឹកជញ្ជូនមុននឹងដឹកជញ្ជូន។ ហាមភ្ជាប់កាំបិតចិញ្ច្រាំដើមដំណាំនៅអំឡុងពេលដឹកជញ្ជូន។**

**ហាមឈរពីក្រោយម៉ាស៊ីននៅពេលកាំបិតចិញ្ច្រាំដើមដំណាំកំពុងដំណើរការ។**

**តទៅទំព័របន្ទាប់**

CP00834,1668672131613-KM-17NOV22-1/2

**ប្តូរអង្គបង្វែរទៅកាន់ទីតាំងប្រតិបត្តិការ**

កំណត់ចំណាំ៖ ប្រតិបត្តិការនៅចំហៀងសងខាងគ្រឿងចក្រ នៅក្នុងពេលដំណាលគ្នា។

1. បន្ធូរប៊ូឡុង (A) និងបង្វិលបន្ទះចាក់ខ្ចាស់ (B) ចេញពីដង។

**⚠ ប្រយ័ត្ន៖ អង្គបង្វែរមានទម្ងន់ប្រហែល 37 គ.ក។ វាចាំបាច់ត្រូវការមនុស្សពីរនាក់ដើម្បីចាត់ចែងវា។**

2. លើកអង្គបង្វែរចេញពីតម្កក់ ហើយដាក់វាចុះក្រោម។
3. ចាក់គន្លឹះ (C)។
4. បង្វិលបន្ទះចាក់ខ្ចាស់លើដង ហើយរឹតបន្តឹងប៊ូឡុង។

**ប្តូរអង្គបង្វែរទៅទីតាំងដឹកជញ្ជូន**


កំណត់ចំណាំ៖ ប្រតិបត្តិការនៅចំហៀងសងខាងគ្រឿងចក្រ នៅក្នុងពេលដំណាលគ្នា។

1. បន្ធូរគន្លឹះ (C)។
2. បន្ធូរប៊ូឡុង (A) និងបង្វិលបន្ទះចាក់ខ្ចាស់ (B) ចេញពីដង។


**⚠ ប្រយ័ត្ន៖ អង្គបង្វែរមានទម្ងន់ប្រហែល 37 គ.ក។ វាចាំបាច់ត្រូវការមនុស្សពីរនាក់ដើម្បីចាត់ចែងវា។**

3. លើកអង្គបង្វែរឡើង ហើយដាក់វាលើតម្កក់។
4. បង្វិលបន្ទះចាក់ខ្ចាស់លើដង ហើយរឹតបន្តឹងប៊ូឡុង។

**A—ប៊ូឡុង (ប្រើ 2)**
**B—បន្ទះចាក់ខ្ចាស់ (ប្រើ 2)**
**C—គន្លឹះ (ប្រើ 2)**
**D—តម្កក់ (ប្រើ 2)**




YC8296—UN—09FEB15



YC21127—UN—21DEC22

អង្គបង្វែរនៅក្នុងទីតាំងប្រតិបត្តិការ



YC21128—UN—21DEC22

អង្គបង្វែរស្ថិតក្នុងទីតាំងដឹកជញ្ជូន

CP00834,1668672131613-KM-17NOV22-2/2

## លៃតម្រូវស្លាបនៅលើអង្គបង្វែរ


**តទៅទំព័របន្ទាប់**

CP00834,1668670535929-KM-17NOV22-1/2

បន្ទប់ប៊ូឡុង (A)។ លៃតម្រូវទីតាំងស្លាប (B) ដើម្បីប្តូរមុំ និងកម្រិតពង្រាយ។

ទទឹងពង្រាយគួរតែត្រូវគ្នាជាមួយទទឹងក្បាលឧបករណ៍កាត់។

**A—ប៊ូឡុង (ប្រើ 12)** **B—ស្លាប (ប្រើ 6)**




CP00834,1668670535929-KM-17NOV22-2/2

# ការប្រើប្រាស់ស្ថាយនីយប្រតិបត្តិករ

## ប្រើប្រាស់ខ្សែក្រវាត់សុវត្ថិភាព

**ប្រយ័ត្ន៖ ត្រួតពិនិត្យខ្សែក្រវាត់សុវត្ថិភាព ហើយភ្ជាប់គ្រឿងខ្ចៅនៅលើគ្រឿងចក្ររបស់អ្នកយ៉ាងហោចណាស់មួយឆ្នាំម្តង។ ប្រសិនបើប្រព័ន្ធខ្សែក្រវាត់សុវត្ថិភាពរួមមានគ្រឿងដំឡើងភ្ជាប់ជាមួយ ក្លាស់គន្លឹះ ខ្សែក្រវាត់ ឬប្រដាប់ពន្លឹបចូល បង្ហាញឲ្យឃើញនូវសញ្ញាខូចខាតដូចជាដាច់ រសាត់ ឬស៊ីកយចរិលខុសប្រក្រតី ស្នែកពណ៌មានស្នាមរលាត់ ប្រព័ន្ធខ្សែក្រវាត់សុវត្ថិភាពទាំងមូលគួរតែផ្លាស់ប្តូរជាបន្ទាន់។ ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នក ផ្លាស់ប្តូរប្រព័ន្ធខ្សែក្រវាត់តែជាមួយនឹងគ្រឿងបន្លាស់ដែលមានការអនុញ្ញាតសម្រាប់គ្រឿងចក្ររបស់អ្នក ចូរពិគ្រោះជាមួយភ្នាក់ងារចែកចាយក្រុមហ៊ុន John Deere របស់អ្នកប៉ុណ្ណោះ។**

CP00834,0008BC3-KM-30MAR21-1/2

ខ្សែក្រវាត់សុវត្ថិភាព (A) គឺជាបរិក្ខារស្តង់ដារនៅលើកៅអីប្រតិបត្តិករ។ ខ្សែក្រវាត់សុវត្ថិភាពប្រភេទរឹតស្តៅមានប្រដាប់បន្ទូរហ៊ីសប៊ូតុងចុច និងប្រដាប់ទាញត្រឡប់ស្វ័យប្រវត្តិដើម្បីឲ្យស្រួលចេញចូល។

**A—ខ្សែក្រវាត់សុវត្ថិភាព**




YC17130—UN—29MAR21

CP00834,0008BC3-KM-30MAR21-2/2

## លៃតម្រូវកៅអីប្រតិបត្តិករ

CP00834,0008F68-KM-09JUL21-1/2

**ការលៃតម្រូវជាសុកភាព៖** កាច់ដៃលៃតម្រូវទម្ងន់/កម្ពស់ (A) ដើម្បីលៃតម្រូវជាសុកភាពកៅអី។


**ការលៃតម្រូវបង្អែកខ្នង៖** កាច់ដៃលៃតម្រូវបង្អែកខ្នង (B) ដើម្បីលៃតម្រូវមុំបង្អែកខ្នង។

**ការលៃតម្រូវកម្ពស់៖** ចុចដៃលៃតម្រូវកម្ពស់ (C) ដើម្បីលៃតម្រូវពូកកៅអីទៅកាន់ទីតាំងតាមចង់បាន។

**ការលៃតម្រូវមុំ៖** ចុចដៃលៃតម្រូវមុំ (D) ដើម្បីលៃតម្រូវពូកកៅអីទៅកាន់ទីតាំងតាមចង់បាន។

**ការលៃតម្រូវមុខ/ក្រោយ៖** ទាញដៃលៃតម្រូវមុខ/ក្រោយ (E) ឡើងលើ ដើម្បីហូតកៅអីទៅកាន់ទីតាំងតាមចង់បាន។

**A—គន្លឹះលៃតម្រូវកម្ពស់/ទម្ងន់**
**B—ដៃលៃតម្រូវបង្អែកខ្នង**
**C—គន្លឹះលៃតម្រូវកៅអី**
**D—ដៃលៃតម្រូវមុំ**
**E—ដៃលៃតម្រូវមុខ/ក្រោយ**




YC17131—UN—30MAR21

CP00834,0008F68-KM-09JUL21-2/2

## លៃតម្រូវទម្រែតដៃចង្កូត

តទៅទំព័របន្ទាប់

CP00834,0008BC5-KM-30MAR21-1/2

**លៃតម្រូវដៃចង្កូត៖** សង្កត់ឈ្នាន់ (B) ទៅមុខ លៃតម្រូវដៃចង្កូត (A) ទៅកាន់ទីតាំងតាមចង់បាន។

**ចាក់ខ្ទាស់ដៃចង្កូត៖** សង្កត់ឈ្នាន់មកក្រោយដើម្បីចាក់ខ្ទាស់ដៃចង្កូត។

**A—ដៃចង្កូត** **B—ឈ្នាន់**




ដៃចង្កូត (ដែលប្រើការអូសដោយអ៊ីដ្រូស្តាទិក)

CP00834,0008BC5-KM-30MAR21-2/2


## បង្អួចខាងស្តាំកាប៊ីន (ច្រកចេញក្នុងគ្រោះអាសន្ន)

**⚠ ប្រយ័ត្ន៖ ប្រសិនបើមានអាសន្នកើតឡើង ហើយទ្វារច្រកចេញបើកមិនរួច ចូរប្រើបង្អួចខាងស្តាំដើម្បីចាកចេញពីកាប៊ីន។**

CP00834,0008BC6-KM-30MAR21-1/2

ទប់ដង (B) ហើយបង្វិលវាស្របទ្រនិចនាឡិកាដើម្បីបើកបង្អួចខាងស្តាំ (A)។ កាច់ដងបញ្ច្រាសទ្រនិចនាឡិកាដើម្បីបិទបង្អួចខាងស្តាំ។

**A—បង្អួចខាងស្តាំ** **B—ដង**




CP00834,0008BC6-KM-30MAR21-2/2

## ប្រអប់ឧបករណ៍


**តទៅទំព័របន្ទាប់**

CP00834,0008BC7-KM-30MAR21-1/2

ប្រអប់ដាក់ឧបករណ៍ (A) ស្ថិតនៅក្រោមកៅអី។

រំកិលគន្លឹះ (B) ឡើងលើដើម្បីបើកប្រអប់ដាក់ឧបករណ៍។

**A—ប្រអប់ឧបករណ៍** **B—គន្លឹះ**




YC17133—UN—30MAR21

CP00834,0008BC7-KM-30MAR21-2/2


## បើកទ្វារ

CP00834,0008BC8-KM-30MAR21-1/2

ប្រសិនបើទ្វារកាប៊ីនមិនបានចាក់ខ្ទាស់ទេ សូមចុចគន្លឹះ (B) ដើម្បីបើកទ្វារកាប៊ីន។ ប្រសិនបើទ្វារកាប៊ីនចាក់ខ្ទាស់ ចូរប្រើសោដើម្បីបើកវា។

ចុចដង (A) ដើម្បីបើកទ្វារកាប៊ីនពីខាងក្នុងកាប៊ីន។

**A—ដង** **B—សោ**




YC17135—UN—30MAR21

CP00834,0008BC8-KM-30MAR21-2/2

## ភ្ជាប់ជណ្តើរនៅទីតាំងដឹកជញ្ជូន

**ប្រយ័ត្ន៖ មុននឹងបើកបរតាមផ្លូវចូរបត់ជណ្តើរ និងទុកដាក់វាឲ្យមានសុវត្ថិភាពនៅក្នុងទីតាំងដឹកជញ្ជូន។**

**ចៀសវាងធ្វើឱ្យអ្នកដទៃរងរបួសនៅពេលលាជណ្តើរ។**

**តទៅទំព័របន្ទាប់**

CP00834,1669015435856-KM-21NOV22-1/2




CP00834,1669015435856-KM-21NOV22-2/2

## ពន្លាជណ្តើរ

CP00834,1669170530230-KM-22NOV22-1/2

ប្រសិនបើប្រើសម្បកកង់ទូលាយ ចូរដោះប៊ូឡុង ទាញបន្ទះភ្ជាប់ (A) ចេញក្រៅ ដើម្បីរឹតបន្តឹងប៊ូឡុង។

**A—បន្ទះតភ្ជាប់**




CP00834,1669170530230-KM-22NOV22-2/2

# ការទុកដាក់ និងការដឹកជញ្ជូន

## រៀបចំគ្រឿងចក្រសម្រាប់ទុកដាក់

### គ្រឿងចក្រ

- សម្អាតផ្នែកខាងក្រៅនិងខាងក្នុងគ្រឿងចក្រឲ្យបានស្អាតល្អ។
- ដោះ ឬបន្ធូរខ្សែពានអូសទាំងអស់។
- ដាក់ប្រេងរំអិលគ្រឿងចក្រ។ ដាក់ប្រេងរំអិលធ្មេញខ្ចៅលៃតម្រូវទាំងពីរ។ ដាក់ប្រេងច្រវាក់ទាំងអស់។
- សម្អាតប្រដាប់បួង ប្រដាប់យោង និងស្បែកជើងសម្អាត។ ទុកទ្វារប្រដាប់យោងឲ្យនៅចំហ។
- ថាក់ប្រេងឥន្ធនៈចូលធុងដើម្បីការពារកំណក។
- បង្ហូរទឹកចេញពីតម្រងចម្រោះទឹក
- លាបថ្នាំត្រង់កន្លែងចាំបាច់ឡើងវិញ។

កំណត់ចំណាំ៖ បិទកុងតាក់ផ្តាច់អាគុយ ប្រសិនបើលោកអ្នកត្រូវរក្សាគ្រឿងចក្រទុកលើសពី *25* ថ្ងៃ។ ប្រសិនបើរក្សាទុកលើសពី *90* ថ្ងៃ ចូរដោះខ្សែអាគុយអវិជ្ជមានចេញដើម្បីកាត់បន្ថយបន្ទុកអាគុយជាអតិបរមា។

- សាកអាគុយឲ្យពេញ។ ទំនាញជាក់លាក់ស្មើនឹង 1.260 រ៉ុល។ ដើម្បីកាត់បន្ថយបន្ទុកចំពោះអាគុយជាអតិបរមា ចូរដោះខ្សែអវិជ្ជមានចេញពីអាគុយ។

កំណត់ចំណាំ៖ ប្រសិនបើត្រូវរក្សាទុកគ្រឿងចក្រក្នុងរយៈពេលយូរ ចូរដោះនិងលាងសម្អាតអាគុយ។ ដាក់អាគុយក្នុងទឹកន្លែងស្ងួតត្រជាក់ ហើយទុកឲ្យវាចូលភ្លើងពេញ។

### ម៉ាស៊ីន

- លាងសម្អាតម៉ាស៊ីនសារធាតុរំលាយដែលមានសុវត្ថិភាព។
- សម្អាតធុងទឹកម៉ាស៊ីនដោយប្រើខ្សល់ ទឹក ឬប្រដាប់បូមធូលី។
- សម្អាតអង្គកំណ និងឧបករណ៍បញ្ចុះកម្តៅប្រេងប្រសិនបើមាន។ លាងសម្អាតឧបករណ៍បញ្ចុះកម្តៅខ្សល់
- រាល់ 60 ទៅ 90 ថ្ងៃ ចូរបញ្ចេះម៉ាស៊ីន និងបើកម៉ាស៊ីនត្រជាក់ចោល ប្រសិនបើមាន។ ដំណើរការម៉ាស៊ីនការ៉ងទីទាបរយៈពេលច្រើននាទី។ ដើម្បីដំណើរការម៉ាស៊ីនត្រជាក់ឲ្យបានត្រឹមត្រូវ សីតុណ្ហភាពខាងក្រៅគួរតែលើសពី 5 °C (40 °F)។

**⚠ ប្រយ័ត្ន៖ ហាមប្រើសាំង។**

- សម្អាតផ្នែកខាងក្នុងសំបុកតម្រងខ្សល់ ហើយដាក់ស្បៃតម្រងខ្សល់ថ្មីចូល។
- បង្ហូរប្រេងម៉ាស៊ីនចេញខណៈដែលម៉ាស៊ីនក្តៅ។ ប្តូរតម្រង និងចាក់ប្រេងត្រឹមត្រូវចូល។ បើកដំណើរការម៉ាស៊ីនដើម្បីឲ្យប្រេងជាចសាចសព្វ។
- បង្ហូរ លាងសម្អាត និងចាក់បំពេញប្រព័ន្ធបញ្ចុះកម្តៅជាមួយល្បាយសារធាតុប្រឆាំងកំណកនិងទឹក 50/50។

CP00834,0008BB7-KM-29MAR21-1/1

## យកគ្រឿងចក្រចេញពីកន្លែងទុកដាក់

- ដំឡើង និងរឹតបន្តឹងខ្សែពានអូសទាំងអស់។ រឹតបន្តឹងច្រវាក់អូសទាំងអស់។
- បិទទ្វារប្រដាប់យោង។
- ពិនិត្យមើលខ្សល់កង និងអានសៀវភៅណែនាំប្រើប្រាស់ឡើងវិញ។
- ត្រួតពិនិត្យបំពង់ពន្លត់អគ្គីភ័យដោយអនុវត្តតាមការណែនាំថែទាំនៅលើស្លាកបិទលើបំពង់ពន្លត់អគ្គីភ័យ។ សាកឡើងវិញ ឬប្តូរថ្មីតាមចាំបាច់។
- ភ្ជាប់នឹង/ឬសាកអាគុយឡើងវិញ។
- ពិនិត្យកម្រិតប្រេងម៉ាស៊ីននិងទឹកថ្នាំស្អំម៉ាស៊ីន។ ពិនិត្យរកមើលកន្លែងលេចធ្លាយ ហើយបន្ថែមប្រេងម៉ាស៊ីន និងទឹកថ្នាំស្អំម៉ាស៊ីនចូល ប្រសិនបើចាំបាច់។

CP00834,0008BBB-KM-29MAR21-1/1

## បើកបរគ្រឿងចក្រលើផ្លូវ

ដើម្បីបើកបរគ្រឿងចក្រលើផ្លូវ អនុវត្តតាមដូចតទៅ៖

- សម្អាតធុងគ្រាប់ធញ្ញជាតិ ហើយដោះក្បាលឧបករណ៍កាត់ចេញ។
- យោលប្រដាប់បួងទម្លាក់។
- បត់ជណ្តើរឡើង។
- ចាក់សោឈ្នាន់ហ្វ្រាំងជើងរួមគ្នា។
- បើកភ្លើងព្រមានគ្រោះថ្នាក់តាមចាំបាច់។

CP00834,1668677436009-KM-17NOV22-1/1

## ដឹកជញ្ជូនគ្រឿងចក្រនៅលើរ៉ឺម៉កសណ្តោង

ដើម្បីដឹកជញ្ជូនគ្រឿងចក្រ អនុវត្តតាមដូចតទៅ៖

1. ដោះក្បាលកាត់ចេញ។
2. បើកបរគ្រឿងចក្រទៅលើរ៉ឺម៉កសណ្តោង។ ដាក់ចង្កឹះលេខ និងដែបញ្ឆាអូសដោយអ៊ីដ្រូស្តាទិក (បើមាន) នៅក្នុងទីតាំងនឹង។
3. បន្ទាបមាត់ច្រកបួងចូលលើរ៉ឺម៉កសណ្តោង។ យោលប្រដាប់បួងទម្លាក់។
4. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
5. បត់ជណ្តើរឡើង។
6. ចងភ្ជាប់គ្រឿងចក្រទៅនឹងរ៉ឺម៉កសណ្តោងដោយប្រើច្រវាក់។

CP00834,1668677457544-KM-17NOV22-1/1

## សណ្តោងគ្រឿងចក្រ

**⚠ ប្រយ័ត្ន៖ កុំសណ្តោងគ្រឿងចក្រជាមួយខ្សែភ្លើង។ ប្រសិនបើខ្សែដាច់ សកម្មភាពបោះបង់អាចបង្ករឲ្យមានរបួសដល់រាងកាយ។**

**សំខាន់៖ កុំសណ្តោងគ្រឿងចក្រ លើកលែងតែក្នុងស្ថានភាពមានអាសន្នសម្រាប់ចម្ងាយជិតនៅល្បឿន 20 គ.ម/ម៉ោង អតិបរមា។**

ដើម្បីសណ្តោងគ្រឿងចក្រ អនុវត្តតាមដូចតទៅ៖

- សម្អាតធុងគ្រាប់ធញ្ញជាតិ ហើយដោះក្បាលឧបករណ៍កាត់ចេញ។
- យោលប្រដាប់បួងទម្លាក់។
- បត់ជណ្តើរឡើង។
- ផ្តាច់ប្រ៊ាំងដៃ។

**⚠ ប្រយ័ត្ន៖ កុំដោះឧបករណ៍ភ្ជាប់ចេញ។ នៅពេលឧបករណ៍ភ្ជាប់ត្រូវបានដោះចេញ ប្រ៊ាំងត្រូវបានបិទ។**

- ដាក់ចង្កឹះលេខ និងដៃបញ្ជាអូសដោយអ៊ីដ្រូស្តាទិក (បើមាន) នៅក្នុងទីតាំងនឹង។
- សណ្តោងគ្រឿងចក្រក្នុងទិសដៅទៅមុខ ដោយភ្ជាប់ច្រវាក់ជុំវិញភ្លៅមេ។ សូមប្រាកដថា ច្រវាក់មិនធ្វើឲ្យខ្សែវារីណាមួយខូចទេ។ មានប្រតិបត្តិការអង្គុយក្នុងកៅអី ដើម្បីកាច់ចង្កូត និងជាន់ប្រ៊ាំងគ្រឿងចក្រ។
- បើកភ្លើងព្រមានគ្រោះថ្នាក់។
- ធ្វើដំណើរនៅល្បឿនដែលសមហេតុផល និងមានសុវត្ថិភាព មិនលើសពី 20 គ.ម/ម៉ោង។

**⚠ ប្រយ័ត្ន៖ បង្ការការប៉ះទង្គិចរវាងអ្នកប្រើប្រាស់ផ្លូវដទៃទៀត ត្រាក់ទ័រដែលភ្ជាប់ទីយឺតៗដោយមានភ្ជាប់ឧបករណ៍បន្ថែម ឬឧបករណ៍សណ្តោងផ្សេងៗ និងគ្រឿងចក្រមានម៉ាស៊ីននៅលើផ្លូវសាធារណៈ។ ពិនិត្យមើលចរាចរណ៍ឲ្យបានញឹកញាប់ពីផ្នែកខាងក្រោយ ជាពិសេសនៅពេលបត់ និងប្រើដៃជាសញ្ញា ឬភ្លើងសញ្ញាពេលបត់។**

**ប្រើភ្លើងមុខ ភ្លើងព្រមានគ្រោះថ្នាក់ និងភ្លើងសញ្ញាបត់នៅពេលថ្ងៃ និងយប់។**

CP00834,1668677466675-KM-17NOV22-1/1

# ប្រេងឥន្ធនៈ ទឹកថ្នាំស្អុំម៉ាស៊ីន និងប្រេងរំអិល

## ការប្រើប្រាស់ និងរក្សាទុកប្រេងម៉ាស៊ូត

**⚠ ប្រយ័ត្ន៖ កាត់បន្ថយហានិភ័យអគ្គិភ័យ។ គ្រប់គ្រង និងចាក់ចែងប្រេងឥន្ធនៈដោយប្រុងប្រយ័ត្ន។ កុំចាក់បំពេញធុងប្រេងនៅពេលម៉ាស៊ីនកំពុងដំណើរការ។ កុំជក់បារីនៅពេលអ្នកចាក់បំពេញធុងប្រេង ឬផ្តល់សេវាជួសជុលប្រព័ន្ធប្រេង។**

ចាក់បំពេញធុងប្រេងនៅពេលចប់បើកបរក្នុងថ្ងៃនីមួយៗ ដើម្បីបង្ការកុំឲ្យមានញើស ឬកកជាដំណក់ទឹកនៅអំឡុងពេលអាកាសធាតុត្រជាក់។

រក្សាអាងរក្សាទុកទាំងអស់ឲ្យនៅពេញតាមភាពជាក់ស្តែងដើម្បីកាត់បន្ថយការឡើងកំហាប់ជាអប្បបរមា។

ជានាថា គម្រប និងរបាំងធុងប្រេងទាំងអស់ត្រូវបានដំឡើងត្រឹមត្រូវដើម្បីបង្ការកុំឲ្យសំណើមចូល។ ត្រួតពិនិត្យចំណុះទឹកនៃប្រេងឥន្ធនៈឲ្យបានទៀងទាត់។

នៅពេលដែលប្រើប្រាស់ជីវម៉ាស៊ីត តម្រងប្រេងឥន្ធនៈអាចត្រូវការការផ្លាស់ថ្មីកាន់តែញឹកញាប់ដោយសារការដោតប៊ូស៊ីមុនពេលកំណត់។

ត្រួតពិនិត្យកម្រិតប្រេងម៉ាស៊ីនប្រចាំថ្ងៃ មុនពេលបញ្ឆោះម៉ាស៊ីន។ កម្រិតប្រេងដែលឡើង អាចបង្ហាញនូវកម្រិតឌីលុយស្បៃងឥន្ធនៈនៃប្រេងម៉ាស៊ីន។

**សំខាន់៖ ធុងប្រេងត្រូវមានហ៊ីយដើម្បីឲ្យខ្យល់ចេញចូលតាមគម្របចាក់ប្រេង។ ប្រសិនបើត្រូវការគម្របតម្រងថ្មីមួយជានិច្ចកាល ចូរប្តូរដាក់គម្រដើមដែលមានរន្ធហ៊ីយ។**

នៅពេលត្រូវរក្សាទុកប្រេងក្នុងរយៈពេលយូរ ឬមានប្រេងឥន្ធនៈឡើងយឺតចូរបន្ថែមឧបនីហ្សិនណីប្រេងដើម្បីស្ថេរភាពប្រេងឥន្ធនៈ។ ការបង្ហូរទឹកចេញឲ្យអស់ និងធ្វើប្រព្រឹត្តិកម្មធុងស្តុកប្រេងរាល់បីខែម្តងជាមួយដូសថែទាំនៃប៊ីយ៉ូស៊ីតនិងការពារមិនឲ្យកើនឡើងនូវមីក្រុប។ សូមទាក់ទងអ្នកផ្គត់ផ្គង់ប្រេងឥន្ធនៈ ឬភ្នាក់ងារចែកចាយ John Deere របស់អ្នកដើម្បីសុំការណែនាំ។

DX,FUEL4-KM-13JAN18-1/1


## គោរពតាមច្បាប់និងបទប្បញ្ញត្តិការពារបរិស្ថាន

CP00718,0004295-KM-19DEC17-1/2

មានការយល់ដឹងអំពីប្រព័ន្ធអេកូឡូស៊ីនិងបរិស្ថាន។

កំណត់វិធីសាស្ត្រចោះចោលយ៉ាងត្រឹមត្រូវមុនពេលបង្ហូរចេញសំណល់រាវអ្វីមួយ។

តែងតែអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិការពារបរិស្ថានជានិច្ច ពេលទុកដាក់ប្រេង ឥន្ធនៈ ទឹកថ្នាំស្អុំម៉ាស៊ីន ប្រេងហ្វ្រាំង សារធាតុគម្រង និងអាគុយ។




CP00718,0004295-KM-19DEC17-2/2

## ប្រេងម៉ាស៊ូត

ប្រឹក្សាជាមួយភ្នាក់ងារចែកចាយប្រេងឥន្ធនៈក្នុងស្រុករបស់អ្នក សម្រាប់លក្ខណៈសម្បត្តិនៃប្រេងម៉ាស៊ូតដែលអាចរកបាននៅក្នុងតំបន់របស់អ្នក។

គួរប្រើប្រេងម៉ាស៊ូតដែលបានបញ្ជាក់ចំពោះ GB 19147។

**លក្ខណៈប្រេងឥន្ធនៈដែលត្រូវការ**

គ្រប់ករណីទាំងអស់ ប្រេងឥន្ធនៈត្រូវមានគុណភាពដូចតទៅ៖

**ចំនួនសេតានអប្បបរមា 40 ។** ចំនួនសេតានដែលធំជាង 47 រឺតែល្អថែមទៀត ជាពិសេសសម្រាប់សីតុណ្ហភាពក្រោម –20 ° C (–4 °F) ឬកម្ពស់លើសពី 1675 ម (5500 ហ្វីត)។

**ចំណុចពពក** គួរតែនៅក្រោមសីតុណ្ហភាពជុំវិញទាបបំផុតដែលរំពឹងទុកឬ **ចំណុចស្ទះតម្រងត្រជាក់** (CFPP) គួរតែមានអតិបរមា 10 អង្សាសេ (18 ° F) ខាងក្រោមចំណុចពពកឥន្ធនៈ។

**ភាពរំអិលនៃប្រេងឥន្ធនៈ:** គួរឆ្លងផុតអង្កត់ផ្ចិតសម្លាកអតិបរមា .52 មម តាមការវាស់វែងដោយ ASTM D6079 ឬ ISO 12156-1។ យកល្អគួរប្រើអង្កត់ផ្ចិតសម្លាកអតិបរមា .45 មម។

**គុណភាព និងចំណុះ:** ស្ពាន់ធ័ររបស់ប្រេងម៉ាស៊ូត ត្រូវតែអនុលោមតាមបទបញ្ជាត្បិបំភាយឧស្ម័នជាធរមានសម្រាប់តំបន់ដែលម៉ាស៊ីនដំណើរការ។ កុំប្រើប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រធំជាង 10 000 មក្រ/គក្រ (10 000 ភាគក្នុងមួយលាន)។

**សម្ភារៈ:** ដូចជាទង់ដែង សំណ ស័ង្កសី សំណប៉ាហាំង ស្ពាន់និងសំរីទ្ធីគួរតែចៀសវាងប្រើជាគ្រឿងបរិក្ខារសម្រាប់ចាត់ចែងចែកចាយនិងទុកដាក់ប្រេងឥន្ធនៈ ពីព្រោះលោហធាតុទាំងនេះ អាចបង្កើតប្រតិកម្មអុកស៊ីដកម្មប្រេងឥន្ធនៈដែលអាចបណ្តាលឲ្យកកប្រព័ន្ធប្រេងឥន្ធនៈនិងស្ទះតម្រងប្រេង។

**ប្រេងឥន្ធៈ E-Diesel**

កុំប្រើប្រេងម៉ាស៊ូត E-Diesel (ល្បាយប្រេងម៉ាស៊ូត និងអេតាណុល)។ ការប្រើប្រាស់ប្រេងម៉ាស៊ូត E-Diesel នៅក្នុងគ្រឿងចក្រ John Deere ណាមួយ អាចធ្វើឲ្យខូចការធានារ៉ាប់រងចំពោះគ្រឿងចក្រ។

**⚠ ប្រយ័ត្ន៖ ប្រយ័ត្នក្រែងលោរងរបួសធ្ងន់ធ្ងរ ឬស្លាប់ដោយសារការផ្ទុះនិងអគ្គីភ័យដែលបណ្តាលមកពីការប្រើប្រេង E-Diesel។**

**ចំណុះស្ពាន់ធ័រសម្រាប់ម៉ាស៊ីនម៉ាស៊ូតនៃគ្រឿងចក្រចល័តមិនប្រើលើផ្លូវថ្នល់ (ប្រទេសចិន IV)**

- ប្រើប្រាស់តែ ប្រេងម៉ាស៊ូតមានស្ពាន់ធ័រទាបខ្លាំង (ULSD) ដែលមានចំណុះស្ពាន់ធ័រអតិបរិមា 15 មក្រ/គក្រ (15 ppm) ប៉ុណ្ណោះ។

**សំខាន់៖ កុំលាយប្រេងម៉ាស៊ីនម៉ាស៊ូតដែលប្រើប្រាស់រួច ឬប្រេងរំអិលប្រភេទផ្សេងទៀតជាមួយនឹងប្រេងម៉ាស៊ីនម៉ាស៊ូត។**

**ការប្រើប្រាស់ប្រេងបន្ថែមមិនបានត្រឹមត្រូវ អាចបង្កការខូចខាតដល់ឧបករណ៍ចាក់បញ្ចូលប្រេងឥន្ធនៈរបស់ម៉ាស៊ីនម៉ាស៊ូត។**

CP00834,1661909695490-KM-30AUG22-1/1

## ប្រេងម៉ាស៊ីនម៉ាស៊ូតដែលទើបប្រើថ្មី — គ្មានការភាយឧស្ម័ន ថ្នាក់ទី 1 ថ្នាក់ទី 2 ថ្នាក់ទី 3 ដំណាក់កាលទី I ដំណាក់កាលទី II និងដំណាក់កាលទី III

ម៉ាស៊ីនថ្មីត្រូវបានចាក់បំពេញនៅរោងចក្រជាមួយផ្នែកពាណិជ្ជកម្ម John DeereBreak-In™ ឬក៏ប្រេងម៉ាស៊ីនផ្នែកពាណិជ្ជកម្ម John DeereBreak-In Plus™ នៅអំឡុងពេលប្រើប្រាស់ដំបូង សូមបន្ថែមប្រេងម៉ាស៊ីនម៉ាក John Deere Break-In™ ឬ Break-In Plus™ តាមតម្រូវការដើម្បីរក្សាកម្រិតប្រេងតាមលក្ខណៈបច្ចេកទេស។

ប្រតិបត្តិការម៉ាស៊ីនក្រោមលក្ខខណ្ឌផ្សេងៗ ជាពិសេសបន្ទុកធ្ងន់ ជាមួយនឹងការការ៉ង់ទីម៉ាស៊ីនតិចតួចបំផុត ដើម្បីជួយឱ្យចូលសមាសភាគម៉ាស៊ីនបានត្រឹមត្រូវ។

ប្រសិនបើប្រើប្រេងម៉ាស៊ីនម៉ាក John Deere Break-In™ នៅអំឡុងពេលប្រតិបត្តិការដំបូងនៃម៉ាស៊ីនថ្មី ឬម៉ាស៊ីនដែលផ្គុំឡើងវិញ សូមប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីនក្នុងរយៈពេលអតិបរិមា 100 ម៉ោង។

ប្រសិនបើប្រើប្រេងម៉ាស៊ីនម៉ាក John Deere Break-In Plus™ សូមប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីននៅចន្លោះពេលអប្បបរមា 100 ម៉ោង និងអតិបរមាស្មើនឹងចន្លោះពេលដែលមានបញ្ជាក់លម្អិតសម្រាប់ប្រេងម៉ាក John Deere Plus-50™ II ឬ Plus-50™ ។

ក្រោយពេលរើជួសជុលម៉ាស៊ីន សូមចាក់ប្រេងម៉ាស៊ីនម៉ាក John Deere Break-In™ ឬ Break-In Plus™ ។

ប្រសិនបើពុំអាចរកបានប្រេងម៉ាស៊ីនម៉ាក John Deere Break-In™ ឬ Break-In Plus™ ទេនោះ សូមប្រើប្រេងម៉ាស៊ីនម៉ាស៊ូតដែលមានកម្រិតស្ថិតអន្ទិល SAE 10W-30 ដែលត្រូវតាមតម្រូវការណាមួយខាងក្រោម ហើយប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីនក្រោយពេលប្រតិបត្តិការអតិបរិមា 100 ម៉ោង៖

- សេវា API ចំណាត់ថ្នាក់ CE
- សេវា API ចំណាត់ថ្នាក់ CD
- សេវា API ចំណាត់ថ្នាក់ CC
- សេវា ACEA ចំណាត់ថ្នាក់ E2
- ប្រេង ACEA លំដាប់ E1

**សំខាន់៖ កុំប្រើប្រេងម៉ាស៊ីន Plus-50™ II, Plus-50™ ឬប្រេងម៉ាស៊ីនទាំងឡាយណាដែលត្រូវនឹងតម្រូវការណាមួយខាងក្រោម សម្រាប់ការប្រើប្រាស់ដំបូងនៃម៉ាស៊ីនថ្មី ឬម៉ាស៊ីនដែលទើបនឹងផ្គុំនឹងឡើងវិញ៖**

| | |
|---|---|
| **API CK-4** | **ACEA E9** |
| **API CJ-4** | **ACEA E7** |
| **API CI-4 PLUS** | **ACEA E6** |
| **API CI-4** | **ACEA E5** |
| **API CH-4** | **ACEA E4** |
| **API CG-4** | **ACEA E3** |
| **API CF-4** | |
| **API CF-2** | |
| **API CF** | |

**ប្រេងម៉ាស៊ីនទាំងនេះ មិនអនុញ្ញាតឲ្យម៉ាស៊ីនប្រើប្រាស់ដំបូងបានត្រឹមត្រូវទេ។**

ប្រេងម៉ាស៊ីនម៉ាក John Deere Break-In Plus™ អាចប្រើប្រាស់សម្រាប់ប្រេងម៉ាស៊ីនម៉ាស៊ូតទាំងអស់របស់ John Deere នៅគ្រប់កម្រិតនៃការបញ្ចាក់អំពីការបំភាយឧស្ម័នទាំងអស់។

ក្រោយពេលចប់រយៈពេលប្រើប្រាស់ដំបូង សូមប្រើប្រេងម៉ាក John Deere Plus-50™ II, John Deere Plus-50™ ឬប្រេងម៉ាស៊ីនម៉ាស៊ូតផ្សេងទៀតតាមការណែនាំនៅក្នុងសៀវភៅណែនាំនេះ។

*Break-In* គឺជានិក្ខិត្តសញ្ញារបស់ *Deere & Company*។
*Break-In Plus* គឺជានិក្ខិត្តសញ្ញារបស់ *Deere & Company*
*PLUS-50* គឺជានិក្ខិត្តសញ្ញារបស់ *Deere & Company*។

DX,ENOIL4-KM-02NOV16-1/1

## ប្រេងម៉ាស៊ីនម៉ាស៊ូត - ថ្នាក់ទី 3 និងដំណាក់កាល IIIA

តទៅទំព័របន្ទាប់

DX,ENOIL11-KM-23APR19-1/2

ការមិនអនុវត្តតាមស្តង់ដារប្រេងនិងចន្លោះពេលបង្ហូរអាចបណ្តាលឱ្យខូចម៉ាស៊ីនធ្ងន់ធ្ងរដែលអាចធ្វើឱ្យបាត់បង់ការធានា។ ការធានា ដែលរួមមានការធានារ៉ាប់រងលើការបំភាយឧស្ម័នគឺមិនមែនជាលក្ខខណ្ឌចំពោះការប្រើពពួកប្រេងម៉ាស៊ីនគ្រឿងបន្លាស់ ឬសេវាកម្ម របស់ក្រុមហ៊ុន John Deere ឡើយ។

ប្រើកម្រិតភាពស្អិតខាប់ដោយផ្អែកលើលំដាប់សីតុណ្ហភាពខ្យល់ដែលបានរំពឹងទុកនៅអំឡុងចន្លោះពេលនៃការផ្លាស់ប្តូរប្រេងម៉ាស៊ីនម្តងៗ។

**ប្រេងម៉ាស៊ីន John Deere Plus-50™ II គេនិយមប្រើជាងគេ។**

ប្រេងម៉ាស៊ីន John Deere Plus-50™ ក៏ត្រូវបានណែនាំផងដែរ។

John Deere Torq-Gard™ ក៏ត្រូវបានអនុញ្ញាតឲ្យប្រើផងដែរ។


ប្រេងដទៃទៀតអាចប្រើបាន ប្រសិនបើឆ្លើយតាមបទដ្ឋានមួយឬច្រើនដូចខាងក្រោម៖

- CK-4 ប្រភេទសេវា API
- សេវា API ប្រភេទ CJ-4
- សេវា API ប្រភេទ CI-4 PLUS
- សេវា API ប្រភេទ CI-4
- ប្រេង ACEA លំដាប់ E9
- ប្រេង ACEA លំដាប់ E7
- ប្រេង ACEA លំដាប់ E6
- ប្រេង ACEA លំដាប់ E5
- ប្រេង ACEA លំដាប់ E4

**យកល្អគួរប្រើប្រេងម៉ាស៊ីនម៉ាស៊ូតដែលមានពហុកម្រិតភាពអន្ទិល។**

គុណភាព និងចំណុះស្ពាន់ធ័ររបស់ប្រេងម៉ាស៊ូត ត្រូវតែអនុលោមតាមបទបញ្ញត្តិបំភាយឧស្ម័នជាធរមានសម្រាប់តំបន់ដែលត្រូវម៉ាស៊ីនដំណើរការ។

កុំប្រើប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រធំជាង 10 000 មក្រ/គក្រ (10 000 ភាគក្នុងមួយលាន)។




កម្រិតស្អិតខាប់នៃប្រេងរំអិលសម្រាប់លំដាប់សីតុណ្ហភាពខ្យល់

*Plus-50* គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*
*Torq-Gard* គឺជានិក្ខិត្តសញ្ញារបស់ *Deere & Company*

DX,ENOIL11-KM-23APR19-2/2

## ចន្លោះពេលផ្តល់សេវាថែទាំប្រេងម៉ាស៊ីននិងតម្រង

ចន្លោះម៉ោងថែទាំប្រេង និងតម្រងដែលត្រូវបានណែនាំ គឺផ្អែកលើការរួមបញ្ចូលគ្នារវាងចំណុះនៃធុងប្រេង ប្រភេទប្រេងម៉ាស៊ីន និងតម្រងដែលត្រូវបានប្រើប្រាស់ និងចំណុះស្តាន់ដារនៃប្រេងម៉ាស៊ូត។ ចន្លោះម៉ោងថែទាំជាក់ស្តែងក៏ពឹងផ្អែកលើប្រតិបត្តិការ និងទម្លាប់អនុវត្តតំហែទាំផងដែរ។

ប្រើប្រាស់ការវិភាគអំពីប្រេងដើម្បីវាយតម្លៃអំពីស្ថានភាពប្រេង និងដើម្បីជួយដល់ការជ្រើសរើសចន្លោះម៉ោងថែទាំប្រេង និងតម្រងដែលត្រឹមត្រូវ។ ទាក់ទងឈ្មួញ John Deere របស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីការវិភាគប្រេងម៉ាស៊ីន។

ផ្លាស់ប្តូរប្រេង និងតម្រងប្រេងយ៉ាងតិចម្តងរៀងរាល់ 12 ខែ ទោះបីជាម៉ោងប្រតិបត្តិការតិចជាងចន្លោះម៉ោងថែទាំដែលបានណែនាំក៏ដោយ។

**ចំណុះស្តាន់ដារប្រេងម៉ាស៊ូត** ប៉ះពាល់ដល់ចន្លោះម៉ោងថែទាំប្រេងម៉ាស៊ីន និងតម្រង។

- គួរប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្តាន់ដារតិចជាង 1000 មក្រ/គក្រ (1000 ភាគក្នុងមួយលាន) ។
- មុនពេលប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្តាន់ដារច្រើនជាង 5000 មក្រ/គក្រ (5000 ភាគក្នុងមួយលាន) កាត់បន្ថយចន្លោះពេលផ្លាស់ប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីន។
- កុំប្រើប្រេងម៉ាស៊ូតដែលមានចំណុះស្តាន់ដារធំជាង 10 000 មក្រ/គក្រ (10 000 ភាគក្នុងមួយលាន)។

**សំខាន់៖ ដើម្បីជៀសវាងការខូចខាតដល់ម៉ាស៊ីន៖**

- **កាត់បន្ថយចន្លោះម៉ោងថែទាំប្រេង និងតម្រងត្រឹម 50% នៅពេលប្រើប្រាស់ការរួមបញ្ចូលគ្នានៃជីវម៉ាស៊ូតលើសពី B20។ ការវិភាគប្រេងនឹងអនុញ្ញាតឱ្យមានចន្លោះសេវាកម្មយូរជាងនេះ។**
- **ប្រើប្រាស់តែប្រភេទប្រេងដែលបានអនុម័តប៉ុណ្ណោះ។**

**ប្រភេទប្រេងដែលបានអនុម័ត៖**

- “ពពួកប្រេង Plus-50” រួមមាន John Deere Plus-50™ II និង John Deere Plus-50™
- “ពពួកប្រេងផ្សេងទៀត” រួមមាន John Deere Torq-Gard™, API CK-4, API CJ-4, API CI-4 PLUS, API CI-4, ACEA E9, ACEA E7, ACEA E6, ACEA E5, និង ACEA E4។

**PowerTech™ ចន្លោះពេលប្តូរតម្រងនិងប្រេងម៉ាស៊ីន**

| **ចំណុះជាតិស្តាន់ដារបស់ប្រេងឥន្ធនៈ:** | ទាប់ជាង 1000 ម.ក/គ.ក (1000 ppm) |
|---|---|
| ប្រេង Plus-50 | 375 ម៉ោង |
| ពពួកប្រេងដទៃទៀត | 250 ម៉ោង |
| **ចំណុះជាតិស្តាន់ដារក្នុងប្រេងឥន្ធនៈ:** | 1000-2000 ម.ក/គ.ក (1000-2000 ppm) |
| ប្រេង Plus-50 | 300 ម៉ោង |
| ពពួកប្រេងដទៃទៀត | 200 ម៉ោង |
| **ចំណុះជាតិស្តាន់ដារក្នុងប្រេងឥន្ធនៈ:** | 2000-5000 ម.ក/គ.ក (2000-5000 ppm) |
| ប្រេង Plus-50 | 275 ម៉ោង |
| ពពួកប្រេងដទៃទៀត | 150 ម៉ោង |
| **ចំណុះជាតិស្តាន់ដារក្នុងប្រេងឥន្ធនៈ:** | 5000-10000 ម.ក/គ.ក (5000-10000 ppm) |
| ប្រេង Plus-50 | 187 ម៉ោង |
| ពពួកប្រេងដទៃទៀត | 125 ម៉ោង |
| ការវិភាគអំពីប្រេងពន្យារចន្លោះម៉ោងថែចាំរបស់ “ប្រេងផ្សេងទៀត” រហូតដល់ចំនួនអតិបរមាដែលមិនលើសពីចន្លោះម៉ោងថែចាំសម្រាប់ប្រេង Plus-50 ឡើយ។ | |

**សំខាន់៖ កុំពន្យាចន្លោះពេលផ្តល់សេវាថែទាំប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីនដល់រយៈពេល 375 ម៉ោងរហូតទាល់តែលក្ខខណ្ឌទាំងអស់ខាងក្រោមត្រូវបានឆ្លើយតប៖**

- **ការប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានបរិមាណស្តាន់ដារតិចជាង 1000 មីលីក្រាម/គីឡូក្រាម (1000 ppm) ។**
- **ការប្រើប្រាស់ប្រេង John Deere Plus-50™ II និង John Deere Plus-50™ ។**
- **ការប្រើប្រាស់តម្រងប្រេងដែលអនុញ្ញាតដោយ John Deere ។**

*Plus-50* គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*
*Torq-Gard* គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*

CO00263,0001D9F-KM-21MAY20-1/1

## ចន្លោះម៉ោងថែទាំប្រេងម៉ាស៊ូតសម្រាប់ការប្រើប្រាស់នៅរយៈកម្ពស់ខ្ពស់សម្រាប់ជាព័ត៌មានបន្ថែម

ដើម្បីជៀសវាងភាពចុះអន់ថយនៃប្រេងខ្លាំងពេក និងការខូចខាតជាសក្តានុពលចំពោះម៉ាស៊ីន ចូរកាត់បន្ថយចន្លោះម៉ោងថែទាំប្រេង និងតម្រងប្រេងមកត្រឹម 50% នៃតម្លៃដើមដែលត្រូវបានណែនាំ នៅពេលធ្វើប្រតិបត្តិការម៉ាស៊ីនដែលមានរយៈកម្ពស់លើស **1675 m (5500 ft)**។

ការវិភាគអំពីប្រេងអាចអនុញ្ញាតឲ្យមានចន្លោះម៉ោងថែទាំយូរជាងនេះ។

ប្រើប្រាស់តែប្រភេទប្រេងដែលបានអនុម័តប៉ុណ្ណោះ។

| ឧទាហរណ៍នៃម៉ោងដើម | ម៉ោងនៃរយៈកម្ពស់ខ្ពស់ដែលពាក់ព័ន្ធគ្នា |
|---|---|
| 125 | 60 |
| 150 | 75 |
| 175 | 85 |
| 200 | 100 |

| ឧទាហរណ៍នៃម៉ោងដើម | ម៉ោងនៃរយៈកម្ពស់ខ្ពស់ដែលពាក់ព័ន្ធគ្នា |
|---|---|
| 250 | 125 |
| 275 | 135 |
| 300 | 150 |
| 350 | 175 |
| 375 | 185 |
| 400 | 200 |
| 500 | 250 |

DX,ENOIL,SERV,HIALT-KM-11NOV14-1/1

## តម្រងប្រេងឥន្ធនៈ:

សារសំខាន់របស់ការត្រងប្រេងឥន្ធនៈ:មិនអាចត្រូវបានបញ្ជាក់ខ្លាំងពេកដោយប្រព័ន្ធប្រេងឥន្ធនៈទំនើបបានឡើយ។ ការរួមបញ្ចូលគ្នារវាងបទប្បញ្ញត្តិស្តីពីការបញ្ចេញផ្សែងដែលមានការរឹតត្បឹតកាន់តែខ្លាំងឡើង និងម៉ាស៊ីនដែលមានប្រសិទ្ធភាពកាន់តែខ្លាំងត្រូវការប្រព័ន្ធប្រេងឥន្ធនៈដើម្បីប្រតិបត្តិការក្នុងសម្ពាធកាន់តែខ្ពស់។ គេអាចទទួលបានសម្ពាធកាន់តែខ្ពស់តែនៅពេលដែលប្រើប្រាស់សមាសធាតុនៃការបញ្ចូលប្រេងឥន្ធនៈដែលមានគម្លាតជិតខ្លាំង។ គម្លាតនៃការផលិតជិតៗគ្នាទាំងនេះបានកាត់បន្ថយចំនួនកម្ទេចកម្ទី និងទឹកបានក្នុងបរិមាណច្រើន។

តម្រងប្រេងឥន្ធនៈម៉ាក John Deere ត្រូវបានរចនា និងផលិតឡើងសម្រាប់ម៉ាស៊ីន John Deere ជាពិសេស។

ដើម្បីការពារម៉ាស៊ីនពីកម្ទេចកម្ទី និងទឹក តែងតែផ្លាស់ប្តូរតម្រងប្រេងម៉ាស៊ីនដូចដែលបានបញ្ជាក់នៅក្នុងសៀវភៅណែនាំនេះ។

DX,FILT2-KM-14APR11-1/1

## តម្រងប្រេង

ការត្រងប្រេងឥន្ធនៈមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការធ្វើប្រតិបត្តិការត្រឹមត្រូវ និងប្រេងរំអិល។ តម្រងប្រេងម៉ាក John Deere ត្រូវបានរចនា និងផលិតឡើងសម្រាប់ការប្រើប្រាស់របស់ John Deere ជាពិសេស។

តម្រងប្រេង John Deere គោរពតាមលក្ខណៈពិសេសផ្នែកវិស្វកម្មសម្រាប់គុណភាពនៃព័ត៌មានអំពីតម្រង ការកំណត់អត្រាប្រសិទ្ធភាពរបស់តម្រង កម្លាំងរបស់ចំណងរវាងព័ត៌មានអំពីតម្រង និងកាប៊ីននៅខាងចុងសមាសធាតុ រយៈពេលមិនដំណើរការរបស់ធុងហ្គាស (ប្រសិនបើមាន) និងចំណុះសម្ពាធរបស់ហ្វីតតម្រង។ តម្រងប្រេងដែលមិនមែនម៉ាក John Deere អាចមិនបំពេញតាមលក្ខណៈពិសេសសំខាន់ៗរបស់ John Deere ទាំងនេះ។

តែងតែផ្លាស់ប្តូរតម្រងប្រេងជាទៀងទាត់ដូចត្រូវបានបញ្ជាក់នៅក្នុងសៀវភៅណែនាំនេះ។

DX,FILT1-KM-11APR11-1/1

## ទឹកស្អុំម៉ាស៊ូតម៉ាស៊ូត (ម៉ាស៊ូតដែលមានស៊ីឡាំងប្រភេទសើម)

ការមិនអនុវត្តតាមស្តង់ដារទឹកថ្នាំស្អុំម៉ាស៊ូតនិងចន្លោះពេលបង្ហូរអាចបណ្តាលឱ្យខូចម៉ាស៊ូតធ្ងន់ធ្ងរដែលអាចធ្វើឱ្យបាត់បង់ការធានា។ ការធានា ដែលរួមមានការធានារ៉ាប់រងលើការប់ភាយឧស្ម័នគឺមិនមែនជាលក្ខខណ្ឌចំពោះការប្រើពពួកទឹកថ្នាំស្អុំម៉ាស៊ូត គ្រឿងបន្លាស់ ឬសេវាកម្ម របស់ក្រុមហ៊ុន John Deere ឡើយ។

### ទឹកស្អុំម៉ាស៊ូតដែលគេនិយមប្រើ

គេនិយមប្រើទឹកស្អុំម៉ាស៊ូតដែលលាយជាមុនខាងក្រោមនេះ៖

- ទឹកស្អុំម៉ាស៊ូត **John Deere COOL-GARD™II**
- ទឹកស្អុំម៉ាស៊ូត **John Deere COOL-GARD II PG**

ទឹកស្អុំម៉ាស៊ូតដែលលាយជាមុន COOL_GARD II មានកំហាប់ផ្សេងៗជាមួយនឹងកម្រិតនៃការការពារការកកផ្សេងៗគ្នា ដូចដែលបានបង្ហាញក្នុងតារាងខាងក្រោម

| COOL-GARD II Pre-Mix | កម្រិតនៃការការពារការកក |
|---|---|
| COOL-GARD II 20/80 | -9°C (16°F) |
| COOL-GARD II 30/70 | -16°C (3°F) |
| COOL-GARD II 50/50 | -37°C (-34°F) |
| COOL-GARD II 55/45 | -45°C (-49°F) |
| COOL-GARD II PG 60/40 | -49°C (-56°F) |
| COOL-GARD II 60/40 | -52°C (-62°F) |

មិនមានទាំងអស់ទេនូវផលិតផលទឹកស្អុំម៉ាស៊ូតដែលលាយជាមុន COOL-GARD II ក្នុងប្រទេសនានា។

ប្រើទឹកស្អុំម៉ាស៊ូត COOL-GARD II PG នៅពេលដែលគេត្រូវការរូបមន្តសារធាតុធ្វើឱ្យត្រជាក់ដែលមិនពុល។

### ទឹកស្អុំត្រជាក់ផ្សេងៗតាមការណែនាំ

ទឹកស្អុំម៉ាស៊ូតខាងក្រោមក៏ត្រូវបានណែនាំឱ្យប្រើប្រាស់ផងដែរ៖

- ទឹកស្អុំម៉ាស៊ូត COOL-Gard II របស់ John Deere លាយជាល្បាយដែលមានកំហាប់ 40-60% ជាមួយបរិមាណទឹក

**សំខាន់៖ នៅពេលលាយកំហាប់ទឹកស្អុំម៉ាស៊ូតជាមួយទឹក កុំលាយកំហាប់ទឹកស្អុំម៉ាស៊ូតអោយតិចជាង 40% ឬលើសពី 60%។ ការលាយកំហាប់ទឹកស្អុំម៉ាស៊ូតតិចជាង 40% មិនអាចផ្តល់ឱ្យសារធាតុបន្ថែមជួយការពារពីច្រេះបានទេ។ ការលាយកំហាប់ទឹកស្អុំម៉ាស៊ូតលើសជាង 60% អាចបណ្តាលធ្វើឱ្យទឹកស្អុំម៉ាស៊ូតកក និងមានបញ្ហាដល់ប្រព័ន្ធបញ្ចុះកំដៅ។**

### ទឹកស្អុំម៉ាស៊ូតត្រជាក់ផ្សេងៗ

ទឹកស្អុំម៉ាស៊ូតផ្សេងទៀតប្រភេទអេទីឡែនគ្លីកូល និងប្រភេទប្រូពីឡែនគ្លីកូល អាចត្រូវបានប្រើប្រាស់ ប្រសិនបើវាបំពេញនូវលក្ខណៈបច្ចេកទេសដូចខាងក្រោម:

- ទឹកស្អុំម៉ាស៊ូតដែលលាយជាមុន ដែលបំពេញនូវលក្ខខណ្ឌចាំបាច់របស់ ASTM D6210
- ត្រូវបានផ្សំរួបមន្តជាមួយនឹងកញ្ចប់សារធាតុបន្ថែមដែលគ្មានសារធាតុនីត្រីត
- កំហាប់ទឹកស្អុំម៉ាស៊ូតដែលបំពេញនូវលក្ខខណ្ឌចាំបាច់របស់ ASTM6210 នៅក្នុងល្បាយដែលមានកំហាប់ 40-60% ជាមួយទឹក

ប្រសិនបើទឹកស្អុំម៉ាស៊ូតមិនបំពេញលក្ខណៈបច្ចេកទេសមួយនៃលក្ខណៈបច្ចេកទេសទាំងឡាយ សូមប្រើកំហាប់ទឹកស្អុំម៉ាស៊ូត ឬទឹកស្អុំម៉ាស៊ូតដែលលាយជាមុន ដែលមានលក្ខណៈរូប និងលក្ខណៈគីមី អប្បរមាដូចខាងក្រោម៖

- ផ្តល់ការការពារស្នាមខូងនៅលើទ្រនាប់ស៊ីឡាំងយោងទៅតាមវិធីធ្វើតេស្តស្នាមខូងឬ ការសិក្សាដ៏ឆាប់រហ័សរបស់ John Deere ដែលដំណើរការនៅសមត្ថភាពផ្តកស្មើ ឬលើស 60%
- ត្រូវបានផ្សំរួបមន្តជាមួយនឹងកញ្ចប់សារធាតុបន្ថែមដែលគ្មានសារធាតុនីត្រីត
- ត្រូវបានផ្សំរួបមន្តជាមួយនឹងកញ្ចប់សារធាតុបន្ថែមដែលគ្មានសារធាតុនីត្រីត
- ការពារលោហៈប្រព័ន្ធបន្តយកម្តៅ (ដែកស្ពិត សំលោហៈអាលុយមីញ៉ូម និងសំលោហៈស្ពាន់លាយស័ង្កសី ដូចជា ទង់ដែង) ពីការកាត់ស៊ី

### គុណភាពទឹក

គុណភាពទឹកមានសារៈសំខាន់ចំពោះការអនុវត្តការងាររបស់ប្រព័ន្ធបន្តយកម្តៅ។ គួរប្រើប្រាស់ទឹកចម្រាញ់បំបាត់អ៊ីយ៉ុងឬបំបាត់ជាតិខណ្ឌិច សម្រាប់លាយជាមួយកំហាប់ទឹកថ្នាំស្អុំម៉ាស៊ូតបាសអេទីឡែនគ្លីកុល និងប្រូពីឡែនគ្លីកុល។

### ចន្លោះពេលបង្ហូរទឹកស្អុំម៉ាស៊ូត

បង្ហូរ និងលាងប្រព័ន្ធបញ្ចុះកំដៅ និងចាក់បំពេញទឹកស្អុំម៉ាស៊ូតថ្មីចូល នៅក្នុងចន្លោះដែលបានកំណត់ ដែលប្រែប្រួលជាមួយនឹងទឹកស្អុំម៉ាស៊ូតដែលបានប្រើ។

នៅពេលដែលគេប្រើប្រាស់ទឹកស្អុំម៉ាស៊ូត COOL-GARD II ឬ COOL-GARD II PG ចន្លោះនៃពេលនៃការបង្ហូរចេញគឺមានរយៈពេល 6ឆ្នាំ ឬ6000ម៉ោងនៃដំណើរការ។

នៅពេលដែលគេប្រើប្រាស់ទឹកស្អុំម៉ាស៊ូតផ្សេងទៀតក្រៅពី COOL-GARD II ឬ COOL-GARD II PG ចន្លោះនៃពេលនៃការបង្ហូរចេញគឺមានរយៈពេល 2ឆ្នាំ ឬ2000ម៉ោងនៃដំណើរការ។[1]

**សំខាន់៖ កុំប្រើសារធាតុបន្ថែមសម្រាប់ភ្ជិតប្រព័ន្ធបន្តយកម្តៅ ឬសារធាតុប្រឆាំងនឹងការកក ដែលផ្តកសារធាតុបន្ថែមភ្ជិត។**

**កុំលាយទឹកស្អុំសអេទីឡែនគ្លីកុល និងប្រូពីឡែនគ្លីកុល។**

**កុំប្រើធាតុជាក់ដែលផ្តកសារធាតុនីត្រីត។**

*COOL-GARD* គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*

[1] ការវិភាគទឹកថ្នាំស្អុំម៉ាស៊ូតអាចពន្យារយៈពេលសេវាថែទាំ "ទឹកថ្នាំស្អុំម៉ាស៊ូត" ផ្សេងទៀតរហូតដល់កម្រិតអតិបរមាមិនលើសពីបរិមាណនៃទឹកថ្នាំស្អុំម៉ាស៊ូត *Cool-Gard II* ឡើយ។ ការវិភាគទឹកថ្នាំស្អុំម៉ាស៊ូតមានន័យថាការយកគំរូទឹកថ្នាំស្អុំម៉ាស៊ូតជាបន្តបន្ទាប់ក្នុងរយៈពេល *1000* ម៉ោងលើសពីចន្លោះសេវាកម្ម ធម្មតារហូតដល់ទិន្នន័យបង្ហាញថាបញ្ហានៃដីវិតទឹកថ្នាំស្អុំម៉ាស៊ូតដែលមានប្រយោជន៍ឬឈានដល់កម្រិតអតិបរិមានៃសេវាថែទាំទឹកថ្នាំស្អុំម៉ាស៊ូត *Cool Gardard*។

DX,COOL3-KM-25AUG20-1/1

## ប្រេងហ្គ្រាំង

ចាក់ប្រេងអ៊ីដ្រូលីកយន្តហោះ 10# ចូលក្នុងធុងស្តុកប្រេងហ្គ្រាំង។

CP00834,0008B2D-KM-11MAR21-1/1

## ប្រេងអ៊ីដ្រូលីក/អ៊ីដ្រូស្តាទិក

CP00834,0008B30-KM-26MAY21-1/2


ប្រើកម្រិតភាពស្អិតខាប់ដោយផ្អែកលើលំដាប់សីតុណ្ហភាពខ្យល់ដែលបានរំពឹងទុកនៅអំឡុងចន្លោះពេលនៃការផ្លាស់ប្តូរប្រេងម៉ាស៊ីនម្តងៗ។

គួរប្រើប្រេងម៉ាស៊ីនខាងក្រោមនេះ៖

- John Deere Hy-Gard™
- ភាពអន្ទិលទាប Hy-Gard™John Deere

ប្រេងផ្សេងៗទៀតអាចប្រើប្រាស់បាន ប្រសិនបើវាឆ្លើយតបនឹងចំណុចណាមួយខាងក្រោម៖

- John Deere Standard JDM J20C
- John Deere Standard JDM J20D




*Hy-Gard* គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*

CP00834,0008B30-KM-26MAY21-2/2

## ប្រេងប្រអប់ស្តីរ៉ូទ័រគ្រឿងបំបែក

ចាក់ប្រេង John Deere Hy-Gard™ ចូលក្នុងប្រអប់ស្តីរ៉ូទ័រគ្រឿងបំបែក។

*Hy-Gard* គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*

CP00834,0008B2F-KM-11MAR21-1/1

## ប្រេងស្តីកាត់បន្ថយល្បឿនស៊ីឡាំងជោកបែន

ចាក់ប្រេង MOBILITH SHC 007 Grease ចូលក្នុងស្តីបន្ថយល្បឿនស៊ីឡាំងជោកបែន។

CP00834,1666593452957-KM-24OCT22-1/1

## ប្រេងហ្គ្រែរ

**តទៅទំព័របន្ទាប់**

DX,GEOIL-KM-14APR11-1/2


ប្រើកម្រិតរំអិលលំដាប់សីតុណ្ហភាពខ្សល់ដែលបានរំពឹងទុកនៅអំឡុងចន្លោះពេលនៃការផ្លាស់ប្តូរប្រេងម៉ាស៊ីនម្តងៗ។

គួរប្រើប្រេងម៉ាស៊ីនខាងក្រោមនេះ៖

- ប្រេងម៉ាស៊ីនហ្គ្រែរ John Deere GL-5
- John Deere EXTREME-GARD™

ប្រេងផ្សេងៗទៀតអាចប្រើប្រាស់បាន ប្រសិនបើវាត្រូវនឹងតម្រូវការណាមួយខាងក្រោម៖

- ប្រភេទសេវាកម្ម API នៃ CF-5




កម្រិតរំអិលនៃប្រេងម៉ាស៊ីនសម្រាប់លំដាប់សីតុណ្ហភាពខ្សល់

*EXTREME-GARD* គឺជានិក្ខិត្តសញ្ញារបស់ *Deere & Company*

DX,GEOIL-KM-14APR11-2/2

## ប្រេងប្រអប់ស្តី

ប្រេងស្តី GI-5 80W/90 ប្រើនៅក្នុងទីតាំងដូចតទៅ៖

- ប្រអប់លេខប្រអប់ស្តី
- ដុំអូសទាញខាងចុង
- ភ្លៅអូសកង់ក្រោយ (ជម្រើស)
- គ្រឿងបញ្ជូនខាងចុងអូសកង់ក្រោយ (ជម្រើស)
- ប្រអប់ស្តីអូសកង់ខាងក្រោយ (ជម្រើស)

CP00834,1663051698078-KM-13SEP22-1/1

## ប្រេងពហុបំណង

គួរតែប្រើខ្លាញ់គោដូចតទៅនេះ៖

- ប្រេងរំអិលម៉ូលីដិនីមស៊ុលហ្វីដលីចូម

កំណត់ចំណាំ៖ សម្រាប់គ្រឿងចក្រច្រូតកាត់ដែលអូសដោយមេកានិក ចូរដាក់ប្រេង *Mobil XHP222* លើគ្រឿងខាងក្រោម *Posi-Torq*™។

CP00834,1660029171638-KM-09AUG22-1/1

## ការរក្សាទុកប្រេងរំអិល

ឧបករណ៍របស់អ្នកអាចប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពខ្ពស់តែនៅពេលណាដែលប្រើប្រាស់ប្រេងរំអិលស្អាតប៉ុណ្ណោះ។

ប្រើសម្ភារផ្គុកដែលស្អាតក្នុងការរក្សាទុកប្រេងរំអិលទាំងអស់។

រក្សាទុកប្រេងរំអិល និងសម្ភារផ្គុកនៅកន្លែងដែលត្រូវបានការពារពីធូលី សំណើម និងភាពកខ្វក់ផ្សេងៗ។ រក្សាទុកសម្ភារៈផ្គុកដោយដាក់ផ្ទៀងដើម្បីជៀសវាងការកកើតឡើងនៃទឹក និងធូលី។

ធ្វើឱ្យប្រាកដថា សម្ភារផ្គុកទាំងអស់ត្រូវមានគំនូសសម្គាល់ចំណុះរបស់វាត្រឹមត្រូវ។

សូមបោះចោលសម្ភារផ្គុកទាំងអស់ និងប្រេងរំអិលសំណល់ដែលអាចមានផ្គុកនៅក្នុងនោះឱ្យបានត្រឹមត្រូវ។

DX,LUBST-KM-11APR11-1/1

# ជំនួយក្នុងការច្រូតកាត់

## កំណត់ស្ថានភាពដំណាំ

តាមគោលការណ៍គឺត្រូវប្រមូលផលឱ្យបានលឿនតាមដែលអាចធ្វើទៅបាននៅពេលចំណុះសំណើមបានធ្លាក់ចុះដល់កម្រិតដែលអាចទទួលយកបាន។

ការឆាប់ប្រមូលផលបណ្តាលឱ្យបាត់បង់ទិន្នផល និងធ្លាក់ចុះនូវគុណភាព។ គ្រាប់ដែលមិនទាន់ទុំផ្តល់ទិន្នផលតិចជាង និងទម្ងន់ស្រាលជាង។ គ្រាប់ក៏ពិបាកក្នុងការបោកបែនជាងផងដែរ ដែលបណ្តាលខូចខាតដល់ការបោកបែន និងបោកបែនមិនបានពេញលេញ។

ការយឺតយ៉ាវក្នុងការប្រមូលផលបណ្តាលឱ្យបាត់បង់ដោយសារការរាយប៉ាយគ្រាប់ដំណាំ ដើមដំណាំរីង ដេកដួល និងថយចុះនូវទម្ងន់។ ការបាត់បង់ដោយសារការរាយប៉ាយកើតឡើងដោយសារគ្រាប់ងាយរលេះពេក។

CP00834,0008B43-KM-12MAR21-1/1

## កំណត់ការបាត់បង់គ្រាប់ធញ្ញជាតិ

ការបាត់បង់គ្រាប់បណ្តាលមកពីការលៃតម្រូវគ្រឿងចក្រច្រូតកាត់មិនត្រឹមត្រូវ។ ទោះបីជាលៃតម្រូវគ្រឿងចក្រឱ្យកាត់បោកបែន បំបែក និងសម្អាតគ្រាប់ធញ្ញជាតិដែលអាចទទួលយកបានក៏ដោយ ប្រតិបត្តិករគួរពិនិត្យមើលគ្រឿងចក្រច្រូតកាត់ម្តងម្កាលដើម្បីប្រាកដថាវានៅតែប្រតិបត្តិការត្រឹមត្រូវ។

### ប្រភពនៃបាត់បង់គ្រាប់ធញ្ញជាតិ

ការបាត់បង់ខ្លះបណ្តាលមកពីប្រតិបត្តិការមិនត្រឹមត្រូវ និងខ្លះទៀតបណ្តាលមកពីការលៃតម្រូវមិនបានត្រឹមត្រូវ។

ទាំងនេះជាប្រភពនៃការបាត់បង់ដែលប្រតិបត្តិករត្រូវតែកំណត់៖

- **ការបាត់បង់មុនពេលច្រូតកាត់**—ការបាត់បង់មុនពេលច្រូតកាត់គឺជាការបាត់បង់ដែលបានកើតឡើងនៅក្នុងស្រែមុននឹងច្រូតកាត់។ ដូចជាបើងដោយសារខ្យល់ ដើមរីងដំណាំធ្លាក់ ឬស្ថានភាពអាកាសធាតុ។
ប្រអប់កញ្ចែងគួរស្របគ្នានឹងស៊ីឡាំងបោកបែន។ ប្រអប់កញ្ចែងត្រូវបានលៃតម្រូវនៅរោងចក្រ។

ពិនិត្យមើលការពង្រាបប្រអប់កញ្ចែងឲ្យបានញឹកញាប់ ហើយលៃតម្រូវដោយមួលក្បាលឡោស៊ី (A និង B) នៅចំហៀងសងខាងតាមចាំបាច់។

កំណត់ចំណាំ៖


- លៃតម្រូវចន្លោះចូលដោយមួលក្បាលឡោស៊ី *(B)* នៅចំហៀងសងខាងគ្រឿងចក្រ។
- លៃតម្រូវចន្លោះចេះដោយមួលក្បាលឡោស៊ី *(A)* នៅចំហៀងសងខាងគ្រឿងចក្រ។

**A—ក្បាលឡោស៊ី (ប្រើ 2)** **B—ក្បាលឡោស៊ី (ប្រើ 2)**




YC21220—UN—21DEC22

បានបង្ហាញចំហៀងខាងឆ្វេងដៃគ្រឿងចក្រ



YC21221—UN—21DEC22

CP00834,1668908392880-KM-19NOV22-2/2

## ពិនិត្យ និងលៃតម្រូវគំណឹងខ្សែពានអូសប្រព័ន្ធបោកបែន

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញមុននឹងធ្វើការថែទាំនៅលើតម្រងប្រេងឥន្ធនៈ។**


CP00834,1668908732087-KM-19NOV22-1/2

ភ្ជាប់ប្រព័ន្ធបោកបែន វាស់ចម្ងាយ (X) រវាងផ្ទៃខ្ចៅលៃតម្រូវ (A) និងបង្គុំប្រដាប់ចង្អុល (D), ចម្ងាយគួរតែមានប្រវែងពី 23 ដល់ 27 ម.ម។

ប្រសិនបើចម្ងាយមិនស្ថិតនៅក្នុងកម្រិតដែលបានណែនាំទេ ចូរបន្ធូរក្បាលឡោស៊ីមានឡក់ (C) ហើយមួលខ្ចៅលៃតម្រូវដើម្បីលៃតម្រូវចម្ងាយ។ រឹតបន្តឹងឡោស៊ីមានឡក់បន្ទាប់ពីលៃតម្រូវរួច។

កំណត់ចំណាំ៖ មុននឹងលៃតម្រូវ ចូរប្រាកដថាប្រព័ន្ធបោកបែនត្រូវបានភ្ជាប់។

**A—វីសលៃតម្រូវ** **D—បង្គុំប្រដាប់ចង្អុល**
**B—វីស័រ** **X—ចម្ងាយ**
**C—ក្បាលឡោស៊ីមានឡក់ (ប្រើ 2)**




YC21222—UN—21DEC22

CP00834,1668908732087-KM-19NOV22-2/2

## លៃតម្រូវខ្សែពានអូសប្រព័ន្ធបោកបែន និងចន្លោះប្រដាប់នាំផ្លូវខ្សែពាន

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**


**តទៅទំព័របន្ទាប់**

CP00834,1668908774767-KM-19NOV22-1/2

ភ្ជាប់ប្រព័ន្ធបោកបែន ចន្លោះរវាងខ្សែពានអូស (B) និងប្រដាប់នាំផ្លូវខ្សែពាន (C) គួរតែមានប្រវែងពី 2 ដល់ 5 ម.ម។

លៃតម្រូវចន្លោះដោយមួយប៊ូឡុងបិគ្រាប់ (A)។ ពិនិត្យមើលចន្លោះឲ្យបានញឹកញាប់។

**A—ប៊ូឡុង (ប្រើ 3)**
**B—ខ្សែពានអូស**
**C—ប្រដាប់នាំផ្លូវខ្សែពាន**




YC21223—UN—21DEC22

CP00834,1668908774767-KM-19NOV22-2/2


## ពិនិត្យមើលការកកស្ទះស៊ីឡាំងបោកបែន

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1668908809681-KM-19NOV22-1/2

បន្ទូរក្បាលឡោស៊ីរីតដោយដៃ (A) នៅចំហៀងសងខាង ហូតចូលក្នុងរួមជាមួយគន្លឹះ ហើយដោះគម្របពិនិត្យ (B) ចេញដើម្បីពិនិត្យមើលការកកស្ទះ។

**A—ក្បាលឡោស៊ីរីតដោយដៃ (ប្រើ 2)**
**B—គម្របពិនិត្យ**




YC21224—UN—21DEC22

បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ

CP00834,1668908809681-KM-19NOV22-2/2

## សម្អាតការកកស្ទះស៊ីឡាំងបោកបែន

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

**តទៅទំព័របន្ទាប់**


**សំខាន់៖ មុននឹងសម្អាតការកកស្ទះ ចូរលៃតម្រូវចន្លោះប្រអប់កញ្ច្រែងទៅដល់តម្លៃអតិបរមា។**

CP00834,1668908846335-KM-19NOV22-1/2


បន្ធូរក្បាលឡោស៊ីរីតដោយដៃ (A) នៅចំហៀងសងខាង ហូតចូលក្នុងរួមជាមួយគន្លឹះ ហើយដោះគម្របពិនិត្យខាងមុខ (B) ចេញ ដើម្បីសម្អាតការកកស្ទះ។

ដោះគម្របពិនិត្យចំហៀង (C) នៅចំហៀងសងខាងចេញដើម្បីសម្អាតការកកស្ទះ។

**A—ក្បាលឡោស៊ីរីតដោយដៃ (ប្រើ 2)**
**B—គម្របពិនិត្យខាងមុខ**
**C—គម្របពិនិត្យចំហៀង (ប្រើ 2)**




បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ




បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ


CP00834,1668908846335-KM-19NOV22-2/2

## សម្អាតការកកស្ទះស៊ីឡាំងបោកបែនដោយបង្ខិលស៊ីឡាំងបោកបែនបញ្ច្រាស

CP00834,1668908892001-KM-19NOV22-1/3

1. ផ្តាច់ប្រព័ន្ធបោកបែន
2. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
3. បន្ធូរក្បាលឡោស៊ីរីតដោយដៃ (A និង D) នៅចំហៀងសងខាង ហូតចូលក្នុងរួមជាមួយគន្លឹះ ហើយដោះគម្របពិនិត្យ (B និង C) ចេញ។

**A—ក្បាលឡោស៊ីរីតដោយដៃ (ប្រើ 2)**
**B—គម្របពិនិត្យ**
**C—គម្របពិនិត្យ**
**D—ក្បាលឡោស៊ីរីតដោយដៃ (ប្រើ 2)**




បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ

**តទៅទំព័របន្ទាប់**

CP00834,1668908892001-KM-19NOV22-2/3


4.

**ស៊ីឡាំងបោកបែនដោយមិនបាច់កាត់បន្ថយស៊ីឡាំង៖** ប្តូរទិសដៅស៊ីឡាំងបោកបែនបញ្ច្រាស់ដោយការបង្វិលដុំ (E) ផ្តួយទៅនឹងទ្រនិចនាឡិកាដោយដែកគាស់ (F)។

**ស៊ីឡាំងបោកបែនដោយត្រូវបន្ថយស៊ីឡាំង៖** ប្តូរទិសដៅស៊ីឡាំងបោកបែនបញ្ច្រាស់ដោយការបង្វិលប៉ូលីដុំអូស (G) តាមទិសដៅទ្រនិចនាឡិកាដោយដែកគាស់ (H)។


កំណត់ចំណាំ៖ អាចប្រើដែកគាស់ដើម្បីជួយត្រឡប់ស៊ីឡាំងបោកបែន។

**E—ដុំកង**
**F—ដែកគាស់**
**G—ប៉ូលីអូស**
**H—ដែកគាស់**




YC21227—UN—21DEC22

ស៊ីឡាំងបោកបែន(ដែលមិនមានស្តីបន្ថយឡើនស៊ីឡាំងបោកបែនចំហៀងខាងស្តាំ)




YC21228—UN—21DEC22

CP00834,1668908892001-KM-19NOV22-3/3


## ប្តូរបារូស

កំណត់ចំណាំ៖ បារូសអាចប្តូរដោយមិនចាំបាច់ដោះស៊ីឡាំងបោកបែនឡើយ។

CP00834,1668909430430-KM-19NOV22-1/3

1. ផ្តាច់ប្រព័ន្ធបោកបែន។
2. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
3. បន្ធូរក្បាលឡោស៊ីរីតដោយដៃ (A) នៅចំហៀងសងខាង ហូតចូលក្នុងរួមជាមួយគន្លឹះ ហើយដោះគម្របពិនិត្យ (B) ចេញ។

**A—ក្បាលឡោស៊ីរីតដោយដៃ (ប្រើ 2)**
**B—គម្របពិនិត្យ**




YC21224—UN—21DEC22

បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ

**តទៅទំព័របន្ទាប់**


CP00834,1668909430430-KM-19NOV22-2/3

កំណត់ចំណាំ៖ ស៊ីឡាំងបោកបែនមានបំពាក់របារូសដែលមានធ្មេញខាងស្តាំ និងខាងឆ្វេងដែលដំឡើងជាជម្រើស។

4. ប្តូរបារូសដែលសឹករេចរឹ និងរបារូសបន្សីនៅចំហៀងម្ខាងទៀតនៃស៊ីឡាំងបោកបែនក្នុងពេលជាមួយគ្នា។

5. រឹតបន្តឹងប៊ូឡុងចាប់របារូស។

**សំខាន់៖ រឹតបន្តឹងប៊ូឡុងរបារូសដែលបានប្តូរឡើងវិញបន្ទាប់ពីដំណើរការបាន 10 ម៉ោងដំបូង។**




**C—របារូស**

CP00834,1668909430430-KM-19NOV22-3/3

## ប្តូរធ្មេញវែង

កំណត់ចំណាំ៖ ធ្មេញវែងអាចប្តូរដោយមិនចាំបាច់ដោះស៊ីឡាំងបោកបែនឡើយ។

CP00834,1668909576085-KM-19NOV22-1/3


1. ផ្តាច់ប្រព័ន្ធបោកបែន។

2. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។

3. បន្ធូរក្បាលឡោស៊ីរីតដោយដៃ (A) នៅចំហៀងសងខាង ហូតចូលក្នុងរួមជាមួយគន្លឹះ ហើយដោះគម្របពិនិត្យ (B) ចេញ។

**A—ក្បាលឡោស៊ីរីតដោយដៃ (ប្រើ 2)**

**B—គម្របពិនិត្យ**




បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ


CP00834,1668909576085-KM-19NOV22-2/3

**សំខាន់៖ យកចិត្តទុកដាក់ចំពោះទិសដៅធ្មេញវែងនៅពេលដំឡើងធ្មេញវែងថ្មី។**

4. ប្តូរធ្មេញវែងដែលសឹករេចរឹល ហើយរឹតបន្តឹងប៊ូឡុងភ្ជាប់ធ្មេញទាំងនោះ។

កំណត់ចំណាំ៖ អាចប្រើញញួរដើម្បីជួយប្តូរធ្មេញវែង។

**C—ធ្មេញវែង**




CP00834,1668909576085-KM-19NOV22-3/3

## រំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងផ្តល់សេវាថែទាំ

1. បិទកុងតាក់ផ្តាច់អាគុយ។


**ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

**តទៅទំព័របន្ទាប់**

CP00834,1668909769039-KM-19NOV22-1/7

2. ផ្តាច់តំណអគ្គិសនីពីអង្គញ្ញាណ (B)។
3. ផ្តាច់ចង្វាយខ្សែភ្លើង (A) ចេញពីគម្របក្រោយ។

**A—ចង្វាយខ្សែភ្លើង**
**B—អង្គញ្ញាណ**





ផ្តាច់តំណអគ្គិសនី

CP00834,1668909769039-KM-19NOV22-2/7

4. ដោះប៊ូឡុង (F) និងគម្របក្រោយ (C) ចេញ។
5. ដោះប៊ូឡុង និងគម្របក្រោយ (E) ចេញ។
6. ចូរដោះប៊ូឡុង និងដោះទម្រ (D)។


**C—គម្របខាងក្រោយ**
**D—ទម្រ**
**E—គម្របខាងក្រោយ**
**F—ប៊ូឡុង (ប្រើ 2)**




CP00834,1668909769039-KM-19NOV22-3/7

7. ដោះប៊ូឡុង (G) និងអង្គបង្វែរ (H) ចេញ។

**G—ប៊ូឡុង (ប្រើ 4)**
**H—អង្គបង្វែរ**





**តទៅទំព័របន្ទាប់**

CP00834,1668909769039-KM-19NOV22-4/7

8. ដោះប៊ូឡុង (I) និងតំណសកល (J)។
9. ដោះប៊ូឡុង (K) នៅចំហៀងសងខាង។

**I—ប៊ូឡុង (ប្រើ 3)**
**J—តំណសកល**
**K—ប៊ូឡុង (ប្រើ 4)**





ដោះតំណសកល

CP00834,1668909769039-KM-19NOV22-5/7

10. ដោះប៊ូឡុង (L និង M) ចេញពីចំហៀងទាំងសងខាងគ្រឿងចក្រ។

**L—ប៊ូឡុង (ប្រើ 2)**
**M—ប៊ូឡុង (ប្រើ 2)**




បានបង្ហាញចំហៀងខាងស្តាំគ្រឿងចក្រ

CP00834,1668909769039-KM-19NOV22-6/7


11. បើកទ្វារច្រកចូលខាងក្រោយ (N) នៅលើគ្រឿងចក្រ។
12. ដោះប៊ូឡុង (O) និងបន្ទះ (P) នៅចំហៀងសងខាង។
13. ដោះប៊ូឡុង (S) ចេញ។
14. ស៊កដែកគាស់ចំនួនពីរនៅក្នុងបំពង់ (R) ពីរ។

**⚠ ប្រយ័ត្ន៖ គ្រឿងបំបែកមានទម្ងន់ធ្ងន់។ ទ្រគ្រឿងបំបែកនៅពេលវាស្ថិតនៅត្រង់ទីតាំងផ្តល់សេវា។**

15. គាស់ដែកគាស់ដើម្បីរំកិលគ្រឿងបំបែកចេញទៅកាន់ទីតាំងផ្តល់សេវា។

កំណត់ចំណាំ៖ រមៀលគ្រឿងបំបែកចេញរហូតទាល់តែវាប៉ះនឹងទំនប់។

**N—ទ្វារច្រកចូលផ្នែកខាងក្រោយ**
**O—ប៊ូឡុង (ប្រើ 6)**
**P—បន្ទះ (ប្រើ 2)**
**Q—ដង**
**R—បំពង់ (ប្រើ 2)**
**S—ប៊ូឡុង**




CP00834,1668909769039-KM-19NOV22-7/7

## ត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារ។

**តទៅទំព័របន្ទាប់**


CP00834,1668911293604-KM-19NOV22-1/8

1. ស៊កដែកគាស៊ចំនួនពីរនៅក្នុងបំពង់ (A) ចំនួនពីរ។
2. គាស់ដែកគាស់ដើម្បីរំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារ។
3. ដំឡើងឧបករណ៍ពិសេស (C និង D)។


កំណត់ចំណាំ៖ រំកិលម៉ូឌុលគ្រឿងបំបែកដើម្បីឲ្យស៊ីគ្នាជាមួយដងទាំងពីរតាមចាំបាច់។

4. ចាប់ប៊ូឡុង (B) ហើយរឹតបន្តឹង។

**A—បំពង់ (ប្រើ 2)**
**B—ប៊ូឡុង (ប្រើ 3)**
**C—ឧបករណ៍ពិសេស**
**D—ឧបករណ៍ពិសេស**



YC20565—UN—02SEP22




YC20566—UN—02SEP22

CP00834,1668911293604-KM-19NOV22-2/8

5. ចាប់ប៊ូឡុង (I) ហើយរឹតបន្តឹងវា។
6. ដំឡើងបន្ទះ (G) ហើយរឹតបន្តឹងប៊ូឡុង (F) នៅចំហៀងសងខាង។
7. បិទទ្វារច្រកចូលផ្នែកខាងក្រោយ (E)។

**E—ទ្វារច្រកចូលផ្នែកខាងក្រោយ**
**F—ប៊ូឡុង (ប្រើ 6)**
**G—បន្ទះ (ប្រើ 2)**
**H—ដង**
**I—ប៊ូឡុង**



YC21236—UN—21DEC22


**តទៅទំព័របន្ទាប់**

CP00834,1668911293604-KM-19NOV22-3/8

8. ចាប់ប៊ូឡុង (J និង K) ហើយរឹតបន្តឹងពួកវានៅចំហៀងសងខាងគ្រឿងចក្រ។

**J—ប៊ូឡុង (ប្រើ 2)**

**K—ប៊ូឡុង (ប្រើ 2)**




YC21237—UN—21DEC22


CP00834,1668911293604-KM-19NOV22-4/8

9. ចាប់ប៊ូឡុង (N) ហើយរឹតបន្តឹងពួកវានៅចំហៀងសងខាង។
10. ដោះប៊ូឡុងទាំងបីគ្រាប់ និងឧបករណ៍ពិសេស។
11. ដំឡើងតំណសកល (M)។
12. ចាប់ប៊ូឡុង (L) ហើយរឹតបន្តឹង។

**L—ប៊ូឡុង (ប្រើ 3)**

**M—តំណសកល**

**N—ប៊ូឡុង (ប្រើ 4)**





YC21238—UN—21DEC22

CP00834,1668911293604-KM-19NOV22-5/8

13. ដំឡើងអង្គបង្វែរ (P) ហើយរឹតបន្តឹងប៊ូឡុង (O)។

**O—ប៊ូឡុង (ប្រើ 4)**

**P—អង្គបង្វែរ**





YC21239—UN—21DEC22

**តទៅទំព័របន្ទាប់**

CP00834,1668911293604-KM-19NOV22-6/8

14. ដំឡើងទម្រ (R) ដោយប្រើប៊ូឡុង។
15. ដំឡើងគម្របក្រោយ (S និង Q) ដោយប្រើប៊ូឡុង។

**Q—គម្របខាងក្រោយ**
**R—ទម្រ**
**S—គម្របខាងក្រោយ**
**T—ប៊ូឡុង (ប្រើ 2)**





YC21240—UN—21DEC22

CP00834,1668911293604-KM-19NOV22-7/8

16. តភ្ជាប់ចង្វាយខ្សែភ្លើង។ (U) ទៅកាន់គម្របខាងក្រោយ។
17. ភ្ជាប់តំណអគ្គិសនីទៅកាន់អង្គញ្ជាណ (B)។

**U—ចង្វាយខ្សែភ្លើង**
**V—អង្គញ្ជាណ**




YC21241—UN—21DEC22

CP00834,1668911293604-KM-19NOV22-8/8

## សម្អាតការកកស្ទះគ្រឿងបំបែក


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

1. បិទកុងតាក់ផ្តាច់អាគុយ។
2. រំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងសេវាថែទាំ។ (អានអំពីការរំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងផ្តល់សេវាថែទាំនៅក្នុងផ្នែកនេះ។)

**តទៅទំព័របន្ទាប់**

CP00834,1668911397460-KM-19NOV22-1/2

3. សម្អាតការកកស្ទះ។
4. ត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារ។ (អានអំពីការត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារនៅក្នុងផ្នែកនេះ។)



YC21242—UN—21DEC22

CP00834,1668911397460-KM-19NOV22-2/2

## សម្អាតស្មៀតគ្រឿងបំបែក

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

**ដើម្បីបង្ការការរងរបួសផ្ទាល់ខ្លួន ត្រូវដឹងអំពីដីនិងកម្ទេចដែលធ្លាក់ នៅពេលដោះបន្ទះចេញ។**


CP00834,1668912793249-KM-19NOV22-1/2

ពិនិត្យមើលស្មៀតគ្រឿងបំបែកឱ្យបានទៀងទាត់។ សម្អាតការកកស្ទះតាមចាំបាច់។

ដោះក្បាលឡោស៊ីស្លាប (B) និងបន្ទះ (A) ចេញដើម្បីសម្អាតការកកស្ទះ។

**A—បន្ទះ (ប្រើ 2)**

**B—ក្បាលឡោស៊ីស្លាប (ប្រើ 8)**




YC21243—UN—21DEC22

CP00834,1668912793249-KM-19NOV22-2/2

## លៃតម្រូវតំណឹងខ្សែពានអូសគ្រឿងបំបែក

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**


**តទៅទំព័របន្ទាប់**

CP00834,1668913080270-KM-19NOV22-1/2

ខ្សែពានអូសគ្រឿងបំបែក (B) ត្រូវបានបន្តឹងដោយស្វ័យប្រវត្តិដោយប្រដាប់បន្តឹងខ្សែពាន (A) តាមរយៈសកម្មភាពរបស់រីស័រ (C)។

លៃតម្រូវប្រវែងរីស័រទៅកាន់ប្រវែងពី 130 ដល់ 160 ម.ម ដោយមួលក្បាលឡោស៊ី (D)។

**A—ប្រដាប់បន្តឹងខ្សែពាន**
**B—ខ្សែពានអូស**
**C—រីស័រ**
**D—ក្បាលឡោស៊ី (ប្រើ 2)**



YC21245—UN—21DEC22

CP00834,1668913080270-KM-19NOV22-2/2

## ប្តូរគ្រឿងសម្រាប់គ្រឿងបំបែក (គ្រឿងបំបែកដែលមានធ្មេញបែបបំពង់)

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

1. បិទកុងតាក់ផ្តាច់អាគុយ។
2. រំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងសេវាថែទាំ។ (អានអំពីការរំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងផ្តល់សេវាថែទាំនៅក្នុងផ្នែកនេះ។)

CP00834,1669007170927-KM-20NOV22-1/2


3. ប្តូរធ្មេញដែលសឹក (A) និងប្រដាប់ញែកលំហូរ (B) តាមចាំបាច់។

កំណត់ចំណាំ៖ ដោះគម្របខាងលើគ្រឿងបំបែកចេញតាមចាំបាច់។

កំណត់ចំណាំ៖ ដើម្បីឲ្យមានលំនឹង ចូរប្តូរគ្រឿងសម្រាប់គ្រឿងបំបែកម្ខាងទៀតក្នុងពេលជាមួយគ្នា។

4. ត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារ។ (អានអំពីការត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារនៅក្នុងផ្នែកនេះ។)

**A—ធ្មេញសម**
**B—ប្រដាប់ញែកលំហូរ**



YC21244—UN—21DEC22

គ្រឿងបំបែកដែលមានធ្មេញបែបបំពង់

CP00834,1669007170927-KM-20NOV22-2/2

## ប្តូរបន្ទះដែលសឹក (គ្រឿងបំបែកមានធ្មេញបែបទ្រុង)

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

1. បិទកុងតាក់ផ្តាច់អាគុយ។
2. រំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងសេវាថែទាំ។ (អានអំពីការរំកិលម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងផ្តល់សេវាថែទាំនៅក្នុងផ្នែកនេះ។)

**តទៅទំព័របន្ទាប់**

CP00834,1669007464510-KM-20NOV22-1/2


3. ដោះប៊ូឡុង (A) ចេញ ។
4. ប្តូរបន្ទះដែលសឹក (B) នៅពេលវាសឹកខ្លាំង។

កំណត់ចំណាំ៖ ដោះគម្របខាងលើគ្រឿងបំបែកចេញតាមចាំបាច់។

5. ត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារ។ (អានអំពីការត្រឡប់ម៉ូឌុលគ្រឿងបំបែកទៅកាន់ទីតាំងបំពេញការងារនៅក្នុងផ្នែកនេះ។)

**A—ប៊ូឡុង (ប្រើ 4)**

**B—បន្ទះការពារសំណឹក**




គ្រឿងបំបែកដែលមានធ្មេញបែបទ្រុង

CP00834,1669007464510-KM-20NOV22-2/2

# ការថែទាំប្រព័ន្ធសម្អាតតាមចាំបាច់

## លៃតម្រូវតំណឹងខ្សែពានអូសប្រព័ន្ធសម្អាត


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1668856357856-KM-19NOV22-1/2

ខ្សែពានអូស (A) ត្រូវបានបន្តឹងដោយស្វ័យប្រវត្តិដោយប្រដាប់បន្តឹងខ្សែពាន (B) តាមរយៈសកម្មភាពរបស់រីស័រ (C)។

លៃតម្រូវប្រវែងរីស័រ 75 ម.ម។

**A—ខ្សែពានអូស**
**B—ប្រដាប់បន្តឹងខ្សែពាន**
**C—រីស័រ**
**D—ប៉ូលីអូស**




YC21214—UN—21DEC22

CP00834,1668856357856-KM-19NOV22-2/2

## លៃតម្រូវតំណឹងច្រវាក់អូសស្បែកជើងសម្អាត


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1668856336170-KM-19NOV22-1/2

ដុំអូសច្រវាក់ស្បែកជើងសម្អាតត្រូវបានបន្តឹងដោយស្វ័យប្រវត្តិដោយប្រដាប់បន្តឹងខ្សែពាន (E) តាមរយៈសកម្មភាពរបស់រីស័រ (A)។

លៃតម្រូវប្រវែងរីស័រដោយមួលក្បាលឡោស៊ុ (C និង D) ដើម្បីកាត់បន្ថយផលប៉ះពាល់លើយន្តការលៃតម្រូវនៅក្នុងលក្ខខណ្ឌបំពេញការងារជាអតិបរមា។

**A—រីស័រ**
**B—ទ្រនាប់កៅស៊ូ**
**C—ក្បាលឡោស៊ុ**
**D—ក្បាលឡោស៊ុ**
**E—ប្រដាប់បន្តឹងខ្សែពាន**




YC21215—UN—21DEC22

CP00834,1668856336170-KM-19NOV22-2/2

## លៃតម្រូវការអូសកង្ហារសម្អាត

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**


**តទៅទំព័របន្ទាប់**

CP00834,1668856370296-KM-19NOV22-1/2

រឹតបន្តឹងប៊ូឡុងទាំងបី (D) ដើម្បីបង្កើតទំហំ (X) ពី 103 ដល់ 105 ម.ម នៅពេលប៉ូលី (B និង C) ត្រូវបានបិទទាំងស្រុង។

កំណត់ចំណាំ៖ វាស់ទំហំពីផ្នែខាងក្រៅប្រដាប់ទប់រឺស័រ *(A)* ទៅដល់ផ្នែខាងក្រៅប៉ូលី *(B)*។

**A—ប្រដាប់ទប់រឺស័រ**
**B—ប៉ូលី**
**C—ប៉ូលី**
**D—ប៊ូឡុង (ប្រើ 3)**
**X—ទំហំ**




YC21216—UN—21DEC22


CP00834,1668856370296-KM-19NOV22-2/2

## ប្តូរសម្រាបកៅស៊ូ

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

កំណត់ចំណាំ៖ ប្តូរសម្រាបកៅស៊ូម្ខាងទៀតនៅពេលប្តូរសម្រាបកៅស៊ូដែលសឹក ឬបាក់។

CP00834,1668856740209-KM-19NOV22-1/2




YC21217—UN—21DEC22

សម្រាបកៅស៊ូ (បានបង្ហាញចំហៀងខាងឆ្វេងគ្រឿងចក្រ)

**A—ដំបងស្បែកជើងសម្អាត**
**B—ប្រដាប់រវៃ**
**1—សម្រាបកៅស៊ូ**
**2—សម្រាបកៅស៊ូ**
**3—សម្រាបកៅស៊ូ**
**4—សម្រាបកៅស៊ូ**
**5—សម្រាបកៅស៊ូ**
**6—សម្រាបកៅស៊ូ**
**7—សម្រាបកៅស៊ូ**
**8—សម្រាបកៅស៊ូ**
**9—សម្រាបកៅស៊ូ**
**10—សម្រាបកៅស៊ូ**
**11—សម្រាបកៅស៊ូ**
**12—សម្រាបកៅស៊ូ**
**13—សម្រាបកៅស៊ូ**

បន្ទាប់ពីប្តូរសម្រាបកៅស៊ូនៅលើដំបងស្បែកជើងសម្អាត (A) និងប្រដាប់ព្យួរ ចូរត្រឡប់ប៉ូលីអូសចម្បងដោយដៃរហូតទាល់តែបន្ទាត់កណ្តាលតាមដំបងស្បែកជើងបង្កើតបានមុំ 90° ជាមួយបន្ទាត់ដែលភ្ជាប់ដុំដងស្តួល និងចំណុចកណ្តាលនៃប្រដាប់រវៃ (B), បន្ទាប់មករឹតបន្តឹងក្បាលឡោស៊ុទាំងអស់។

អនុវត្តតាមលំដាប់ (1 ដល់ 13) ដើម្បីប្តូរសម្រាបកៅស៊ូទាំងអស់។

CP00834,1668856740209-KM-19NOV22-2/2

# ការថែទាំប្រព័ន្ធបួងទម្លាក់ និងប្រដាប់យោងតាមចាំបាច់

## លៃតម្រូវតំណឹងខ្សែពានប្រដាប់យោងគ្រាប់ធញ្ញជាតិ


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1668914195212-KM-19NOV22-1/2

ខ្សែពានអូស (B) ត្រូវបានបន្តឹងដោយស្វ័យប្រវត្តិដោយប្រដាប់បន្តឹងខ្សែពាន (C) តាមរយៈសកម្មភាពរបស់រីស័រ (D)។

លៃតម្រូវប្រវែងរីស័រពី 79 ដល់ 81 ម.ម។

**A—ប្រដាប់យោងគ្រាប់ធញ្ញជាតិ**
**B—ខ្សែពានអូស**
**C—ប្រដាប់បន្តឹងខ្សែពាន**
**D—រីស័រ**




YC21246—UN—21DEC22

CP00834,1668914195212-KM-19NOV22-2/2


## លៃតម្រូវតំណឹងច្រវាក់អូសប្រដាប់យោងគ្រាប់ស្អក

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1668914256573-KM-19NOV22-1/2

បន្ទរក្បាលឡោស៊ី (A), រំកិលប្រដាប់បន្តឹងខ្សែពាន (B) ឡើងលើដើម្បីបន្តឹងច្រវាក់អូស (D)។ រឹតបន្តឹងឡោស៊ី បន្ទាប់ពីលៃតម្រូវរួច។

**A—ក្បាលឡោស៊ី**
**B—ប្រដាប់បន្តឹងខ្សែពាន**
**C—បន្ទាបនងប្រដាប់បួងគ្រាប់ស្អក**
**D—ច្រវាក់អូស**
**E—បន្ទាបនងប្រដាប់បួងគ្រាប់ធញ្ញជាតិ**




YC21247—UN—21DEC22

CP00834,1668914256573-KM-19NOV22-2/2

## ពិនិត្យមើលតំណឹងច្រវាក់គ្រឿងបញ្ជូនប្រដាប់យោង


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។ សំខាន់៖ ពិនិត្យមើលចន្លោះរៀបរាល់ថ្ងៃ។**

**តទៅទំព័របន្ទាប់**

CP00834,1668914306285-KM-19NOV22-1/2

នៅពេលច្រវាក់គ្រឿងបញ្ជូនប្រដាប់យោងតឹង អាចរំកិលតំណច្រវាក់ដោយដៃទៅឆ្វេង និងស្តាំនៅលើកង់ច្រវាក់។

ជាធម្មតា តំណច្រវាក់ទីមួយនៅក្រោយកង់ច្រវាក់អាចលើកបានពី 6 ដល់ 10 ម.ម។ លៃតម្រូវភាពតឹងច្រវាក់គ្រឿងបញ្ជូនប្រដាប់យោងតាមចាំបាច់។




CP00834,1668914306285-KM-19NOV22-2/2

## លៃតម្រូវតំណឹងច្រវាក់គ្រឿងបញ្ជូនប្រដាប់យោងគ្រាប់ធញ្ញជាតិ


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

កំណត់ចំណាំ៖ ធ្វើការលៃតម្រូវនៅចំហៀងសងខាងក្នុងពេលជាមួយគ្នា។

CP00834,1669008221194-KM-21NOV22-1/2

1. បន្ធូរប្រដាប់បន្តឹង (C) ដើម្បីបន្ធូរច្រវាក់អូស (F)។
2. បន្ធូរក្បាលឡោស៊ី (D) ដើម្បីលៃតម្រូវទីតាំងសម្បកបាដាង (E) ដោយមួលក្បាលឡោស៊ី (B) នៅចំហៀងសងខាង។
3. រឹតបន្តឹងក្បាលឡោស៊ី (B និង D) ហើយពិនិត្យមើលតំណឹងច្រវាក់គ្រឿងបញ្ជូន។
4. បន្តឹងច្រវាក់អូស និងរឹតបន្តឹងប្រដាប់បន្តឹង (C)។

**A—ប៊ូឡុង (ប្រើ 2)**
**B—ក្បាលឡោស៊ី (ប្រើ 6)**
**C—ប្រដាប់បន្តឹងខ្សែពាន**
**D—ឡោស៊ី (ប្រើ 4)**
**E—សម្បកបាដាង (ប្រើ 2)**
**F—ច្រវាក់អូស**




CP00834,1669008221194-KM-21NOV22-2/2

## លៃតម្រូវតំណឹងច្រវាក់គ្រឿងបញ្ជូនប្រដាប់យោងគ្រាប់ស្ពក

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**


កំណត់ចំណាំ៖ ធ្វើការលៃតម្រូវនៅចំហៀងសងខាងក្នុងពេលជាមួយគ្នា។

**តទៅទំព័របន្ទាប់**

CP00834,1669008791256-KM-21NOV22-1/2

1. បន្ទរក្បាលឡោស៊ុ (D) នៅលើប្រដាប់បន្តឹង (E) ដើម្បីបន្ទរច្រវាក់អូស (F)។
2. បន្ទរក្បាលឡោស៊ុ (G) ដើម្បីលៃតម្រូវទីតាំងសម្បកបាដាង (A) ដោយមួលក្បាលឡោស៊ុ (B) នៅចំហៀងសងខាង។
3. រឹតបន្តឹងក្បាលឡោស៊ុ (B និង G) ហើយពិនិត្យមើលតំណឹងច្រវាក់គ្រឿងបញ្ជូន។
4. រឹតបន្តឹងច្រវាក់ និងរឹតបន្តឹងក្បាលឡោស៊ុ (D)។

**A—សម្បកបាដាង (ប្រើ 2)**
**B—ក្បាលឡោស៊ុ (ប្រើ 6)**
**C—ប៊ូឡុង (ប្រើ 2)**
**D—ក្បាលឡោស៊ុ**
**E—ប្រដាប់បន្តឹងខ្សែពាន**
**F—ច្រវាក់អូស**
**G—ក្បាលឡោស៊ុ (ប្រើ 4)**




ផ្នែកខាងក្រៅប្រដាប់យោងគ្រាប់ស្កក

CP00834,1669008791256-KM-21NOV22-2/2


## លៃតម្រូវតំណឹងច្រវាក់អូសប្រដាប់បួងពង្រាបគ្រាប់ធញ្ញជាតិ

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1669008868397-KM-21NOV22-1/2

បន្ទរក្បាលឡោស៊ុ (B) នៅលើប្រដាប់បន្តឹង (A), រឹតបន្តឹងច្រវាក់អូស (C), ហើយរឹតបន្តឹងក្បាលឡោស៊ុ។

**A—ប្រដាប់បន្តឹងខ្សែពាន**
**B—ក្បាលឡោស៊ុ**
**C—ច្រវាក់អូស**




CP00834,1669008868397-KM-21NOV22-2/2

## លៃតម្រូវតំណឹងច្រវាក់អូសប្រដាប់បួងគ្រាប់ស្កកខាងលើ


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

**តទៅទំព័របន្ទាប់**

CP00834,1669009405434-KM-21NOV22-1/2

បន្ទរក្បាលឡោស៊ី (A) នៅលើប្រដាប់បន្តឹង (B), រឺតបន្តឹងច្រវាក់អូស (C), ហើយរឺតបន្តឹងក្បាលឡោស៊ី។

**A—ក្បាលឡោស៊ី**
**B—ប្រដាប់បន្តឹងខ្សែពាន**
**C—ច្រវាក់អូស**




CP00834,1669009405434-KM-21NOV22-2/2

## សម្អាតប្រដាប់យោង


**ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1669009889101-KM-21NOV22-1/2

មុននឹងប្រតិបត្តិការគ្រឿងចក្រជារៀងរាល់ថ្ងៃ ឬប្តូរដំណាំប្រមូលផល ចូរសម្អាតប្រដាប់យោង។

បើកទ្វារប្រដាប់យោងគ្រាប់ធញ្ញជាតិ (B) និងទ្វារប្រដាប់យោងគ្រាប់ស្កក (D) ដោយរំកិលដង (A និង C)។

**A—ដង**
**B—ទ្វារប្រដាប់យោងគ្រាប់ធញ្ញជាតិ**
**C—ដង**
**D—ទ្វារប្រដាប់យោងគ្រាប់ស្កក**




CP00834,1669009889101-KM-21NOV22-2/2

## សម្អាតប្រដាប់បួងគ្រាប់ធញ្ញជាតិនិងគ្រាប់ស្កកខាងក្រោម

**ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**


**តទៅទំព័របន្ទាប់**

CP00834,1669009982875-KM-21NOV22-1/2

បន្ទាប់ពីដំណើរការគ្រឿងចក្រមួយរយៈពេលមក ឬដំណាំប្រមូលផលប្តូរ ចូរសម្អាតប្រដាប់បួងខាងក្រោម។

ដោះក្បាលឡោស៊ី (B) និងតង្កៀបទប់ (A), បើកគម្របប្រដាប់បួង (E) ដើម្បីសម្អាតប្រដាប់បួងគ្រាប់ស្កក (D) និងប្រដាប់បួងគ្រាប់ធញ្ញជាតិ (C)។

**A—កន្លាស់ខ្ចាស់ទប់គម្រប (ប្រើ 2)**
**B—ក្បាលឡោស៊ី (ប្រើ 2)**
**C—ប្រដាប់បួងគ្រាប់ធញ្ញជាតិ**
**D—ប្រដាប់បួងគ្រាប់ស្កក**
**E—គម្របប្រដាប់បួង (ប្រើ 2)**



YC8552—UN—24APR15

CP00834,1669009982875-KM-21NOV22-2/2

## លៃតម្រូវខ្សែពានអូសប្រព័ន្ធបួងទម្លាក់ និងចន្លោះប្រដាប់នាំផ្លូវខ្សែពាន


**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1669010268088-KM-21NOV22-1/2

នៅពេលភ្ជាប់ប្រព័ន្ធបួងទម្លាក់ ចន្លោះរវាងខ្សែពានអូស (A) ប្រដាប់នាំផ្លូវខ្សែពាន (C) គួរមានប្រវែងពី 3 ដល់ 5 ម.ម (0.12 ដល់ 0.20 អ៊ីញ)។

ប្រសិនបើតម្លៃចន្លោះមិនស្ថិតនៅក្នុងកម្រិតណែនាំទេ ចូរបន្ធូរក្បាលឡោស៊ី (B) និងលៃតម្រូវប្រដាប់នាំផ្លូវខ្សែពាន។ រឹតបន្តឹងក្បាលឡោស៊ីក្រោយពីលៃតម្រូវរួច។

**A—ខ្សែពានអូស**
**B—ក្បាលឡោស៊ី (ប្រើ 2)**
**C—ប្រដាប់នាំផ្លូវខ្សែពាន**



YC21293—UN—22NOV22

CP00834,1669010268088-KM-21NOV22-2/2


## លៃតម្រូវតំណឹងច្រវាក់អូសប្រដាប់បួងខ្វែង/ប្រដាប់រុញទម្លាក់

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1669011003707-KM-21NOV22-1/2

បន្ធូរក្បាលឡោស៊ី (A និង C), រឹតបន្តឹងច្រវាក់អូស ហើយរឹតបន្តឹងក្បាលឡោស៊ី។

**A—ក្បាលឡោស៊ី**
**B—ប្រដាប់បន្តឹងខ្សែពាន**
**C—ក្បាលឡោស៊ី**
**D—ប្រដាប់បន្តឹងខ្សែពាន**



YC21295—UN—21DEC22

CP00834,1669011003707-KM-21NOV22-2/2


## លៃតម្រូវតំណឹងច្រវាក់អូសប្រដាប់បួងទម្លាក់

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**


CP00834,1669011322503-KM-21NOV22-1/2

1. ដោះប៊ូឡុង (A) និងគម្រប (B) ចេញ។
2. បន្ធូរក្បាលឡោស៊ី (C និង D), រឹតបន្តឹងច្រវាក់អូស ហើយរឹតបន្តឹងក្បាលឡោស៊ី។

**A—ប៊ូឡុង (ប្រើ 2)**
**B—គម្រប**
**C—ក្បាលឡោស៊ី (ប្រើ 3)**
**D—ក្បាលឡោស៊ី (ប្រើ 2)**




YC10851—UN—08DEC16




YC21296—UN—21DEC22

CP00834,1669011322503-KM-21NOV22-2/2

## ប្តូរប៊ូឡុងមួលផ្តាច់ដុំអូសប្រដាប់បួងទម្លាក់គ្រាប់

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1669010796871-KM-21NOV22-1/2


ប៊ូឡុងមួលផ្តាច់ (A) ការពារប្រព័ន្ធទម្លាក់។

ប្រើតែប៊ូឡុងមួលផ្តាច់របស់ John Deere ប៉ុណ្ណោះ ចូរទាក់ទងអ្នកចែកចាយ John Deere ដែលទទួលសិទ្ធដើម្បីទិញប៊ូឡុងមួលផ្តាច់។

**លក្ខណៈបច្ចេកទេស**

| | |
|---|---|
| ប៊ូឡុងមួលផ្តាច់ប្រព័ន្ធទម្លាក់—កម្លាំងបង្វិល | 15 ញូតុនម៉ែត្រ (11 ផោនហ្វីត) |

**A—ប៊ូឡុងមួលផ្តាច់**




YC21294—UN—21DEC22

CP00834,1669010796871-KM-21NOV22-2/2


## លៃតម្រូវឧបករណ៍ផ្តាច់ប្រដាប់បួងទម្លាក់ស្វ័យប្រវត្តិ

**⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**

CP00834,1669012327255-KM-21NOV22-1/2

យោលប្រដាប់បួងទម្លាក់។ លៃតម្រូវឡោស៊ុ (E) ដើម្បីប្តូរប្រវែងរីស័រ (F) រហូតដល់ប្រវែង (X) 39 ម.ម។ ប្រសិនបើខ្សែយារខ្លាំងពេក ចូរលៃតម្រូវក្រចាប់រឹត (A) ដើម្បីឱ្យខ្លី។

**A—ក្រចាប់រឹត**
**B—ប៉ូលី**
**C—ខ្សែស្ពឹង**
**D—ប៉ូលីប្រដាប់នាំផ្លូវ**
**E—ឡោស៊ុ (ប្រើ 2)**
**F—រីស័រ**
**G—ប្រវែង (39 ម.ម)**




CP00834,1669012327255-KM-21NOV22-2/2


## លៃតម្រូវតំណឹងខ្សែពានអូសកាំបិតចិញ្ច្រាំដើមដំណាំ

CP00834,1668856177284-KM-19NOV22-1/2

ខ្សែពានអូសកាំបិតចិញ្ច្រាំដើមដំណាំ (A) តឹងដោយស្វ័យប្រវត្តិដោយប្រដាប់បន្តឹងខ្សែពានតាមរយៈសកម្មភាពរបស់រីស័រ (B)។ លៃតម្រូវប្រវែងរីស័រទៅតាមស្ថានភាពបំពេញការងារ។

គោលការណ៍លៃតម្រូវគឺថាខ្សែពានអូសមិនក្តៅខ្លាំងនៅក្រោមបន្ទុកការងារធម្មតាឡើយ។

**A—ខ្សែពានអូស**
**B—រីស័រ**
**C—ប៉ូលីអូស**




YC21213—UN—21DEC22

CP00834,1668856177284-KM-19NOV22-2/2

## ប្តូរផ្លែវិលកាំបិតចិញ្ច្រាំដើមដំណាំ

**ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។ ដើម្បីបង្ការការរងរបួស ចូរធានាសុវត្ថិភាពរ៉ូទ័រមុននឹងប្តូរផ្លែកាំបិតចិញ្ច្រាំ។**

**សំខាន់៖ កាំបិតចិញ្ច្រាំដែលជាក់អាចបណ្តាលឱ្យមានរំញ័រ។**

**ហាមប្រើផ្លែដែលសំលៀង។**

**ហាមប្រើផ្លែដែលវិល។**

CP00834,1659688542788-KM-05AUG22-1/2


ប្តូរផ្លែដែលជាក់ និងផ្លែនៅផ្នែកម្ខាងទៀតដោយដាក់ផ្លែថ្មីដែលមានទម្ងន់ស្មើដូចគ្នានៅពេលជាមួយគ្នា។

ដោះប៊ូឡុងនិងក្បាលឡោស៊ីចាក់ខ្ចាស់ខ្លួនឯង (A), ប្តូរផ្លែ ដាក់ផ្លែថ្មី ហើយរឹតបន្តឹងប៊ូឡុងទៅតាមបច្ចេកទេស។

**លក្ខណៈបច្ចេកទេស**

ប៊ូឡុងរឹតផ្លែវិលកាំបិតចិញ្ច្រាំដើមដំណាំ
—កម្លាំងបង្វិល . . . . . 50 ញូតុនម៉ែត្រ

**A—ក្បាលឡោស៊ីចាក់ខ្ចាស់ខ្លួនឯង (ចំណាត់ថ្នាក់ 10.9, M10×50)**
**B—ផ្លែវិល**




YC8240—UN—28JAN15

CP00834,1659688542788-KM-05AUG22-2/2

## ប្តូរផ្លែបញ្ចោស់ថេរកាំបិតចិញ្ច្រាំដើមដំណាំ

**ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។**


**តទៅទំព័របន្ទាប់**

**ប្រយ័ត្នផ្លែបញ្ចោសថេរមុត។**

CP00834,1659688548302-KM-05AUG22-1/2

1. ដោះកន្លាស់ខ្ចាស់ (C) ចេញ។
2. ទាញដងទប់ (A) ចេញ។
3. ប្តូរផ្លែដែលជាក់និងរឺលដាក់ផ្លែថ្មី។
4. ដំឡើងដងទប់ និងកន្លាស់ខ្ចាស់។

**A—ដងរឺតទប់**
**B—ផ្លែថែរ**
**C—កន្លាស់ខ្ចាស់(ប្រើ 2)**




CP00834,1659688548302-KM-05AUG22-2/2

## មាត់ច្រកបួងចូល

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **ការច្រកបញ្ចូលដើមដំណាំទៅកាន់ស៊ីឡាំងមិនរាបស្មើ ឬលោត** | ប្រដាប់បួងក្បាលឧបករណ៍កាត់ខ្ពស់ពេក។ | លៃតម្រូវប្រដាប់បួងចុះក្រោមនិងថយក្រោយ។<br>ចូរអានសៀវភៅណែនាំប្រើប្រាស់ក្បាលឧបករណ៍កាត់។ |
| | គំនរគ្រាប់ធញ្ញជាតិនៅលើរបារកាត់ | បន្ទាបកង់រ៉ក ហើយកំណត់ទីតាំងមុខនិងក្រោយឲ្យកៀកទៅនឹងរបារកាត់និងប្រដាប់បួងតាមដែលអាចធ្វើទៅបាន។<br>ចូរអានសៀវភៅណែនាំប្រើប្រាស់ក្បាលឧបករណ៍កាត់។ |
| | ដៃស្តុរអណ្តែតបត់ឡើងទៅសន្លឹកចំហៀងនៅចំហៀងម្ខាង។ | បន្ធូរនិងរឹតបន្តឹងច្រវាក់ម្តងទៀត។ ពន្លាឲ្យត្រង់ ឬប្តូរផ្នែកដែលកោងចេញ។ |
| | ច្រវាក់អូសប្រដាប់ច្រកបញ្ចូលខ្ពស់ពេកនិងទប់ស្តុរអណ្តែតមិនឲ្យចុះក្រោម។ | លៃតម្រូវច្រវាក់ដឹកនាំឲ្យដល់តំណឹងត្រឹមត្រូវ។ |
| | ការរអិលខ្សែពានអូសក្បាលឧបករណ៍កាត់។ | លៃតម្រូវកង់ដើម្បីបន្តឹងខ្សែពានអូស។ |
| | ប្រដាប់បួងនៅខាងមុខឆ្ងាយពីប្រដាប់ច្រៀកពេក។ | លៃតម្រូវប្រដាប់បួងត្រលប់ទៅកាន់ប្រដាប់ច្រៀក។<br>ចូរអានសៀវភៅណែនាំប្រើប្រាស់ក្បាលឧបករណ៍កាត់។ |
| | ច្រវាក់គ្រឿងបញ្ជូនប្រដាប់ច្រកបញ្ចូលស្ថិតនៅលើកង់ត្រឹមត្រូវ។ | ដាក់ច្រវាក់នៅលើកង់មានធ្មេញត្រឹមត្រូវ។ |
| | បន្ទះប្រដាប់អូសប្រដាប់ច្រកបញ្ចូលបានដើយឡើង។ | ពន្លាឲ្យត្រង់ ឬប្តូរបន្ទះដែលកោងចេញ។ |
| | កម្ទេចកម្ទីនិងដំរកកក្តាំពនៅលើបាតមាត់ច្រកបួងចូល។ | សម្អាតបាតមាត់ច្រកបួងចូល។ |
| | គម្លាតធំពេករវាងប្រដាប់បួងផ្លែតហ្វូមនិងស្តុរខាងមុខមាត់ច្រកបួងចូល។ | បន្ថែមតំណទៅលើច្រវាក់មាត់ច្រកបួងចូល។ |
| **ក្បាលឧបករណ៍កាត់ឬកង់រ៉កនឹងមិនលើកដោយត្រឹមត្រូវឡើយ** | ខ្សល់នៅក្នុងប្រព័ន្ធអ៊ីដ្រូលីក។ | រឹតបន្តឹងក្រចាប់រឹតនៅលើទុយោ ឬបំពង់ដែលធ្លាយ។ ច្រាលខ្សល់ចេញពៅប្រព័ន្ធលើកកង់រ៉ក។<br>ចូរអានសៀវភៅណែនាំប្រើប្រាស់ក្បាលឧបករណ៍កាត់។ |

CP00834,0008B71-KM-17MAR21-1/1

## ប្រព័ន្ធបោកបែន និងប្រព័ន្ធសម្អាត

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **គ្រាប់ដែលមិនរលេះ** | ល្បឿនបើកបែនយឺតពេកសម្រាប់ដំណាំ។ | បង្កើនល្បឿនបោកបែន។ បន្ទាប់ពីលៃតម្រូវរួច ចូរពិនិត្យមើលគុណភាពគ្រាប់ធញ្ញជាតិ។ |
| | ចន្លោះប្រអប់ក្រញែងធំទូលាយពេក។ | បន្តយចន្លោះប្រអប់ក្រញែង។ បន្ទាប់ពីលៃតម្រូវរួច ចូរពិនិត្យមើលគុណភាពគ្រាប់ធញ្ញជាតិ។ |
| | ចន្លោះប្រអប់ក្រញែងមិនស្មើគ្នាចាប់ពីមុខទៅដល់ក្រោយ។ | លៃតម្រូវការពង្រាបប្រអប់ក្រញែង។ |
| | មិនមានសម្ភារគ្រប់គ្រាន់ចូលទៅក្នុងគ្រឿងចក្រច្រូតកាត់សម្រាប់បោកបែនឱ្យបានត្រឹមត្រូវ។ | បង្កើនល្បឿនលើដី។ |
| **គ្រាប់ធញ្ញជាតិនៅក្នុងធុងជាក់ច្រើនពេក** | ល្បឿនបើកបែនលឿនពេកសម្រាប់ដំណាំ។ | បន្តយល្បឿនបោកបែន។ បន្ទាប់ពីលៃតម្រូវរួច ចូរពិនិត្យមើលគុណភាពគ្រាប់ធញ្ញជាតិ។ |
| | ចន្លោះប្រអប់ក្រញែងតូចពេក។ | បង្កើនចន្លោះប្រអប់ក្រញែង។ បន្ទាប់ពីលៃតម្រូវរួច ចូរពិនិត្យមើលគុណភាពគ្រាប់ធញ្ញជាតិ។ |
| | គ្រាប់ច្រើនពេកនៅក្នុងបន្ទះបិទបើកខាងក្រោយ។ | បង្កើនប្រឡោះកន្ត្រែងបន្តិច។ |
| | មិនមានសម្ភារគ្រប់គ្រាន់ចូលទៅក្នុងគ្រឿងចក្រ។ | បង្កើនល្បឿនលើដី។ |
| **ធុងគ្រាប់ធញ្ញជាតិកខ្វក់** | ការបោកបែនមិនគ្រប់គ្រាន់។ | បង្កើនល្បឿនបោកបែន។ បន្ទាប់ពីលៃតម្រូវរួច ចូរពិនិត្យមើលគុណភាពគ្រាប់ធញ្ញជាតិ។ |
| | | បន្តយចន្លោះប្រអប់ក្រញែង។ បន្ទាប់ពីលៃតម្រូវរួច ចូរពិនិត្យមើលគុណភាពគ្រាប់ធញ្ញជាតិ។ |
| | | ពិនិត្យមើលការពង្រាបប្រអប់ក្រញែង។ |
| | ល្បឿនកង្ហារសម្អាតយឺតពេក។ | បង្កើលល្បឿនកង្ហារសម្អាត។ |
| **ការបាត់បង់គ្រាប់ធញ្ញជាតិទៅលើស្បែកជើងសម្អាត** | ពិនិត្យមើលប្រឡោះធ្មេញកញ្ច្រែង/កន្ត្រែង | ពិនិត្យនិងក្រិតប្រឡោះធ្មេញ/កន្ត្រែងតាមខ្នាត។ |
| | ការបែងចែកដើមដំណាំ/គ្រាប់នៅលើការសម្អាតប្រអប់ជើងមិនត្រឹមត្រូវ។ | កែតម្រូវល្បឿនកង្ហារសម្អាត។ |

CP00834,0008B72-KM-17MAR21-1/1

## ប្រព័ន្ធអូសលើដី (ការអូសដោយមេកានិក)

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **គ្រឿងចក្រនឹងមិនដំណើរការទៅមុខ ឬថយក្រោយឡើយ** | ប្រអប់លេខស្ថិតនៅក្រៅស្តីហ្គែរ។ | ប្តូរប្រអប់លេខ។ |
| | គ្រឿងក្រោម Posi-Torq™ មិនដំណើរការ។ | ដាក់ប្រេងរំអិលគ្រឿងខាងក្រោម Posi-Torq™។ |
| **ប្រអប់លេខពិបាកប្តូរ ឬមិនប្តូរ។** | អំប្រាយ៉ាមិនភ្ជាប់។ | លៃតម្រូវចន្លោះអំប្រាយ៉ា។ |
| | ខ្សែគ្រប់គ្រងចង្កឹះលេខមិនអាចលៃតម្រូវបាន។ | លៃតម្រូវខ្សែគ្រប់គ្រងចង្កឹះលេខ។ |
| | ខ្សែគ្រប់គ្រងចង្កឹះលេខដែលខូច កខ្វក់ច្រេះស៊ី ឬកំពិត។ | ពិនិត្យ សម្អាត លៃតម្រូវ ឬប្តូរខ្សែគ្រប់គ្រងចង្កឹះលេខ។ |
| | បញ្ហាប្រអប់លេខខាងក្នុង។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ល្បឿនធ្វើដំណើរលើដីប្រែប្រួល** | ប្រេងអ៊ីដ្រូលីកទាប។ | ពិនិត្យមើលការលេចធ្លាយហើយជួសជុល។ ចាក់ប្រេងអ៊ីដ្រូលីកចូលធុងស្តុក។ |

CP00834,1660029519649-KM-09AUG22-1/1

## ប្រព័ន្ធអូសទាញលើដី (ការអូសដោយអ៊ីដ្រូស្តាទិក)

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **ដៃបញ្ហូរអូសដោយអ៊ីដ្រូស្តាទិកនឹងមិនត្រឡប់ក្រោយ។** | ផ្នែកដែកកោងឬបែកបាក់នៅក្នុងតំណប្រដាប់បញ្ហូរ។ | ចូរប្តូរនិងជួសជុលវាតាមចាំបាច់។ |
| **ការជាប់ជំពាក់តំណ** | តំណឃ្លីនៅលើខ្សែឧបករណ៍បញ្ហូរកកឬខូច។ | ដាក់ប្រេងរំអិល ឬប្តូរចេញ។ |
| | កណ្តឹងរវៃ ឬការចងស្នូល។ | ដាក់ប្រេងរំអិល ឬប្តូរចេញ។ |
| | ខ្សែឧបករណ៍បញ្ហូរកួច ឬកក។ | ចូរប្តូរចេញប្រសិនបើចាំបាច់។ |
| **ប្រព័ន្ធឡើងកម្តៅខ្លាំង** | ឧបករណ៍បញ្ហូរកម្តៅប្រេង ឬធុងទឹកម៉ាស៊ីនស្ទះ។ | បាញ់ខ្យល់កាត់តាមស្នូល និងសម្អាត។ |
| | កង្វះលំហូរប្រេងចូល។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ខ្សែពានកង្ហារម៉ាស៊ីនរអិល ឬដាច់។ | ពិនិត្យខ្សែពានក្រែងលោសឹក ឬដាច់។ |
| | តម្រងប្រេងស្ទះ។ | ប្តូរតម្រងប្រេង។ |
| | លើសសម្ពាធវ៉ាល់សុវត្ថិភាព។ | ប្តូរទៅស្តីហ្គ័រទាប។ |
| | វ៉ាល់សុវត្ថិភាពស្ទះជិត។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | វ៉ាល់ឆ្លងកាត់បិទមិនបិទ។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ការបាត់បង់ប្រេងច្រើន** | បន្ទះតំណ ឬទុយោអ៊ីដ្រូលីកលេចធ្លាយទុយោ ឬកងមូល។ | រឹតបន្តឹងតំណ ឬប្តូរទុយោដែលខូច ទុយោ ឬកងមូល។ |
| | ការលេចធ្លាយប្រេងពីដងស្នប់បូមអ៊ីដ្រូស្តាទិក។ | ប្តូរហ្វឺតដងស្នប់បូមអ៊ីដ្រូស្តាទិក។ |
| **គ្រឿងចក្រនឹងមិនដំណើរការទៅមុខ ឬថយក្រោយឡើយ** | ប្រអប់លេខស្ថិតនៅក្រៅស្តីហ្គ័រ។ | ប្តូរប្រអប់លេខ។ |
| | កម្រិតប្រេងម៉ាស៊ីនទាប | ពិនិត្យមើលការលេចធ្លាយហើយជួសជុល។ ចាក់ប្រេងបំពេញធុងស្តុកអ៊ីដ្រូលីក។ |
| | ការធ្លាយខ្យល់នៅក្នុងប្រព័ន្ធ។ | រឹតបន្តឹងតំណ។ |
| | តំណឧបករណ៍បញ្ហូបាក់ ឬលុង។ | រឹតបន្តឹងតំរុង ឬប្តូរចេញតាមចាំបាច់។ |
| | កង្វះលំហូរចូល ឬសម្ពាធសាកបញ្ចូល។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | តម្រងប្រេងស្ទះ។ | ប្តូរតម្រងប្រេង។ |
| | លើសការកំណត់សម្ពាធប្រតិបត្តិការអតិបរមា។ | ប្តូរទៅស្តីហ្គ័រទាប។ |
| | ប្រព័ន្ធអូសទាញមិនអាចបង្កើនសម្ពាធបានឡើយ។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |

តទៅទំព័របន្ទាប់

| អាគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| | ការបើកវ៉ាល់សុវត្ថិភាព។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ប្រអប់លេខពិបាកប្តូរ ឬមិនប្តូរ។** | ដៃបញ្ជាអូសអ៊ីដ្រូស្តាទិកមិននៅក្នុងទីតាំងនឹង។ | រំកិលដៃបញ្ជាអូសអ៊ីដ្រូស្តាទិកទៅទីតាំងនឹង។ |
| | ខ្សែគ្រប់គ្រងចង្កឹះលេខមិនអាចលៃតម្រូវបាន។ | លៃតម្រូវខ្សែគ្រប់គ្រងចង្កឹះលេខ។ |
| | ខ្សែគ្រប់គ្រងចង្កឹះលេខដែលខូច កខ្វក់ ច្រេះស៊ី ឬកំពិត។ | ពិនិត្យ សម្អាត លៃតម្រូវ ឬប្តូរខ្សែកាប។ |
| | បញ្ហាប្រអប់លេខខាងក្នុង។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ល្បឿនធ្វើដំណើរលើដីប្រែប្រួល** | ប្រេងអ៊ីដ្រូលីកទាប។ | ពិនិត្យមើលការលេចធ្លាយហើយជួសជុល។ ចាក់ប្រេងបំពេញធុងស្តុកអ៊ីដ្រូលីក។ |
| | តម្រងប្រេងស្ទះ។ | ប្តូរតម្រងប្រេងសាកអ៊ីដ្រូលីក។ |
| | លើសការកំណត់សម្ពាធប្រតិបត្តិការអតិបរមា។ | ប្តូរទៅស្តីហ្គែរទាបជាង ឬភ្ជាប់ការអូសដោយកង់ក្រោយ។ |
| | ដៃបញ្ជាអូសអ៊ីដ្រូស្តាទិករំកិលតិចៗទៅកាន់ទីតាំងនឹង។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ប្រព័ន្ធមិនអាចរក្សាសម្ពាធសាកបាន។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ម៉ាស៊ីននឹងមិនឈប់ដំណើរការនៅពេលដៃបញ្ជាអូសដោយអ៊ីដ្រូស្តាទិកនៅក្នុងទីតាំងនឹង។** | ខ្សែឧបករណ៍បញ្ជាមិនអាចលៃតម្រូវបាន។ | លៃតម្រូវខ្សែទៅកាន់ទីតាំងដោះលេខ។ |
| **ខុះថាមពល ឬបាត់បង់ថាមពល។ ម៉ាស៊ីនមិនមានការឆ្លើយតបទៅនឹងចង្កឹះបញ្ជាអូសដោយអ៊ីដ្រូស្តាទិក។** | កម្រិតប្រេងអ៊ីដ្រូលីកទាប។ | ពិនិត្យមើលការលេចធ្លាយហើយជួសជុល។ ចាក់ប្រេងបំពេញធុងស្តុកអ៊ីដ្រូលីក។ |
| | តម្រងប្រេងស្ទះ។ | ប្តូរតម្រងប្រេងសាកអ៊ីដ្រូលីក។ |
| | កង្វះលំហូរចូល ឬសម្ពាធសាកបញ្ចូល។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ប្រព័ន្ធអូសទាញមិនអាចរក្សា ឬបង្កើនសម្ពាធបានឡើយ។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ប្រព័ន្ធចាប់សញ្ញាកំហុសដុំអូសលើដី។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |

CP00834,0008B74-KM-17MAR21-2/2

## ប្រព័ន្ធចង្កូត

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **កង់ក្រោយរំចុះឡើងពេលស្ថិតក្នុងល្បឿនខ្ពស់ជាងគេ** | មិនអាចលៃតម្រូវកង់កន្ទែកចូលបាន។ | លៃតម្រូវការកន្ទែកចូលនៃកង់។ |
| **ដៃចង្កូតមិនប៉ះទង្គិចនៅពេលបត់ពេញ** | ស៊ីឡាំងចង្កូតមិនអាចលៃតម្រូវបាន។ | លៃតម្រូវស៊ីឡាំងចង្កូត។ |
| **ចង្កូតតឹង** | កម្រិតប្រេងទាបនៅក្នុងធុងស្តុកអ៊ីដ្រូលីក។ | ថែមប្រេងអ៊ីដ្រូលីក។ |

CP00834,0008B75-KM-17MAR21-1/1

## ប្រព័ន្ធហ្វ្រាំង

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **សម្ពាធឈ្មាន់ហ្វ្រាំងស្បឹត** | កម្រិតប្រេងហ្វ្រាំងទាប។ | បន្ថែមប្រេងហ្វ្រាំង។ |
| | មានខ្យល់នៅក្នុងប្រព័ន្ធ។ | សាប់បន្ទូរប្រព័ន្ធហ្វ្រាំង។ |
| **បាត់បង់ថាមពលហ្វ្រាំង** | ហ្វ្រាំងជើងមិនបានលៃតម្រូវឲ្យបានត្រឹមត្រូវ។ | លៃតម្រូវហ្វ្រាំងជើង។ |
| **ហ្វ្រាំងដៃចាប់មិនស៊ី** | ហ្វ្រាំងដៃមិនបានលៃតម្រូវឲ្យបានត្រឹមត្រូវ។ | លៃតម្រូវហ្វ្រាំងដៃ។ |

CP00834,0008B76-KM-17MAR21-1/1

## ម៉ាស៊ីន

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **ម៉ាស៊ីននឹងមិនវៃបញ្ឆេះ** | អាគុយខ្សោយ។ | សាក ឬប្តូរអាគុយ |
| | តំណអាគុយធូរលុង ឬច្រេះស៊ី។ | សម្អាតក្បាលតំណអាគុយនិងតំណ។ |
| | កុងតាក់ផ្តាច់អាគុយ ឬកុងតាក់សុវត្ថិភាពបញ្ឆេះមានបញ្ហា។ | ជួសជុលកុងតាក់តាមចាំបាច់។ |
| | ដេម៉ារ៉ែមានបញ្ហា។ | ប្តូរដាម៉ារ៉ែ។ |
| **ម៉ាស៊ីនពិបាកបញ្ឆេះ ឬមិនឆេះ** | បញ្ហាប្រព័ន្ធបញ្ឆេះ។ | ប្រព័ន្ធបញ្ឆេះមិនខ្លាំងគ្រប់គ្រាន់ក្នុងការបញ្ឆេះ |
| | | ចូរអនុវត្តជំហានដែលមាននៅក្នុងផ្នែកម៉ាស៊ីននឹងមិនឆេះ។ |
| | គុណភាពប្រេងឥន្ធនៈទាប។ | បង្ហូរប្រេងឥន្ធនៈ ហើយប្តូរដាក់ប្រេងដែលមានគុណភាពដែលមានគុណភាពត្រឹមត្រូវ។ |
| | ល្បឿនវៃបញ្ឆេះយឺត។ | ពិនិត្យរកមើលបញ្ហានៅក្នុងប្រព័ន្ធសាក/បញ្ឆេះ។ |
| | ប្រេងម៉ាស៊ីនមានកម្រិតស្អិតខាប់ខ្ពស់ពេក។ | បង្ហូរប្រេងម៉ាស៊ីន និងប្តូរដាក់ប្រេងដែលមានភាពស្អិតខាប់ត្រឹមត្រូវ។ |
| | បញ្ហាប្រព័ន្ធបញ្ហាអេឡិកត្រូនិក ឬបញ្ហាម៉ាស៊ីនមូលដ្ឋាន។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ការឧកថ់ហេះ ឬដំណើរការមិនទៀងទាត់** | គុណភាពប្រេងឥន្ធនៈទាប។ | បង្ហូរប្រេងឥន្ធនៈ ហើយប្តូរដាក់ប្រេងដែលមានគុណភាពដែលមានគុណភាពត្រឹមត្រូវ។ |
| | បញ្ហាប្រព័ន្ធបញ្ហាអេឡិកត្រូនិក ឬបញ្ហាម៉ាស៊ីនមូលដ្ឋាន។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ខ្សោយថាមពលម៉ាស៊ីន** | គុណភាពប្រេងឥន្ធនៈទាប។ | បង្ហូរប្រេងឥន្ធនៈ ហើយប្តូរដាក់ប្រេងដែលមានគុណភាពដែលមានគុណភាពត្រឹមត្រូវ។ |
| | តម្រងប្រេងឥន្ធនៈស្ទះ។ | ប្តូរតម្រងប្រេងឥន្ធនៈ។ |
| | ម៉ាស៊ីនផ្ទុកលើសកំណត់។ | បន្ថយបន្ទុកម៉ាស៊ីន។ |
| | ប្រេងម៉ាស៊ីនមិនត្រឹមត្រូវ។ | បង្ហូរប្រេងម៉ាស៊ីន និងប្តូរដាក់ប្រេងដែលមានភាពស្អិតខាប់ត្រឹមត្រូវ។ |
| | បញ្ហាប្រព័ន្ធបញ្ហាអេឡិកត្រូនិក ឬបញ្ហាម៉ាស៊ីនមូលដ្ឋាន។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ម៉ាស៊ីនស្ថិតនៅក្នុងតំហយអ្រាដោយសារតែកូដបញ្ហារោគវិនិច្ឆ័យសកម្ម។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ម៉ាស៊ីនស្ថិតនៅក្នុងតំហយអ្រាពីព្រោះតម្រូវការសម្អាតតម្រងបំពង់ស៊ីម៉ាំង។ | ភ្ជាប់ម៉ូដសម្អាតស្វ័យប្រវត្តិតម្រងបំពង់ស៊ីម៉ាំង និងតម្រូវឲ្យធ្វើការសម្អាតតម្រងបំពង់ស៊ីម៉ាំងប្រចាំឆ្នាំ។ |

តទៅទំព័របន្ទាប់

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **ម៉ាស៊ីនបញ្ចេញផ្សែងខ្មៅ ឬប្រផេះ** | ម៉ាស៊ីនផ្ទុកលើសកំណត់។ | បន្ថយបន្ទុកម៉ាស៊ីន។ |
| | ប្រភេទប្រេងឥន្ធនៈមិនត្រឹមត្រូវ។ | ប្រើប្រាស់ប្រេងឥន្ធនៈដែលត្រឹមត្រូវ។ |
| | សំបុកតម្រងខ្យល់ស្ទះ ឬកខ្វក់។ | ប្តូរសមាសភាគសំបុកតម្រងតាមចាំបាច់។ |
| | គ្រឿងផ្គុបសំឡេង/បំពង់ផ្សែងស៊ីមុាំងខូច (បណ្តាលឲ្យមានសម្ពាធច្រាស)។ | ប្តូរគ្រឿងផ្គុបសំឡេង ឬបំពង់ដែលខូច។ |
| | បញ្ហាប្រព័ន្ធបញ្ចាអេឡិកត្រូនិក ឬបញ្ហាម៉ាស៊ីនមូលដ្ឋាន។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ប៊ិចប្រេងឥន្ធនៈមិនស្អាត។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ស្នប់បូមប្រេងសម្ពាធខ្ពស់អស់ពេល។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | តួប៊ីនមិនដំណើរការ។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | តម្រងប្រេងបំពង់ស៊ីមុាំងប្រេះបែក ឬខូច។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ម៉ាស៊ីនបញ្ចេញផ្សែងស** | ការសង្កត់ម៉ាស៊ីនទាបពេក។ | កំណត់មូលហេតុនៃការបង្ហាប់ទាប ហើយជួសជុលតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ប្រភេទប្រេងឥន្ធនៈមិនត្រឹមត្រូវ។ | ប្រើប្រាស់ប្រេងឥន្ធនៈដែលត្រឹមត្រូវ។ |
| | សីតុណ្ហភាពម៉ាស៊ីនទាប។ | កម្តៅម៉ាស៊ីនទៅដល់សីតុណ្ហភាពប្រតិបត្តិការធម្មតា។ |
| | ទែរម៉ូស្តាតមានបញ្ហា។ | តេស្តទែរម៉ូស្តាត ប្តូរទែរម៉ូស្តាតតាមចាំបាច់។ |
| | ទឹកថ្នាំសុំម៉ាស៊ីនចូលក្នុងបន្ទប់ចំហេះ (រំងគម្របស៊ីឡាំងខូច ឬគម្របស៊ីឡាំងប្រេះ)។ | ចូរប្តូរនិងជួសជុលវាតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | បញ្ហាប្រព័ន្ធបញ្ចាអេឡិកត្រូនិក ឬបញ្ហាម៉ាស៊ីនមូលដ្ឋាន។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ប៊ិចប្រេងឥន្ធនៈខូច។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ស្នប់បូមប្រេងសម្ពាធខ្ពស់អស់ពេល។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ម៉ាស៊ីនការ៉ងទីមិនស្រួល។** | គុណភាពប្រេងឥន្ធនៈទាប។ | បង្ហូរប្រេងឥន្ធនៈ ហើយប្តូរដាក់ប្រេងដែលមានគុណភាពដែលមានគុណភាពត្រឹមត្រូវ។ |
| | ការលេចធ្លាយខ្យល់នៅលើជ្រុងបូមប្រព័ន្ធបឺតខ្យល់ចូល។ | ពិនិត្យមើលតំណទុយោនិងបំពង់ក្រែងលោធូរ ចូរជួសជុលតាមចាំបាច់។ |

តទៅទំព័របន្ទាប់

| អោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| | បញ្ហាប្រព័ន្ធបញ្ជាអេឡិកត្រូនិក ឬបញ្ហាម៉ាស៊ីនមូលដ្ឋាន។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ស៊ីប្រេងឥន្ធនៈច្រើនជ្រុល។** | គុណភាពប្រេងឥន្ធនៈទាប។ | បង្ហូរប្រេងឥន្ធនៈ ហើយប្តូរដាក់ប្រេងដែលមានគុណភាពដែលមានគុណភាពត្រឹមត្រូវ។ |
| | ម៉ាស៊ីនផ្ទុកលើសកំណត់។ | បន្ថយបន្ទុកម៉ាស៊ីន។ |
| | សំបុកតម្រងខ្យល់ស្ទះ ឬកខ្វក់។ | ប្តូរសមាសភាគសំបុកតម្រងតាមចាំបាច់។ |
| | ការសង្កត់ទាបពេក។ | កំណត់មូលហេតុនៃការបង្ហាប់ទាប ហើយជួសជុលតាមចាំបាច់។ |
| | ការលេចធ្លាយនៅក្នុងប្រព័ន្ធផ្គត់ផ្គង់ប្រេង។ | ស្វែងរកប្រភពលេចធ្លាយ និងជួសជុលតាមចាំបាច់។ |
| | ប្រភេទប្រេងឥន្ធនៈមិនត្រឹមត្រូវ។ | ប្រើប្រភេទប្រេងឥន្ធនៈត្រឹមត្រូវ។ |
| | គុណភាពប្រេងឥន្ធនៈទាប។ | បង្ហូរប្រេងឥន្ធនៈ ហើយប្តូរដាក់ប្រេងដែលមានគុណភាពដែលមានគុណភាពត្រឹមត្រូវ។ |
| | ចន្លោះវាល់មិនត្រឹមត្រូវ។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ប៊ិចប្រេងឥន្ធនៈខូច។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ស្នប់បូមប្រេងសម្ពាធខ្ពស់អស់ពេល។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ប្រតិបត្តិការតួប៊ីនមិនត្រឹមត្រូវ។ | ពិនិត្យតួប៊ីន។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | សីតុណ្ហភាពម៉ាស៊ីនទាប។ | ពិនិត្យទែរម៉ូស្តាត។ |
| **ប្រេងឥន្ធនៈនៅក្នុងប្រេងម៉ាស៊ីន** | គម្របស៊ីឡាំងបែក។ | រកមើលស្នាមប្រេះ ជួសជុល/ប្តូរគ្រឿងតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | កងមូលអង្គចាក់បញ្ចូលរួមអេឡិកត្រូនិកប្រេះ ឬសឹក។ | ដោះអង្គចាក់បញ្ចូលរួមអេឡិកត្រូនិកដែលសង្ស័យ និងប្តូរវាងមូលចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **សម្ពាធប្រេងទាប** | តម្រងប្រេងឥន្ធនៈស្ទះ។ | ប្តូរតម្រងប្រេងឥន្ធនៈ។ |
| | ទុយោប្រេងឥន្ធនៈស្ទះ។ | រកមើលការស្ទះ ជួសជុលតាមចាំបាច់។ |
| | ស្នប់បូមផ្ទេរប្រេងឥន្ធនៈខូច។ | ដោះស្នប់បូមផ្ទេរប្រេងឥន្ធនៈចេញ ជួសជុល/ប្តូរស្នប់បូមតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |

តទៅទំព័របន្ទាប់

| ហេតុសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **ការចូលខ្សល់ក្នុងប្រេង** | ក្រចាប់រឹតអង្គចាក់បញ្ចូលរួមអេឡិកត្រូនិកធ្ងរលុង។ | រឹតបន្តឹងប៊ូឡុងក្រចាប់រឹតឲ្យដល់កម្លាំងបង្វិលត្រឹមត្រូវ។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | កងមូលអង្គចាក់បញ្ចូលរួមអេឡិកត្រូនិកប្រេះ ឬសឹក។ | ដោះអង្គចាក់បញ្ចូលរួមអេឡិកត្រូនិកដែលសង្ស័យ និងប្តូរវាងរាងមូលចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **សម្ពាធប្រេងម៉ាស៊ីនទាប** | កម្រិតប្រេងម៉ាស៊ីនទាប។ | ចាក់ប្រេងចូលម៉ាស៊ីទៅដល់កម្រិតត្រឹមត្រូវ។ |
| | កម្រិតប្រេងម៉ាស៊ីនខ្ពស់ពេក។ | ចាក់ប្រេងចូលម៉ាស៊ីទៅដល់កម្រិតត្រឹមត្រូវ។ |
| | អង្គញ្ញាណសម្ពាធប្រេងម៉ាស៊ីនមានកំហុស។ | ប្តូរអង្គញ្ញាណ។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ឧបករណ៍បញ្ជាកម្តៅប្រេងម៉ាស៊ីន ឬតម្រងស្ទះ។ | ដោះនិងពិនិត្យឧបករណ៍បញ្ជាកម្តៅប្រេង។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | សីតុណ្ហភាពប្រេងម៉ាស៊ីនខ្ពស់ពេក។ | ដោះនិងពិនិត្យឧបករណ៍បញ្ជាកម្តៅប្រេងម៉ាស៊ីន។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ស្នប់បូមប្រេងម៉ាស៊ីនខូច។ | ដោះនិងពិនិត្យស្នប់បូមប្រេងម៉ាស៊ីន។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ប្រេងម៉ាស៊ីនមិនត្រឹមត្រូវ។ | បង្ហូរប្រេងម៉ាស៊ីនចេញ និងចាក់ប្រេងល្អចូលវិញ។ |
| | អង្គចាក់បញ្ចូលប្រេងឥន្ធនៈខូច។ | ប្តូរអង្គចាក់បញ្ចូលប្រេងឥន្ធនៈ។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | តម្រងសំណាញ់ស្នប់បូមប្រេងម៉ាស៊ីនស្ទះ ឬបំពង់ទទួលប្រេះបែក។ | ដោះខ្ទះប្រេងចេញ ហើយសម្អាតតម្រងសំណាញ់/ប្តូរបំពង់ទទួល។ |
| | ចន្លោះជាដាងដងភ្ជាប់ ឬជាដាងមេធំពេក។ | កំណត់ចន្លោះជាដាង។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **សម្ពាធប្រេងខ្ពស់** | ចំណាត់ថ្នាក់ប្រេងម៉ាស៊ីនមិនត្រឹមត្រូវ | បង្ហូរប្រេងម៉ាស៊ីនចេញ និងចាក់ប្រេងល្អចូលវិញ។ |
| | អង្គញ្ញាណសម្ពាធប្រេងម៉ាស៊ីនមានកំហុស។ | ប្តូរអង្គញ្ញាណ។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | អង្គចាក់បញ្ចូលប្រេងឥន្ធនៈឥន្ធនៈស្ទះ។ | ប្តូរអង្គចាក់បញ្ចូលប្រេងឥន្ធនៈ។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ការស៊ីប្រេងច្រើន** | ប្រេងប្រអប់រវៃមានភាពស្អិតខាប់ទាបពេក។ | បង្ហូរប្រេងម៉ាស៊ីនចេញ និងចាក់ប្រេងដែលមានកម្រិតស្អិតខាប់ត្រឹមត្រូវចូលវិញ។ |

តទៅទំព័របន្ទាប់

| អាគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| | កម្រិតប្រេងម៉ាស៊ីនខ្ពស់ពេក។ | បង្ហូរប្រេងម៉ាស៊ីនចេញរហូតទាល់តែកម្រិតប្រេងត្រឹមត្រូវ។ |
| | ការលេចធ្លាយប្រេងម៉ាស៊ីនខាងក្រៅ។ | កំណត់ប្រភពលេចធ្លាយប្រេង និងជួសជុលតាមចាំបាច់។ |
| | កងឧបករណ៍គ្រប់គ្រងប្រេងមិនចូលកប។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | កងឧបករណ៍គ្រប់គ្រងប្រេងសឹកដាច់ឬបាក់។ | ប្តូរកងពីស្តុង។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ទ្រនាប់ស៊ីឡាំង ឬពីស្តុងឆេះ។ | ដោះនិងពិនិត្យស៊ីឡាំងនិងទ្រនាប់រន្ធ ប្តូរចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | បំពង់នាំវ៉ាល់និងដងវ៉ាល់សឹកដាច់។ | ពិនិត្យនិងវាស់វែងដងវ៉ាល់និងបំពង់នាំវ៉ាល់ ជួសជុលតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | សម្ពាធប្រេងម៉ាស៊ីនខ្លាំងពេក | ចូរអានអំពីសម្ពាធប្រេងខ្ពស់នៅខាងដើមនៃផ្នែកនេះ។ |
| | ចង្ហូរក្រវាត់ពីស្តុងសឹកខ្លាំងពេក។ | ដោះនិងពិនិត្យពីស្តុង។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ក្រវាត់ពីស្តុងជាប់ក្នុងចង្ហូរកង។ | ដោះនិងពិនិត្យពីស្តុង។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | តំណឹងក្រវាត់ពីស្តុងមិនគ្រប់គ្រាន់។ | ដោះនិងពិនិត្យពីស្តុង។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | គម្លាតកងពីស្តុងមិនរង្គើ។ | ដោះនិងពិនិត្យពីស្តុង។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ការខូចហ្វឺតប្រេងដងវែខាងមុខនិង/ឬខាងក្រោយ។ | ប្តូរហ្វឺតប្រេង។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **តួប៊ីន "ហួច"** | ការធ្លាយខ្យល់នៅក្នុងកបំពង់បែងចែកស្រូបខ្យល់ចូល។ | ពិនិត្យរ៉ងកបំពង់បែងចែកស្រូបខ្យល់ចូលនិងកបំពង់បែងចែក ជួសជុលតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ប្រេងនៅលើកង់ឧបករណ៍បឺតខ្យល់ចូលតួប៊ីន ឬនៅក្នុងផើងឧបករណ៍បឺតខ្យល់ចូល (ប្រេងដែលរុញឬបឺតកាត់តាមផើងកណ្តាល)** | សម្ពាធប្រអប់រវែខ្លាំងពេក។ | កំណត់មូលហេតុនៃសម្ពាធប្រអប់រវែខ្លាំងពេក ចូរជួសជុលតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ស្ទះខ្យល់ស្រូបចូល។ | កំណត់មូលហេតុនៃការស្ទះខ្យល់ចូល ចូរជួសជុលតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |

តទៅទំព័របន្ទាប់

| ហេតុសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| | ការស្ទះបំពង់បង្ហូរ។ | កំណត់មូលហេតុនៃការស្ទះបំពង់បង្ហូរ ចូរជួសជុលតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ប្រេងនៅក្នុងកប៉ាំងបែងចែកស្រូបខ្យល់ចូល ឬស្រកចេញពីផើងតួប៊ិន** | សម្ពាធប្រអប់រំវែខ្លាំងពេក។ | កំណត់មូលហេតុនៃសម្ពាធប្រអប់រំវែខ្លាំងពេក ចូរជួសជុលតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ស្ទះខ្យល់ស្រូបចូល។ | កំណត់មូលហេតុនៃការស្ទះខ្យល់ចូល ចូរជួសជុលតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ការស្ទះបំពង់បង្ហូរ។ | កំណត់មូលហេតុនៃការស្ទះបំពង់បង្ហូរ ចូរជួសជុលតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | បាដាងផើងខូច ឬសឹករេចរឹល។ | ពិនិត្យតួប៊ិន ជួសជុល/ប្តូរវាចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | អតុល្យភាពនៃបង្គុំបង្វិល។ | ពិនិត្យតួប៊ិន ជួសជុល/ប្តូរវាចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ការខូចខាតចំពោះតួប៊ិន ឬកង់ឧបករណ៍បឺតខ្យល់ចូល ឬកាំបិត។ | ពិនិត្យតួប៊ិន ជួសជុល/ប្តូរវាចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ដី ឬកំណកាបោននៅលើកង់ឬកាំបិត។ | ពិនិត្យរកមើលការលេចធ្លាយខ្យល់ស្រូបចូល (តម្រងខ្យល់ខាងក្រោយ)។ ពិនិត្យតួប៊ិន ជួសជុល/ប្តូរវាចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | សំណឹកបាដាង។ | ពិនិត្យតួប៊ិន ជួសជុល/ប្តូរវាចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | កង្វះប្រេង ឬប្រេងរំអិលមិនគ្រប់គ្រាន់។ | កំណត់មូលហេតុនៃការខ្វះប្រេងរំអិល ចូរជួសជុលតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ហ្វឺតដងសឹករេចរឹល។ | ពិនិត្យតួប៊ិន ជួសជុល/ប្តូរវាចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ការអូសកង់តួប៊ិនរបស់ម៉ាស៊ីនដើរដោយតួប៊ិន** | កំណកាបោននៅខាងក្រោយកង់តួប៊ិនបង្កឡើងដោយប្រេងកករ ឬកំណចំហេះ។ | ពិនិត្យតួប៊ិន ជួសជុល/ប្តូរវាចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | កម្ទេចកម្ទីដែលកកនៅខាងក្រោយកង់ឧបករណ៍បឺតខ្យល់ចូលបណ្តាលមកពីការលេចធ្លាយខ្យល់ដែលស្រូបចូល។ | ពិនិត្យតួប៊ិន ជួសជុល/ប្តូរវាចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |

តទៅទំព័របន្ទាប់

| អោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| | ការគាំង ឬកម្ទេចកម្ទីបាដាង, បាដាងសឹករេចរឹល។ | ពិនិត្យតួប៊ីន ជួសជុល/ប្តូរវាចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ម៉ាស៊ីនឡើងកម្តៅខ្លាំង** | ម៉ាស៊ីនផ្ទុកលើសកំណត់។ | បន្ថយបន្ទុកម៉ាស៊ីន។ |
| | កម្រិតទឹកថ្នាំស្អុំម៉ាស៊ីនទាប។ | ចាក់បំពេញប្រព័ន្ធបញ្ចុះកម្តៅឲ្យដល់កម្រិតត្រឹមត្រូវ, ពិនិត្យធុងទឹកម៉ាស៊ីន និងទុយោក្រែងលោមានតំណក្រូរលុង ឬលេចធ្លាយ។ |
| | គម្របធុងខ្ពោលខូច។ | ប្តូរគម្របធុងខ្ពោលចេញតាមចាំបាច់។ |
| | ខ្សែពានកង្ហារធ្លុរលុង ឬខូច | ប្តូរខ្សែពានកង្ហារចេញតាមចាំបាច់។ ពិនិត្យប្រដាប់បន្តឹងខ្សែពាន។ |
| | កម្រិតប្រេងម៉ាស៊ីនទាប។ | ត្រួតពិនិត្យកម្រិតប្រេងម៉ាស៊ីន។ បន្ថែមប្រេងម៉ាស៊ីនចូលតាមការចាំបាច់។ |
| | ប្រព័ន្ធបន្ថយកម្តៅត្រូវការលាងសម្អាត។ | លាងសម្អាតប្រព័ន្ធបញ្ចុះកម្តៅ។ |
| | ទែរម៉ូស្តាតមានបញ្ហា។ | ដោះ និងពិនិត្យទែរម៉ូស្តាតតាមចាំបាច់។ |
| | នាឡិកាវាស់ ឬឧបករណ៍បញ្ជូនព័ត៌មានអំពីសីតុណ្ហភាពខូច។ | ពិនិត្យទឹកថ្នាំស្អុំម៉ាស៊ីនដោយប្រើទែរម៉ូម៉ែត្រ ហើយប្តូរវាចេញតាមចាំបាច់។ |
| | ប្រភេទប្រេងឥន្ធនៈមិនត្រឹមត្រូវ | ប្រើកម្រិតប្រេងឥន្ធនៈត្រឹមត្រូវ។ |
| | ស្នូលធុងទឹកម៉ាស៊ីនកខ្វក់។ | សម្អាតធុងទឹកម៉ាស៊ីនតាមចាំបាច់។ |
| | កម្រិតប្រេងម៉ាស៊ីនទាបពេក។ | ចាក់ប្រេងចូលម៉ាស៊ីទៅដល់កម្រិតត្រឹមត្រូវ។ |
| | វ៉ែនគម្របស៊ីឡាំងខូច។ | ប្តូរវ៉ែនគម្របស៊ីឡាំង។។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ស្នប់បូមទឹកថ្នាំស្អុំខូច។ | ប្តូរស្នប់បូមទឹកថ្នាំស្អុំម៉ាស៊ីន។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **ទឹកថ្នាំស្អុំម៉ាស៊ីននៅក្នុងប្រអប់រំវែ** | វ៉ែនគម្របស៊ីឡាំងខូច។ | ប្តូរវ៉ែនគម្របស៊ីឡាំង។។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | គម្របស៊ីឡាំង ឬដុំស៊ីឡាំងប្រេះ។ | រកមើលស្នាមប្រេះ ជួសជុល/ប្តូរគ្រឿងតាមចាំបាច់។ |
| | ហ្វឺតទ្រនាប់ស៊ីឡាំងលេចធ្លាយ។ | ដោះនិងពិនិត្យទ្រនាប់ស៊ីឡាំង។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | លេចធ្លាយឧបករណ៍បញ្ចុះកម្តៅប្រេង។ | ធ្វើតេស្តសម្ពាធឧបករណ៍បញ្ចុះកម្តៅ ជួសជុល/ប្តូរចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |

តទៅទំព័របន្ទាប់

| លេខកូដសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| | កងរាងមូលឧបករណ៍បញ្ចេញកម្តៅប្រេងខូច។ | ដោះនិងពិនិត្យកងរាងមូលឧបករណ៍បញ្ចេញកម្តៅប្រេង ប្តូរចេញតាមចាំបាច់។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ហ្វីតស្តប់បូមខូច សម្ពាធរន្ធូរ ទឹកថ្នាំស្អុំម៉ាស៊ីនដែលលេចធ្លាយតាមជាដាង។ | ប្តូរហ្វីតស្តប់បូមទឹកថ្នាំស្អុំម៉ាស៊ីន។ ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| **សីតុណ្ហភាពទឹកថ្នាំស្អុំក្រោមកម្រិតធម្មតា** | ខែរម៉ូស្តាតមានបញ្ហា។ | តេស្តខែរម៉ូស្តាត ប្តូរខែរម៉ូស្តាតតាមចាំបាច់។ |

CP00834,0008B77-KM-07JUN21-8/8

## ប្រព័ន្ធអគ្គិសនី

| រោគសញ្ញា | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| **ប្រព័ន្ធដែលសាកមិនគ្រប់** | បន្ទុកអគ្គិសនីច្រើនពេកបណ្តាលពីគ្រឿងបន្ទាប់បន្សំបន្ថែម។ | ដោះគ្រឿងបន្ទាប់បន្សំ ឬដំឡើងគ្រឿងបំលែងអគ្គិសនីកម្លាំងខ្ពស់។ |
| | ការ៉ែងទីម៉ាស៊ីនច្រើនពេក។ | បង្កើនដុំ/នាទីរបស់ម៉ាស៊ីននៅពេលប្រើបន្ទុកអគ្គិសនីធ្ងន់។ |
| | តំណអគ្គិសនីនៅលើអាគុយមិនត្រឹមត្រូវ ខ្សែម៉ាស ដេម៉ារ៉ែ ឬគ្រឿងបំលែងអគ្គិសនី។ | ពិនិត្យនិងសម្អាតតាមចាំបាច់។ |
| | អាគុយខូច។ | តេស្តអាគុយ។ |
| | គ្រឿងបំលែងអគ្គិសនីខូច។ | តេស្តប្រព័ន្ធសាក។ |
| **អាគុយមិនសាកភ្លើង** | តំណភ្ជាប់ធូររលុង ឬច្រេះស៊ី។ | សម្អាត និងរឹតបន្តឹងតំណភ្ជាប់។ |
| | អាគុយឡើងជាតិអំបិល ឬខូច។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
| | ខ្សែពានយឺត ឬប្រដាប់បន្តឹងខ្សែពានខូច។ | លៃតម្រូវតំណឹងនៃខ្សែពាន ឬផ្លាស់ប្តូរខ្សែពានថ្មី។ |
| **ដេម៉ារ៉ែនឹងមិនវៃបញ្ឆោះ** | កាឡេម៉ាស៊ីនបានភ្ជាប់។ | ផ្តាច់កាឡេម៉ាស៊ីន។ |
| | តំណភ្ជាប់ធូររលុង ឬច្រេះស៊ី។ | សម្អាត និងរឹតបន្តឹងតំណភ្ជាប់ដែលធូររលុង។ |
| | កម្លាំងវ៉ុលត៍អាគុយទាប ឬអាគុយមិនសាក។ | សាក ឬប្តូរអាគុយ |
| | រីឡេសៀគ្វីបញ្ឆោះខូច។ | ចូរទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់អ្នក។ |
